# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

## ភាគ ៣៨

## មហាវារវគ្គ ទសមភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

៦ សំយុត្ត

ព្រះអដ្ឋកថាកែសេចក្ដី ៨២ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

# សារត្ថប្បកាសិនី

## ភាគ ៣៨

## មហាវារវគ្គ ទសមភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

៦ សំយុត្ត

ព្រះអដ្ឋកថាកែសេចក្តី ៨២ សូត្រ

# មហាវារវគ្គ

## ទសមភាគ មាន ៦ សំយុត្ត

| | |
|---|---|
| ១-សតិប្បដ្ឋានសំយុត្ត | មាន ៥ វគ្គ |
| | អដ្ឋកថាកែ ២៧ សូត្រ |
| ២-ឥន្ទ្រិយសំយុត្ត | មាន ៧ វគ្គ |
| | អដ្ឋកថាកែ ៣២ សូត្រ |
| ៣-សម្មប្បធានសំយុត្ត | អដ្ឋកថាកែសេចក្តីរួម |
| ៤-ពលសំយុត្ត | អដ្ឋកថាកែសេចក្តីរួម |
| ៥-ឥទ្ធិបាទសំយុត្ត | មាន ៣ វគ្គ |
| | អដ្ឋកថាកែ ១៤ សូត្រ |
| ៦-អនុរុទ្ធសំយុត្ត | មាន ២ វគ្គ |
| | អដ្ឋកថាកែ ៧ សូត្រ |

រួមក្នុងទសមភាគនេះ មាន
៦ សំយុត្ត ព្រះអដ្ឋកថាចានកែសេចក្តីដែល
លំបាកសរុបមានចំនួន ៨២ សូត្រ

# ស្រៈពេញតួ
# *Voyelles.*

| | |
|---|---|
| ខ្មែរ Cambodgien | អ អា ឥ ឦ ឧ ឩ ឯ ឱ |
| ឡូប Romain | *a* , *ā* *i* *ī* *u* *ū* *e* *o* |
| សៀម Siamois | อ อา อิ อี อุ อู เอ โอ |
| លាវ Laotien | ອ ອາ ອິ ອີ ອຸ ອູ ເອ ໂອ |
| លង្កា Cinghalais | අ ආ ඉ ඊ උ ඌ එ ඔ |
| ភូមា Birman | အ အာ ဣ ဤ ဥ ဦ ဧ ဩ |

# ស្រៈនិងស្រ័យ

# *Signes et accents:*



# ព្យញ្ជនៈ
# Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| Romain | k | kh | g | gh | ṅ |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| [illegible] Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សឹង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ဉ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សិង្ហល Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សិង្ហល Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្តើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្តើមឡើងដោយពាក្យថា សេចក្តីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្តែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្តី

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទឹកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានធនុះ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣ អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

**៤ អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ

សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់

ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញុំាញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់របូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុក ជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុថៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្សៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការបានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីបាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នួវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆ្នុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សួវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

**ក្រុមរៀបរៀង និងប្រែសម្រួល**

# មាតិកាធម៌

ឈ្មោះធម៌ ទំព័រ

## សតិប្បសំយុត្តទី ១

### អម្ពបាលិវគ្គទី ១


| | | |
|---|---|---|
| អដ្ឋកថា អម្ពបាលិសូត្រ | ទី ១ | ១ |
| អដ្ឋកថា សតិសូត្រ | ទី ២ | ១២ |
| អដ្ឋកថា ភិក្ខុសូត្រ | ទី ៣ | ៥២ |
| អដ្ឋកថា កោសលសូត្រ | ទី ៤ | ៥៣ |
| អដ្ឋកថា សកុណគ្ឃីសូត្រ | ទី ៦ | ៥៤ |
| អដ្ឋកថា មក្កដសូត្រ | ទី ៧ | ៥៦ |
| អដ្ឋកថា សូទសូត្រ | ទី ៨ | ៥៧ |
| អដ្ឋកថា គិលានសូត្រ | ទី ៩ | ៥៩ |
| អដ្ឋកថា ភិក្ខុនីសូត្រ | ទី ១០ | ៦៧ |


### នាឡន្ទវគ្គទី ២


| | | |
|---|---|---|
| អដ្ឋកថា នាឡន្ទសូត្រ | ទី ២ | ៧៤ |
| អដ្ឋកថា ចុន្ទសូត្រ | ទី ៣ | ៨៨ |
| អដ្ឋកថា ឧក្កាចេលសូត្រ | ទី ៤ | ១១៦ |
| អដ្ឋកថា ពាហិយសូត្រ | ទី ៥ | ១១៨ |
| អដ្ឋកថា ឧទយសូត្រ | ទី ៦ | ១១៩ |
| អដ្ឋកថា ព្រហ្មសូត្រ | ទី ៨ | ១២០ |
| អដ្ឋកថា បឋមសេទកសូត្រ | ទី ៩ | ១២១ |

អដ្ឋកថា ទុតិយសេខកសូត្រ ទី ១០ ១២៥

## សីលដ្ឋិតិវគ្គទី ៣

អដ្ឋកថា សីលសូត្រ ទី ១ ១២៨
អដ្ឋកថា ឋិតិសូត្រ ទី ២ ១២៩
អដ្ឋកថា បរិហានសូត្រ ទី ៣ ១៣០
អដ្ឋកថា បទេសសូត្រ ទី ៦ ១៣១
អដ្ឋកថា សមត្តសូត្រ ទី ៧ ១៣២
អដ្ឋកថា លោកសូត្រ ទី ៨ ១៣៣

## អននុស្សុតវគ្គទី ៤

អដ្ឋកថា សតិសូត្រ ទី ៥ ១៣៥

## អមតវគ្គទី ៥

អដ្ឋកថា សមុទយសូត្រ ទី ២ ១៣៧
អដ្ឋកថា សតិសូត្រ ទី ៤ ១៣៨
អដ្ឋកថា ធាតិមោក្ខសូត្រ ទី ៦ ១៣៩
អដ្ឋកថា ទុច្ចរិតសូត្រ ទី ៧ ១៤២

## ឥន្ទ្រិយសំយុត្តទី ២

## សុទ្ធិកវគ្គទី ១

អដ្ឋកថា សុទ្ធិកសូត្រ ទី ១ ១៤៣
អដ្ឋកថា ទុតិយ....សូត្រ ទី ៧ ១៤៤
អដ្ឋកថា ទដ្ឋព្វសូត្រ ទី ៨ ១៤៦
អដ្ឋកថា បឋមវិភង្គសូត្រ ទី ៩ ១៤៩

## មុទុតរវគ្គទី ២


| | | |
|---|---|---|
| អដ្ឋកថា បដិលាភសូត្រ | ទី ១ | ១៥១ |
| អដ្ឋកថា បឋមសង្ខិត្តសូត្រ | ទី ២ | ១៥២ |
| អដ្ឋកថា ទុតិយសង្ខិត្តសូត្រ | ទី ៣ | ១៥៥ |
| អដ្ឋកថា តតិយសង្ខិត្តសូត្រ | ទី ៤ | ១៥៦ |
| អដ្ឋកថា បឋមវិត្ថារសូត្រ | ទី ៥ | ១៥៧ |
| អដ្ឋកថា បដិបន្នសូត្រ | ទី ៨ | ១៥៩ |
| អដ្ឋកថា ឧបសមសូត្រ | ទី ៩ | ១៦០ |
| អដ្ឋកថា អាសវក្ខយសូត្រ | ទី ១០ | ១៦១ |


## ឆឡិន្ទ្រិយវគ្គទី ៣


| | | |
|---|---|---|
| អដ្ឋកថា ជីវិតិន្ទ្រិយសូត្រ | ទី ២ | ១៦២ |
| អដ្ឋកថា អញ្ញាតាវិន្ទ្រិយសូត្រ | ទី ៣ | ១៦៣ |
| អដ្ឋកថា ឯកាភិញ្ញាសូត្រ | ទី ៤ | ១៦៥ |
| អដ្ឋកថា សុទ្ធកសូត្រ | ទី ៥ ជាដើម | ១៧២ |


## សុខិន្ទ្រិយវគ្គទី ៤


| | | |
|---|---|---|
| អដ្ឋកថា សុទ្ធកសូត្រ | ទី ១ | ១៧៣ |
| អដ្ឋកថា សោតាបន្នសូត្រ | ទី ២ ជាដើម | ១៧៤ |
| អដ្ឋកថា បឋមវិភង្គសូត្រ | ទី ៦ | ១៧៥ |
| អដ្ឋកថា អរហន្តសូត្រ | ទី ៩ | ១៧៧ |
| អដ្ឋកថា ឧប្បដិកសូត្រ | ទី ១០ | ១៧៨ |


## ជរាវគ្គទី ៥


| | | |
|---|---|---|
| អដ្ឋកថា ជរាសូត្រ | ទី ១ | ១៨៣ |

អដ្ឋកថា ឧណ្ណាភព្រាហ្មណ ទី ២ ១៩៤
អដ្ឋកថា សាកេតសូត្រ ទី ៣ ១៩៣
អដ្ឋកថា បុព្វកោដ្ឋកសូត្រ ទី ៤ ១៩៥
អដ្ឋកថា បឋមបុព្វារាមសូត្រទី ៥ ១៩៦
អដ្ឋកថា សទ្ធាសូត្រ ទី ១០ ១៩៧

## សូករខាតវគ្គទី ៦

អដ្ឋកថា កោសលសូត្រ ទី ១ ១៩៩
អដ្ឋកថា មល្លកសូត្រ ទី ២ ២០០
អដ្ឋកថា សេក្ខសូត្រ ទី ៣ ២០១
អដ្ឋកថា បទសូត្រ ទី ៤ ២០៣
អដ្ឋកថា បតិដ្ឋិតសូត្រ ទី ៦ ២០៤
អដ្ឋកថា សូករខាតសូត្រ ទី ៨ ២០៥

## ពោធិបក្ខិយវគ្គទី ៧

អដ្ឋកថា ពោធិបក្ខិយវគ្គ ២០៧

## សម្មប្បធានសំយុត្តទី ៣

អដ្ឋកថា សម្មប្បធានសំយុត្ត ២០៩

## ពលសំយុត្តទី ៤

អដ្ឋកថា ពលសំយុត្ត ២១០

## ឥទ្ធិបាទសំយុត្តទី ៥
## ចាបាលវគ្គទី ១

| | | |
|---|---|---|
| អដ្ឋកថា អធារសូត្រ | ទី ១ | ២១១ |
| អដ្ឋកថា ឥទ្ធិបទេសសូត្រ | ទី ៥ | ២១៣ |
| អដ្ឋកថា សម្មត្តសូត្រ | ទី ៦ | ២១៤ |
| អដ្ឋកថា ចេតិយសូត្រ | ទី ១០ | ២១៥ |

## បាសាទកម្បនវគ្គទី ២

| | | |
|---|---|---|
| អដ្ឋកថា បុព្វសូត្រ | ទី ១ | ២២៧ |
| អដ្ឋកថា ឆន្ទសូត្រ | ទី ៣ | ២២៨ |
| អដ្ឋកថា មោគ្គល្លានសូត្រ | ទី ៤ | ២៣៣ |
| អដ្ឋកថា ព្រាហ្មណសូត្រ | ទី ៥ | ២៣៥ |
| អដ្ឋកថា ទេសនាសូត្រ | ទី ៩ | ២៣៦ |
| អដ្ឋកថា វិភង្គសូត្រ | ទី ១០ | ២៣៧ |

## អយោគុឡវគ្គទី ៣

| | | |
|---|---|---|
| អដ្ឋកថា អយោគុឡសូត្រ | ទី ២ | ២៤៤ |
| អដ្ឋកថា ភិក្ខុសុទ្ធកសូត្រ | ទី ៣ | ២៤៧ |
| អដ្ឋកថា បឋមផលសូត្រ | ទី ៤ | ២៤៨ |
| អដ្ឋកថា មោគ្គល្លានសូត្រជាដើម | | ២៤៩ |

## អនុរុទ្ធសំយុត្តទី ៦

## រហោគតវគ្គទី ១

| | | |
|---|---|---|
| អដ្ឋកថា បឋមរហោគត | ទី ១ | ២៥០ |
| អដ្ឋកថា ទុតិយរហោគត | ទី ២ | ២៥១ |
| អដ្ឋកថា សុតនុសូត្រ | ទី ៣ | ២៥២ |

អដ្ឋកថា បឋមកណ្ដកីសូត្រ ទី៤ ជាដើម ២៥៣

អដ្ឋកថា សលឡាគារសូត្រ ទី៨ ២៥៤

អដ្ឋកថា អម្ពចាលិសូត្រ ទី៩ ២៥៥


## ទុតិយវគ្គទី ២


អដ្ឋកថា ទុតិយវគ្គទី ២ ២៥៦

# ព្រះសុត្តន្តបិដក
# សំយុត្តនិកាយ មហាវារវគ្គ
# ឈ្មោះ
# សារត្ថប្បកាសិនី
# ទសមភាគ
# ភាគ ៣៨

## សតិប្បដ្ឋានសំយុត្ត

## អម្ពបាលិវគ្គទី ១

## អ ដ្ឋ ក ថា

## អម្ពបាលិសូត្រទី ១

*គប្បីជ្រាបក្នុង អម្ពបាលិសូត្រទី ១ នៃសតិប្បដ្ឋានសំយុត្ត ។*

[១] *បទថា អម្ពបាលិវនេ បានដល់ ក្នុងព្រៃស្វាយ ដែលស្ត្រីអ្នកអាស្រ័យរូបចិញ្ចឹមជីវិត ឈ្មោះ អម្ពបាលី ដាំទុក ។ ឧទ្យានស្វាយនោះទើបបានជារបស់នាងអម្ពបាលី ។ នាងអម្ពបាលីនោះ ស្តាប់ព្រះធម៌ទេសនា*

របស់ព្រះសាស្ដា មានចិត្តជ្រះថ្លា ទើបកសាងវិហារទុកក្នុងទីនោះ បង្អោន ថ្វាយដល់ព្រះតថាគត ។ បទថា **អម្ពបាលីវនេ** នេះ លោកពោលសំដៅ ដល់វិហារនោះ ។

[២] បទថា **ឯកាយនោយំ** កាត់បទជា **ឯកាយនោ អយំ** ប្រែថា នេះជាផ្លូវមួយ ។ ក្នុងបទទាំងនោះ បទថា **ឯកាយនោ** ប្រែថា ផ្លូវមួយ ។

ផ្លូវ មានឈ្មោះច្រើនថា **មគ្គ បន្ថ: បថ: បជ្ជ: អញ្ជស: វដុម: អាយន: នាវា ឧត្តរសេតុ កុលល: កិសិសង្កម:** ដូច្នេះ ។ ក្នុងទីនេះ លោក ពោលដល់ផ្លូវទាំងនោះ ដោយឈ្មោះ **អយន:** ។ ព្រោះដូច្នោះ ក្នុងបទថា **ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវឯក (ឯកាយនោយំ ភិក្ខវេ មគ្គោ)** គប្បី ឃើញសេចក្ដីយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះ ជាផ្លូវមូលតែមួយ មិនមែនជាផ្លូវបែកពីរ ។ បទថា **មគ្គោ** ឈ្មោះថា មគ្គ ដោយអត្ថដូចម្ដេច ។ ដោយអត្ថ ជាគ្រឿងស្វែងរកនិព្វាន និងដោយអត្ថ ដែលអ្នកមានសេចក្ដី ត្រូវការនិព្វានគប្បីស្វែងរក ។ បទថា **ដើម្បីសេចក្ដីបរិសុទ្ធរបស់សត្វទាំង ឡាយ (សត្តានំ វិសុទ្ធិយា)** បានដល់ ដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ អ្នកមានចិត្តសៅហ្មងហើយដោយមន្ទិល មានរាគ:ជាដើម និងដោយឧបក្កិលេស មានអភិជ្ឈាវិសមលោភ:ជាដើម ។ បទថា **ដើម្បីឈានកន្លងសេចក្ដីសោក**

និងសេចក្ដីខ្សឹកខ្សួល (សោកបរិទេវានំ សមតិក្កមាយ) សេចក្ដីថា ដើម្បីឈានកន្លង គឺ ដើម្បីលះបង់សេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួល ។ បទថា ដើម្បីរំលត់សូន្យនៃទុក្ខ និងទោមនស្ស (ទុក្ខទោមនស្សានំ អត្ថង្គមាយ) សេចក្ដីថា ដើម្បីការអស់ទៅ គឺ ដើម្បីសេចក្ដីរលត់នៃទុក្ខ និងទោមនស្ស ទាំងពីរទាំងនេះ គឺ ទុក្ខដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងទោមនស្សដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ។ បទថា ដើម្បីសម្រេចញាយធម៌ (ញាយស្ស អធិគមាយ) សេចក្ដីថា អរិយមគ្គមានអង្គ ៨ លោកហៅថា ញាយ ។ លោកអធិប្បាយថា ដើម្បីសម្រេច គឺ ដើម្បីដល់អរិយមគ្គនោះ ។ ពិតណាស់ មគ្គ គឺ សតិប្បដ្ឋានដែលជាលោកិយៈ ជាចំណែកខាងដើមនេះ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសម្រេចដល់លោកុត្តរមគ្គ ។ ព្រោះហេតុនោះ លោកទើបពោលថា ញាយស្ស អធិគមាយ ដូច្នេះ ។ បទថា ដើម្បីធ្វើនិព្វានឲ្យជាក់ច្បាស់ (និព្វានស្ស សច្ឆិកិរិយាយ) លោកអធិប្បាយថា ដើម្បីធ្វើឲ្យជាក់ច្បាស់ គឺ ដើម្បីឲ្យប្រចក្សដល់ខ្លួននៃអមតធម៌ ដែលបានឈ្មោះថា និព្វាន ព្រោះវៀរចាកគ្រឿងជាតក្រង គឺ តណ្ហា ។ ពិតណាស់ មគ្គនេះ ញុំាងសច្ឆិកិរិយាឲ្យសម្រេច ។ ព្រោះហេតុនោះ លោកទើបពោលថា និព្វានស្ស សច្ឆិកិរិយាយ ដូច្នេះ ។ ដោយប្រការដូច្នេះ ព្រះមានព្រះភាគ

ទើបត្រាស់គុណនៃឯកាយមគ្គ ដោយបទ ៧ បទ ។ ប្រសិនបើសួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់គុណរបស់ឯកាយនមគ្គនោះ ។ ឆ្លើយថា ដើម្បីឲ្យភិក្ខុទាំងឡាយកើតឧស្សាហៈ ។ ពិតហើយ ភិក្ខុទាំងនោះលុះស្តាប់ការពោលដល់គុណហើយ កើតសេចក្តីឧស្សាហៈថា ន័យថា មគ្គនេះ រមែងកម្ចាត់ឧបទ្រវៈ ៤ គឺ សេចក្តីសោកដែលដុតចិត្ត ១ បរិទេវៈដែលជាសេចក្តីខ្សឹកខ្សួល ១ ទុក្ខដែលជាសេចក្តីមិនសប្បាយផ្លូវកាយ ១ ទោមនស្សដែលជាសេចក្តីមិនសប្បាយផ្លូវចិត្ត ១ ។ រមែងនាំមកនូវគុណវិសេស ៣ គឺ សេចក្តីបរិសុទ្ធ ១ អរិយមគ្គ ១ និព្វាន ១ ទើបសម្គាល់ទេសនានេះ គួរកាន់យក គួររៀន គួរទ្រទ្រង់ទុក និងមគ្គនេះ គួរធ្វើឲ្យកើត ។ ព្រះមានព្រះភាគជាម្ចាស់ បានត្រាស់គុណដើម្បីឲ្យភិក្ខុទាំងនោះកើតឧស្សាហៈ ដូចឈ្មួញសំពត់កម្ពលជាដើម ពោលដល់គុណរបស់សំពត់កម្ពលជាដើម ដូច្នោះ ។

បទថា **យទិទំ** ជានិបាត ។ មានសេចក្តីស្មើនឹង **យេ ឥមេ** ។ បទថា **ចត្តារោ** បានដល់ កំណត់ចំនួន ។ ដោយការកំណត់ចំនួននោះ លោកសម្តែងកំណត់សតិប្បដ្ឋានថា មិនតិច មិនច្រើនពីនេះ ។ បទថា **សតិប្បដ្ឋានា** បានដល់ សតិជាទីតាំង ៣ គឺ សតិជាគោចរខ្វះ សភាពដែលព្រះសាស្តា

កន្ទ្រងបដិឃៈ និងតណ្ហា ក្នុងពេលសាវកទាំងឡាយបដិបត្តិ (សតិប្បដ្ឋាន) បីយ៉ាងខ្លះ តួសតិខ្លះ ។ ពិតហើយ សតិជាគោចរ លោកពោលថា សតិ-ប្បដ្ឋាន ក្នុងព្រះបាលីមានជាអាទិថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងការកើត និងការរលត់របស់សតិប្បដ្ឋាន ៤ ពួកអ្នកចូរស្តាប់ ម្នាលភិក្ខុទាំងឡាយ អ្វីជាការកើតរបស់កាយ ព្រោះអាហារជាហេតុកើត កាយទើបកើត ដូច្នេះ ។ លោកពោលទុកយ៉ាងនោះ សូម្បីក្នុងបាលីមានជាអាទិថា កាយប្រាកដ មិនមែនសតិ , សតិប្រាកដផង ជាតួសតិផង ដូច្នេះ ។ ព្រះបាលីនោះមានសេចក្តីថា ឈ្មោះថា បដ្ឋានៈ ព្រោះអត្ថថា ជាទីតាំង ។ សួរថា អ្វីតាំង ។ ឆ្លើយថា សតិ ។ ការតាំងនៃសតិ ឈ្មោះថា សតិប្បដ្ឋាន ដូចទីនៃដំរី និងទីតាំងនៃសេះជាដើម ។

*សតិប្បដ្ឋាន* លោកពោលថា សតិប្បដ្ឋាន ព្រោះព្រះសាស្តាកន្ទ្រងបដិឃៈ និងតណ្ហា ក្នុងកាលសាវកទាំងឡាយបដិបត្តិក្នុងសតិប្បដ្ឋាន ៣ ចំណែក ក្នុងបទនេះថា ព្រះអរិយៈរមែងសេពធម៌ គឺ សតិប្បដ្ឋាន ៣ កាលសេព ឈ្មោះថា មានព្រះសាស្តាគួរទូន្មានគណៈ (ដោយធម៌នោះ) ។ ព្រះបាលីនោះមានសេចក្តីថា ឈ្មោះបដ្ឋានៈ ព្រោះគួរឲ្យតាំងទុក ។ អធិប្បាយថា ព្រោះគួរឲ្យប្រព្រឹត្តទៅ ។ (សួរ) គួរឲ្យតាំងទុកដោយអ្វី ។ (ឆ្លើយ)

ដោយសតិ ។ ការតាំងទុកដោយសតិ ឈ្មោះថា សតិប្បដ្ឋាន ។

ក៏សតិនោះឯង លោកពោលថា សតិប្បដ្ឋាន ក្នុងបាលីមានជាអាទិថា សតិប្បដ្ឋាន ៤ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងញុំាងពោជ្ឈង្គៈ ៧ ឲ្យបរិបូណ៌ ។ ព្រះបាលីនោះមានសេចក្តីថា ឈ្មោះ បដ្ឋាន ព្រោះអត្ថថា តាំងទុក អធិប្បាយថា រមែងចូលទៅតាំងទុក គឺ តម្កល់ទុក ។ សតិនោះឯង ជាទីតាំង ឈ្មោះសតិប្បដ្ឋាន ។ មយ៉ាងទៀត ឈ្មោះថា សតិ ព្រោះអត្ថថា ជាគ្រឿងរឭកដល់ , ឈ្មោះបដ្ឋានៈ ព្រោះអត្ថថា ចូលទៅតាំងទុក ព្រោះអត្ថថា ជាទីតាំង ព្រោះហេតុនោះ ទើបឈ្មោះថា សតិប្បដ្ឋាន ព្រោះជាសតិផង ជាទីតាំងផង ។ លោកបំណងសតិប្បដ្ឋាននេះ ក្នុងទីនេះ ។

ប្រសិនបើយ៉ាងនោះ ព្រោះហេតុអ្វី លោកទើបធ្វើឲ្យជាពហុវចនៈថា **សតិប្បដ្ឋានា** ព្រោះសតិមានច្រើន ។ ពិតហើយ សតិមានច្រើន ដោយសេចក្តីផ្សេងនៃអារម្មណ៍ ។ បើដូច្នោះ ព្រោះហេតុអ្វី បទថា **មគ្គោ** ទើបជាឯកវចនៈ ព្រោះមានតែមួយ ដោយអត្ថថា មគ្គ ។ ពិតណាស់ សតិទាំងនោះសូម្បីមាន ៤ យ៉ាង ក៏សេចក្តីមានតែមួយដូចគ្នា ដោយអត្ថនៃមគ្គ ។ ដូចដែលលោកពោលថា បទថា **មគ្គោ** ឈ្មោះថា មគ្គ ដោយអត្ថដូចម្តេច ដោយអត្ថថា ស្វែងរកព្រះនិព្វាន និងដោយអត្ថថា ដែលអ្នកមានសេចក្តីត្រូវ

ការព្រះនិព្វានគប្បីស្វែងរក ។ សូម្បីសតិប្បដ្ឋានទាំង ៤ នេះ ញុាំងកិច្ចឲ្យសម្រេចក្នុងអារម្មណ៍ទាំងឡាយ មានកាយជាដើម ។ ក្នុងវេលាតមក រមែងសម្រេចនិព្វាន បុគ្គលត្រូវការនិព្វានទាំងឡាយរមែងស្វែងរក តាំងអំពីដើមដោយប្រការដូច្នេះ ព្រោះដូច្នោះ សតិប្បដ្ឋានទាំង ៤ លោកហៅថា ផ្លូវឯក ។ ទេសនាព្រមទាំងអនុសន្ធិ រមែងមានដោយការបន្តបទនៃសតិ ដោយប្រការដូច្នេះឯង ។

បទថា **កតមេ ចត្តារោ** គឺ សួរបំណងនឹងឲ្យឆ្លើយ ។

[៣] បទថា **កាយេ** គឺ រូបកាយ ។ បទថា **ពិចារណាឃើញកាយ (កាយានុបស្សី)** សេចក្តីថា ភិក្ខុអ្នកមានប្រក្រតីពិចារណាឃើញកាយ ឬថាពិចារណាឃើញកាយហើយ ។ ក៏ភិក្ខុនេះ រមែងពិចារណាឃើញកាយនេះថាជារបស់មិនទៀង ដោយអំណាចនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម មិនពិចារណាឃើញថាជារបស់មិនទៀង រមែងពិចារណាឃើញថាជាទុក្ខ មិនពិចារណាឃើញថាជាសុខ រមែងពិចារណាឃើញថាមិនមែនខ្លួន មិនពិចារណាឃើញថាជាខ្លួន រមែងនឿយណាយ រមែងមិនត្រេកអរ រមែងប្រាសចាកតម្រេក រមែងមិនប្រាថ្នា រមែងរលត់ រមែងមិនកើតឡើង រមែងលះបង់ រមែងលះបង់សេចក្តីប្រកាន់នោះចេញ ដូច្នេះ ។

បទថា **នៅ (វិហរតិ)** គឺ ប្រព្រឹត្ត ។ បទថា **មានសេចក្ដីព្យាយាម (អាតាបី)** ឈ្មោះថា អាតាប: ព្រោះអត្ថថា រមែងដុតកិលេសទាំងឡាយក្នុងភពបី ។ ពាក្យនេះជាឈ្មោះរបស់សេចក្ដីព្យាយាម ឈ្មោះថា **អាតាបី** ព្រោះអត្ថថា មានសេចក្ដីព្យាយាម ។ បទថា **មានសម្បជញ្ញៈ (សម្បជានោ)** សេចក្ដីថា ភិក្ខុអ្នកប្រកបដោយញាណ ពោលគឺ សម្បជញ្ញៈ ។ បទថា **មានសតិ (សតិមា)** សេចក្ដីថា អ្នកប្រកបដោយសតិកំណត់ត្រង់កាយ ។ ក៏ព្រោះភិក្ខុនេះកំណត់អារម្មណ៍ដោយសតិហើយ ទើបពិចារណាឃើញដោយបញ្ញា ។ តែធម្មតាថា ការពិចារណាឃើញ រមែងមិនមានដល់ភិក្ខុអ្នកវៀរសតិ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលសតិថា គួរប្រាថ្នាក្នុងទីទាំងពួង ។ ដូច្នេះ កាយានុបស្សនា-សតិប្បដ្ឋាន គឺ ទ្រង់ត្រាស់ហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ក្នុងទីនេះថា **កាយេ កាយានុបស្សី វិហរតិ** ជាដើម ។ មួយវិញទៀត ព្រោះសេចក្ដីសង្ខេបពេក រមែងធ្វើអន្តរាយដល់ភិក្ខុអ្នកមិនមានសេចក្ដីព្យាយាម គឺ អ្នកមិនមានសម្បជញ្ញៈ រមែងវង្វេងក្នុងការកំណត់យកវត្ថុដែលជាឧបាយ និងក្នុងការវៀរវត្ថុដែលមិនមែនឧបាយ អ្នកគ្មានសតិ រមែងមិនអាចលះបង់វត្ថុដែលមិនមែនឧបាយ និងក្នុងការកំណត់យកវត្ថុដែលជាឧបាយបាន ។ ដោយ

ហេតុនោះ កម្មដ្ឋាននោះ ទើបមិនដល់ព្រមដល់ភិក្ខុនោះ ព្រោះដូច្នេះ កម្ម-ដ្ឋាននោះ រមែងដល់ព្រមដោយអានុភាពនៃធម៌ពួកណា ដើម្បីសម្តែងធម៌ពួកនោះ គប្បីជ្រាបថា សេចក្តីនេះលោកពោលថា មានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិ ដូច្នេះ ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងកា-យានុបស្សនាសតិប្បដ្ឋាន និងអង្គនៃសេចក្តីព្យាយាមដល់ភិក្ខុនោះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងអង្គនៃការលះ ។ ទើបត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កម្ចាត់ (វិនេយ្យ)** សេចក្តីថា កម្ចាត់ហើយ ព្រោះការកម្ចាត់ដោយខណៈ ឬព្រោះការកម្ចាត់ដោយការគ្របសង្កត់ទុក ។ បទថា **ក្នុងលោក (លោកេ)** គឺ ក្នុងកាយនោះ ។ ក៏កាយ លោកបំណង យកថា **លោក** ដោយអត្ថថា បែកធ្លាយ ក្នុងទីនេះ ។ ក៏ព្រោះភិក្ខុនោះ មិនមែនលះអភិជ្ឈា និងទោមនស្សបាន ព្រោះពិចារណាត្រឹមកាយតែម្យ៉ាង សូម្បីក្នុងវេទនាជាដើម ក៏លះបានដូចគ្នា ។ ដូច្នោះ លោកទើបពោលទុកក្នុងវិភង្គថា ឧបាទានក្ខន្ធទាំង ៥ ក៏ជាលោក ។ មួយទៀត ប្រការនោះ លោកពោលដោយន័យអធិប្បាយសេចក្តីនៃធម៌ទាំងនោះ ព្រោះកាយនោះ ទាក់ទងក្នុងលោក ក៏លោកពោលថា ក្នុងប្រការនោះ លោកដូចម្តេច លោក

គឺ កាយ ។ នេះជាន័យក្នុងប្រការនេះ អ្នកសិក្សាគប្បីឃើញសម្ពន្ធយ៉ាងនេះថា លះអភិជ្ឈា និងទោមនស្សក្នុងលោកនោះចេញបាន ។

ក្នុងបទថា **ក្នុងវេទនា** (វេទនាសុ) នេះ វេទនាមានបី ។ វេទនាទាំងនោះជាលោកិយៈ សូម្បីចិត្តក៏ជាលោកិយៈ ធម៌ទាំងឡាយក៏យ៉ាងនោះ ដូចបុគ្គលកាលពិចារណាឃើញវេទនាដោយប្រការណា ភិក្ខុនេះ កាលពិចា-រណាឃើញដោយប្រការនោះ គប្បីជ្រាបថា **វេទនានុបស្សី** ។ ក្នុងចិត្ត និងធម៌ទាំងឡាយ ក៏មានន័យនេះ ។ សួរថា **វេទនា** បុគ្គលគប្បីពិចារណាឃើញដូចម្តេច ។ ឆ្លើយថា គប្បីពិចារណាឃើញសុខវេទនាដោយសភាពជាទុក្ខ ទុក្ខវេទនាដោយសភាពជាកូនសរ អទុក្ខមសុខដោយសភាពមិនទៀងសមដូចដែលលោកពោលទុកថា ៖

> ភិក្ខុណា ឃើញសុខដោយសភាពជាទុក្ខ បានឃើញ
> ទុក្ខ ដោយសភាពជារបស់ចាក់ដោត ការមិនមានទុក្ខ
> មិនមានសុខ មានហើយ បានឃើញវត្ថុនោះ ដោយ
> សភាពមិនទៀង ភិក្ខុនោះឯង ឈ្មោះថា ឃើញត្រូវ
> ជាអ្នកស្ងប់ នឹងត្រាច់ទៅ ។

គួរពិចារណាឃើញវេទនាទាំងអស់នោះថា ជាទុក្ខខ្លះ ដូចទ្រង់ត្រាស់

ថា តថាគតឃើញថា វត្ថុដែលសោយហើយទាំងអស់នោះនៅក្នុងទុក្ខ ។ និង គួរពិចារណាឃើញដោយសភាពជាសុខ និងទុក្ខៈ សមដូចដែលលោក ពោលថា វិសាខៈមានអាយុ សុខវេទនានោះឯងជាសុខ ព្រោះការតាំងនៅ ជាទុក្ខ ព្រោះការប្រែប្រួល ។ ទាំងអស់គួរឲ្យពិស្តារ ។ ក៏គួរពិចារណា សូម្បីដោយអំណាចនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ។ គួរ ពិចារណាតាមទូវចិត្ត សូម្បីក្នុងធម៌ ពោលដោយចិត្ត ដោយអំណាចនៃ ប្រភេទដែលមានសេចក្តីផ្សេងគ្នា ។ មានអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ ភូមិ កម្មវិបាក និងកិរិយាចិត្តជាដើម និងប្រភេទនៃចិត្ត មានរាគៈជាដើម ដែលជាអនុបស្សនា មានអនិច្ចានុបស្សនាជាដើមមុន ។

គួរពិចារណាឃើញធម៌ ដោយអំណាចនៃសាមញ្ញលក្ខណៈព្រមទាំង លក្ខណៈ នៃសុញ្ញតធម៌ នៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម និងនៃប្រភេទមានជាដើមថា កាមច្ឆន្ទៈ មាននៅខាងក្នុង ដូច្នេះ ។ ដ៏សេស មានន័យពោលទុកហើយ ។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ។ តែគប្បី ជ្រាបសេចក្តីពិស្តារដោយន័យដែលពោលទុកហើយ ក្នុងអដ្ឋកថាសតិប្បដ្ឋាន ក្នុងអដ្ឋកថាទីឃនិកាយមជ្ឈិមបណ្ណាសក: ។

ចប់អដ្ឋកថា អម្ពបាលិសូត្រទី ១

# អ ដ្ឋ ក ថា

## សតិសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង សតិសូត្រទី ២ ។

[៥] បទថា **មានសតិ** (សតោ) បានដល់ ដល់ព្រមហើយដោយសតិតាមឃើញកាយជាដើម ។ បទថា **មានសម្បជញ្ញៈ** (សម្បជានោ) បានដល់ ដល់ព្រមដោយបញ្ញា គឺ សម្បជញ្ញៈ ៤ ។

[៧] ក្នុងបទថា **ការឈានទៅមុខ ការថយក្រោយ** (អភិក្កន្តេ បដិក្កន្តេ) នេះ ការដើរទៅ លោកពោលថា ឈានទៅខាងមុខ ការត្រឡប់ លោកពោលថា ថយក្រោយ សូម្បីទាំងពីរយ៉ាងនោះ រមែងបានក្នុងឥរិយាបថ ៤ ។ ក្នុងការដើរទៅ កាលនាំកាយទៅខាងមុខ ឈ្មោះថា រមែងឈានទៅខាងមុខ ។ កាលត្រឡប់ ឈ្មោះថា រមែងថយក្រោយ ។ សូម្បីក្នុងការឈរ អ្នកឈរឱនកាយទៅខាងមុខ ក៏ ឈ្មោះថា រមែងឈានទៅខាងមុខ ។ ពេលឱនកាយទៅខាងក្រោយ រមែងឈ្មោះថា ថយក្រោយ ។ សូម្បីក្នុងការអង្គុយ អ្នកអង្គុយបែរមុខស្របតាមអាសនៈ បង្អោនកាយទៅ ឈ្មោះថា ឈានទៅខាងមុខ ។ ការផ្អែកកាយទៅខាងក្រោយ អែនកាយទៅខាងក្រោយ ឈ្មោះថា រមែងថយ

ក្រោយ ។ សូម្បីក្នុងការដេក ក៏មានន័យនេះឯង ។

បទថា ជាអ្នកធ្វើសេចក្ដីដឹងខ្លួន (សម្បជានការី ហោតិ) បានដល់ការធ្វើកិច្ចទាំងអស់ដោយសេចក្ដីដឹងខ្លួន ឬធ្វើសេចក្ដីដឹងខ្លួនប៉ុណ្ណោះ ។ ពិតហើយ គេរមែងធ្វើសេចក្ដីដឹងខ្លួនក្នុងការឈានទៅខាងមុខជាដើម ។ ក្នុងទីណាៗ មិនវៀរការដឹងខ្លួន ។

ក្នុងបទថា សម្បជានការី នោះ សម្បជញ្ញៈ មាន ៤ យ៉ាង គឺ ៖

-សាត្ថកសម្បជញ្ញៈ ១

-សប្បាយសម្បជញ្ញៈ ១

-គោចរសម្បជញ្ញៈ ១

-អសម្មោហសម្បជញ្ញៈ ១ ។

ក្នុងសម្បជញ្ញៈ ៤ នោះ ពេលចិត្តគិតនឹងឈានទៅខាងមុខ កើតឡើងការមិនទៅតាមអំណាចចិត្ត កំណត់ដល់ប្រយោជន៍ និងមិនមែនប្រយោជន៍ថា កាលយើងនឹងទៅ ក្នុងទីនេះនឹងមានប្រយោជន៍ ឬមិនមានប្រយោជន៍ហ្ន៎ ហើយកាន់យកតែប្រយោជន៍ ឈ្មោះថា សាត្ថកសម្បជញ្ញៈ ។ មួយ៉ាងទៀត សេចក្ដីចម្រើនដោយធម៌ ដោយអំណាចការឃើញព្រះចេតិយ ការឃើញទីត្រាស់ដឹង ការឃើញព្រះសង្ឃ ការឃើញព្រះថេរៈ និងការឃើញអសុភៈ

ជាដើម លោកពោលថាប្រយោជន៍ក្នុងសេចក្ដីនោះ ។ បុគ្គលសូម្បីឃើញ ព្រះចេតិយ បីតិកើតឡើង មានព្រះពុទ្ធជាម្ចាស់ជាអារម្មណ៍ មានព្រះសង្ឃ ជាអារម្មណ៍ ព្រោះការឃើញព្រះសង្ឃ ពិចារណាដល់វត្ថុនោះៗ ឯង ដោយ ការអស់ទៅ រមែងសម្រេចព្រះអរហត្តបាន ។ ភិក្ខុបីម៉ឺនរូប ឈរនៅត្រង់ ទ្វារទិសខាងត្បូងក្នុងមហាវិហារ ក្រឡេកមើលមហាចេតិយ បានសម្រេច ព្រះអរហត្ត ។ ត្រង់ទ្វារទិសខាងលិច ទិសខាងជើង ទិសខាងកើត ក៏ដូច គ្នា ។ ក្នុងបាលី ព្រះអភយវាសី បានសម្រេចព្រះអរហត្ត ត្រង់កន្លែងតាំង ជាប្រចាំដើម្បីសួរបញ្ហា ។ ព្រះអនុរាជវាសី បានសម្រេចព្រះអរហត្តត្រង់ ទ្វារទិសខាងត្បូងនៃនគរ ជិតទ្វារថូបារាម ។

ក៏ព្រះថេរៈអ្នកពោលមហាចរិយវង្ស ពោលថា ពួកលោកនិយាយ អ្វី គួរនឹងនិយាយថា ក្នុងទីដែលប្រាកដ តាំងតែពីចំណែកជាន់ក្រោមរបស់ ទីបូជាដោយជុំវិញមហាចេតិយ ជើងទាំងពីរអាចនឹងឲ្យប្រតិស្ឋានស្មើគ្នាបាន ក្នុងទីណាៗ ភិក្ខុគ្រប់ៗ បីម៉ឺនរូប បានសម្រេចព្រះអរហត្តក្នុងការលើកជើង ម្ខាងឡើងក្នុងទីនោះៗ ។

តែព្រះមហាថេរៈមួយរូបទៀតពោលថា ភិក្ខុទាំងឡាយច្រើនជាងជី ខ្សាច់ដែលរាត់រាយនៅត្រង់លានមហាចេតិយ ក៏បានសម្រេចព្រះអរហត្ត ។

បុគ្គលឃើញព្រះថេរៈហើយ តាំងនៅក្នុងឱវាទរបស់លោក ឃើញអសុភៈ ញុំាងបឋមឈានឲ្យកើតក្នុងអសុភៈនោះ ពិចារណាអសុភៈនោះៗ ឯងដោយការអស់ទៅ រមែងសម្រេចព្រះអរហត្ត ។ ព្រោះដូច្នោះ ការឃើញវត្ថុទាំងនេះ ទើបមានប្រយោជន៍ ។

អាចារ្យពួកខ្លះពោលថា សេចក្តីចម្រើន សូម្បីដោយអាមិស ក៏ជាប្រយោជន៍ដូចគ្នា ព្រោះអាស្រ័យអាមិសនោះ បដិបត្តិដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈ ។

ក៏ក្នុងការដើរនោះ ការកំណត់វត្ថុដែលសប្បាយ និងមិនសប្បាយ ហើយកាន់យកវត្ថុដែលសប្បាយ ជា **សប្បាយសម្បជញ្ញៈ** ដូចម្តេច ដូចការឃើញព្រះចេតិយមានប្រយោជន៍ដល់យ៉ាងនោះ ។ ប្រសិនបើថា ពពួកជនប្រជុំគ្នាក្នុងរវាង ១២០ យោជន៍ ដើម្បមហាបូជាព្រះចេតិយ ។ ស្ត្រីខ្លះបុរសខ្លះ តាក់តែងប្រដាប់តាមសមគួរដល់សម្បត្តិរបស់ខ្លួន នាំគ្នាដើរទៅដូចរូបចិត្រកម្ម ។ ក៏ក្នុងរឿងនោះ សេចក្តីលោភក្នុងអារម្មណ៍ដែលគួរប្រាថ្នា សេចក្តីទាស់ចិត្តក្នុងអារម្មណ៍ដែលមិនគួរប្រាថ្នា សេចក្តីវង្វេងដោយការមិនសមបំណង រមែងកើតដល់ភិក្ខុនោះ ។ ភិក្ខុនោះរមែងត្រូវអាបត្តិ ដែលជាកាយសំសគ្គៈ និងជាអន្តរាយដល់ជីវិតព្រហ្មចរិយៈ ។ ឋានៈនោះ រមែងជា

ឋានៈដែលមិនសប្បាយ ដោយប្រការដូច្នេះ ។ ឋានៈជាទីសប្បាយ ព្រោះការមិនមានអន្តរាយ មានប្រការដូចពោលហើយ ។ សូម្បីការឃើញព្រះសង្ឃក៏មានប្រយោជន៍ ។ ប្រសិនបើ កាលមនុស្សក្រសាងមហាមណ្ឌលខាងក្នុងស្រុក ហើយស្តាប់ធម៌រហូតមួយយប់ដល់ភ្លឺ ការជុំនុំជន និងអន្តរាយ រមែងមាន ដោយប្រការដូចពោលហើយនោះឯង ។ ទីនោះ ជាទីមិនសប្បាយដោយប្រការដូច្នេះ ។ ជាទីសប្បាយ ព្រោះមិនមានអន្តរាយ ។ សូម្បីក្នុងការឃើញព្រះថេរៈដែលមានបរិស័ទច្រើនជាបរិវារ ក៏មានន័យនេះ ដូចគ្នា ។ សូម្បីការឃើញអសុភៈក៏មានប្រយោជន៍ ។ ក៏រឿងនេះ (លោកពោលទុក) ដើម្បីសម្តែងប្រយោជន៍នៃការឃើញអសុភៈនោះ ។

មានរឿងដំណាលថា ភិក្ខុកម្លោះមួយរូប នាំសាមណេរទៅដើម្បីត្រូវការឈើស្ទន់ ។ សាមណេរគេចចេញអំពីផ្លូវ ដើរទៅខាងមុខឃើញអសុភៈ ទើបញុំាងបឋមឈានឲ្យកើត ធ្វើបឋមឈាននោះឲ្យជាបាទ ពិចារណាសង្ខារធ្វើឲ្យជាក់ច្បាស់នូវផលបី បានឈរកំណត់ព្រះកម្មដ្ឋានដើម្បីត្រូវការមគ្គខាងលើ ។ ភិក្ខុកម្លោះ កាលមិនឃើញសាមណេរនោះ ទើបហៅសាមណេរ ។ សាមណេរគិតថា តាំងតែពីថ្ងៃដែលយើងបួស មិនធ្លាប់និយាយជាមួយភិក្ខុដល់ពីរម៉ាត់ឡើយ យើងនិងញុំាងគុណវិសេសខាងលើឲ្យកើតក្នុងថ្ងៃដទៃចុះ

ទើបបានទទួលថា អ្វី លោកម្ចាស់ដ៏ចម្រើន ។ ភិក្ខុនោះពោលថា អ្នកចូរត្រឡប់មក ។ សាមណេរទើបត្រឡប់ដោយពាក្យនិយាយត្រឹមតែម្តង ហើយពោលថា លោកម្ចាស់ សូមលោកម្ចាស់ទៅតាមផ្លូវនេះសិន ក្នុងខណៈដែលខ្ញុំករុណាឈរចាំ ចូរសម្លឹងទៅផ្លូវទិសខាងកើតមួយសន្ទុះ ភិក្ខុធ្វើយ៉ាងនោះបានសម្រេចគុណវិសេសដែលកំណត់ហើយដោយអសុភៈនោះ ។ អសុភៈមួយ កើតដើម្បីប្រយោជន៍ដល់ជនទាំងពីរ ដោយប្រការដូច្នេះ ។ ក៏អសុភៈនេះ មានប្រយោជន៍សូម្បីយ៉ាងនេះ ។ (តែ) អសុភៈរបស់មាតុគ្រាម មិនជាទីសប្បាយរបស់បុរស ។ អសុភៈរបស់បុរស ក៏មិនជាទីសប្បាយរបស់មាតុគ្រាម អសុភៈដែលមានចំណែកស្មើគ្នាប៉ុណ្ណោះ ទើបជាទីសប្បាយ ព្រោះដូច្នោះ ការកំណត់វត្ថុដែលជាទីសប្បាយយ៉ាងនេះ ឈ្មោះថា **សប្បាយសម្បជញ្ញៈ** ។

ក៏ការរៀនធម៌ជាគោចរ ពោលគឺ កម្មដ្ឋានក្នុងសេចក្តីពេញចិត្តរបស់ខ្លួន ក្នុងកម្មដ្ឋាន ៣៨ នៃវត្ថុជាទីសប្បាយដែលមានប្រយោជន៍ ដែលខ្លួនកំណត់ហើយ យ៉ាងនេះ ហើយកាន់យកគោចរនោះទៅក្នុងភិក្ខាចារគោចរ ឈ្មោះថា **គោចរសម្បជញ្ញៈ** ។ ដើម្បីឲ្យរឿងនោះជាក់ច្បាស់ គប្បីជ្រាបភិក្ខុ ៤ ប្រភេទនេះ ។ ភិក្ខុពួកខ្លះក្នុងធម្មវិន័យនេះ នាំទៅមិននាំត្រឡប់ ពួក

ខ្លះនាំត្រឡប់មិននាំទៅ តែពួកខ្លះទាំងមិននាំទៅទាំងមិនត្រឡប់ ពួកខ្លះទាំងនាំទៅទាំងនាំត្រឡប់ ។

ក្នុងភិក្ខុ ៤ ជំពូកនោះ ភិក្ខុណាជម្រះចិត្តឲ្យបរិសុទ្ធចាកធម៌ជាគ្រឿងកន្លល់ ដោយការចង្រ្កម ដោយការអង្គុយអស់ថ្ងៃ អស់បឋមយាមនៃរាត្រីក៏យ៉ាងនោះ សម្រេចការដេកក្នុងមជ្ឈិមយាម សូម្បីក្នុងបច្ឆិមយាម ក៏ឲ្យកន្លងទៅ ដោយការអង្គុយ និងដើរចង្រ្កម ពេលព្រឹកព្រលឹម បោសសម្អាតលានចេតិយ និងលានពោធិព្រឹក្ស ស្រោចទឹកត្រង់ដើមពោធិព្រឹក្ស តាំងរបស់ផឹក របស់បរិភោគ បដិបត្តិអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម ។ ភិក្ខុនោះជម្រះកាយហើយ ចូលទៅកាន់សេនាសនៈ អង្គុយពត់ភ្នែន ២-៣ ដងដើម្បីកាន់យកនូវកំដៅអប់អ៊ុន ប្រកបកម្មដ្ឋាន ក្រោកឡើងក្នុងវេលាភិក្ខាចារកាន់បាត្រ និងចីវរដោយប្រធាននៃកម្មដ្ឋាន ចេញចាកសេនាសនៈ មនសិការកម្មដ្ឋាន ទៅកាន់លានចេត្តិយ ។ ប្រសិនបើពុទ្ធានុស្សតិកម្មដ្ឋានមាន មិនលះបង់កម្មដ្ឋាននោះ ចូលទៅកាន់លានចេតិយ ប្រសិនបើជាកម្មដ្ឋានដទៃមាន លះបង់កម្មដ្ឋាននោះ ដូចឈរនៅត្រង់ជើងជណ្តើរ ដាក់ភណ្ឌៈដែលកាន់ទុក កាន់យកបីតិមានព្រះពុទ្ធជាអារម្មណ៍ ឡើងកាន់លានចេតិយ ប្រសិនបើជាចេតិយធំ គប្បីធ្វើប្រទក្សិណ ៣ ជុំ ហើយគប្បីថ្វាយបង្គំក្នុងទី ៤ ទិស

បើចេតិយតូច គប្បីធ្វើប្រទក្សិណយ៉ាងនោះ ហើយថ្វាយបង្គំក្នុងទី ៨ ទិស ។ លុះថ្វាយបង្គំព្រះចេតិយហើយ សូម្បីទៅដល់លានពោធិព្រឹក្ស គួរសម្តែងសេចក្តីគោរពថ្វាយបង្គំពោធិព្រឹក្ស ដូចនៅចំពោះព្រះភក្ត្រព្រះពុទ្ធជាម្ចាស់ ភិក្ខុនោះ លុះថ្វាយបង្គំចេតិយ និងពោធិព្រឹក្សយ៉ាងនេះហើយ កាន់យកកម្មដ្ឋានដែលរក្សាទុក ដូចអ្នកទៅកាន់ទីដែលរក្សារបស់ទុក កាន់យកកណ្ឌៈដែលតម្កល់ទុក ដណ្តប់ចីវរ ដោយគោលនៃកម្មដ្ឋាន ក្នុងទីជិតស្រុក ចូលទៅកាន់ស្រុកបិណ្ឌបាត្រ ។

គ្រានោះ ពួកមនុស្សឃើញភិក្ខុនោះ ទើបនាំគ្នាទទួលថា លោកម្ចាស់របស់ពួកយើងមកហើយ ទើបទទួលបាត្រ និមន្តឲ្យគង់លើអាសនសាលា (រោងឆាន់) ឬលើរានថ្វាយយាគូ លាងជើង លាបជើង អង្គុយខាងមុខនឹងសួរបញ្ហា ឬបំណងនឹងស្តាប់ធម៌ ក្នុងវេលាកត្តនៅមិនទាន់សម្រេច ។ ព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា សូម្បីបើពួកមនុស្សមិនសួរ ភិក្ខុក៏គួរសម្តែងធម៌ដើម្បីសង្គ្រោះជន ។ ពិតហើយ ធម្មកថា ឈ្មោះថានឹងផុតចាកកម្មដ្ឋាន រមែងមិនមាន ។ ព្រោះដូច្នោះ ភិក្ខុនោះពោលធម៌ដោយគោលនៃកម្មដ្ឋាន ឆាន់អាហារដោយគោលនៃកម្មដ្ឋាន ធ្វើអនុមោទនា សូម្បីពួកមនុស្សដែលនៅ (មិន) ទាន់ត្រឡប់ ក៏តាមជូនទៅ លុះចេញចាកស្រុកហើយ

ឲ្យពួកមនុស្សត្រឡប់ក្នុងទីនោះ ដើរទៅកាន់ផ្លូវ ។

គ្រានោះ សាមណេរ និងភិក្ខុកម្លោះ ធ្វើភត្តកិច្ចស្រេចហើយខាង ក្រៅស្រុក ចេញទៅមុន ឃើញភិក្ខុនោះ (មកហើយ) ទើបនាំគ្នាក្រោកទទួល ទទួលបាត្រ និងចីវររបស់លោក ។ន័យថា ពួកភិក្ខុចាស់ៗ សម្លឹងមើលមុខ ដោយគិតថា ភិក្ខុនេះមិនមែនឧបជ្ឈាយ៍ អាចារ្យរបស់យើង ធ្វើការប្រតិបត្តិ ធ្វើដោយកំណត់ក្នុងពេលជួបប៉ុណ្ណោះ ។ ពួកភិក្ខុ សួរភិក្ខុនោះថា លោក ម្ចាស់ ពួកមនុស្សទាំងនេះជាអ្វីនឹងលោក មានសេចក្ដីទាក់ទងចំណែកខាង មាតា ឬខាងបិតា ។ ភិក្ខុនោះសួរថា ពួកលោកឃើញដូចម្ដេច ទើបនាំគ្នា សួរ ។ ពួកភិក្ខុពោលថា ពួកមនុស្សទាំងនោះដោយច្រើន ស្រឡាញ់រាប់ អានលោក ។ ភិក្ខុពោលថា លោកដ៏មានអាយុទាំងឡាយ ពួកមនុស្សទាំង នេះ ធ្វើកម្មដែលសូម្បីមាតាបិតាក៏ធ្វើបានលំបាកដល់យើង សូម្បីបាត្រ និង ចីវររបស់យើងក៏ជារបស់ពួកគេ យើងមិនដឹងភ័យក្នុងភ័យ មិនដឹងការឃ្លាន ក្នុងការឃ្លាន ដោយអំណាចរបស់ពួកគេ ពួកមនុស្សអ្នកមានឧបការៈដល់ យើងដូច្នេះមិនមានឡើយ ។ ភិក្ខុនោះ កាលពោលដល់គុណរបស់ពួកមនុស្ស ទាំងនោះ ទើបទៅ នេះលោកពោលថា **នាំទៅមិននាំត្រឡប់** ។

កាលភិក្ខុណា ធ្វើប្រការដូចដែលពោលហើយ ភ្លើងកើតអំពីកម្មឆេះ

ព្រលែងសន្ធារមិនមានចិត្តគ្រប់គ្រង កាន់យកសន្ធារដែលមានចិត្តគ្រប់គ្រង ញើសហូរចាកសរីរៈ ។ មិនឡើងកាន់ផ្លូវនៃកម្មដ្ឋាន ។ ភិក្ខុនោះកាន់បាត្រចីវរពីព្រឹកព្រលឹម រួតរះទៅថ្វាយបង្គំព្រះចេតិយ ក្នុងវេលាចេញទៅរកអាហារចូលទៅស្រុកដើម្បីរកបបរយាគូ បានបបរយាគូហើយ ទៅអាសនសាលាហើយឆាន់ ។ លំដាប់នោះ ដោយត្រឹមតែលេបចូលទៅ ២-៣ ដង ភ្លើងកើតពីកម្មរបស់ភិក្ខុនោះ ព្រលែងសន្ធារមានចិត្តគ្រប់គ្រង កាន់យកសន្ធារមិនមានចិត្តគ្រប់គ្រង ។ ភិក្ខុនោះ ក៏រលត់សភាពក្តៅនៃភ្លើងធាតុ ដូចងូតទឹកដោយឆ្នាំងទឹក ១០០ ឆ្នាំង ឆាន់បបរយាគូដោយចាប់យកគោលកម្មដ្ឋានលាងបាត្រ និងមាត់ មនសិការកម្មដ្ឋានក្នុងរវាងកត្ត ត្រាច់ទៅបិណ្ឌបាត្រក្នុងទីដ៏សេស ឆាន់អាហារដោយកាន់យកគោលកម្មដ្ឋាន តាំងពីនោះ ទើបកាន់យកកម្មដ្ឋាន ប្រាកដដូចកូនសរស្មុះទៅមិនដាច់ ហើយមក ។ នេះលោកពោលថា **នាំមកមិននាំទៅ** ។ មួយ៉ាងទៀត ភិក្ខុដូចនេះ ឆាន់បបរយាគូហើយប្រារព្ធវិបស្សនា ឈ្មោះថា សម្រេចព្រះអរហត្តក្នុងព្រះពុទ្ធសាសនា រាប់មិនអស់ ភិក្ខុទាំងឡាយឆាន់បបរយាគូហើយ មិនសម្រេចព្រះអរហត្ត មិនមានក្នុងអាសនៈណា អាសនៈនោះមិនមានក្នុងអាសនសាលាក្នុងពួកស្រុកនោះៗ ក្នុងកោះសីហឡៈ ។

ក៏ភិក្ខុណានៅដោយសេចក្តីប្រមាទ ដាក់ធុរៈ ទម្លាយវត្តទាំងអស់ មានចិត្តចងទុកដោយគ្រឿងចង ៥ យ៉ាងហើយ មិនធ្វើសញ្ញាថា ឈ្មោះថា កម្មដ្ឋានមានហើយដូច្នេះ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត្រ ជាប់ជំពាក់ ដោយការស្និទ្ធស្នាលជាមួយគ្រហស្ថដែលមិនសមគួរ ទាំងត្រាច់ទៅរួមគ្នា បរិភោគរួមគ្នា ជាអ្នកចេញទៅទទេរ នេះលោកពោលថា **មិននាំទៅមិននាំត្រឡប់** ។

ក៏ភិក្ខុណា លោកពោលថា ភិក្ខុនេះទាំងនាំចេញទាំងនាំត្រឡប់នោះ គប្បីជ្រាបដោយអំណាចវត្តដែលប្រព្រឹត្តទៅ ដោយការទៅ និងការត្រឡប់ ។ ពិតណាស់ កុលបុត្តអ្នកប្រាថ្នាប្រយោជន៍ បួសក្នុងសាសនា នៅរួមគ្នា ១០ រូបខ្លះ ២០ រូបខ្លះ ៣០ រូបខ្លះ ៤០ រូបខ្លះ ៥០ រូបខ្លះ ១០០ រូបខ្លះ ធ្វើសេចក្តីព្រមព្រៀងគ្នាថា លោកដ៏មានអាយុទាំងឡាយ ពួកលោកបួសព្រោះជំពាក់គេក៏ទេ ព្រោះខ្លាចក៏ទេ ព្រោះចិញ្ចឹមជីវិតក៏ទេ ប្រាថ្នានឹងផុតចាកទុក្ខទើបបួសក្នុងធម្មវិន័យនេះ ។ ព្រោះដូច្នោះ ក្នុងការដើរទៅ ត្រូវតែគ្របសង្កត់កិលេសដែលកើតឡើងក្នុងខណៈដើរ ក្នុងការឈរ ក្នុងការអង្គុយ ក្នុងការដេក ចូរគ្របសង្កត់កិលេសដែលកើតឡើង ក្នុងការឈរ ក្នុងការស្ដាប់ ក្នុងការដេក ។

ភិក្ខុទាំងនោះ ធ្វើការព្រមព្រៀងគ្នាយ៉ាងនោះហើយ ទើបទៅដើម្បីភិក្ខាចារ ក្នុងរវាងកន្ទះឧសភៈ មួយឧសភៈ កន្ទះគាវុត មួយគាវុត មានផ្ទាំងថ្មហើយ មនសិការកម្មដ្ឋានដោយសញ្ញានោះទៅ បើមានកិលេសកើតឡើងក្នុងការទៅរបស់ភិក្ខុណា ភិក្ខុនោះរមែងគ្របសង្កត់កិលេសនោះ ក្នុងទីនោះ កាលមិនអាចគ្របសង្កត់បាន រមែងឈរនៅយ៉ាងនោះ បន្ទាប់មកសូម្បីភិក្ខុដែលមកក្រោយភិក្ខុនោះ ក៏នៅតែឈរ ។ ភិក្ខុនោះដាស់តឿនខ្លួនថា ភិក្ខុនេះដឹងវិតក្កដែលកើតឡើងដល់ខ្លួន នេះមិនសមគួរដល់អ្នកហើយចម្រើនវិបស្សនា ឈានចុះកាន់អរិយភូមិក្នុងទីនោះឯង ។ ប្រការថា កាលមិនអាច (គ្របសង្កត់កិលេសដែលកើតឡើង) ក៏អង្គុយនៅយ៉ាងនោះមានន័យនេះដូចគ្នា ។ សូម្បីពេលមិនអាចឈានចុះកាន់អរិយភូមិបាន ក៏គ្របសង្កត់កិលេសនោះ ហើយមនសិការកម្មដ្ឋាន ។ ភិក្ខុមានចិត្តប្រាសចាកកម្មដ្ឋាន រមែងលើកជើងឡើងមិនបាន ។ បើលើកឡើង បានត្រឡប់ទៅត្រឡប់មក ហើយក៏មកកាន់ទីដើម ដូច **ព្រះមហាបុស្សទេវត្ថេរ** អ្នកនៅក្នុង**អាលិន្ទកៈ** ដូច្នោះ ។

បានឮថា ព្រះថេរៈនោះ បំពេញវត្តដែលប្រព្រឹត្តទៅក្នុងការទៅ និងការត្រឡប់រហូតអស់ ១៩ ឆ្នាំ សូម្បីពួកមនុស្សក៏បានឃើញព្រះថេរៈនោះ

ក្នុងវាងផ្លូវនោះឯង ទាំងពួកគេកំពុងសាបព្រោះ ទាំងធ្វើការកាប់ឆ្ការដើម្បីការងារ ឃើញព្រះថេរៈទៅមកយ៉ាងនោះ ទើបសន្ទនាគ្នាថា ព្រះថេរៈនេះត្រឡប់ទៅមករឿយៗ លោកវង្វេងផ្លូវឬហ្ន៎ ឬថាភ្លេចអ្វីៗ ។ ព្រះថេរៈមិនធ្វើទុកចិត្តនូវរឿងនោះ ធ្វើសមណធម៌ដោយចិត្តប្រកបដោយកម្មដ្ឋាន សម្រេចព្រះអរហត្តក្នុងឆ្នាំទី ២០ ។ ក៏ក្នុងថ្ងៃដែលលោកសម្រេចព្រះអរហត្ត ពួកទេវតាដែលស្ថិតនៅខាងចុងទីចង្ក្រមរបស់លោក បានឈរបណ្តាលពន្លឺឲ្យភ្លឺរុងរឿងដោយម្រាមដៃ ។ សូម្បីស្តេចមហារាជទាំង ៤ ស្តេចសក្កទេវរាជ និងស្តេចសហម្បតីព្រហ្ម ក៏នាំគ្នាទៅឧបដ្ឋាក ។ ព្រះមហាតិស្សត្ថេរ ដែលនៅក្នុងព្រៃ ឃើញពន្លឺនោះ ទើបសួរព្រះថេរៈក្នុងថ្ងៃទីពីរថា ក្នុងពេលកណ្តាលយប់មានពន្លឺក្នុងសម្នាក់របស់លោក ពន្លឺនោះជាអ្វី ។ ព្រះថេរៈកាលនឹងពោលបង្វែងជាន ទើបពោលពាក្យមានជាដើមយ៉ាងនេះថា ធម្មតាពន្លឺ មានពន្លឺនៃប្រទីបខ្លះ ពន្លឺនៃកែវមុណីខ្លះ ដូច្នេះ ។ តពីនោះ ព្រះមហាតិស្សត្ថេរត្រូវព្រះថេរៈបញ្ជាក់ទៀតថា សូមលោកស្ងៀមចុះ លុះដឹងថា លោកទទួលហើយទើបប្រាប់ថា ។ ដូចព្រះមហានាគត្ថេរ អ្នកនៅក្នុងកាលវល្លិមណ្ឌប ។

មានរឿងដំណាលថា សូម្បីព្រះថេរៈនោះ ក៏បំពេញវត្តដែលប្រព្រឹត្តទៅក្នុងការទៅ និងការត្រឡប់ បានអធិដ្ឋានការដើរចង្ក្រមដោយការឈរហូត

អស់ ៧ ឆ្នាំថា យើងនឹងបូជាសេចក្ដីព្យាយាមជាលើកដំបូងដល់ព្រះមាន-ព្រះភាគជាម្ចាស់មុន ។ ព្រះថេរៈបំពេញវត្តដែលប្រព្រឹត្តទៅក្នុងការទៅ និងការត្រឡប់រហូតអស់ ១៦ ឆ្នាំ តទៅក៏បានសម្រេចព្រះអរហត្ត ។ ព្រះថេរៈមានចិត្តប្រកបដោយកម្មដ្ឋានទើបលើកជើងឡើង កាលចិត្តប្រាសចាកកម្ម-ដ្ឋានមិនលើកឡើង នឹងត្រឡប់ទៅទៀត បានទៅជិតស្រុក ឈរក្នុងប្រទេសដែលគួរសង្ស័យថា ជាមេគោ ឬបព្វជិតហ្ន៎ ដូច្នេះ ទើបដណ្ដប់ចីវរ លាងបាត្រដោយទឹកអំពីថ្លុកទឹក ហើយបៀមទឹកពេញមាត់ ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះកាលមនុស្សមកដើម្បីឲ្យភិក្ខាដល់យើង ឬដើម្បីថ្វាយបង្គំយើង សេចក្ដីរាយមាយរបស់កម្មដ្ឋាន កុំមានដោយហេតុនៃពាក្យនិយាយថា សូមលោកម្ចាស់ទាំងឡាយដ៏មានអាយុឈរ ដូច្នេះ ។ ព្រះថេរៈកាលត្រូវសួរដល់ថ្ងៃថា លោកម្ចាស់ ថ្ងៃនេះ ថ្ងៃទីប៉ុន្មាន ឬសួរចំនួនភិក្ខុ ឬបញ្ហាលេបទឹកមុនហើយទើបប្រាប់ ។ បើមិនមានអ្នកសួរដល់ថ្ងៃជាដើម ក្នុងវេលាចេញទៅ ខ្ជាក់ទឹកត្រង់ទ្វារស្រុកហើយទើបទៅ ។ ដូចភិក្ខុ ៥០ រូប ចូលចាំវស្សាក្នុង កលម្ពតិត្ថវិហារ ។

មានរឿងដំណាលថា ភិក្ខុទាំងនោះ ក្នុងថ្ងៃពេញបូរមី ខែ ៨ បានធ្វើសេចក្ដីព្រមព្រៀងគ្នាថា យើងនៅមិនទាន់សម្រេចអរហត្ត នឹងមិននិយាយ

គ្នា កាលចូលទៅស្រុកដើម្បីបិណ្ឌបាត្រ បៀមទឹកមួយទុកដៃហើយ ទើបចូលទៅ ពេលត្រូវគេសួរដល់ថ្ងៃជាដើម ក៏បដិបត្តិតាមន័យដែលពោលហើយនោះឯង ។ ពួកមនុស្សក្នុងស្រុកនោះឃើញស្នាមជើងបាត់ទៅ ដឹងថា ថ្ងៃនេះមកតែមួយរូប ថ្ងៃនេះមក ២ រូប ។ ក៏ពួកមនុស្សនាំគ្នាគិតយ៉ាងនេះថា ភិក្ខុទាំងនេះមិនសន្ទនាជាមួយយើងមែនឬ ឬសូម្បីជាមួយគ្នានិងគ្នាផង បើមិនសន្ទនាជាមួយគ្នានិងគ្នា នឹងកើតការឈ្លោះគ្នាដោយពិត ពួកលោកចូរមក យើងនឹងឲ្យភិក្ខុទាំងនោះសូមខមាទោសដល់គ្នានិងគ្នា ទាំងអស់នាំគ្នាទៅវិហារ បណ្តាភិក្ខុ ៥០ រូប មិនបានឃើញ សូម្បីពីររូបនៅក្នុងឱកាសតែមួយជាមួយគ្នា ។ តាំងតែពីនោះ បណ្តាមនុស្សទាំងនោះ បុរសដែលមានភ្នែកល្អពោលថា អ្នកដ៏ចម្រើនទាំងឡាយ ឱកាសរបស់អ្នកដែលឈ្លោះគ្នាមិនដូច្នេះទេ លោកបោសសម្អាតលានចេតិយ សម្អាតលានពោធិព្រឹក្ស រក្សាអំបោសទុកមានរបៀប តាំងទឹកផឹក ទឹកប្រើប្រាស់យ៉ាងរៀបរយ ។ អំពីនោះពួកមនុស្សក៏នាំគ្នាត្រឡប់ទៅវិញ ។ សូម្បីពួកភិក្ខុទាំងនោះ ក៏សម្រេចព្រះអរហត្តខាងក្នុង ៣ ខែ នោះឯង ក្នុងថ្ងៃមហាបវារណា ភិក្ខុមួយរូបៗ ក៏បវារណាវិសុទ្ធិបវារណា ។

ភិក្ខុមានចិត្តប្រកបដោយកម្មដ្ឋានដូច **ព្រះមហានាគត្ថេរ** អ្នកនៅក្នុង

កាលវេលាមណ្ឌប និងដូចភិក្ខុចាំវស្សាក្នុង កលម្ពតិត្ថវិហារ លើកជើងឡើង ដល់ទីជិតស្រុក បៀមទឹកពេញមាត់ កំណត់ផ្លូវ ដើរទៅកាន់ផ្លូវដែលមិនមាន មនុស្សឈ្លោះប្រកែកគ្នា មានអ្នកលេងសុរា និងអ្នកលេងល្បែងភ្នាល់ជាដើម ឬដំរីកាច សេះកាចជាដើម ។ ត្រាច់ទៅបិណ្ឌបាត្រក្នុងទីនោះ មិនទៅដោយប្រញាប់ប្រញាល់ ព្រោះថា ធម្មតាធុតង្គដែលប្រព្រឹត្តទៅដើម្បីបិណ្ឌ-បាត្រដោយប្រញាប់ណាមួយ រមែងមិនមាន ។ ជាអ្នកមិនញាប់ញ័រ ទៅដូចរទេះដឹកទឹកដែលដល់ទីមិនរាបស្មើ ដូច្នោះ ។ ម្យ៉ាងទៀត ភិក្ខុចូលទៅកាន់ផ្ទះតាមលំដាប់ រង់ចាំពេលដែលសមគួរនោះ ដើម្បីសង្កេតអ្នកបំណងនឹងឲ្យ ឬមិនបំណងនឹងឲ្យ ទទួលភិក្ខាហើយ មកកាន់វិហារ ខាងក្នុងស្រុក ឬខាងក្រៅស្រុក អង្គុយក្នុងឱកាសដែលសមគួរតាមសប្បាយ មនសិការកម្មដ្ឋានតាំងបដិកូលសញ្ញាក្នុងអាហារ ពិចារណា ដោយឧបមាដូចប្រេងភ្លៅរទេះ ថ្នាំលាបដំបៅ និងសាច់បុត្រ ឲ្យនាំមកនូវអាហារប្រកបដោយអង្គ ៨ មិនបរិភោគដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់ ដើម្បីតាក់តែង ។ល។ ឆាន់ទឹកហើយ រម្ងាប់សេចក្តីក្រវល់ក្រវាយព្រោះអាហារមួយភ្លែត ហើយមនសិការកម្មដ្ឋានរហូតអស់យាមខាងដើម និងយាមខាងចុង ខាងក្រោយអាហារ ដូចមុនអាហារ ដូច្នោះ ។ នេះលោកពោលថា ទាំងនាំទៅ ទាំងនាំ

ត្រឡប់ ដោយប្រការដូច្នេះ ។

ក៏ភិក្ខុបំពេញវត្តដែលប្រព្រឹត្តទៅ ក្នុងការទៅនិងការត្រឡប់ ពោលគឺការនាំទៅនិងការនាំត្រឡប់នេះ បើជាអ្នកដល់ព្រមដោយឧបនិស្ស័យ រមែងសម្រេចព្រះអរហត្តក្នុងបឋមវ័យនោះឯង ប្រសិនបើនៅមិនទាន់សម្រេចក្នុងបឋមវ័យ រមែងសម្រេចក្នុងមជ្ឈិមវ័យតទៅ បើមិនសម្រេចក្នុងមជ្ឈិមវ័យ រមែងសម្រេចក្នុងមរណសម័យតទៅ បើមិនសម្រេចក្នុងមរណសម័យ ជាទេវបុត្រហើយសម្រេច បើជាទេវបុត្រនៅមិនទាន់សម្រេច កាលព្រះពុទ្ធជាម្ចាស់នៅមិនទាន់ឧបត្តិ កើតហើយរមែងធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិ ប្រសិនបើនៅមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិបាន តទៅក៏នឹងជាអ្នកត្រាស់ដឹងរហ័សចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ដូចជាព្រះ-ពាហិយទារុចិរិយៈ ។ ឬជាអ្នកមានបញ្ញាច្រើន ដូចព្រះសារីបុត្តត្ថេរ ឬជាអ្នកមានឫទ្ធិច្រើន ដូចព្រះមោគ្គល្លានត្ថេរ ។ ឬជាអ្នកពោលកម្ចាត់កិលេសដូចព្រះមហាកស្សបត្ថេរ ។ ឬជាអ្នកមានចក្ខុទិព្វ ដូចព្រះអនុរុទ្ធត្ថេរ ។ ឬជាអ្នកទ្រទ្រង់វិន័យ ដូចព្រះឧបាលីត្ថេរ ។ ឬជាធម្មកថឹក ដូចព្រះបុណ្ណ-មន្តានីបុត្តត្ថេរ ។ ឬជាអ្នកនៅព្រៃជាវត្ត ដូចព្រះរេវតត្ថេរ ។ ឬជាពហុស្សូត ដូចព្រះអានន្ទត្ថេរ ។ ឬជាអ្នកប្រាថ្នាការសិក្សា ដូចព្រះរាហុលត្ថេរពុទ្ធឱរស

**គោចរសម្បជញ្ញៈ** របស់ភិក្ខុឈ្មោះថា ទាំងនាំទៅទាំងនាំត្រឡប់ ក្នុង ៤ ពួកនេះ ម្រេចជាការសិក្សាហើយ ដោយប្រការដូច្នេះ ។

ក៏ការមិនវង្វេង ក្នុងឥរិយាបថ មានការឈានទៅខាងមុខជាដើម ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** ។ អសម្មោហសម្បជញ្ញៈនោះ គប្បីជ្រាបដូចតទៅនេះ ៖

ភិក្ខុក្នុងធម្មវិន័យនេះ ឈានទៅខាងមុខ ឬថយក្រោយ ពេលចិត្តកើតឡើងថា យើងមិនវង្វេងហើយឈានទៅខាងមុខ វាយោធាតុដែលមានចិត្តជាសមុដ្ឋាន ជាមួយដោយចិត្តនោះ ឲ្យកើតការកម្រើកកើតឡើង គ្រោងឆ្អឹងដែលសម្មតិថាកាយនេះ រមែងឈានទៅខាងមុខ ដោយអំណាចការផ្សាយទៅនៃវាយោធាតុ ដែលជាកិរិយារបស់ចិត្ត ដោយប្រការដូច្នេះ ។ ដូចពួកបុគ្គលល្ងង់ខ្លៅរមែងវង្វេងថា ក្នុងការឈានទៅខាងមុខជាដើម ខ្លួនឈានទៅការឈានទៅខ្លួនធ្វើឲ្យកើត ឬយើងឈានទៅ ការឈានទៅយើងធ្វើឲ្យកើតដូច្នោះ ។ កាលភិក្ខុនោះ ឈានទៅខាងមុខយ៉ាងនេះ ក្នុងខណៈលើកជើងឡើងម្ដងៗ ធាតុទាំងពីរ គឺ បឋវីធាតុ អាបោធាតុ មានតិចតួច និងមានកម្លាំងខ្សោយ ធាតុទាំងពីរក្រៅនេះ មានប្រមាណក្រៃលែង និងមានកម្លាំងខ្លាំង ។ ក្នុងការឈានជើងទៅ និងការបន្តទៅ ក៏យ៉ាងនោះ ។ ក្នុងការឈប់

តេជោធាតុ វាយោធាតុមានតិចតួច និងមានកម្លាំងខ្សោយ ធាតុទាំងពីរក្រៅនេះ មានប្រមាណក្រៃលែង និងមានកម្លាំង ។ ក្នុងការដាក់ជើង និងការទប់ក៏យ៉ាងនោះ ។

រូបធម៌ និងអរូបធម៌ទាំងឡាយដែលប្រព្រឹត្តទៅហើយក្នុងការលើក (ជើង) ឡើងនោះ រមែងមិនដល់ការឈានទៅ រូបធម៌អរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងការឈានជើងទៅ ក៏យ៉ាងនោះ រមែងមិនដល់ការបន្ត រូបធម៌និងអរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងការបន្ត រមែងមិនដល់ការឈប់ រូប-ធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងការឈប់ រមែងមិនដល់ការដាក់ រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងការដាក់ រមែងមិនដល់ការទប់ ។ រូបធម៌ និងអរូបធម៌ ជាប្រការៗ និងចំណែកៗ ក្នុងទីនោះៗ មានសំឡេង តដៈ តដៈ បែកធ្លាយទៅ ដូចគេដាក់ល្ងចុះទៅក្នុងក្បឿងក្ដៅ ក្នុងសេចក្ដីនោះ បុគ្គលណាមួយឈានទៅខាងមុខ ឬការឈានទៅខាងមុខរបស់បុគ្គលណា មានឬ ។ ពិតណាស់ ដោយបរមត្ថ ធាតុនោះឯងដើរ ធាតុនោះឯងឈរ ធាតុនោះឯងអង្គុយ ធាតុនោះឯងដេក ។ ព្រោះថា ៖

ចិត្តដទៃកើតឡើង ចិត្តដទៃរលត់ ព្រមជាមួយរូប
ក្នុងចំណែកនោះៗ រមែងប្រព្រឹត្តទៅដូចក្រសែទឹក

ជាប់តាមទឹកហូរទៅ ដោយប្រការដូច្នេះ ។

ការមិនវង្វេង ក្នុងការឈានទៅខាងមុខជាដើមយ៉ាងនេះ ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** ។

ចប់សេចក្ដីនៃបទថា **អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ** ត្រឹមប៉ុណ្ណេះ ។

ក៏ក្នុងបទថា **ការក្រឡេកមើល ការរមិលមើល (អាលោកិតេ វិលោកិតេ)** នេះ ការសម្លឹងទៅខាងមុខ ឈ្មោះថា **ឱលោកិតៈ** (ការមើល) ការសម្លឹងទៅតាមទិស ឈ្មោះថា **វិលោកិតៈ** (ការរមិលមើល) សូម្បីការសម្លឹងយ៉ាងដទៃ ឈ្មោះថា មើលចុះ មើលឡើង រមិលមើល ដោយការសម្លឹងតាមខាងក្រោម ខាងលើ ខាងក្រោយ ។ ក្នុងទីនេះមិនកាន់យកការសម្លឹងយ៉ាងដទៃនោះទេ ។ តែដោយសេចក្ដីសមគួរ កាន់យកការសម្លឹងពីរយ៉ាងទាំងនេះ ។ ឬលោកកាន់យកការសម្លឹងសូម្បីទាំងអស់នោះ ដោយមាតិកានេះ ។ ក្នុងសម្បជញ្ញៈទាំងនោះ កាលចិត្តកើតឡើងថា យើងនឹងក្រឡេកមើល ការមិនក្រឡេកមើលដោយអំណាចចិត្តប៉ុណ្ណោះ ហើយកំណត់យកប្រយោជន៍ ឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។ សាត្ថកសម្បជញ្ញៈនេះ ធ្វើព្រះនន្ទៈឲ្យជាកាយសក្ខីហើយ គប្បីជ្រាបចុះ ។ សមដូចដែលព្រះមានព្រះភាគជាម្ចាស់

ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បើនន្ទៈក្រឡេកមើលទៅមុខយ៉ាងនេះ នន្ទៈប្រមូលវត្ថុទាំងអស់ដោយចិត្ត ហើយក្រឡេកមើលទៅមុខថា កាលយើងមើលទៅមុខយ៉ាងនេះ អកុសលធម៌ដ៏លាមក គឺ អភិជ្ឈា និងទោមនស្សនឹងមិនគ្របសង្កត់យើង ដូច្នេះ ឈ្មោះថា ជាអ្នកមានសម្បជញ្ញៈក្នុងវត្ថុនោះ ។ ម្នាលភិក្ខុទាំងឡាយ បើនន្ទៈក្រឡេកមើលទិសខាងក្រោយ ទិសខាងជើង ទិសខាងត្បូង ទិសខាងលើ ខាងក្រោម នន្ទៈប្រមូលវត្ថុទាំងពួងដោយចិត្តមើលតាមលំដាប់ទិសថា កាលយើងមើលតាមលំដាប់ទិសយ៉ាងនេះ ។ល។ ឈ្មោះថា ជាអ្នកមានសម្បជញ្ញៈ ដូច្នេះ ។

ក៏ក្នុងទីនេះ គប្បីជ្រាបការមានប្រយោជន៍ និងសប្បាយ ដោយការឃើញចេតិយ ដូចដែលពោលហើយក្នុងខាងដើមនោះឯង ។

ក៏ការមិនលះបង់កម្មដ្ឋាន ឈ្មោះថា **គោចរសម្បជញ្ញៈ** ព្រោះដូច្នោះ អ្នកបំពេញកម្មដ្ឋាន មានខន្ធ ធាតុ អាយតនៈជាអារម្មណ៍ក្តី អ្នកបំពេញកម្មដ្ឋាន មានកសិណជាដើមជាអារម្មណ៍ក្តី ដោយអំណាចកម្មដ្ឋានរបស់ខ្លួន គប្បីធ្វើការក្រឡេកមើល រមិលមើល ដោយមាតិកាកម្មដ្ឋានតែម្យ៉ាង ។ ឈ្មោះថា អត្តាក្នុងខាងក្នុង មិនមានការមើល ឬការរមិលមើល ក៏កាលចិត្តកើតឡើងថា យើងនឹងក្រឡេកមើល ដូច្នេះ វាយោធាតុ ដែលមានចិត្តជា

សមុដ្ឋានជាមួយចិត្តនោះឯង ធ្វើឲ្យកើតការកម្រើកឡើង ត្របកភ្នែកខាងក្រោមទាញចុះ ត្របកភ្នែកខាងលើក៏ទាញបើកទៅខាងលើ ដោយការផ្សាយទៅនៃវាយោធាតុ ដែលសម្រេចពីកិរិយារបស់ចិត្ត មិនមាននរណាៗ ឈ្មោះថាបើកបានដោយគ្រឿងយន្ត ។ តពីនោះ ចក្ខុវិញ្ញាណឲ្យសម្រេចកិច្ច គឺ ការឃើញកើតឡើង ក៏សេចក្ដីដឹងយ៉ាងនេះ ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** ក្នុងទីនេះ ។

គប្បីជ្រាប អសម្មោហសម្បជញ្ញៈក្នុងទីនេះ ដោយអំណាចនៃមូលបរិញ្ញា អាគន្តុកៈ និងតាវកាលិក ។ គប្បីជ្រាបដោយអំណាចមូលបរិញ្ញា (ការដឹងមូល) មុន ។

**ភវង្គៈ អាវជ្ជនៈ ទស្សនៈ សម្បដិច្ឆន្នៈ**

**សន្តីរណៈ វោដ្ឋព្វនៈ ជវនៈជាទី ៧ ។**

ក្នុងចិត្តទាំងនោះ ភវង្គៈ ញុំាងកិច្ចដែលជាអង្គនៃឧប្បត្តិភពឲ្យសម្រេចប្រព្រឹត្តទៅ ។ កិរិយាមនោធាតុ នឹកដល់អារម្មណ៍ ញុំាងអាវជ្ជនៈកិច្ចឲ្យសម្រេច ។ ព្រោះអាវជ្ជនកិច្ចនោះរលត់ ចក្ខុវិញ្ញាណញុំាងទស្សនកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ ។ ព្រោះរលត់ទស្សនកិច្ចនោះ វិបាកមនោធាតុញុំាងសម្បដិច្ឆន្នកិច្ចឲ្យសម្រេច ប្រព្រឹត្តទៅ ។ ព្រោះរលត់សម្បដិច្ឆន្នកិច្ចនោះ

វិបាកមនោវិញ្ញាណធាតុញ៉ាំងសន្តីរណកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ ។ ព្រោះវេលត់សន្តីរណកិច្ចនោះ កិរិយាមនោវិញ្ញាណធាតុ ញ៉ាំងវោដ្ឋព្វនកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ ។ ព្រោះវេលត់វោដ្ឋព្វនកិច្ចនោះ ជវនៈស្ទុះទៅ ៧ ខណៈ ។ ក្នុងជវនៈទាំងនោះ សូម្បីក្នុងបឋមជវនៈ ក៏មិនមានការក្រឡេកមើល និងការរមិលមើលដោយអំណាចរាគៈ សេចក្តីក្រោធ និងសេចក្តីវង្វេងថា នេះស្ត្រី នេះបុរស ដូច្នេះ ។ សូម្បីក្នុងទុតិយជវនៈ សូម្បីក្នុងសត្តមជវនៈ ក៏មិនមាន ។ កាលជវនៈទាំងនោះបែកធ្លាយទៅ ដោយអំណាចកិលេសដែលមានក្នុងខាងក្រោម ខាងលើ ដូចទាហានបែកខ្ញែកដោយការចាញ់សង្គ្រាមក្នុងសមរភូមិ ការក្រឡេកមើល និងការរមិលមើល រមែងមានដោយអំណាចរាគៈជាដើមថា នេះជាស្ត្រី នេះជាបុរស ដូច្នេះ ។ គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** ដោយអំណាចមូលបរិញ្ញាក្នុងទីនេះមុន ដោយប្រការដូច្នេះ ។

ក៏កាលរូបក្នុងចក្ខុទ្វារមកកាន់គន្លង កាលអាវជ្ជនៈជាដើមកើតហើយរលត់ទៅ ដោយអំណាចធ្វើកិច្ចរបស់ខ្លួនឲ្យសម្រេច បន្ទាប់ពីកវង្គចលនៈ ក្នុងទីបំផុតជវនៈរមែងកើតឡើង ។ ជវនៈនោះ ដូចជាអាគន្តុកបុរស ក្នុងចក្ខុទ្វារ ដែលជាផ្ទះរបស់អាវជ្ជនៈជាដើម ដែលកើតឡើងក្នុងកាលមុន ។ កាលអាគន្តុកបុរសនោះចូលទៅក្នុងផ្ទះរបស់អ្នកដទៃ ដើម្បីសូមអ្វីៗ សូម្បី

ពេលម្ចាស់ផ្ទះអង្គុយស្ងៀម ក៏មិនគួរបង្គាប់បញ្ជា (ម្ចាស់ផ្ទះ) យ៉ាងណា កាលអាវជ្ជនៈជាដើម ក្នុងចក្ខុទ្វារដែលជាផ្ទះរបស់អាវជ្ជនៈជាដើម មិនពេញចិត្ត មិនក្រោធ និងមិនវង្វេង ក៏មិនគួរពេញចិត្ត ក្រោធ និងវង្វេង ដូច្នោះ ។ គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** ដោយអំណាចជាអាគន្តុកៈ (អ្នកត្រាច់មក) យ៉ាងនេះ ដោយប្រការដូច្នេះ ។

ក៏ចិត្តទាំងនេះ ដែលមានវោដ្ឋពនៈជាទីបំផុតកើតឡើងក្នុងចក្ខុទ្វារ ចិត្តទាំងនោះ រមែងបែកធ្លាយទៅក្នុងទីនោះៗ ឯង ព្រមទាំងសម្បយុត្តធម៌ រមែងមិនឃើញគ្នានិងគ្នា ចិត្តក្រៅនេះ រមែងប្រព្រឹត្តទៅដោយជួរខណៈ ។ ក្នុងសេចក្តីនោះ ឧបមាដូចក្នុងផ្ទះមួយខ្នង កាលមនុស្សស្លាប់អស់ មនុស្សដ៏សេសមិនគួរត្រេកអរក្នុងការរាំ ការច្រៀងជាដើម របស់អ្នកមានមរណធម៌ក្នុងខណៈនោះ យ៉ាងណា កាលអាវជ្ជនៈជាដើម សម្បយុត្តក្នុងទ្វារមួយ រលត់ទៅក្នុងអារម្មណ៍នោះៗ សូម្បីជវនៈនៃមរណធម៌ក្នុងខណៈនោះដ៏សេស ក៏មិនគួរត្រេកអរដោយអំណាចរាគៈ សេចក្តីក្រោធ និងសេចក្តីវង្វេង គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** ដោយអំណាចភាពជាតាវកាលិក (ប្រព្រឹត្តទៅដោយជួរខណៈ) យ៉ាងនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** ដោយអំណាចការ

ពិចារណាខន្ធ ធាតុ អាយតនៈ និងបច្ច័យ ។ ក្នុងសេចក្តីនេះ មានអធិប្បាយ ដូច្នេះ ចក្ខុ និងរូប ជារូបក្ខន្ធ , វិញ្ញាណដែលអាស្រ័យរូបក្ខន្ធកើត ជាវិញ្ញាណក្ខន្ធ , វេទនាដែលសម្បយុត្តជាមួយវិញ្ញាណក្ខន្ធ ជាវេទនាខន្ធ , សញ្ញាសម្បយុត្តដោយវេទនានោះ ជាសញ្ញាខន្ធ , សង្ខារមានផស្សៈជាដើម ជាសង្ខារក្ខន្ធ ។ ការក្រឡេកមើល និងការរមិលមើលរមែងប្រាកដក្នុងការព្រមព្រៀងនៃខន្ធទាំងឡាយ ៥ នេះ ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីនោះ នរណាម្នាក់រមែងមើល នរណាម្នាក់រមែងរមិលមើល មិនមាន ។ម្យ៉ាងទៀត ចក្ខុជាចក្ខាយតនៈ រូបជារូបាយតនៈ ។ ការឃើញជាមនាយតនៈ ។ សម្បយុត្តធម៌ទាំងឡាយ មានវេទនាជាដើមជាធម្មាយតនៈ ។ ការក្រឡេកមើល និងការរមិលមើល រមែងប្រាកដក្នុងការព្រមព្រៀង (ប្រជុំ) នៃអាយតនៈ ៤ ទាំងនេះ ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីនោះ នរណាម្នាក់រមែងក្រឡេកមើល នរណារមែងរមិលមើល ។ ម្យ៉ាងទៀត ចក្ខុជាចក្ខុធាតុ រូបជារូបធាតុ ការឃើញជាចក្ខុវិញ្ញាណធាតុ ធម៌មានវេទនាជាដើមសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ ជាធម្មធាតុ ។ ការក្រឡេកមើល និងការរមិលមើលរមែងប្រាកដក្នុងសេចក្តីព្រមព្រៀង (ប្រជុំ) នៃធាតុ ៤ ទាំងនេះ ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីនោះ នរណាម្នាក់រមែងក្រឡេកមើល នរណា

រមែងរមិលមើល ។ម្យ៉ាងទៀត ចក្ខុជានិស្សយប្បច្ច័យ រូបជាអារម្មណ-ប្បច្ច័យ អាវជ្ជនៈជាអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ អាលោកៈ (ពន្លឺ) ជាឧបនិស្សយប្បច្ច័យ វេទនាជាដើម ជាសហជាតាទិប្បច្ច័យ ។ ការក្រឡេកមើល និងការរមិលមើលរមែងប្រាកដក្នុងសេចក្តីព្រមព្រៀងនៃបច្ច័យទាំងនេះ ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីនោះ នរណាម្នាក់រមែងក្រឡេកមើល នរណារមែងរមិលមើល គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** សូម្បីដោយអំណាចការពិចារណាជាខន្ធ អាយតនៈ ធាតុ និងបច្ច័យ ក្នុងប្រការនេះ ដោយប្រការដូច្នេះ ។

បទថា **ការបត់ចូល ការលាចេញ (សម្មិញ្ជិតេ បសារិតេ)** បានដល់ក្នុងការបត់ និងលានៃដៃជើងទាំងឡាយ ។ ក្នុងបទនោះ មានអធិប្បាយថាការមិនធ្វើការបត់ និងលា ដោយអំណាចចិត្ត ហើយកំណត់វត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ព្រោះបច្ច័យ គឺ ការបត់ និងការលាដៃនិងជើងហើយ កំណត់វត្ថុដែលជាប្រយោជន៍ ឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។ ក្នុងបទនោះ កាលបុគ្គលបត់ចូល ឬលាដៃ និងជើង ឈរយូរពេក វេទនារមែងកើតឡើងក្នុងខណៈនោះៗ បាន ។ ចិត្តរមែងមិនបានអារម្មណ៍តែមួយកម្មដ្ឋានរមែងធ្លាក់ទៅ រមែងមិនសម្រេចគុណវិសេស ដូច្នេះ ។ ក៏កាលបត់

និងលាក្នុងពេលដែលគួរ វេទនាទាំងនោះរមែងមិនកើត ។ ចិត្តរមែងមានអារម្មណ៍តែមួយ កម្មដ្ឋានរមែងដល់ការទ្រទ្រង់ទុក (សម្រេច) រមែងសម្រេចបាននូវគុណវិសេស គប្បីជ្រាប ការកំណត់វត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍យ៉ាងនេះ ដោយប្រការដូច្នេះ ។

ក៏សូម្បីកាលមានប្រយោជន៍ ការកំណត់វត្ថុដែលជាសប្បាយៈ និងអសប្បាយៈ ហើយកំណត់យកវត្ថុដែលជាសប្បាយៈ ឈ្មោះ **សប្បាយសម្បជញ្ញៈ** ក្នុងសេចក្ដីនោះ មានន័យដូចតទៅនេះ ។

បានឮថា ត្រង់លានមហាចេតិយ ពួកភិក្ខុកម្លោះស្វាធ្យាយព្រះធម៌ ។ ពួកភិក្ខុនីក្រមុំស្ដាប់ធម៌នៅខាងក្រោយភិក្ខុកម្លោះទាំងនោះ ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុកម្លោះមួយរូបលាដៃទៅត្រូវកាយសំសគ្គៈ ។ ទើបជាគ្រហស្ថដោយហេតុនោះឯង ។ ភិក្ខុមួយរូបទៀត កាលសណ្ដូកជើង បានសណ្ដូកទៅចំកន្លែងភ្លើង ភ្លើងឆេះរហូតដល់ឆ្អឹង ។ មួយរូបទៀត សណ្ដូកទៅត្រង់ដំបូកត្រូវអសិរពិសចឹក ។ មួយរូបទៀត សណ្ដូកទៅត្រង់ដងកូស់ ត្រូវពស់វែកខាំលោក ។ ព្រោះដូច្នេះ មិនគួរលាទៅក្នុងទីជាអសប្បាយៈបែបនេះ គួរលាទៅក្នុងទីសប្បាយៈ ។ នេះឈ្មោះថា **សប្បាយសម្បជញ្ញៈ** ក្នុងទីនេះ ។

ក៏គប្បីសម្ដែងគោចរសម្បជញ្ញៈ ដោយរឿងព្រះមហាថេរៈ ។ បាន

ឮថា ព្រះមហាថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃ កាលនិយាយជាមួយអន្តេ-វាសិកទាំងឡាយ បត់ដៃចូលហើយ ដាក់ទុកក្នុងទីដើមទៀត រឿយៗ ។ ពួកអន្តេវាសិកសួរលោកថា លោកម្ចាស់ ព្រោះហេតុអ្វី លោកទើបបត់ដៃហើយ ដាក់ទុកក្នុងទីដើម ហើយបត់រឿយៗ ។ ព្រះមហាថេរៈពោលថា អ្នកមានអាយុទាំងឡាយ ក៏ព្រោះយើងផ្តើមមនសិការកម្មដ្ឋាន យើងមិនធ្លាប់មិនមានកម្មដ្ឋានហើយ បតដៃឡើយ ក៏ឥឡូវនេះ យើងនិយាយជាមួយពួកលោក ភ្លេចកម្មដ្ឋានទើបបត់ដៃ ដូច្នោះ យើងទើបដាក់ទុកក្នុងទីដើមទៀត ហើយបត់ដៃ ។ ពួកអន្តេវាសិកពោលថា លោកម្ចាស់ ល្អហើយ ធម្មតាភិក្ខុគួរជាអ្នកបែបនោះ ។ ការមិនលះបង់កម្មដ្ឋាន សូម្បីក្នុងបទនេះ គប្បីជ្រាបថា ជា **គោចរសម្បជញ្ញៈ** ដោយប្រការដូច្នេះ ។

ឈ្មោះថា អត្តាក្នុងខាងក្នុងមិនមាន នរណាបត់ ឬលា ។ ក៏ការបត់ និងលា រមែងមាន ដោយការផ្សាយទៅនៃវាយោធាតុ ដែលជាកិរិយារបស់ចិត្ត ដូចពោលហើយ ដូចការកម្រើកដៃ និងជើងរបស់ទីងមោង ដោយអំណាចការទាញខ្សែ ព្រោះដូច្នោះ ការកំណត់ដឹងគប្បីជ្រាបថា ជា **អសម្មោហសម្បជញ្ញៈ** ក្នុងទីនេះ ។

ក្នុងបទថា ក្នុងការទ្រទ្រង់សំពត់សង្ឃាដិ បាត្រ និងចីវរ (សង្ឃាដិ-

បត្តចីវរធារណោ) នេះ មានអធិប្បាយថា ការប្រើប្រាស ឈ្មោះថា ទ្រទ្រង់ ដោយអំណាចការស្លៀក និងការដណ្តប់សង្ឃាដិ និងចីវរ ដោយអំណាចការនាំបាត្រទទួលភិក្ខាជាដើម ។ ក្នុងការទ្រទ្រង់សង្ឃាដិ និងចីវរនោះ ភិក្ខុស្លៀកដណ្តប់មុនហើយ ត្រាច់ទៅដើម្បីបិណ្ឌបាត្រ បានអាមិស និងប្រយោជន៍មានប្រការដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុក ដោយន័យមានជាអាទិថា ដើម្បីកម្ចាត់ភាពរងា ដូច្នេះ ឈ្មោះថាប្រយោជន៍ គប្បីជ្រាប **សាត្ថកសម្បជញ្ញៈ** ដោយអំណាចប្រយោជន៍នោះ ។ ក៏ចីវរសាច់ល្អិត ជាសប្បាយរបស់អ្នកមានសេចក្តីក្តៅជាប្រក្រតី និងអ្នកទុព្វលភាព ចីវរសាច់ក្រាស់ពីរជាន់ ជាទីសប្បាយរបស់អ្នកមានសេចក្តីត្រជាក់ជាប្រក្រតី ក្រៅអំពីនោះ មិនជាទីសប្បាយឡើយ ចីវរចាស់ មិនជាទីសប្បាយដល់នរណាៗឡើយ ។ ព្រោះថា ចីវរចាស់ទ្រុឌទ្រោមនោះ ធ្វើសេចក្តីកង្វល់ឲ្យដល់គេ ដោយការដេរប៉ះជាដើម ។ ចីវរដែលគួរបាន មានប្រភេទជាសំពត់ពោមចៀមពីរជាន់ជាដើម ក៏យ៉ាងនោះ ។ ព្រោះថា ចីវរដូច្នោះ រមែងធ្វើអន្តរាយដល់ការស្លៀក និងធ្វើអន្តរាយដល់ជីវិតរបស់ភិក្ខុមួយរូបក្នុងព្រៃបាន ។ ក៏ចីវរកើតដោយអំណាចមិច្ឆាជីវៈ មាននិមិត្តកម្មជាដើម (ជាគ្រូទាយ) និងអកុសលធម៌ រមែងចម្រើនដល់អ្នកប្រើប្រាស កុសលធម៌ រមែងវិនាសទៅ

ចីវរនោះ មិនជាទីសប្បាយ ឯក្រៅអំពីនោះជាទីសប្បាយ ។ គប្បីជ្រាប **សប្បាយសម្បជញ្ញៈ** ក្នុងសេចក្ដីនេះ ដោយអំណាចសប្បាយៈនោះ និង **គោចរសម្បជញ្ញៈ** ដោយអំណាចការមិនលះបង់កម្មដ្ឋាន ។

ឈ្មោះថា អត្តាក្នុងខាងក្នុង មិនមាននរណាៗ ដណ្ដប់ចីវរ ។ តែការដណ្ដប់ចីវររមែងមាន ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ដូចដែលពោលហើយ ។ ក្នុងការដណ្ដប់ចីវរនោះ សូម្បីចីវរក៏មិនមានចេតនា សូម្បីកាយក៏មិនមានចេតនា ចីវររមែងមិនដឹងថា យើងដណ្ដប់កាយ សូម្បីកាយក៏មិនដឹងថា យើងដណ្ដប់ចីវរ ធាតុប៉ុណ្ណោះបិទបាំងពួកធាតុ ដូចក្នុងការបិទបាំងស្បែដោយសំពត់ដូតដូលី ព្រោះដូច្នោះ បានចីវរល្អក៏មិនគួរត្រេកអរ បានចីវរមិនល្អក៏មិនគួរទោស់ចិត្ត ។ ពិតណាស់ មនុស្សពួកខ្លះ ធ្វើសក្ការៈដោយផ្កាឈើ គ្រឿងក្រអូប ធូប និងសំពត់ជាដើម ក្នុងដើមខ្លឹង ដំបូក ចេតិយ និងដើមឈើជាដើម ពួកខ្លះធ្វើអសក្ការៈដោយលាមក មូត្រ ភក់ល្បាប់ និងគ្រឿងប្រហារ គឺ កំណាត់ឈើ និងសស្ត្រាជាដើម ដំបូក និងដើមឈើជាដើម មិនធ្វើសេចក្ដីត្រេកអរ ដោយហេតុនោះ កាលបានចីវរល្អហើយក៏មិនគួរត្រេកអរ បានចីវរមិនល្អក៏មិនគួរទោស់ចិត្ត ។ គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** ក្នុងទីនេះ ដោយអំណាចការពិចារណា

ដែលប្រព្រឹត្តទៅហើយយ៉ាងនេះ ដោយប្រការដូច្នេះ ។

សូម្បីក្នុងការទ្រទ្រង់បាត្រ ក៏គប្បីជ្រាប **សាត្ថកសម្បជញ្ញៈ** ដោយអំណាចប្រយោជន៍ ដែលភិក្ខុមិនប្រញាប់ប្រញាល់ក្នុងការកាន់បាត្រ ព្រោះការកាន់បាត្រ ជាបច្ច័យយ៉ាងនេះថា យើងកាន់បាត្រនេះហើយ ត្រាច់ទៅដើម្បីបិណ្ឌបាត្រ នឹងបានភិក្ខា ។ ក៏បាត្រធ្ងន់មិនជាទីសប្បាយដល់រាងកាយដែលស្គម និងមានកម្លាំងតិច ។ បាត្រដែលផ្សាភ្ជាប់ (ដែក) គ្នា ៤-៥ ផ្ទាំង មិនជាទីសប្បាយដល់នរណាៗ ។ ពិតហើយ បាត្រលាងលំបាក មិនគួរសេចក្តីកង្វល់រមែងមានដល់អ្នកលាងបាត្រនោះ ។ ចំណែកបាត្រមានពណ៌ដូចកែវមណី ជាទីកើតលោភៈ មិនជាទីសប្បាយ ដោយន័យដែលពោលទុកហើយក្នុងចីវរនោះឯង ។ ក៏បាត្រណា ដែលបានហើយដោយអំណាចនិមិត្តកម្មជាដើម អកុសលធម៌រមែងចម្រើនឡើងដល់អ្នកប្រើប្រាស (បាត្រ) នោះ កុសលធម៌រមែងវិនាស បាត្រនេះមិនសប្បាយដោយចំណែកមួយ ក្រៅអំពីនេះជាទីសប្បាយ ។ គប្បីជ្រាបសប្បាយសម្បជញ្ញៈ ក្នុងប្រការនេះ ដោយអំណាចសប្បាយៈនោះ និងគោចរសម្បជញ្ញៈ ដោយអំណាចការមិនលះបង់កម្មដ្ឋាន ។

ឈ្មោះថា អត្តាក្នុងខាងក្នុង មិនមាននរណាកាន់បាត្រ ។ ឈ្មោះថា

ការកាន់បាត្រ រមែងមាន ដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្ត ដូចពោលហើយ ។ ក្នុងការកាន់បាត្រនោះ សូម្បីបាត្រក៏មិនមានចេតនា សូម្បីដៃក៏មិនមានចេតនា បាត្ររមែងមិនដឹងថា យើងត្រូវដៃចាប់ សូម្បីដៃក៏មិនដឹងថា យើងចាប់បាត្រ ធាតុប៉ុណ្ណោះកាន់យកពួកធាតុ ដូចក្នុងការកាន់បាត្រដែលមានពណ៌ដូចភ្លើង ដោយដង្កាប់ ។ គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** ក្នុងទីនេះ ដោយអំណាចការពិចារណាដែលប្រព្រឹត្តទៅហើយយ៉ាងនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ដូចមនុស្សទាំងឡាយអ្នកមានសេចក្តីអាណិត ឃើញមនុស្សអនាថាត្រង់អនាថសាលា មានដៃ និងជើងកំបុត មានខ្ទុះ ឈាម និងពួកដង្កូវហូរចេញអំពីដំបៅ មានរុយក្បាលខៀវចោមរោម នាំក្រណាត់រុំដំបៅ និងថ្នាំ ព្រមទាំងអំបែងក្បឿងជាដើមឲ្យដល់ពួកគេ ។ ក្នុងប្រការនោះ សំពត់សាច់ល្អិតរមែងមានដល់បុគ្គលខ្លះ សាច់គ្រោតគ្រាតរមែងមានដល់បុគ្គលខ្លះ ឯអំបែងក្បឿងដាក់ថ្នាំ មានសណ្ឋានល្អរមែងមានដល់បុគ្គលខ្លះ មានសណ្ឋានមិនល្អមានដល់បុគ្គលខ្លះ ។ ពួកមនុស្សអនាថាទាំងនោះ មិនត្រេកអរ ឬមិនទាស់ចិត្តក្នុងប្រការនោះឡើយ ។ ព្រោះថា សេចក្តីត្រូវការរបស់ពួកគេ ត្រឹមតែសំពត់រុំដំបៅប៉ុណ្ណោះ និងអំបែងក្បឿងសម្រាប់ដាក់ថ្នាំ

ប៉ុណ្ណោះ យ៉ាងណា ភិក្ខុសម្គាល់ចីវរដូចក្រណាត់រុំដំបៅ បាត្រដូចអំបែងក្បឿងដាក់ថ្នាំ ភិក្ខាដែលដាក់ក្នុងបាត្រដូចថ្នាំក្នុងអំបែងក្បឿង ដូច្នោះ គប្បីជ្រាបថា ភិក្ខុនេះ ជាអ្នកធ្វើសម្បជញ្ញៈដ៏ខ្ពស់បំផុតដោយ **អសម្មោហសម្បជញ្ញៈ** ក្នុងការទ្រទ្រង់សង្ឃដិ បាត្រ និងចីវរ ។

គប្បីជ្រាបក្នុងបទថា **អសិត** ជាដើម ។ បទថា **ការបរិភោគ (អសិតេ)** បានដល់ ក្នុងការឆាន់អាហារ ។ បទថា **ការផឹក (បិតេ)** បានដល់ ក្នុងការហុត មានបបរយាគូជាដើម ។ បទថា **ការទំពារ (ខាយិតេ)** បានដល់ ក្នុងការទំពារមានមេ្សៅ និងរបស់ទំពារជាដើម ។ បទថា **ការលិទ្ធ (សាយិតេ)** បានដល់ ក្នុងការលិទ្ធភក្សរសជាតិ មានទឹកឃ្មុំ ទឹកអំពៅជាដើម ។ ក្នុងបទទាំងនោះ ប្រយោជន៍សូម្បី ៨ យ៉ាង លោកពោលទុកមានជាដើមថា **នេវទវាយ** (មិនមែនដើម្បីលេង) ដូច្នេះ ឈ្មោះថា ប្រយោជន៍ ។ គប្បីជ្រាបសាត្ថកសម្បជញ្ញៈដោយអំណាចប្រយោជន៍នោះ ។ សេចក្តីមិនសប្បាយមានដល់បុគ្គលណា ដោយភោជនណា ក្នុងបណ្តាភោជនដែលសៅហ្មង ប្រណីតល្វីង និងផ្អែមជាដើម ភោជនបែបនោះ មិនជាទីសប្បាយដល់បុគ្គលនោះ ។ តែភោជនណាដែលបានមកដោយនិមិត្តកម្មជាដើម និងអកុសលធម៌ទាំងឡាយរមែងចម្រើន ដល់អ្នកបរិភោគភោជនប្រភេទណា កុសលធម៌ទាំងឡាយរមែង

វិនាសទៅ ភោជននោះ មិនជាទីសប្បាយដោយចំណែកមួយ ក្រៅអំពីនោះជាទីសប្បាយ គប្បីជ្រាបសប្បាយសម្បជញ្ញៈក្នុងទីនេះ ដោយអំណាចសប្បាយៈនោះ និងគោចរសម្បជញ្ញៈ ដោយអំណាចការមិនលះបង់កម្មដ្ឋាននោះឯង ។

ឈ្មោះថា អត្តាក្នុងខាងក្នុង មិនមាននរណាជាអ្នកបរិភោគ ។ ក៏ធម្មតា ការទទួលបាត្ររមែងមាន ដោយអំណាចការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្ត មានប្រការដូចពោលហើយ ។ ធម្មតាការញុំាងដៃចុះក្នុងបាត្រ រមែងមាន ដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្ត ។ ការពូតពំនូតបាយ ការលើកពំនូតបាយ និងការហាមាត់រមែងមាន ដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្ត ។ នរណាៗ រមែងមិនបើកឆ្អឹងចង្កាដោយកូនសោរ មិនមែនប្រើគ្រឿងយន្តទាញឆ្អឹងចង្កា ការដាក់ដុំបាយក្នុងមាត់ ធ្មេញខាងលើធ្វើនាទីជាអង្រែ ធ្មេញខាងក្រោមធ្វើនាទីជាត្បាល់ និងអណ្តាតធ្វើនាទីជាដៃ រមែងមាន ដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្ត ។ ទឹកមាត់តិចៗរមែងផ្សើមភោជននោះត្រង់ចុងអណ្តាតនោះ ទឹកមាត់ច្រើនរមែងផ្សើមត្រង់គល់អណ្តាត ។ ភោជននោះ ត្រឡប់ទៅមកដោយដៃ គឺ អណ្តាត ក្នុងត្បាល គឺ ធ្មេញ គឺ ធ្មេញខាងក្រោម ផ្សើមដោយទឹក គឺ ទឹកមាត់ បុកដោយ

អង្រែ គឺ ធ្មេញខាងលើ មិនមាននរណាៗ យកស្លាបព្រា ឬវែកស៊កបញ្ចូល ទៅខាងក្នុងបាន រមែងចូលទៅដោយវាយោធាតុ (ភោជននោះៗ) ចូលទៅហើយ ក៏មិនមាននរណាក្រាលចំបើងត្រងទទួលបាន តាំងនៅដោយវាយោធាតុប៉ុណ្ណោះ (ភោជននោះ) តាំងនៅហើយៗ ក៏មិនមាននរណាតាំងចង្ក្រាន ចម្អិនឲ្យរលួយបាន ការចម្អិនឲ្យរលួយដោយធាតុភ្លើង ចម្អិនហើយ ក៏មិនមាននរណានាំចេញខាងក្រៅ ដោយដំបង ឬឈើច្រត់បាន ក៏ចេញដោយវាយោធាតុប៉ុណ្ណោះ ដោយប្រការដូច្នេះ វាយោធាតុ រមែងនាំទៅយ៉ាងក្រៃលែងយ៉ាងវិសេស តាំងទុក ផ្លាស់ប្តូរ កិនស្ងួត និងនាំចេញ ។ បឋវីធាតុ តាំងទុកផ្លាស់ប្តូរ កិន និងស្ងួត ។ អាបោធាតុ រមែងផ្សេម រក្សាភាពស្រស់ ។ តេជោធាតុដុតវត្ថុទីចូលទៅខាងក្នុង អាកាសធាតុជាផ្លូវទៅ វិញ្ញាណធាតុអាស្រ័យការពេញចិត្តក្នុងធាតុនោះៗ រមែងចងទុក គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** ក្នុងទីនេះ ដោយអំណាចការពិចារណាដែលប្រព្រឹត្តទៅហើយយ៉ាងនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាប អសម្មោហសម្បជញ្ញៈក្នុងទីនេះ ព្រោះការពិចារណាអត្ថរបស់បដិកូល ១០ យ៉ាង គឺ ព្រោះការទៅ ព្រោះការស្វែងរក ព្រោះការបរិភោគ ព្រោះទីអាស្រ័យ ព្រោះការតម្កល់ទុក ព្រោះមិនរលួយ

ព្រោះរលួយហើយ ព្រោះផល ព្រោះការហូរចេញ ព្រោះប្រឡាក់ប្រឡូស ។ ក្នុងកថាពោលដោយពិស្តារក្នុងរឿងនេះ គប្បីកាន់យកពីនិទ្ទេសពោលដោយការសម្គាល់ក្នុងអាហារថា ជារបស់បដិកូលក្នុងគម្ពីរវិសុទ្ធិមគ្គចុះ ។

បទថា ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ (ឧច្ចារបស្សាវកម្មេ) បានដល់ ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ ។ ញើសរមែងហូរចេញពីខ្លួនរបស់អ្នកមិនបន្ទោបង់ឧច្ចារៈ បស្សាវៈ កាលបើដល់វេលា ភ្នែកទាំងពីររមែងស្រវាំង ចិត្តមិនតាំងមាំ រោគដទៃរមែងកើត តែទាំងអស់នោះរមែងមិនមានដល់អ្នកបន្ទោបង់ នេះជាការអធិប្បាយក្នុងបទនេះ ។ គប្បីជ្រាប សាត្ថកសម្បជញ្ញៈដោយអំណាចនៃសេចក្តីនោះ ។ ក៏កាលបើភិក្ខុបន្ទោបង់ឧច្ចារៈបស្សាវៈក្នុងជាទីមិនគួរ រមែងជាអាបត្តិ វិនាសយស សូម្បីអន្តរាយដល់ជីវិតរមែងមាន កាលបន្ទោបង់ក្នុងទីសមគួរ ទាំងអស់នោះរមែងមិនមាន នេះជាសប្បាយៈក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។ គប្បីជ្រាបសប្បាយសម្បជញ្ញៈដោយអំណាចនៃសប្បាយៈនោះ និងគោចរសម្បជញ្ញៈ ដោយអំណាចការមិនលះបង់កម្មដ្ឋាននោះឯង ។ ឈ្មោះថា អត្តាក្នុងខាងក្នុង មិនមានបន្ទោបង់ឧច្ចារៈ បស្សាវៈ ក៏ការបន្ទោបង់ឧច្ចារៈ បស្សាវៈ រមែងមានដោយការនាំទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ ។ ដូច

ជា កាលបួសចាស់ ព្រោះបែកធ្លាយ ខ្ទុះរមែងហូរចេញ ដោយមិនត្រូវការ យ៉ាងណា និងដូចជា ទឹកហូរចេញពីភាជនៈទឹកដែលពេញប្រៀបដោយមិនត្រូវការ យ៉ាងណា ឧច្ចារៈ បស្សាវៈ ដែលសន្សំទុកក្នុងក្រពះអាហារ និងក្រពះបស្សាវៈ ត្រូវកម្លាំងខ្យល់បៀតបៀន រមែងហូរចេញទាំងដែលមិនមានសេចក្តីប្រាថ្នា ក៏ដូច្នោះដូចគ្នា ។ ចំណែកឧច្ចារៈ បស្សាវៈនេះ កាលហូរចេញទៅយ៉ាងនេះ មិនបានជារបស់ខ្លួន របស់ភិក្ខុនោះ មិនបានជារបស់ជនដទៃ មានត្រឹមតែជាការហូរចេញពីសរីរៈតែម្យ៉ាង ។ សួរថា ដូចអ្វី? ឆ្លើយថា ដូចកាលបុគ្គលចាក់ទឹកចាស់ចេញពីថ្នាំង ទឹកនោះមិនបានជារបស់ខ្លួន មិនបានជារបស់ជនពួកដទៃ បានត្រឹមតែសម្រាប់ប្រើប្រាស់តែម្យ៉ាងប៉ុណ្ណោះ អសម្មោហសម្បជញ្ញៈក្នុងសេចក្តីនេះ គប្បីជ្រាបដោយអំណាចនៃការពិចារណាដូចពោលហើយ ដោយប្រការដូច្នេះ ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **គត** ស័ព្ទជាដើម បទថា **ការដើរ (គតេ)** គឺ ក្នុងការដើរ ។ បទថា **ការឈរ (ឋិតេ)** គឺ ក្នុងការឈរ ។ បទថា **ការអង្គុយ (និសិន្នេ)** គឺ ក្នុងការអង្គុយ ។ បទថា **កាដេក (សុត្តេ)** គឺ ក្នុងការដេក ។ បទថា **ការភ្ញាក់ (ជាគរិតេ)** គឺ ក្នុងការភ្ញាក់ ។ បទថា **ការនិយាយ (ភាសិតេ)** គឺ ក្នុងការនិយាយ ។ បទថា **កាស្ងៀម (តុណ្ហីភាវេ)**

គឺ ក្នុងការមិននិយាយ ។

ក៏ក្នុងឥរិយាបថនេះ ភិក្ខុរូបណា ដើរ ឬចង្ក្រមយូរហើយ ក្នុងកាលតមក ឈរពិចារណាយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយក្នុងវេលាដើរចង្ក្រម ក៏រលត់ក្នុងទីនេះហើយ ដូច្នេះ ។ នេះឈ្មោះថា ធ្វើសេចក្ដីដឹងខ្លួនក្នុងការដើរ ។

ភិក្ខុរូបណា កាលធ្វើការស្វាធ្យាយ ឆ្លើយបញ្ហា ឬមនសិការដល់កម្មដ្ឋាន ឈរយូរ ក្នុងកាលតមកអង្គុយពិចារណាយ៉ាងនេះថា រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាឈរ ក៏រលត់ក្នុងទីនេះឯង ដូច្នេះ ។ នេះឈ្មោះថា ធ្វើសេចក្ដីដឹងខ្លួនក្នុងការឈរ ។

ភិក្ខុរូបណា អង្គុយយូរដោយអំណាចនៃការស្វាធ្យាយជាដើម ក្នុងកាលតមក ទើបដេកពិចារណាយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយក្នុងវេលាអង្គុយ ក៏រលត់ក្នុងទីនេះ ដូច្នេះ ។ នេះឈ្មោះថា ធ្វើសេចក្ដីដឹងខ្លួនក្នុងការអង្គុយ ។

ចំណែកភិក្ខុរូបណា ពេលដេកធ្វើការស្វាធ្យាយ ឬមនសិការដល់កម្មដ្ឋានហើយលក់ទៅ ក្នុងកាលតមក ក្រោកឡើងពិចារណាយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយក្នុងវេលាដេក ក៏រលត់ក្នុងទីនេះ

ដូច្នេះ នេះឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការលក់ និងការភ្ញាក់ ។ ព្រោះថា ការមិនប្រព្រឹត្តទៅនៃចិត្តដែលសម្រេចដោយកិរិយា ឈ្មោះថា លក់ ឈ្មោះថា ភ្ញាក់ ដោយប្រការដូច្នេះ ។

ចំណែកភិក្ខុរូបណា ពេលនិយាយ រមែងនិយាយមានសតិសម្បជញ្ញៈថា ឈ្មោះថា សំឡេងនេះរមែងកើត ព្រោះអាស្រ័យបបូរមាត់ ព្រោះអាស្រ័យធ្មេញ អណ្តាត និងពិតាន និងព្រោះអាស្រ័យការប្រកបនៃចិត្តដែលសមគួរដល់សំឡេងនោះ ឬការស្វាធ្យាយ ឬពោលធម៌ ឲ្យផ្លាស់ប្តូរកម្មដ្ឋាន ឬឆ្លើយបញ្ហាអស់កាលយូរ ក្នុងកាលតមក ក៏នៅស្ងៀម ពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ដែលកើតឡើងហើយក្នុងវេលានិយាយ ក៏រលត់ក្នុងទីនេះ ដូច្នេះ ។ នេះឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការនិយាយ ។

ភិក្ខុរូបណាស្ងៀម ធ្វើទុកក្នុងចិត្តដល់ធម៌ ឬកម្មដ្ឋានរហូតអស់កាលយូរ ក្នុងកាលតមក រមែងពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាស្ងៀម ក៏រលត់ក្នុងទីនេះ ដូច្នេះ ។ កាលការប្រព្រឹត្តទៅនៃឧបាទាយរូបមាននៅ ឈ្មោះថា និយាយ ។ កាលមិនមាន ឈ្មោះថា ជាអ្នកស្ងៀម ដូច្នេះ ។ នេះឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការស្ងៀម ដោយប្រការដូច្នេះ ។ ក្នុងប្រការនេះ ជាអសម្មោហសម្បជញ្ញៈ

សេចក្តីដឹងខ្លួន គប្បីជ្រាបដោយអំណាចនៃអសម្មោហសម្បជញ្ញៈនោះឯង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់សម្បជញ្ញៈលាយដោយសតិប្បដ្ឋានថា ជាបុព្វភាគ ដូច្នេះ ។

ចប់អដ្ឋកថា សតិសូត្រទី ២

# អ ដ្ឋ ក ថា

## ភិក្ខុសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភិក្ខុសូត្រទី ៣*

[៩] *បទថា* **មោឃបុរសពួកខ្លះក្នុងលោក...យ៉ាងនេះដូចគ្នា** *(ឯវមេវ បនិធេកច្ចេ) សេចក្តីថា បានឮថា ភិក្ខុនោះឲ្យប្រាប់កម្មដ្ឋានហើយ រមែងត្រាច់ទៅខាងណេះខាងណោះ មិនតាមប្រកបកាយវិវេក ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់គ្របសង្កត់ភិក្ខុនោះ ទើបត្រាស់យ៉ាងនេះ ។*

[១០] *បទថា* **ព្រោះហេតុនោះ** *(តស្មា) បានដល់ ព្រោះភិក្ខុនោះសូមទេសនាដោយសង្ខេប ។ បទថា* **ការឃើញ** *(ទិដ្ឋិ) បានដល់ ការឃើញថា សត្វមានកម្មជារបស់ខ្លួន ។*

ចប់អដ្ឋកថា ភិក្ខុសូត្រទី ៣

# អ ដ្ឋ ក ថា

## កោសលសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***កោសលសូត្រទី ៤***

[១៤] *បទថា* ***ធម្មវិន័យ (ធម្មវិនយោ)*** *សេចក្តីថា បទទាំង ២ ថា ធម៌ ឬវិន័យនោះ ជាឈ្មោះរបស់សត្ថុសាសន៍ប៉ុណ្ណោះ ។ បទថា* ***គប្បីឲ្យសមាទាន (សមា ទបេតព្វា)*** *បានដល់ ដែលអ្នកទាំងឡាយគប្បីឲ្យកាន់យក ។*

[១៥] *បទថា* ***មានធម៌ឯកកើតឡើង (ឯកោទិភូតា)*** *បានដល់ ភាពជាអ្នកមានចិត្តស្ងប់ដោយខណិកសមាធិ ។ បទថា* ***មានចិត្តតាំងមាំ មានចិត្តមានអារម្មណ៍តែមួយ (សមាហិតា ឯកគ្គចិត្តា)*** *សេចក្តីថា មានចិត្តតាំងមាំដោយប្រពៃ និងមានចិត្តមានអារម្មណ៍តែមួយ ដោយអំណាចឧបចារៈ និងអប្បនា ។ ក្នុងសូត្រនេះ សតិប្បដ្ឋានដែលភិក្ខុថ្មីទាំងឡាយ និងព្រះខីណាស្រពទាំងឡាយចម្រើនហើយ ជាបុព្វភាគ ។ ព្រះសេខៈ ៧ ពួក ចម្រើនហើយ ជាមិស្សកៈ (លាយគ្នា) ។*

ចប់អដ្ឋកថា កោសលសូត្រទី ៤

# អ ដ្ឋ ក ថា

## សកុណគ្ឃីសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុង សកុណគ្ឃិសូត្រទី ៦

[២១] បទថា *សត្វខ្លែង (សកុណគ្ឃិ)* បានដល់ ឈ្មោះថា សកុណគ្ឃិ ព្រោះអត្ថថា សម្លាប់បក្សី ។ ពាក្យនោះជាឈ្មោះរបស់សត្វស្ទាំ ។ បទថា **ចាប់យកដោយរហ័ស (សហសា អជ្ឈប្បត្តា)** បានដល់ ចាប់យកដោយរហ័ស ព្រោះសេចក្តីលោភ ។ បទថា **អាប់ជោគ (អលក្ខិកា)** បានដល់ ជាអ្នកមិនមានសិរី ។ បទថា **មានបុណ្យតិច (អប្បបុញ្ញា)** ប្រែថា ជាអ្នកមានបុញ្ញតិច ។ បទថា **ប្រសិនបើថ្ងៃនេះ... យើង (សចជ្ជ មយំ)** កាត់បទជា **សចេ អជ្ជ មយំ** បើថ្ងៃនេះយើង ។ បទថា **ដែលគេធ្វើការភ្ជួរហើយ (នង្គលកដ្ឋករណំ)** បានដល់ ការធ្វើស្រែដោយនង្គ័ល អធិប្បាយថា ទីស្រែដែលភ្ជួរថ្មីៗ ។ បទថា **ទីដែលមានដុំដី (លេឌ្ឌុដ្ឋានំ)** គឺ ទីបែកក្រហែង ។ បទថា **អួតអាង (អវាទមានា)** គឺ សត្វខ្លែងពោលអួតអាង អធិប្បាយថា ពោលសរសើរកម្លាំងរបស់ខ្លួនដោយល្អ ។ បទថា **ឡើងកាន់ដុំធំ (មហន្តំ លេឌ្ឌុំ អភិរូហិត្វា)** សេចក្តីថា សត្វប្រចៀចកំណត់ត្រង់ដុំដី ៣ ដុំ តាំងនៅ

ដោយសណ្ឋានដូចមុំចង្ក្រានថា កាលសត្វខ្លែង ហើរមកខាងនេះ យើងនឹងគេចទៅខាងនោះ បើហើរមកខាងនោះ យើងនឹងគេចទៅខាងនេះ ដូច្នេះ ក៏ឡើងទំលើដុំដីមួយដុំ ក្នុងដុំដី ៣ ដុំ នោះ ឈរបង្កជម្លោះ ។ បទថា **អូតអាង (អវាទមានា)** គឺ ពោលអូត ។ បទថា **សម្ងបស្ងាប (សន្នាយ)** បានដល់ សម្ងបស្ងាប គឺ តាំងទុកដោយល្អ ។ បទថា **សត្វខ្លែងធាបចុះដោយរហ័ស (ពហុ អាគតោ ខោ ម្យាយំ)** សេចក្ដីថា សត្វប្រចៀបដឹងថា សត្វខ្លែងនេះហើរមកពីទីឆ្ងាយដើម្បីត្រូវការយើង ដែលមានកម្លាំងតិច ឥឡូវនេះ នឹងចាប់យើង ដូច្នេះ ទើបគេចចូលទៅក្នុងចន្លោះដីនោះឯង ដូចទឹកអំពៅជ្រាបចូលទៅក្នុងផែនដី ។ បទថា **សត្វខ្លែងក៏ទន្ទិចទ្រូងនឹងដុំដី (ឧរំ បច្ច-តាឡេសិ)** សេចក្ដីថា សត្វខ្លែងកាលមិនអាចបញ្ឈប់សេចក្ដីរហ័សទុកបាន ព្រោះស្ទុះទៅដោយគិតថា យើងនឹងចាប់ត្រង់ក្បាលរបស់ប្រចៀប ក្នុងគ្រានេះ ដូច្នេះ ទើបទន្ទិះទ្រូងនឹងដុំដីនោះ ក្នុងពេលនោះឯង ទ្រូងរបស់សត្វខ្លែងក៏បែកក្នុងគ្រានោះ សត្វប្រចៀបត្រេកអរថា យើងឃើញខ្នងរបស់សត្រូវ ដូច្នេះ ទើបដើរជាន់ទៅមកត្រង់បេះដូងរបស់សត្វខ្លែងនោះ ។

ចប់អដ្ឋកថា សកុណគ្ឃិសូត្រទី ៦

# អ ដ្ឋ ក ថា

## មក្កដសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង មក្កដសូត្រទី ៧ ដូចតទៅ ៖

[២៤] បទថា ដែលទៅបានលំបាក (ទុគ្គា) ប្រែថា ទៅលំបាក ។ បទថា ទីត្រាច់ទៅ (ចារី) ប្រែថា ជាទីត្រាច់ ។ បទថា ដាក់ជ័រស្អិត (លេបំ ឱឌ្ឌេន្តិ) សេចក្តីថា ពួកព្រានធ្វើជ័រស្អិតផ្សំដោយជ័រជ្រៃជាដើម កំណត់ថា ទីនោះៗ ជាផ្លូវដើរប្រចាំរបស់ពួកស្វា ដូច្នេះ ហើយដាក់ទុកត្រង់មែកដើមឈើជាដើម ។ បទថា ចំណងប្រាំប្រការ (បញ្ចោឌ្ឌិតោ) សេចក្តីថា ស្វាត្រូវចំណងក្នុងទីទាំង ៥ ដូចសង្រែក ដែលខ្លួនស៊ីកដងវែកចូលទៅហើយខ្វាស់ទុក ដូច្នេះ ។ បទថា ដេកដកដង្ហើមធំ (ថុនំ សេតិ) បានដល់ ដេកដកដង្ហើមធំហើយ ។

ចប់អដ្ឋកថា មក្កដសូត្រទី ៧

# អ ដ្ឋ ក ថា

## សូទសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង សូទសូត្រទី ៨*

[២៧] *បទថា **អ្នកគ្រួ** (សូទោ) ប្រែថា អ្នកចម្អិនភត្ត ។ បទថា **ដោយម្ហូបមានប្រភេទផ្សេងៗ** (នានច្ចយេហិ) គឺ ច្រើនប្រភេទ អធិប្បាយថា ច្រើនយ៉ាង ។ ម្យ៉ាងទៀត បាឋៈនេះក៏ដូចគ្នា ។ បទថា **រសជូរ** (អម្ពិលគ្គេហិ) បានដល់ មានរសជូរ ។ ក្នុងបទទាំងពួងក៏ន័យនេះដែរ ។ បទថា **ទទួល** (អភិហរតិ) បានដល់ លាដៃចេញដើម្បីត្រូវការទទួល ។ បទថា **ទទួលយកច្រើន** (ពហុំ គណ្ហាតិ) សេចក្ដីថា កាលទទួលច្រើន ដោយទទួលតែម្ដងក្ដី ទទួលរឿយៗ ក្ដី ក៏ឈ្មោះថា ទទួលច្រើននោះឯង ។ បទថា **រង្វាន់** (អភិហារានំ) សេចក្ដីថា រង្វាន់មួយរយ ឬមួយពាន់ ដែលគេប្រគល់ឲ្យ ។*

[២៨] *បទថា **ឧបក្កិលេស** (ឧបក្កិលេសា) បានដល់ និវរណៈ ៥ យ៉ាង ។ បទថា **មិនរៀននូវនិមិត្ត** (និមិត្តំ ន ឧគ្គណ្ហាតិ) សេចក្ដីថា ភិក្ខុរមែងមិនដឹងថា កម្មដ្ឋាននេះរបស់យើង ចូលដល់អនុលោមញាណ ឬគោត្រ-ភូញាណហើយ ដូច្នេះ រមែងមិនអាចកាន់យកនិមិត្តនៃចិត្តរបស់ខ្លួនបាន ។*

ក្នុងព្រះសូត្រនេះ ព្រះអង្គត្រាស់សតិប្បដ្ឋាន ដែលជាបុព្វភាគនៃវិបស្សនា នោះឯង ។

ចប់អដ្ឋកថា សូទសូត្រទី ៨

# អ ដ្ឋ ក ថា

## គិលានសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង គិលានសូត្រទី ៩*

[៣១] *បទថា* ***វេឡុវគ្រាម (វេឡុវគាមកេ)*** *សេចក្តីថា មានបុរគាមមួយកន្លែង មានឈ្មោះយ៉ាងនេះ ជិតក្រុងវេសាលី ។ ត្រង់បុរគាមនោះ ។ ក្នុងបទទាំងឡាយ មានបទថា* ***យថាមិត្តំ*** *ជាដើម គប្បីជ្រាបខ្លឹមសារដូចតទៅនេះ បទថា* ***មិត្ត (មិត្តំ)*** *បានដល់ មិត្តទាំងឡាយ ។ បទថា* ***តាមសហាយ (សន្ទិដ្ឋំ)*** *សេចក្តីថា មិត្តជួបគ្នាដំបូងរួមគ្នាក្នុងទីនោះៗ ចាត់ជាមិត្តដែលមិនមុតទាំ ។ បទថា* ***តាមពួក (សម្ភត្តំ)*** *សេចក្តីថា មិត្តល្អ មានសេចក្តីស្និទ្ធស្នាល ចាត់ជាមិត្តមាំទាំ ។ អធិប្បាយថា ពួកអ្នកទាំងឡាយចូរចូលចាំវស្សាក្នុងទីដែលមានភិក្ខុទាំងឡាយបែបនោះចុះ ។ សួរថា ត្រាស់យ៉ាងនោះ ព្រោះហេតុអ្វី ។ ឆ្លើយថា ដើម្បីនៅជាសុខរបស់ភិក្ខុទាំងឡាយនោះ ។ បានឮថា ក្នុងវេឡុវគ្រាម សេនាសនៈមិនល្មមសម្រាប់ភិក្ខុទាំងនោះទាំងភិក្ខាក៏តិច តែជុំវិញក្រុងវេសាលី មានសេនាសនៈច្រើន ទាំងភិក្ខាក៏រកបានងាយ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់យ៉ាងនេះ ។*

សួរថា បើដូច្នោះ ព្រោះហេតុអ្វី ព្រះអង្គទើបទ្រង់មិនអនុញ្ញាតទៅថា អ្នកទាំងឡាយ ចូរទៅតាមសប្បាយចុះ ។ ឆ្លើយថា ដើម្បីអនុគ្រោះភិក្ខុទាំងឡាយនោះ ។ បានឮថា ព្រះអង្គទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតតាំងនៅត្រឹមកន្លះខែនឹងបរិនិព្វាន ។ បើភិក្ខុទាំងឡាយនឹងទៅឆ្ងាយពីតថាគត ភិក្ខុទាំងឡាយនឹងមិនអាចឃើញតថាគត ក្នុងវេលាបរិនិព្វាន ។ គ្រានោះ ពួកគេគប្បីមានសេចក្ដីក្ដៅក្រហាយថា កាលព្រះសាស្ដាបរិនិព្វាន មិនបានប្រទានសូម្បីត្រឹមតែសតិដល់យើងទាំងឡាយ បើយើងទាំងឡាយដឹង ក៏មិនគប្បីនៅឆ្ងាយយ៉ាងនេះ ។ តែកាលភិក្ខុទាំងឡាយនៅជុំវិញក្រុងវេសាលី នឹងមកស្ដាប់ធម៌មួយខែ ៨ ដង នឹងបានឱវាទរបស់ព្រះសុគតដូច្នេះ ទើបទ្រង់មិនអនុញ្ញាត ។

[៣២] បទថា **ខ្លាំង (ខរោ)** បានដល់ ខ្លាំងក្លា ។ បទថា **អាពាធោ** បានដល់ រោគដែលជាវិសភាគៈ ។ បទថា **ធ្ងន់ (ពាឡ្ហា)** ប្រែថា មានកម្លាំង ។ បទថា **ជិតមរណៈ (មរណន្តិកា)** បានដល់ អាចនឹងស្លាប់ គឺជិតស្លាប់បាន ។ បទថា **ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់អត់ទ្រាំ (សតោ សម្បជានោ អធិវាសេតិ)** សេចក្ដីថា ទ្រង់តាំងព្រះសតិទុកដោយល្អ កំណត់ដោយញាណ ទ្រង់អត់ទ្រាំ ។ បទថា **ទ្រង់មិនឲ្យវេទនាបៀតបៀន (អវិហញ្ញមានោ)**

សេចក្តីថា ទ្រង់មិនរសាប់រសល់ទៅតាមអំណាចវេទនា គឺ ទ្រង់អត់ទ្រាំមិនឲ្យវេទនាបៀតបៀន និងមិនឲ្យកើតទុក្ខ ។ បទថា **មិនប្រាប់ (អានាមន្តេត្វា)** គឺ មិនប្រាប់ភិក្ខុឲ្យដឹង និងមិនប្រកាសភិក្ខុសង្ឃឲ្យដឹង លោកអធិប្បាយថា មិនប្រទានឱវាទានុសាសនី ។ បទថា **ដោយសេចក្តីព្យាយាម (វិរិយេន)** បានដល់ ដោយសេចក្តីព្យាយាមជាបុព្វភាគ និងដោយសេចក្តីព្យាយាមជាផលសមាបត្តិ ។ បទថា **បណ្តេញចេញ (បដិប្បណាមេត្វា)** គឺ សង្កត់ទុក ។ ក្នុងបទថា **ជីវិតសង្ខារ (ជីវិតសង្ខារំ)** នេះ សូម្បីជីវិតចាត់ជាជីវិតសង្ខារ ។ ជីវិតដែលបុគ្គលរក្សា គឺ ដល់ជីវិតដែលកំពុងដាច់ តាំងនៅបានដោយធម៌ គឺ សមាបត្តិណា សូម្បីធម៌ គឺ ផលសមាបត្តិនោះ ក៏ចាត់ជាជីវិតសង្ខារ ។ ជីវិតសង្ខារនោះ ទ្រង់បំណងក្នុងទីនេះ ។ បទថា **ទ្រង់តាំងអធិដ្ឋាន (អធិដ្ឋាយ)** សេចក្តីថា តថាគតគប្បីចូលផលសមាបត្តិ ដែលអាចអធិដ្ឋានហេតុឲ្យតាំងជីវិតនៅតទៅបាន ដូច្នេះ ។ នេះជាសេចក្តីសង្ខេបក្នុងប្រការនេះ ។

សួរថា មុនអំពីនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់មិនចូលផលសមាបត្តិឬ ។ ឆ្លើយថា ទ្រង់ចូល ។ តែសមាបត្តិនោះ ជាខណិកសមាបត្តិ ក៏ខណិកសមាបត្តិ រមែងគ្រប់សង្កត់វេទនាបានក្នុងខាងក្នុងសមាបត្តិប៉ុណ្ណោះ ពេលចេញចាកសមាបត្តិហើយ វេទនារមែងគ្របសង្កត់សរីរៈទៀត ដូចជា

សាកាយជាប់អំពីគ្នា ព្រោះកំណាត់ឈើធ្លាក់ ឬព្រោះថ្មធ្លាក់ ហើយក៏សោត់គ្របទឹកវិញ ដូច្នេះ ។ សមាបត្តិដែលចូលដោយអំណាចមហាវិបស្សនា ធ្វើពួក ៧ នៃរូប និងពួក ៧ នៃអរូប មិនឲ្យកកើត មិនឲ្យជាព្រៃក្រាស់ណា សមាបត្តិនោះ រមែងគ្របសង្កត់ទុកដោយល្អ ។ កាលចេញចាកសមាបត្តិនោះហើយ វេលាយូរ វេទនាទើបកើតឡើងបាន ដូចសាកាយដែលប្រើឲ្យមនុស្សចុះកាន់ស្រះបោក្ខរណីយកដៃ និងជើងវែក មិនឲ្យចូលជិតគ្នា វេលាយូរ ទើបរួមមកគ្របទឹកបាន ដូច្នេះ ។ ដោយប្រការយ៉ាងនោះ ក្នុងថ្ងៃនោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ធ្វើពួក ៧ នៃរូប និងពួក ៧ នៃអរូប មិនឲ្យកកើត មិនឲ្យជាព្រៃក្រាស់ ដូចផ្តើមតាំងវិបស្សនាថ្មីៗ ត្រង់មហា-ពោធិបល្ល័ង្ក ហូរទៅដោយអាការ ១៤ ទ្រង់គ្របសង្កត់វេទនាដោយមហាវិបស្សនា ទ្រង់ចូលសមាបត្តិ ដោយទ្រង់ត្រិះរិះថា រហូត ១០ ខែ វេទនាកុំកើតឡើងឡើយ ដូច្នេះ ។ វេទនាដែលសមាបត្តិគ្របសង្កត់ទុក ក៏កើតឡើងមិនបានរហូត ១០ ខែ ។ បទថា ***ទ្រង់សះស្បើយ (គិលានា វុដ្ឋិតោ)*** បានដល់ទ្រង់សះស្បើយចាកអាពាធ ។

[៣៣] បទថា ***មធុរកជាតោ វិយ*** សេចក្តីថា កើតសេចក្តីធ្ងន់ កើតសេចក្តីរឹង ដូចត្រូវអ្នកផាលំពែងឡើងធ្វើឲ្យក័យខ្វាច ។ បទថា ***មិនប្រាកដ***

(ន បក្ខាយន្តិ) បានដល់ រមែងមិនប្រកាស គឺ រមែងមិនប្រាកដ ព្រោះហេតុផ្សេងៗ ។ បទថា **សូម្បីធម៌ទាំងឡាយក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ (ធម្មាបិ មំ នប្បដិភន្តិ)** លោកសម្តែងថា សតិប្បដ្ឋានធម៌ រមែងមិនប្រាកដដល់ខ្ញុំព្រះអង្គ ។ ចំណែកធម៌ដែលជាបែបផែន ជាធម៌ជំនាញដោយល្អរបស់ព្រះថេរៈ ។ បទថា **មិនត្រាស់ (ន ឧទាហរតិ)** សេចក្តីថា ព្រះអានន្ទពោលសំដៅដល់ប្រការថា ព្រះមានព្រះភាគជាម្ចាស់នៅមិនទាន់ប្រទានបច្ឆិមឱវាទ ។

បទថា **មិនឲ្យមានក្នុង មិនឲ្យមានក្រៅ (អនន្តរំ អពាហិរំ)** សេចក្តីថា ក៏ភិក្ខុកាលមិនធ្វើឲ្យមានខាងក្នុង មិនឲ្យមានខាងក្រៅ ទាំងពីរដោយអំណាចធម៌ ឬដោយអំណាចបុគ្គល គិតថា តថាគតនឹងមិនសម្តែងធម៌ប្រមាណប៉ុណ្ណេះ ឈ្មោះថា ធ្វើធម៌ឲ្យមានក្នុងខាងក្នុង ។ ពេលគិតថា នឹងសម្តែងធម៌ប្រមាណប៉ុណ្ណេះដល់បុគ្គលដទៃ ឈ្មោះថា ធ្វើបុគ្គលឲ្យមានក្នុងខាងក្រៅ ។ តែកាលគិតថា នឹងសម្តែងដល់បុគ្គលដទៃ ឈ្មោះថា ធ្វើបុគ្គលឲ្យមានក្នុងខាងក្នុង ។ កាលគិតថា នឹងមិនសម្តែងដល់បុគ្គលនេះ ឈ្មោះថា ធ្វើបុគ្គលឲ្យមានក្នុងខាងក្រៅ ។ អធិប្បាយថា តថាគតមិនធ្វើយ៉ាងនេះ ហើយសម្តែងធម៌ ។ បទថា **កណ្តាប់ដៃអាចារ្យ (អាចរិយមុដ្ឋិ)** សេចក្តីថា ឈ្មោះថា កណ្តាប់ដៃអាចារ្យរមែងមាន សម្រាប់ពួកបុគ្គលខាងក្រៅ ។ ក្នុងវេលាកម្លោះ

លោកមិនពោលដល់នរណាក្នុងបច្ចិមកាល ពេលដេកលើគ្រែសម្រាប់ស្លាប់ ទើបពោលដល់អន្តេវាសិកអ្នកជាទីស្រឡាញ់ ជាទីពេញចិត្ត លោកសម្តែងថា ព្រះតថាគតមិនមានពាក្យអ្វី ដែលមានក្នុងកណ្តាប់ដៃរក្សាទុកយ៉ាងនេះថា តថាគតនឹងពោលពាក្យនេះ ក្នុងវេលាចាស់ ក្នុងវេលាចុងក្រោយ ដូច្នេះ ។

បទថា **តថាគតនឹងរក្សាភិក្ខុសង្ឃ (អហំ ភិក្ខុសង្ឃំ)** សេចក្តីថា តថាគតនឹងរក្សាភិក្ខុសង្ឃឬ ។ បទថា **មានតថាគតជាទីអាង (មមុទ្ទេសិកោ)** សេចក្តីថា ឬថា តថាគតឈ្មោះថា មមុទ្ទេសកៈ ព្រោះវិគ្រោះថា មានសេចក្តីអាងដោយអត្ថថា ដែលភិក្ខុសង្ឃគប្បីអាង អធិប្បាយថា បុគ្គលណាមួយ មាន (សេចក្តីត្រិះរិះ) ដូច្នេះថា សូមភិក្ខុសង្ឃចូរសង្ឃឹមយើង ចំពោះយើងប៉ុណ្ណោះ ទោះបីជារឿងណាមួយក៏ដោយ កុំកន្លងយើងឡើយ ។ បទថា **មិនមានសេចក្តីត្រិះរិះយ៉ាងនេះ (ន ឯវំ ហោតិ)** សេចក្តីថា តថាគតរមែងមិនមានយ៉ាងនេះ ព្រោះតណ្ហា និងមច្ឆរិយៈទាំងឡាយអស់ហើយត្រង់ពោធិបល្ល័ង្កនោះឯង ។ បទថា **ស កឹ គឺ សោ កឹ** ប្រែថា តថាគតនឹងប្រារព្ធ...មិនធ្វើ ។ បទថា **វ័យ ៨០ ឆ្នាំ (អសីតិកោ)** សេចក្តីថា វ័យ ៨០ ឆ្នាំ ។ ពាក្យនេះត្រាស់ដើម្បីទ្រង់សម្តែងដល់វ័យ ដែលកន្លងមកតាមលំដាប់ដល់បច្ឆិមវ័យ ។ បទថា **អបជោយរណបបូស្សី (វេឡមិស្សកេន)** សេចក្តីថា ព្រោះអបជោយ

វេណាបឫស្សីប្រកបដោយគ្រឿងចងត្រង់ទូក និងកង់ជាដើម ។ បទថា **នៅប្រព្រឹត្តទៅបាន (មញ្ញេ យាបេតិ)** លោកសំដែងថា ការឈានទៅដោយឥរិយាបថ ៤ រមែងមានដល់តថាគត ព្រោះចងដោយព្រះអរហត្តផល ដូចរទេះចាស់នៅប្រព្រឹត្តទៅបាន ព្រោះអបដោយវេណាបដោយឫស្សី ដូច្នេះ ។

[៣៤] ឥឡូវនេះ ពេលព្រះអង្គទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ពាក្យជាដើមថា **យស្មឹ អានន្ទ សមយេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **និមិត្តទាំងពួង (សព្វនិមិត្តា)** បានដល់ រូបនិមិត្តជាដើម ។ បទថា **វេទនាខ្លះ (ឯកច្ចានំ វេទនានំ)** បានដល់ លោកិយវេទនា ។ បទថា **តស្មាតិហានន្ទ** លោកសំដែងថា ព្រោះសេចក្តីសុខរមែងមានដោយផលសមាបត្តិវិហារនេះ ។ ដូច្នោះ សូម្បីអ្នកទាំងឡាយចូរនៅយ៉ាងនេះ ដើម្បីប្រយោជន៍ដល់កនៅជាសុខចុះ ។ បទថា **មានខ្លួនជាកោះ (អត្តទីបា)** សេចក្តីថា អ្នកទាំងឡាយចូរធ្វើខ្លួនឲ្យជាកោះ គឺ ជាទីពឹងចុះ ដូចបុគ្គលនៅក្នុងមហាសមុទ្រពឹងកោះអាស្រ័យនៅ ដូច្នោះ ។ បទថា **មានខ្លួនជាទីពឹង (អត្តសរណា)** សេចក្តីថា អ្នកទាំងឡាយចូរមានខ្លួនជាគតិ កុំមានអ្នកដទៃជាគតិឡើយ ។ សូម្បីក្នុងបទមានធម៌ជាកោះ មានធម៌ជាទីពឹង ក៏ន័យនេះឯង ។ លោកុត្តរធម៌ ៩ យ៉ាង គប្បីជ្រាបថា ធម៌ក្នុងបទនេះ ។ បទថា **តមតគ្គេ មេ តេ** កាត់

បទថា **តមអគ្គេ** , ត អក្សរ ក្នុងកណ្តាល លោកពោលដោយអំណាចការ តបទ ។ មានអធិប្បាយថា ភិក្ខុទាំងនេះឈ្មោះថា តមតគ្គា ព្រោះអត្ថថា ធម៌នោះជាកំពូល ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់កាន់យកទេសនាដោយ ធម៌ដ៏កំពូល គឺ ព្រះអរហត្តថា ម្នាលអានន្ទ ភិក្ខុទាំងឡាយនោះរបស់តថាគត កាត់ក្រសែនៃសេចក្តីងងឹតបានទាំងអស់យ៉ាងនេះហើយ នឹងជាបុគ្គលកំពូល គឺ ចំណែកខ្ពស់បំផុតមិនមានអ្វីប្រៀប គឺ នឹងជាបុគ្គលប្រសើរជាងពួកភិក្ខុ ទាំងនោះ ។ ភិក្ខុពួកណាមួយជាអ្នកប្រាថ្នាដល់ការសិក្សា និងភិក្ខុទាំងនោះ មានសតិប្បដ្ឋាន ៤ ជាអារម្មណ៍ នឹងជាបុគ្គលដ៏កំពូល ដូច្នេះ ។

ចប់អដ្ឋកថា គិលានសូត្រទី ៩

# អ ដ្ឋ ក ថា

# ភិក្ខុនីសូត្រ

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភិក្ខុនីសូត្រទី ១០*

[៣៧] *បទថា **ចូលទៅកាន់សម្នាក់ភិក្ខុនី (តេនុបសង្កមិ)** សេចក្តីថា ព្រះអានន្ទចូលទៅរក ដោយគិតថា យើងនឹងឲ្យពួកភិក្ខុនីអ្នកបំពេញកម្មដ្ឋាន មាននៅក្នុងសម្នាក់នោះ កើតសេចក្តីខ្វល់ខ្វាយ ទើបប្រាប់កម្មដ្ឋានដល់ភិក្ខុនីទាំងនោះ ។ បទថា **គុណវិសេសដ៏ក្រៃលែងយ៉ាងដទៃ ក្រៅពីគុណវិសេសក្នុងកាលមុន (ឧឡារំ បុព្វេនាបរំ វិសេសំ)** សេចក្តីថា រមែងដឹងគុណវិសេសដ៏ក្រៃលែងចាកគុណវិសេសក្នុងខាងដើម ។ ការកំណត់មហាភូតរូបក្នុងបទនោះ ជាគុណវិសេសក្នុងខាងដើម ការកំណត់ឧបាទាយរូប ឈ្មោះថា គុណ-វិសេសក្នុងខាងចុង ដូចជាការកំណត់សកលរូប ជាគុណវិសេសក្នុងខាងដើមក៏យ៉ាងនោះ ការកំណត់អរូប ឈ្មោះថា គុណវិសេសក្នុងខាងចុង ។ ការកំណត់រូប និងអរូប ជាគុណវិសេសក្នុងខាងដើម ។ ការកំណត់បច្ច័យ ឈ្មោះថា គុណវិសេសក្នុងខាងចុង ។ ការឃើញនាមរូបព្រមទាំងបច្ច័យ ជាគុណ-វិសេសក្នុងខាងដើម ។ ការលើកឡើងកាន់ត្រៃលក្ខណ៍ ឈ្មោះថា គុណវិសេស*

ខាងចុង អធិប្បាយថា រមែងដឹងគុណវិសេសដ៏ក្រៃលែង ខាងចុងចាកគុណ-វិសេសក្នុងខាងដើមយ៉ាងនេះ ។

[៤០] បទថា **មានកាយជាអារម្មណ៍ (កាយារម្មណោ)** សេចក្ដីថា អ្នករមែងពិចារណាឃើញកាយណា និងសេចក្ដីក្ដៅក្រហាយព្រោះកិលេស រមែងកើតឡើង ព្រោះធ្វើកាយនោះឯងឲ្យជាអារម្មណ៍ ។

[៤១] បទថា **ចិត្តរាយមាយទៅខាងក្រៅ (ពហិទ្ធា វា ចិត្តំ វិក្ខិបតិ)** សេចក្ដីថា ចិត្តុប្បាទរមែងផ្សាយទៅខាងក្រៅ គឺ ក្នុងអារម្មណ៍ច្រើនខ្ទះ ។ បទថា **គប្បីតាំងចិត្តទុក ក្នុងនិមិត្តដែលជាទីតាំងនៃសេចក្ដីជ្រះថ្លាណាមួយ (កិស្មិញ្ចិទេវ បសាទនីយេ និមិត្តេ ចិត្តំ បណិទហិតព្វំ)** សេចក្ដីថា កាលសេចក្ដីក្ដៅក្រហាយព្រោះកិលេស សេចក្ដីរួញរា និងសេចក្ដីរាយមាយទៅខាងក្រៅ កើតឡើងហើយ មិនគប្បីប្រព្រឹត្តទៅតាមសេចក្ដីត្រេកអររបស់កិលេស គឺ គប្បីតាំងចិត្តទុកក្នុងកម្មដ្ឋាន ក្នុងនិមិត្តដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា គឺ នាំសេចក្ដីជ្រះថ្លាណាមួយមកឲ្យ គឺ ក្នុងឋានៈណាមួយ ក្នុងបណ្ដាព្រះពុទ្ធជាម្ចាស់ជាដើម ។ បទថា **ចិត្តរមែងតម្កល់មាំ (ចិត្តំ សមាធិយតិ)** សេចក្ដីថា ចិត្តទទួលអារម្មណ៍ដោយល្អ រមែងតាំងមាំល្អ ។ បទថា **ប្រមូលមកនូវចិត្ត (បដិសំហរាមិ)** បានដល់ យើងនឹងប្រមូលនូវចិត្តពីឋានៈដែលជា

ទីតាំងនៃសេចក្ដីជ្រះថ្លា អធិប្បាយថា (យើង) នឹងធ្វើចិត្តនោះឲ្យឆ្ពោះត្រង់ដល់មូលកម្មដ្ឋាន ។ បទថា **ប្រមូលមកនូវចិត្ត (សោ បដិសំហរតិ ចេវ)** សេចក្ដីថា នាងបញ្ជូនចិតឆ្ពោះត្រង់ដល់មូលកម្មដ្ឋាន ។ បទថា **មិនត្រិះរិះ មិនពិចារណា (ន ច វិតក្កេតិ ន ច វិចារេតិ)** សេចក្ដីថា មិនត្រិះរិះដល់កិលេស មិនពិចារណាដល់កិលេស ។ បទថា **មិនមានវិតក្កៈ មិនមានវិចារៈ (អវិតក្កោម្ហិ អវិចារោ)** សេចក្ដីថា យើងមិនមានវិតក្កៈ មិនមានវិចារៈ ដោយវិតក្កៈ វិចារៈក្នុងកិលេស ។ បទថា **មានសតិខាងក្នុង ជាអ្នកមានសេចក្ដីសុខ (អជ្ឈត្តំ សតិមា សុខមស្មិ)** សេចក្ដីថា នាងរមែងដឹងច្បាស់ថា យើងមានសតិ និងមានសេចក្ដីសុខ ដូច្នេះ ដោយសតិដែលប្រព្រឹត្តទៅខាងក្នុងអារម្មណ៍ ។

បទថា **អានន្ទ ភាវនារមែងមានព្រោះតាំងចិត្តទុកយ៉ាងនោះឯង (ឯវំ ខោ អានន្ទ បណិធាយ ភាវនា ហោតិ)** សេចក្ដីថា អានន្ទ ភាវនាមានក៏ព្រោះការតាំងចិត្តទុកយ៉ាងនោះ ។ ក៏ភាវនារបស់ភិក្ខុនេះ អ្នកកាន់យកកម្មដ្ឋានដើម្បីសម្រេចព្រះអរហត្ត កាលសេចក្ដីក្ដៅហាយក្នុងកាយជាដើមកើតឡើងហើយ បញ្ឈប់កម្មដ្ឋាននោះទុក ញុំាងចិត្តឲ្យជ្រះថ្លា ដោយការរឭកក្នុងព្រះពុទ្ធគុណជាដើម ធ្វើឲ្យជាទីតាំងនៃការងារប្រព្រឹត្តទៅ ដូចការដើរទៅ

របស់បុគ្គលលីបាច់អំពៅធ្ងន់ ទៅកាន់រោងកៀបអំពៅ ក្នុងវេលានឿយហត់ខ្លះ ដាក់ចុះលើផែនដី ហើយទំពាស៊ីកំណាត់អំពៅ ក៏លីទៅទៀត ដូច្នោះ ។ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា ភាវនាមាន ព្រោះការតាំងចិត្តទុក ។ គប្បីជ្រាបការសោយសុខក្នុងផលសមាបត្តិរបស់ភិក្ខុនេះ ដែលបំពេញកម្ម-ដ្ឋានដល់ទីបំផុតហើយ បានសម្រេចព្រះអរហត្ត ដូចបុគ្គលនាំអំពៅដ៏ធ្ងន់នោះទៅកាន់រោងកៀបអំពៅ កៀបអំពៅស្រេចហើយ ផឹករស ដូច្នោះ ។

[៤២] បទថា **ខាងក្រៅ** (ពហិទ្ធា) សេចក្តីថា លះបង់មូលកម្មដ្ឋានទៅក្នុងអារម្មណ៍ដទៃជាខាងក្រៅ ។ បទថា **ព្រោះមិនបានតាំងទុក** (អប្ប-ណិធាយ) ប្រែថា មិនបានតាំងចិត្តទុក ។ ក្នុងបទថា **ក្នុងលំដាប់នោះ អ្នករមែងដឹងច្បាស់ថា ចិត្តរបស់យើងមិនបានរាយមាយទៅខាងមុខ ខាងក្រោយរួចផុតហើយ មិនបានតាំងនៅ** (អថ បច្ឆា បុរេ អសង្ខិត្តំ វិមុត្តំ អប្បណិ-ហិតន្តិ បជានាតិ) នេះ គប្បីជ្រាបអត្ថន័យដោយអំណាចកម្មដ្ឋានខ្លះ ដោយអំណាចសរីរៈខ្លះ ដោយអំណាចទេសនាខ្លះ ។

ក្នុងបទទាំងនោះ គប្បីជ្រាបក្នុងកម្មដ្ឋានមុន ការជឿមាំដល់កម្មដ្ឋានឈ្មោះថា ខាងមុខ , ព្រះអរហត្ត ឈ្មោះថា ខាងក្រោយ ។ ក្នុងធម៌ទាំងនោះ ភិក្ខុរូបណាកាន់យកមូលកម្មដ្ឋាន មិនបណ្តោយឱកាសឲ្យសេចក្តីក្តៅ

ក្រហាយក្នុងកិលេស សេចក្ដីរួញរា ឬសេចក្ដីរាយមាយទៅខាងក្រៅ កើតឡើងបាន កាលផ្ដើមវិបស្សនា មានចិត្តមុតមាំ មិនជាប់ជំពាក់ រមែងសម្រេចព្រះអរហត្ត ដូចទឹមគោដែលហ្វឹកហាត់ល្អឲ្យស្ទុះទៅ និងដូចដាក់ស្នៀតបួនជ្រុងដែលចាំងដោយល្អ ក្នុងប្រហោងបួនជ្រុង ។ ភិក្ខុរូបនោះ ឈ្មោះថា រមែងដឹងច្បាស់ថា ចិត្តមិនរាយមាយទៅខាងក្រោយ និងខាងមុខ រួចផុតហើយ មិនបានតាំងនៅ ដោយអំណាចសេចក្ដីជឿមាំក្នុងកម្មដ្ឋាន ពោលគឺ ខាងមុខ និងព្រះអរហត្ត ពោលគឺ ខាងក្រោយ ។

ចំណែកក្នុងសរីរៈ ខាងចុងម្រាមជើង ឈ្មោះថា ខាងមុខ លលាដ៍-ក្បាល ឈ្មោះថា ខាងក្រោយ ។ ក្នុងពីរយ៉ាងនោះ ភិក្ខុរូបណា តាំងចិត្តក្នុងឆ្អឹងចុងម្រាមជើង កាលកំណត់ឆ្អឹង ដោយអំណាចការកំណត់ពណ៌ សណ្ឋាន ទិស ឱកាស ដូចយកវែកបាយផាត់កករបាយចេញ ហាមការកើតសេចក្ដីក្ដៅក្រហាយព្រោះកិលេស ក្នុងចន្លោះៗ ជាដើម បំពេញការនោរហូតដល់លលាដ៍ក្បាល ភិក្ខុរូបនោះ ឈ្មោះថា រមែងដឹងច្បាស់ថា ចិត្តរបស់យើងមិនរាយមាយទៅខាងក្រោយ និងខាងមុខ រួចផុតហើយ មិនបានតាំងនៅដោយអំណាចនៃចុងម្រាមជើង ពោលគឺ ខាងមុខ និងលលាដ៍ក្បាល ពោលគឺ ខាងក្រោយ ។

សូម្បីក្នុងទេសនា សក់ទាំងឡាយ ឈ្មោះថា ខាងមុខ ដោយការសម្តែងអាការ ៣២ មត្ថលុង្គំ (ខួរក្បាល) ឈ្មោះថា ខាងក្រោយ ។ ក្នុងពីរយ៉ាងនោះ ភិក្ខុរូបណា តាំងចិត្តក្នុងសក់ កំណត់យកសក់ ដោយអំណាចពណ៌ សណ្ឋាន ទិស ឱកាស ហាមការកើតនៃសេចក្តីក្តៅក្រហាយក្នុងកិលេសជាដើម ក្នុងចន្លោះបំពេញភាវនា រហូតដល់ខួរក្បាល ។ ភិក្ខុរូបនោះ ឈ្មោះថា រមែងដឹងច្បាស់ថា ចិត្តរបស់យើងមិនរាយមាយទៅខាងក្រោយនិងខាងមុខ រួចផុតហើយ មិនបានតាំងនៅ ដោយអំណាចសក់ ពោលគឺខាងមុខ និងខួរក្បាល ពោលគឺ ខាងក្រោយ ។

[៤៦] បទថា **អានន្ទ ភាវនារមែងមាន ព្រោះមិនបានតាំងចិត្តទុកយ៉ាងនេះឯង (ឯវំ ខោ អានន្ទ អប្បណិធាយ ភាវនា ហោតិ)** សេចក្តីថា ម្នាលអានន្ទ ភាវនារមែងមាន ព្រោះមិនបានតាំងចិត្តទុកយ៉ាងនេះ ក៏កម្មដ្ឋានភាវនារបស់ភិក្ខុនេះ រមែងប្រព្រឹត្តទៅ ព្រោះហាមការកើតឡើងនៃសេចក្តីក្តៅក្រហាយផ្លូវកាយជាដើម នៃការផ្តើមភាវនា ដើម្បីសម្រេចព្រះអរហត្តដូចបុគ្គលបានជុំស្កអំពៅដ៏ច្រើន កាលនាំទៅកាន់ផ្ទះរបស់ខ្លួន មិនឈប់ក្នុងរវាងផ្លូវ ទំពារជុំស្កអំពៅដែលដាក់ក្នុងថ្នក់ រមែងដើរចូលទៅផ្ទះរបស់ខ្លួនដូច្នោះ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា ភាវនារមែងមាន ព្រោះមិនបាន

តាំងចិត្តទុក ។ គប្បីជ្រាបការសោយសេចក្តីសុខ ក្នុងផលសមាបត្តិ របស់ភិក្ខុនេះ ដែលបំពេញកម្មដ្ឋានដល់ទីបំផុតហើយ សម្រេចព្រះអរហត្ត ដូចជាបុគ្គលអ្នកនាំស្ករអំពៅដ៏ច្រើនទៅកាន់ផ្ទះរបស់ខ្លួន ហើយបរិភោគព្រមដោយពួកញាតិ ដូច្នោះ ។ ក្នុងព្រះសូត្រនេះ ត្រាស់បុព្វភាគវិបស្សនា ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងនោះឯង ។

ចប់អដ្ឋកថា ភិក្ខុនីសូត្រទី ១០

## ចប់អម្ពបាលិវគ្គទី ១

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

| | |
|---|---|
| ១ អដ្ឋកថា អម្ពបាលិសូត្រ | ២ អដ្ឋកថា សតិសូត្រ |
| ៣ អដ្ឋកថា ភិក្ខុសូត្រ | ៤ អដ្ឋកថា កោសលសូត្រ |
| ៥ អដ្ឋកថា សកុណគ្ឃិសូត្រ | ៦ អដ្ឋកថា មក្កដសូត្រ |
| ៧ អដ្ឋកថា សូទសូត្រ | ៨ អដ្ឋកថា គិលានសូត្រ |
| ៩ អដ្ឋកថា ភិក្ខុនីសូត្រ | |

# នាឡន្ទវគ្គទី ២

## អ ដ្ឋ ក ថា

## នាឡន្ទសូត្រទី ២

*គប្បីជ្រាបអធិប្បាយក្នុង នាលន្ទសូត្រទី ២ នៃ ទុតិយវគ្គ ។*

[៤៩] *ពាក្យថា* ***ក្នុងនាលន្ទា*** *(នាឡន្ទាយំ) បានដល់ ក្នុងនគរដែលមានឈ្មោះយ៉ាងនេះថា* ***នាលន្ទា*** *។ ទ្រង់ធ្វើនគរនោះឲ្យជាគោចរគាម ។ ពាក្យថា* ***បាវារិកអម្ពវ័ន*** *(បាវារិកម្ពវនេ) បានដល់ ឧទ្យានស្វាយរបស់សេដ្ឋីឈ្មោះថា ទុស្សបាវារិកៈ ។ ន័យថា ព្រៃស្វាយនោះ ជាឧទ្យានរបស់សេដ្ឋីនោះ ។ បាវារិកសេដ្ឋីនោះ ស្ដាប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគជាម្ចាស់ ជ្រះថ្លាក្នុងព្រះមានព្រះភាគជាម្ចាស់ បានសាងវិហារថ្វាយព្រះមាន-ព្រះភាគជាម្ចាស់ ព្រមដោយកុដិ ទីពួនសម្ងំ និងមណ្ឌបជាដើមក្នុងឧទ្យាននោះ វិហារនោះដល់ការរាប់ថា បាវារិកម្ពវ័ន ដូចជីវកម្ពវ័ន អធិប្បាយថា ព្រះមានព្រះភាគជាម្ចាស់ ប្រថាប់នៅក្នុងបាវារិកម្ពវ័ននោះ ។*

*បទថា* ***ជ្រះថ្លាហើយយ៉ាងនេះ*** *(ឯវំ បសន្នោ) សេចក្ដីថា សទ្ធាដល់*

ព្រមហើយយ៉ាងនេះ អធិប្បាយថា យើងជឿយ៉ាងនេះ ។ បទថា **ដោយក្រៃលែងជាង១ (ភិយ្យោ ភិយ្យតរោ)** សេចក្តីថា អ្នកមានឈ្មោះបោះសំឡេង អធិប្បាយថា ជាអ្នកមានកេរ្តិ៍ឈ្មោះ ឬថា ជាអ្នកមានប្រាជ្ញាដ៏ក្រៃលែង ។ បទថា **ក្នុងការត្រាស់ដឹងព្រម (សម្ពោធិយំ)** សេចក្តីថា ក្នុងសព្វញ្ញុតញ្ញាណ ឬក្នុងអរហត្តមគ្គញ្ញាណ ។ ព្រោះថា ព្រះពុទ្ធគុណទាំងអស់ លោកកាន់យកហើយដោយអរហត្តមគ្គតែម្យ៉ាង ។ សូម្បីព្រះអគ្គសាវកទាំងពីរ ក៏បានចំពោះនូវសាវកបារមីញាណដោយអរហត្តមគ្គប៉ុណ្ណោះ ។ ព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយ រមែងបានដោយចំពោះនូវព្រះបច្ចេកពោធិញ្ញាណ ។ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងបានចំពោះព្រះសព្វញ្ញុតញ្ញាណ និងព្រះពុទ្ធគុណទាំងអស់ អរហត្តមគ្គញ្ញាណសូម្បីទាំងអស់ រមែងសម្រេចដល់លោកទាំងនោះ ដោយអរហត្តមគ្គនោះឯង ព្រោះដូច្នោះ អរហត្តមគ្គញ្ញាណ ទើបឈ្មោះថា គុណជាគ្រឿងត្រាស់ដឹងព្រម ។ មិនមានបុគ្គលដែលក្រៃលែងជាងព្រះមានព្រះភាគជាម្ចាស់ដោយញាណជាគ្រឿងត្រាស់ដឹងព្រមនោះ ។ ព្រោះហេតុនោះ ព្រះសារីបុត្តទើបពោលថា សមណៈ ឬព្រាហ្មណ៍ដទៃ ដែលដឹងក្រៃលែងជាងព្រះមានព្រះភាគ ក្នុងផ្លូវបញ្ញាជាគ្រឿងត្រាស់ដឹង មិនមាន ។

បទថា **ខ្ពង់ខ្ពស់ (ឧឡារា)** គឺ ប្រសើរ ។ ក៏ឧឡារៈ សព្ទនេះ រមែង

មកក្នុងអត្ថថា **ឆ្ងាញ់** ក្នុងបទជាដើមថា រមែងទំពារស៊ីរបស់ដែលគួរទំពារដ៏ឆ្ងាញ់ ។ រមែងមកក្នុងអត្ថថា **ប្រសើរ** ក្នុងបទជាដើមថា បាទព្វថា វច្ឆាយនព្រាហ្មណ៍ដ៏ចម្រើន រមែងសរសើរព្រះសមណគោតម ដោយការសរសើរដ៏ប្រសើរ ។ មកក្នុងអត្ថថា **ធំទូលាយ** ក្នុងបទជាដើមថា និងក្ដីដ៏ធំទូលាយរកប្រមាណមិនបាន ។ **ឧឡារ** សព្ទនេះ មកហើយក្នុងអត្ថថា **ប្រសើរ** ក្នុងទីនេះ ។ ព្រោះហេតុនោះ លោកទើបពោលថា បទថា **ឧឡារ** បានដល់ប្រសើរ ។ បទថា **អង់អាច (អាសភិ)** សេចក្ដីថា មិនញាប់ញ័រ គឺ មិនតក់ស្លុត ដូចសំឡេងគោឧសភៈ ។ បទថា **កាន់យកដោយចំណែកមួយ (ឯកំសោ គហិតោ)** សេចក្ដីថា មិនពោលតាមដែលបានឮមកខ្លះ តៗ គ្នានៃអាចារ្យខ្លះ តាមដែលបានឮមកយ៉ាងនេះយ៉ាងនោះខ្លះ ដោយការអាងតម្រាខ្លះ ដោយការត្រិះរិះតាមអាការខ្លះ ដោយពេញចិត្តត្រូវជាមួយលទ្ធិខ្លួនខ្លះ ព្រោះហេតុប៉ាន់ស្មានខ្លះ ព្រោះហេតុនៃការទាយខ្លះ កាន់យកដោយចំណែកមួយ ដូចចាក់ចុះដោយញាណដោយប្រចក្សុ ។ អធិប្បាយថា លោកពោលដល់ការពោលដោយការព្រមព្រៀង ។ បទថា **ថ្លែងដូចសីហៈ (សីហនាទោ)** សេចក្ដីថា បន្លឺដ៏ប្រសើរ អធិប្បាយថា បន្លឺយ៉ាងខ្ពស់បំផុត ដូចជាសីហៈមិនលេង មិនផ្ដេសផ្ដាស់ បន្លឺហើយ ។

[៥០] បទថា **សារីបុត្ត ប្រយោជន៍អ្វីដល់អ្នក (កិន្នុ តេ សារីបុត្ត)** សេចក្តីថា ប្រារព្ធធម្មទេសនានេះ ដើម្បីអ្វី? ដើម្បីឲ្យការតាមប្រកប ព្រោះថា បុគ្គលពួកខ្លះបន្លឺសីហនាទហើយ មិនអាចនឹងឲ្យការតាមប្រកបក្នុងការបន្លឺរបស់ខ្លួនបាន មិនអត់ធន់ដល់ការសើកសៀត ដូចជាស្វាជាប់ទៅក្នុងជ័រស្អិត ។ ភ្លើងធ្យូង រមែងដុតលោហៈដែលមិនបរិសុទ្ធជាធម្មតា យ៉ាងណា បុគ្គលក៏ដូចជាធ្យូងភ្លើងឆេះហើយ ដូច្នោះ ។ បុគ្គលខ្លះត្រូវគេឲ្យតាមប្រកបក្នុងការបន្លឺដូចសីហៈ រមែងអាចនឹងឲ្យបាន រមែងទាំងអត់ធន់ដល់ការសើកសៀត បុគ្គលនេះឈ្មោះថា រមែងស្អាតក្រៃលែង ដូចប្រាក់ដែលមិនមានស្នឹមតាមធម្មតា ។ ព្រះថេរៈក៏ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបព្រះថេរៈនោះថា បុគ្គលនេះជាអ្នកអត់ធន់ដល់អនុយោគ ដូច្នេះហើយ ទ្រង់ប្រារព្ធទេសនានេះ ដើម្បីឲ្យតាមប្រកបក្នុងការបន្លឺសីហនាទ ។

បណ្តាបទទាំងនោះ បទថា **ទាំងនោះ គ្រប់ព្រះអង្គ (សព្វេ តេ)** សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ទាំងពួងនោះ ដែលអ្នក (កំណត់ដឹងហើយ) ។ បទថា **មានសីលយ៉ាងនេះ (ឯវំសីលា)** សេចក្តីថា មានសីលយ៉ាងនេះ ដោយមគ្គសីល ផលសីល លោកិយសីល និងលោកុត្តរសីល ។ ធម៌ដែលជាចំណែកនៃសមាធិ លោកបំណងយកក្នុងបទនេះថា **អ្នកមានធម៌**

យ៉ាងនេះ (ឯវំធម្មា) អធិប្បាយថា អ្នកមានសមាធិយ៉ាងនេះ ដោយមគ្គ-សមាធិ ផលសមាធិ ដែលជាលោកិយៈ និងលោកុត្តរៈ ។

បទថា **អ្នកមានបញ្ញាយ៉ាងនេះ (ឯវំបញ្ញា)** សេចក្តីថា និងអ្នកមានបញ្ញាយ៉ាងនេះ ដោយអំណាចមគ្គបញ្ញាជាដើម ។ ក៏ក្នុងបទនេះថា **អ្នកមានធម៌ជាគ្រឿងនៅយ៉ាងនេះ (ឯវំវិហារិនោ)** ដូច្នេះ បើមានពាក្យសួរថា ធម៌ជាគ្រឿងនៅឈ្មោះថា លោកកាន់យកហើយ ព្រោះធម៌ដែលជាចំណែកនៃសមាធិលោកកាន់យកហើយក្នុងខាងក្រោយ ព្រោះហេតុអ្វី ទើបកាន់យកធម៌ជាគ្រឿងនៅដែលកាន់យកហើយ ។ ឆ្លើយថា ពាក្យនេះព្រះថេរៈកាន់យកហើយ ។ ក៏ពាក្យនេះ លោកពោលទុកដើម្បីសម្តែងនិរោធសមាបត្តិ ។ ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា ព្រះមានព្រះភាគជាម្ចាស់ទាំងនោះ ទ្រង់ជាអ្នកមានប្រក្រតីនៅដោយនិរោធសមាបត្តិយ៉ាងនេះ ។

ក្នុងបទថា **អ្នកមានវិមុត្តិយ៉ាងនេះ (ឯវំវិមុត្តា)** បានដល់ វិមុត្តិ ៥ គឺ **វិក្ខម្ភនវិមុត្តិ តទង្គវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណ-វិមុត្តិ** ។

ក្នុងវិមុត្តិទាំងនោះ សមាបត្តិ ៨ ដល់ការរាប់ថា **វិក្ខម្ភនវិមុត្តិ** (រួចផុតបានដោយការគ្របសង្កត់) ព្រោះរួចផុតចាកនិវរណៈជាដើម ដែលខ្ទួន

ឯងគ្រប់សង្កត់បានហើយ ។

**អនុបស្សនា ៧** មានការតាមឃើញថា មិនទៀងជាដើម ដល់ការរាប់ថា **តទង្គវិមុត្តិ** (រួចផុតបានដោយអង្គនោះ) ព្រោះរួចផុតចាកសេចក្ដីសម្គាល់ថា ទៀងជាដើម ដែលខ្លួនឯងលះបង់បានដោយអំណាចជាសត្រូវដល់និវរណៈជាដើមនោះ ។

**អរិយមគ្គ ៤** ដល់ការរាប់ថា **សមុច្ឆេទវិមុត្តិ** (រួចផុតដាច់ខាត) ព្រោះរួចផុតចាកកិលេសទាំងឡាយ ដែលខ្លួនដកចេញហើយ ។

**សាមញ្ញផល ៤** រមែងដល់ការរាប់ថា **បដិបស្សទ្ធិវិមុត្តិ** (រួចផុតបានដោយការស្ងប់រម្ងាប់) ព្រោះកើតឡើងក្នុងទីបំផុតនៃការស្ងប់រម្ងាប់កិលេសទាំងឡាយ ដោយអានុភាពមគ្គ ។

**និព្វាន** ដល់ការរាប់ថា **និស្សរណវិមុត្តិ** (រួចផុតបានដោយការរលាស់ចេញ) ព្រោះរលាស់ គឺ ព្រោះប្រាសចាក បានដល់ តាំងនៅក្នុងទីឆ្ងាយពីកិលេសទាំងឡាយ ។ គប្បីឃើញអត្ថក្នុងបទនេះថា ឈ្មោះថា រួចផុតហើយយ៉ាងនេះ ដោយអំណាចវិមុត្តិ ៥ ទាំងនេះ ដោយប្រការដូច្នេះ ។

[៥១] បទថា **សារីបុត្ត** ព្រះអរហន្តសម្មាសម្ពុទ្ធពួកណា ដែលនឹងមានក្នុងអនាគតកាល និងព្រះមានព្រះភាគទាំងនោះគ្រប់ព្រះអង្គ ដែលអ្នក

កំណត់...ដូច្នោះឬ (កឹ បន តេ សារិបុត្ត យេ តេ ភវិស្សន្តិ) សេចក្តីថា ព្រះមានព្រះភាគកាលត្រាស់សួរថា ព្រះពុទ្ធទាំងឡាយកន្លងទៅហើយ គឺរលត់ទៅហើយ មិនមានសល់ បានដល់ ភាពជាអ្នករកបញ្ញត្តិមិនបាន រលត់ទៅហើយ ដូចអណ្តាតប្រទីប ឈ្មោះថា រលត់ហើយយ៉ាងនេះ អ្នកកាន់យកភាពជាអ្នកស្វែងរកបញ្ញត្តិមិនបាន នឹងដឹងបានដូចម្តេច ក៏ព្រះពុទ្ធគុណដែលមិនទាន់មកដល់ទាំងឡាយ អ្នកកំណត់ដឹងដោយចិត្តរបស់ខ្លួនឬ ។

[៥២] ហើយទើប ត្រាស់យ៉ាងនេះថា សារីបុត្ត ព្រះអរហន្តសម្មាសម្ពុទ្ធក្នុងឥឡូវនេះ គឺ តថាគត ដែលអ្នកកំណត់... ដូច្នោះឬ (កឹ បន ត្យាហំ សារិបុត្ត ឯតរហិ) ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សួរថា ព្រះពុទ្ធជាម្ចាស់សូម្បីដែលមិនទាន់មកហើយ នៅមិនមានព្រះជាតិ មិនទាន់កើត មិនទាន់ឧប្បត្តិ អ្នកនឹងដឹងព្រះពុទ្ធជាម្ចាស់ទាំងនោះ បានដូចម្តេច ។ ក៏ការដែលនឹងដឹងព្រះពុទ្ធជាម្ចាស់ទាំងនោះ ដូចជាការក្រឡេកមើលស្នាមជើងក្នុងអាកាសដែលមិនប្រាកដស្នាមជើង ឥឡូវនេះ អ្នកនៅវិហារជាមួយតថាគត ត្រាច់ទៅដើម្បីភិក្ខាជាមួយគ្នា វេលាសម្តែងធម៌ ក៏អង្គុយខាងស្តាំ ក៏គុណទាំងឡាយរបស់តថាគត អ្នកកំណត់ដឹងដោយចិត្តរបស់ខ្លួនឬ ទើបត្រាស់យ៉ាងនេះ ។ ព្រះថេរៈបដិសេធបញ្ហាដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់សួរហើយៗ ពោល

ថា យ៉ាងនោះក៏មិនមែន ព្រះអង្គ ។

**សួរថា** ក៏វត្ថុដែលព្រះថេរៈដឹងហើយក៏មាន មិនដឹងក៏មាន ។ លោករមែងជំទាស់ក្នុងទីដែលខ្លួនដឹងហើយ ឬក្នុងទីដែលខ្លួនមិនដឹងហើយ ។

**ឆ្លើយថា** រមែងជំទាស់ក្នុងទីដែលខ្លួនមិនដឹងហើយប៉ុណ្ណោះ បានឮថា ពេលផ្តើមពាក្យសួរហើយ ព្រះថេរៈបានដឹងហើយយ៉ាងនេះថា នេះមិនមែនពាក្យសួរ ពាក្យសួរត្រូវសួរក្នុងសាវកបារមីញាណ ទើបមិនធ្វើការជំទាស់ដោយសាវកបារមីញាណរបស់ខ្លួន រមែងជំទាស់ក្នុងព្រះសព្វញ្ញុត-ញ្ញាណក្នុងឋានៈដែលខ្លួនមិនយល់ ព្រោះហេតុនោះ ព្រះថេរៈទើបសម្តែងពាក្យសួម្បីនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនមានសព្វញ្ញុតញ្ញាណដែលអាចនឹងដឹងហេតុនៃសីល សមាធិ បញ្ញា និងវិមុត្តិ របស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ដែលជាអតីត អនាគត និងបច្ចុប្បន្នបាន ។

[៥៣] បទថា នេះ (ឯត្ថ) បានដល់ ព្រះពុទ្ធទាំងឡាយ មានព្រះពុទ្ធក្នុងអតីតជាដើមទាំងនេះ ។

បទថា កាលបើដូច្នោះ ព្រោះហេតុអ្វី (អថ កិញ្ចរហិ) សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា ក៏កាលមិនមានសេចក្តីដឹងយ៉ាងនោះ ហេតុអ្វី ទើបពោលយ៉ាងនេះ ។

បទថា **ស្ទង់តាមធម៌ (ធម្មន្វយោ)** បានដល់ ការកាន់យកន័យ គឺ ញាណដោយអនុមាណ ដែលព្រះថេរៈតាមទៅប្រកបនៃញាណ ដែលកើតឡើងហើយដោយប្រច័ក្សដល់ធម៌ ដឹងហើយ និងព្រះថេរៈតាំងនៅក្នុងសាវកបារមីញាណក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ រមែងដឹងដោយហេតុនេះ ។

[៥៤] ព្រោះថា ការកាន់យកដោយន័យរបស់ព្រះថេរៈ មិនមានប្រមាណមិនមានទីបំផុត សព្វញ្ញុតញ្ញាណរមែងមិនមានប្រមាណ ឬទីបំផុតដោយជុំវិញយ៉ាងណា ការកាន់យកដោយន័យរបស់ព្រះធម្មសេនាបតី ក៏មិនមានប្រមាណឬទីបំផុតដោយជុំវិញ ដូច្នោះ ព្រោះហេតុនោះ ព្រះថេរៈនោះរមែងដឹងថាព្រះសាស្តានោះទ្រង់ជាយ៉ាងនេះ ដោយហេតុនេះៗ ទ្រង់មិនមានបុគ្គលដទៃក្រៃលែងជាងដោយហេតុនេះៗ ព្រោះថា ការកាន់យកដោយន័យរបស់ព្រះថេរៈគឺ គតិនៃព្រះសព្វញ្ញុតញ្ញាណនោះឯង ឥឡូវនេះ កាលព្រះថេរៈនឹងសម្តែងឧបមា ដើម្បីធ្វើឲ្យការកាន់យកដោយន័យនោះប្រាកដ ទើបពោលពាក្យជាដើមថា **សូម្បីយ៉ាងណា ខ្ញុំព្រះអង្គ (សេយ្យថាបិ ភន្តេ)** ។

ព្រោះក្នុងមជ្ឈិមប្រទេសនោះ បន្ទាយ ឬកំពែងជាដើមរបស់ក្រុងនឹងរឹងមាំ ឬមិនរឹងមាំក៏ដោយ មិនត្រូវត្រិះរិះអ្វីទាំងអស់ រឿងចោរមិនត្រូវសង្ស័យ ព្រោះដូច្នោះ ព្រះថេរៈមិនកាន់យករឿងនោះជាសំខាន់ ទើបពោល

ថា ក្រុងជាយដែនជាដើម ។ បទថា **មានជើងកំពែងរឹងមាំ (ទឡ្ហុទ្ទាលំ)** សេចក្តីថា មានជើងកំពែងរឹងមាំ ។ បទថា **មានកំពែង និងសសរខឿនដ៏មាំ (ទឡ្ហ-បាការតោរណំ)** សេចក្តីថា មានកំពែងរឹងមាំ និងមានទ្វារក្រាស់រឹងមាំ ។ សួរថា ព្រោះហេតុអ្វី ព្រះថេរៈទើបពោលថា មានទ្វារតែមួយ ។ ឆ្លើយថា ព្រោះថា ក្នុងក្រុងដែលមានទ្វារច្រើន នឹងត្រូវមានអ្នករក្សាទ្វារដែលឆ្លាតច្រើននាក់ ចំណែកក្នុងក្រុងដែលមានទ្វារតែមួយ ប្រើមនុស្សតែម្នាក់ក៏ល្មម មិនមានបុគ្គលដទៃស្មើដោយបញ្ញារបស់ព្រះថេរៈ ព្រោះដូច្នោះ ព្រះថេរៈទើបពោលថា មានទ្វារតែមួយ ដើម្បីសម្តែងអ្នករក្សាទ្វារតែម្នាក់ប៉ុណ្ណោះ ដើម្បីនឹងប្រៀបធៀបដល់ខ្លួនជាអ្នកឈ្លាសវៃ ។

បទថា **ជាអ្នកឈ្លាស (បណ្ឌិតោ)** គឺ ប្រកបដោយភាពជាអ្នកឆ្លាត ។ បទថា **អ្នកអាច (ព្យត្តោ)** គឺ ប្រកបដោយភាពជាអ្នកមានសមត្ថភាព បានដល់ ជាអ្នកមានសេចក្តីជំនាញ ។ បទថា **មានបញ្ញា (មេធាវី)** គឺ ប្រកបដោយមេធា ពោលគឺ បញ្ញា ពិចារណាការកើតឡើងនៃស្ថានការណ៍ ។ បទថា **ផ្លូវជុំវិញព្រះនគរ (អនុបរិយាយបថំ)** បានដល់ ផ្លូវជុំវិញកំពែងឈ្មោះថា ផ្លូវជុំវិញនគរ ។

បទថា **ទី.តកំពែង (បាការសន្ធី)** បានដល់ ទីដែលឥដ្ឋពីរជុំភ្ជាប់គ្នា ។

បទថា ចន្លោះកំពែង (បាការវិវរំ) បានដល់ ទីធ្វើជាចន្លោះកំពែង ។

បទថា គ្រឿងសៅហ្មងនៃចិត្ត (ចេតសោ ឧបក្កិលេសេ) បានដល់ និវរណៈ ៥ ធ្វើចិត្តឲ្យសៅហ្មង គឺ ធ្វើសេចក្តីសៅហ្មង បានដល់ ឲ្យក្តៅក្រហាយ បៀតបៀនហើយ ព្រោះដូច្នោះ ព្រះថេរៈទើបពោលថា គ្រឿងសៅហ្មងនៃចិត្ត ។ បទថា ធ្វើបញ្ញាឲ្យមានកម្លាំងថយ (បញ្ញាយ ទុព្វលីករណេ) សេចក្តីថា និវរណៈទាំងឡាយ ពេលកើតឡើង រមែងមិនឲ្យបញ្ញាកើតឡើង ដែលបញ្ញាមិនទាន់កើតឡើង ព្រោះដូច្នោះ ព្រះថេរៈទើបហៅថា ធ្វើបញ្ញាឲ្យថយកម្លាំង ។ បទថា អ្នកមានចិត្តតម្កល់ខ្ជាប់ (សុប្បតិដ្ឋិតចិត្តា) សេចក្តីថា ជាអ្នកមានចិត្តតាំងមាំហើយក្នុងសតិប្បដ្ឋាន ៤ ។ បទថា ក្នុងពោជ្ឈង្គៈ ៧ តាមសេចក្តីពិត (សត្ត ពោជ្ឈង្គេ យថាភូតំ) បានដល់ ចម្រើនពោជ្ឈង្គៈ ៧ ហើយតាមការៈរបស់ខ្លួន ។ ដោយបទថា អនុត្តរសម្មាសម្ពោធិ (អនុត្តរ សម្មាសម្ពោធឹ) ព្រះថេរៈសម្តែងថា (ព្រះពុទ្ធទាំងឡាយ) ចាក់ធ្លុះភាពជាព្រះអរហន្ត និងសព្វញ្ញុតញ្ញាណ ។

ម្យ៉ាងទៀត ក្នុងបទថា អ្នកមានចិត្តតម្កល់ខ្ជាប់ក្នុងសតិប្បដ្ឋាន ៤ នេះ បទថា សតិប្បដ្ឋាន (សតិប្បដ្ឋានា) នេះ គឺ វិបស្សនាពោជ្ឈង្គ គឺ មគ្គ ។ ព្រះអនុត្តរសម្មាសម្ពោធិ គឺ ព្រះអរហត្ត ម្យ៉ាងទៀត ពាក្យថា សតិប្បដ្ឋាន

គឺ វិបស្សនាពោជ្ឈង្គៈ គឺ មគ្គដែលលាយដោយសមថៈ និងវិបស្សនា ភាពជាព្រះអរហត្ត គឺ សម្មាសម្ពោធិញ្ញាណនោះឯង ។ ចំណែកព្រះទីឃភាណកមហាសិវត្ថេរ ពោលហើយថា កាលកាន់យកវិបស្សនាក្នុងសតិប្បដ្ឋានហើយ កាន់យកពោជ្ឈង្គៈថា ជាមគ្គ និងជាសព្វញ្ញុតញ្ញាណ ក៏នឹងគប្បីជាបញ្ញាដែលស្អាត តែថា កុំកាន់យកយ៉ាងនោះ ។ ព្រះថេរៈកាលនឹងសម្តែងការមិនមានសេចក្តីផ្សេងគ្នា ដូចមាស និងប្រាក់ បែកហើយត្រង់កណ្តាលក្នុងការលះនិវរណៈ ក្នុងការចម្រើនសតិប្បដ្ឋាន និងក្នុងការត្រាស់ដឹងឯងរបស់ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ទាំងឡាយ ដោយប្រការដូច្នេះ ។

ឈប់ត្រឹមនេះសិន គួរប្រៀបធៀបសេចក្តីឧបមា ដូច្នេះ ក៏ព្រះសារីបុត្ត សម្តែងដល់ក្រុងជាយដែន កំពែង ផ្លូវជុំវិញព្រះនគរ អ្នករក្សាទ្វារដែលឆ្លាត ពួកសត្វដ៏ច្រើនកុះករ ចេញចូលក្រុង ។ សម្តែងសត្វទាំងនោះប្រាកដដល់នាយទ្វារ ។ ក្នុងពាក្យនោះបើមានពាក្យសួរថា ដូចអ្វី? ។ ឆ្លើយថា ព្រោះថា ព្រះនិព្វានដូចនគរ សីលដូចកំពែង សេចក្តីខ្មាស់ដូចផ្លូវជុំវិញព្រះនគរ អរិយមគ្គដូចទ្វារ ព្រះធម្មសេនាបតីដូចនាយទ្វារដែលឆ្លាត ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទាំងអតីត អនាគត និងបច្ចុប្បន្ន ដូចពួកសត្វចំនួនច្រើនចេញចូលព្រះនគរ ប្រការដែលព្រះពុទ្ធទាំងឡាយ ទាំងអតីត អនាគត និង

បច្ចុប្បន្ន ប្រាកដដោយសីលស្មើគ្នាជាដើម ដល់ព្រះសារីបុត្ត ដូចប្រការដែលសត្វទាំងនោះ ប្រាកដដល់នាយទ្វារ ។ ដោយហេតុប្រមាណប៉ុណ្ណេះ ព្រះថេរៈបានក្រាបទូលយ៉ាងនេះ ដល់ព្រះមានព្រះភាគជាម្ចាស់ថា ខ្ញុំព្រះអង្គតាំងនៅក្នុងសាវកបារមីញាណ រមែងដឹង កាន់យកដោយន័យតាមក្រសែធម៌ ដូច្នេះការតាមប្រកបសីហនាទរបស់ខ្លួន ព្រះថេរៈបានទូលថ្វាយហើយ ។

[៥៥] បទថា *ព្រោះដូច្នោះ (តស្មា)* សេចក្តីថា ព្រោះព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរមែងមិនមានញាណជាគ្រឿងកំណត់ដឹងព្រះទ័យ ក្នុងព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ ទាំងជាអតីត អនាគត និងបច្ចុប្បន្នទេ តែថា ស្ទង់តាមធម៌ ខ្ញុំព្រះអង្គដឹងហើយ ដូច្នេះ ។

[៥៥] បទថា *គប្បីពោលឲ្យរឿយៗ (អភិក្ខណំ ភាសេយ្យាសិ)* សេចក្តីថា អ្នកគប្បីពោលរឿយៗ ។ អធិប្បាយថា មិនពោលក្នុងវេលាព្រឹក និងវេលាថ្ងៃត្រង់ជាដើមថា យើងពោលហើយក្នុងវេលាព្រឹក មិនពោលក្នុងថ្ងៃដទៃ ជាដើមថា យើងពោលហើយក្នុងថ្ងៃនេះ ។

បទថា *និងលះការងឿងឆ្ងល់ ឬសេចក្តីសង្ស័យនោះ (សា បហីយិស្សតិ)* សេចក្តីថា កាលបុគ្គលទាំងឡាយគិតថា ដែលឈ្មោះថា ព្រះសាវកដល់ព្រមដោយការស្ទុះទៅនៃបញ្ញា ដូចជាព្រះសារីបុត្ត ក៏មិនអាចនឹងដឹង

ការត្រាច់ទៅនៃចិត្តរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ព្រះតថាគត ដែលនរណាៗ គប្បីប្រៀប មិនបានយ៉ាងនេះ ដូច្នេះ គេនឹងលះបង់សេចក្តីងឿងឆ្ងល់ សង្ស័យ ក្នុងព្រះតថាគតបាន ។

ចប់អដ្ឋកថា ឆាឡន្ទសូត្រទី ២

# អដ្ឋកថា

## ចុន្ទសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចុន្ទសូត្រទី ៣*

*ពាក្យថា* ***ក្នុងដែនមគធ (មគធេសុ)*** *គឺ ក្នុងជនបទដែលមានឈ្មោះយ៉ាងនោះ ។ ពាក្យថា* ***ក្នុងតំបន់នាឡកៈ (នាឡកគាមកេ)*** *គឺ ក្នុងតំបន់ដែលមានឈ្មោះយ៉ាងនោះ ដែលជាត្រកូលរបស់ខ្លួន មិនឆ្ងាយក្រុងរាជគ្រឹះ ។*

[៥៦] *បទថា* ***សាមណេរឈ្មោះថាចុន្ទៈ (ចុន្ទោ សមណុទ្ទេសោ)*** *សេចក្តីថា ព្រះថេរៈនេះជាប្អូនប្រុសពៅរបស់ព្រះធម្មសេនាបតី ក្នុងកាលដែលលោកនៅមិនទាន់ឧបសម្បទ ពួកភិក្ខុហៅលោកថា សាមណេរចុន្ទៈ សូម្បីវេលាជាព្រះថេរៈ ក៏ហៅយ៉ាងនោះដូចគ្នា ព្រោះហេតុនោះ លោកទើបពោលថា សាមណេរចុន្ទៈ ។ បទថា* ***ជាឧបដ្ឋាក (ឧបដ្ឋាកោ ហោតិ)*** *សេចក្តីថា ជាឧបដ្ឋាកដោយទឹកលាងមុខ ឈើស្ទន់ និងទឹកឆាន់ បោសសំអាតបរិវេណ គក់ប្រាប់ខ្នង និងទទួលបាត្រចីវរ ។ បទថា* ***បរិនិព្វានហើយ (បរិនិព្វាយិ)*** *សេចក្តីថា បរិនិព្វានហើយដោយអនុបាទិសេសនិព្វានធាតុ ។*

*សួរថា បរិនិព្វានក្នុងវេលាណា ។ ឆ្លើយថា ក្នុងឆ្នាំបរិនិព្វានរបស់*

ព្រះមានព្រះភាគ ក្នុងរឿងនោះ មានអណុបុព្វិកថាដូចតទៅនេះ ៖

ជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ចាំវស្សាហើយ ស្ដេចចេញចាកភូមិវេឡុវៈ ទ្រង់ត្រិះរិះថា តថាគតនឹងទៅក្រុងសាវត្ថី ហើយស្ដេចទ្រង់ត្រឡប់ដោយផ្លូវដែលស្ដេចមកនោះឯង ដល់ក្រុងសាវត្ថីដោយលំដាប់ ហើយស្ដេចទៅព្រះជេតពន ។ ព្រះធម្មសេនាបតីសម្ដែងវត្តថ្វាយព្រះមានព្រះភាគហើយ ទៅទីសម្រាកពេលថ្ងៃ ។ កាលពួកអន្តេវាសិកក្នុងទីនោះសម្ដែងវត្តហើយនាំគ្នាចេញទៅ លោកទើបបោសសំអាតទីសម្រាកពេលថ្ងៃ ក្រាលផ្ទាំងស្បែក លាងជើង ហើយអង្គុយពត់ភ្នែនចូលផលសមាបត្តិ ។ លំដាប់នោះ កាលលោកចេញអំពីផលសមាបត្តិនោះតាមកំណត់ហើយ កើតបរិវិតក្កៈនេះថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ នឹងបរិនិព្វានមុនឬហ្ន៎ ឬថា ព្រះអគ្គសាវកបរិនិព្វានមុន ពេលនោះដឹងថា ព្រះអគ្គសាវកបរិនិព្វានមុន ទើបពិចារណាមើលអាយុសង្ខាររបស់ខ្លួន ។ ដឹងថា អាយុសង្ខាររបស់យើងនឹងប្រព្រឹត្តទៅបានត្រឹម ៧ ថ្ងៃទៀតប៉ុណ្ណោះ ទើបគិតថា យើងនឹងបរិនិព្វានទីណាហ្ន៎ ។ លំដាប់នោះ ទើបគិតទៀតថា ព្រះរាហុលបរិនិព្វានក្នុងតាវត្តឹង្សពិភព ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ បរិនិព្វាននៅឯស្រះឆទ្ទន្ត យើងនឹងបរិនិព្វានកន្លែងណាហ្ន៎ ដូច្នេះ ទើបកើតសេចក្ដីសង្វេគប្រារព្ធចំពោះមាតាថា មាតារបស់

យើង ជាមាតារបស់ព្រះអរហន្តដល់ទៅ ៧ អង្គ តែនៅមិនទាន់ជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃឡើយ លោកមានឧបនិស្ស័យឬទេហ្ន៎ បានឃើញឧបនិស្ស័យនៃព្រះសោតាបត្តិមគ្គ ទើបពិចារណាមើលថា នឹងសម្រេចដោយទេសនារបស់នរណា ជ្រាបថា នឹងសម្រេចដោយធម្មទេសនារបស់យើងប៉ុណ្ណោះ មិនមែនរបស់អ្នកដទៃ បើយើងគប្បីខ្វល់ខ្វាយតិច ក៏មានអ្នកពោលនឹងយើងថា ព្រះសារីបុត្តត្ថេរជាទីពឹងរបស់របស់បុគ្គលដ៏សេសទាំងឡាយពិត ដូចក្នុងថ្ងៃសម្ដែងសមចិត្តសូត្ររបស់លោក ទេវតាពាន់កោដិបានសម្រេចព្រះអរហត្ត ទេវតាដែលចាក់ធ្លុះមគ្គ ៣ ក៏មិនរាប់អស់ ប្រាកដការត្រាស់ដឹងក្នុងទីដទៃៗ ច្រើនទៀត និងត្រកូលប្រាំបីម៉ឺនធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះថេរៈ ក៏បានកើតក្នុងសួគ៌នោះឯង ឥឡូវនេះ លោកមិនអាចនឹងដោះចេញសូម្បីត្រឹមសេចក្ដីឃើញខុសនៃមាតារបស់ខ្លួនបាន ព្រោះដូច្នោះ ទើបដាក់ចិត្តថា យើងនិងដោះ មាតាចេញពីសេចក្ដីឃើញខុស ហើយបរិនិព្វានក្នុងបន្ទប់ដែលកើតនោះ ទើបគិតថា ថ្ងៃនេះ យើងនឹងសូមអនុញ្ញាតព្រះមាន-ព្រះភាគជាម្ចាស់ ហើយចេញទៅ ដូច្នេះ ទើបហៅព្រះចុន្ទៈត្ថេរមកថា ចុន្ទៈ អ្នកចូរឲ្យសញ្ញាដល់ភិក្ខុបរិស័ទ ៥០០ រូបរបស់យើងថា លោកមានអាយុទាំងឡាយ ចូរកាន់យកបាត្រ និងចីវរទៅ ព្រះធម្មសេនាបតី បំណងនឹងទៅ

កាន់ស្រុកនាឡកៈ ។ ព្រះថេរៈក៏បានធ្វើយ៉ាងនោះ ។ ភិក្ខុទាំងឡាយ ទើបរក្សាសេនាសនៈ កាន់បាត្រ និងចីវរទៅកាន់សម្នាក់ព្រះថេរៈ ។

ព្រះថេរៈទុកដាក់សេនាសនៈ បោសសំអាតទីសម្រាកពេលថ្ងៃ និងឈរត្រង់ទ្វារទីសម្រាកពេលថ្ងៃ ក្រឡេកមើលទីសម្រាកពេលថ្ងៃ គិតថា ឥឡូវនេះ ជាការឃើញគ្រាចុងក្រោយ នឹងមិនមានការមកទៀតឡើយ មានភិក្ខុ ៥០០ រូបហែហម ចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់ ថ្វាយបង្គំហើយបានក្រាបទូលព្រះមានព្រះភាគជាម្ចាស់យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់អនុញ្ញាតខ្ញុំព្រះអង្គ សូមព្រះសុគតទ្រង់អនុញ្ញាត កាលនេះ ជាកាលបរិនិព្វានរបស់ខ្ញុំព្រះអង្គ អាយុសង្ខារខ្ញុំព្រះអង្គដាក់ចុះហើយ ក៏ព្រោះព្រះពុទ្ធទាំងឡាយ កាលត្រាស់ថា អ្នកចូរបរិនិព្វាន ក៏នឹងសរសើរសេចក្តីស្លាប់ កាលត្រាស់ថា អ្នកកុំបរិនិព្វាន បុគ្គលជាមិច្ឆាទិដ្ឋិ ក៏នឹងលើកទោសថា ពោលសរសើរគុណរបស់វដ្តៈ ដូច្នេះ ទើបមិនត្រាស់ពាក្យសូម្បីទាំងពីរ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា អ្នកនឹងបរិនិព្វានទីណា សារីបុត្ត កាលព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបរិនិព្វាន ក្នុងបន្ទប់ដែលខ្ញុំព្រះអង្គកើត ក្នុងស្រុកនាឡកៈ ដែនមគធៈនោះ ទើបត្រាស់ថា សារីបុត្ត អ្នកចូរសម្គាល់ដល់

កាលដែលគួរចុះ ក៏ការឃើញភិក្ខុដូចអ្នករបស់ភិក្ខុ ទាំងបង និងប្អូនរបស់អ្នក រកបានលំបាកក្នុងឥឡូវនេះ អ្នកចូរសម្ដែងធម៌ដល់ភិក្ខុទាំងនោះ ។

ព្រះថេរៈដឹងហើយថា ព្រះសាស្ដាទ្រង់សង្ឃឹមចំពោះការសម្ដែងធម៌ដែលផ្ដើមដោយការសម្ដែងឫទ្ធិរបស់យើង ថ្វាយបង្គំព្រះមានព្រះភាគហើយហោះឡើងទៅប្រមាណមួយដូរដើមត្នោត ចុះមក ថ្វាយបង្គំព្រះបាទព្រះ-ទសពល និងហោះឡើងទៅប្រមាណពីរដូរដើមត្នោតទៀត ចុះមក ថ្វាយបង្គំព្រះបាទព្រះទសពល ហើយហោះឡើងទៅប្រមាណប្រាំពីរដូរដើមត្នោត ធ្វើបែបនេះ សម្ដែងបាដិហារិយ៍ច្រើនយ៉ាង ហើយប្រារព្ធធម្មកថា ។ ព្រះថេរៈពោលធម្មកថាដោយកាយដែលប្រាកដខ្លះ មិនប្រាកដខ្លះ ដោយកាយខាងលើ ខាងក្រោម ឬពាក់កណ្ដាលកាយ ពេលខ្លះក៏សម្ដែងជារូបព្រះច័ន្ទដោយមិនមាននរណាឃើញ ពេលខ្លះក៏ជារូបព្រះអាទិត្យ ពេលខ្លះក៏ជារូបភ្នំ ពេលខ្លះក៏ជារូបសមុទ្រ ពេលខ្លះក៏ជាស្ដេចចក្រពត្តិ ពេលខ្លះក៏ជាវេស្សវណ្ណមហារាជ ពេលខ្លះក៏ជាស្ដេចសក្កមហារាជ ពេលខ្លះក៏ជាស្ដេចមហាព្រហ្ម ពេលសម្ដែងបាដិហារយ៍ច្រើនយ៉ាង យ៉ាងនេះ ព្រះថេរៈទើបពោលធម្មកថាអ្នកនគរទាំងអស់ប្រជុំគ្នាហើយ ព្រះថេរៈហោះចុះហើយ បានឈរថ្វាយបង្គំព្រះបាទព្រះទសពល ។

លំដាប់នោះ ព្រះសាស្តាបានត្រាស់នឹងព្រះថេរៈនោះថា សារីបុត្ត ធម្មបរិយាយនេះ ឈ្មោះអ្វី?

ស, ឈ្មោះ សីហនិកីឡិតៈ (លីលានៃព្រះអរហន្ត) ព្រះអង្គ ។

ព, សារីបុត្ត ណ្ហើយចុះ ធម្មបរិយាយនេះ ឈ្មោះថា សីហនិកីឡិតៈ សារីបុត្ត ណ្ហើយចុះ កម្រងធម៌នេះ ឈ្មោះថា សីហនិកីឡិតៈ ។ ព្រះថេរៈ បានលាដៃមានពណ៌ដូចអាចម៍លក្ខស្រស់ ហើយចាប់ត្រង់កព្រះបាទ ដូចជាក្បាច់អណ្តើកមាស របស់ព្រះសាស្តាបណ្តើរ ក្រាបទូលបណ្តើរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបំពេញបារមីមកមួយអសង្ខេយ្យកម្រៃសែនកប្បក៏ដើម្បីថ្វាយបង្គំព្រះបាទទាំងពីរនេះរបស់ព្រះអង្គ មនោរថរបស់ខ្ញុំព្រះអង្គដល់ទីបំផុតហើយ ឥឡូវនេះ អំពីនេះទៅការប្រជុំគ្នាក្នុងទីជាមួយគ្នាដោយអំណាចបដិសន្ធិនឹងមិនមានទៀតឡើយ សមាគមក៏នឹងមិនមាន សេចក្តីស្និទ្ធស្នាលគ្នាបានដាច់ហើយ ខ្ញុំព្រះអង្គនឹងចូលក្រុង គឺ ព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ក្សេម មានសុខ ត្រជាក់ មិនមានភ័យ ដែលព្រះពុទ្ធច្រើនសែនព្រះអង្គចូលទៅហើយ បើថា ព្រះអង្គទ្រង់មិនគាប់ព្រះទ័យ ទោសណាៗរបស់ខ្ញុំព្រះអង្គ ដែលប្រព្រឹត្តផ្លូវកាយ ឬផ្លូវវាចា សូមព្រះអង្គទ្រង់អត់ទោសនោះផង បពិត្រព្រះដ៏មានព្រះភាគ កាលនេះ ជាកាលទៅរបស់ខ្ញុំព្រះអង្គ

ហើយ ។

៣. សារីបុត្ត តថាគតអត់ទោសដល់អ្នក ក៏ទោសណាៗ របស់អ្នក ដែលប្រព្រឹត្តទៅផ្លូវកាយ ឬផ្លូវវាចា ដែលមិនគាប់ចិត្តតថាគតមិនមានឡើយ សារីបុត្ត ឥឡូវនេះអ្នកចូរសម្គាល់កាលគួរចុះ ។

កាលព្រះសារីបុត្តថ្វាយបង្គំព្រះបាទព្រះសាស្តា ក្រោកឡើងក្នុងលំដាប់ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ផែនដីដ៏ធំសូម្បីកំណត់រាប់ដោយភ្នំសិនេរុ ភ្នំចក្រវាឡ ភ្នំហិមពាន្ត និងភ្នំបរិភ័ណ្ឌ ស្រែកឡើងព្រមគ្នា ដូចពោលថា យើងមិនអាចនឹងទ្រទ្រង់គំនរនៃព្រះគុណនេះទុកបាន ក្នុងថ្ងៃនេះបានកម្រើកហើយរហូតដល់ទឹកជាទីបំផុត ទេពស្គរជ័យក្នុងអាកាសក៏ប្រគុំឡើង មហាមេឃតាំងឡើងហើយ ញ៉ាំងភ្លៀងបោក្ខរព័ស្សធ្លាក់ហើយ ។ ព្រះសាស្តាទ្រង់ត្រិះរិះថា តថាគតនឹងឲ្យព្រះធម្មសេនាបតីសម្តែងដោយចំពោះ ដូច្នេះហើយទើបទ្រង់ក្រោកឡើងចាកទីស្តាប់ធម៌ ស្តេចបែរព្រះភក្ត្រទៅកាន់ព្រះគន្ធកុដិ ទ្រង់ប្រថាប់ឈរលើផែនកែវ ។ ព្រះថេរៈធ្វើប្រទក្សិណ ៣ ដងហើយ ថ្វាយបង្គំក្នុងទី ៤ កន្លែង ក្រាបទូលថា បពិត្រព្រះមានព្រះភាគ កន្លងផុតទៅមួយអសង្ខេយ្យកម្រៃសែនកប្ប អំពីកប្បនេះទៅ ខ្ញុំព្រះអង្គក្រាបចុះទីជិតព្រះបាទរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ព្រះនាមថា អនោមទស្សី

ប្រាថ្នាឃើញព្រះអង្គ សេចក្តីប្រាថ្នារបស់ខ្ញុំព្រះអង្គនោះសម្រេចហើយ ខ្ញុំព្រះអង្គឃើញព្រះអង្គហើយក្នុងការឃើញលើកដំបូង នេះជាការឃើញលើកចុងក្រោយ ការបានឃើញព្រះអង្គមិនមានទៀតឡើយ ដូច្នេះ ហើយផ្គងអញ្ជលីដ៏រុងរឿងដោយការប្រជុំនៃម្រាមទាំងដប់ បែរមុខចំពោះដរាបដែលនឹងឃើញបាន ថយក្រោយហើយថ្វាយបង្គំ ហើយជៀសចេញទៅ ។ មហាប្រឹថពីមិនអាចនឹងទ្រទ្រង់ទុកបាន ញាប់ញ័ររហូតដល់ទឹកទ្រផែនដី ។ ព្រះមានព្រះភាគជាម្ចាស់ បានត្រាស់នឹងពួកភិក្ខុដែលឈរជុំវិញថា ភិក្ខុទាំងឡាយពួកអ្នកចូរជាប់តាមបងប្រុសរបស់ពួកអ្នកចុះ ខណៈនោះ បរិស័ទ ៤ លះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទុកព្រះអង្គមួយអង្គឯងក្នុងព្រះជេតពន ចេញទៅមិនសល់ឡើយ ។

ចំណែកអ្នកនគរសាវត្ថី នាំគ្នានិយាយថា បានឮថា ព្រះសារីបុត្តត្ថេរ ទូលលាព្រះសម្មាសម្ពុទ្ធជាម្ចាស់ហើយ បំណងនឹងបរិនិព្វាន ចេញទៅហើយ ពួកយើងនឹងទៅសួរសុខទុក្ខលោក នាំគ្នាកាន់យកគ្រឿងក្រអូប និងកម្រងផ្កាជាដើម ចេញទៅរហូតណែនទ្វារក្រុង រំសាយសក់ ស្រែកយំ រៀបរាប់ ដោយន័យជាដើមថា ឥឡូវនេះពួកឡើងកាលសួរថា លោកអ្នកមានបញ្ញាច្រើនអង្គុយទីណា ព្រះធម្មសេនាបតីអង្គុយទីណា ដូច្នេះ នឹងទៅសម្នាក់

របស់នរណា នឹងទៅធ្វើសក្ការៈក្នុងដៃរបស់អ្នកណា ព្រះថេរៈចេញទៅហើយ ទើបបានជាប់តាមព្រះថេរៈ ។ ព្រះថេរៈ ព្រោះភាពដែលខ្លួនតាំងនៅក្នុងបញ្ញាច្រើន គិតថា ផ្លូវនេះអ្នកទាំងអស់មិនគួរឈានមកឡើយ ហើយឲ្យឱវាទមហាជនថា អ្នកមានអាយុទាំងឡាយ សូម្បីពួកលោកចូរឈប់ កុំដល់នូវសេចក្ដីប្រមាទក្នុងព្រះទសពលឡើយ ហើយឲ្យពួកភិក្ខុត្រឡប់ ក៏ចេញទៅជាមួយបរិស័ទរបស់ខ្លួន ។ ពួកមនុស្សផ្សេងៗ យំរៀបរាប់ថា គ្រាមុនលោកម្ចាស់ត្រាច់ចារិកទៅហើយក៏ត្រឡប់មក ឥឡូវនេះ ការទៅនេះ ជាការទៅមិនត្រឡប់មកទៀតឡើយ ទើបនាំគ្នាជាប់តាមទៅយ៉ាងនោះ ។ ព្រះថេរៈពោលជាមួយមនុស្សទាំងនោះថា អ្នកទាំងឡាយ ពួកអ្នកចូរជាអ្នកមិនប្រមាទឈ្មោះថា សង្ខារទាំងឡាយរមែងជាយ៉ាងនេះ ទើបឲ្យត្រឡប់ ។

លំដាប់នោះឯង ព្រះសារីបុត្តធ្វើការសង្គ្រោះពួកមនុស្សរហូតអស់ប្រាំពីរថ្ងៃ ក្នុងរវាងផ្លូវសម្រាកតែពេលយប់ ដល់ស្រុកនាឡកៈពេលល្ងាច បានឈរត្រង់ក្រោមដើមនិគ្រោធជិតទ្វារផ្ទះ លំដាប់នោះ ញាតិរបស់ព្រះថេរៈឈ្មោះថា ឧបរេវតៈ ទៅក្រៅផ្ទះ បានឃើញព្រះថេរៈហើយ ទើបចូលទៅឈរសំពះ ។ ព្រះថេរៈទើបពោលនឹងគេថា យាយរបស់អ្នកនៅក្នុងផ្ទះឬ ។

ឧ, បាទ លោកម្ចាស់ ។

ស, អ្នកចូរទៅប្រាប់ថា យើងមកទីនេះ ។ ពេលយាយពោលថា មកព្រោះហេតុអ្វី? ចូរពោលថា បានឮថា ព្រះថេរៈនឹងនៅក្នុងផ្ទះអស់មួយថ្ងៃក្នុងថ្ងៃនេះ សូមលោកចូរចាត់ចែងបន្ទប់ដែលព្រះថេរៈកើត និងបានឮថា សូមលោកចូរដឹងកន្លែងដែលជាទីនៅរបស់ភិក្ខុ ៥០០ រូប ។ គេទៅហើយប្រាប់ថា យាយ អ៊ុំប្រុសរបស់ខ្ញុំមកហើយ ។

យាយ, ពេលនេះ នៅទីណា ។

ខ, ត្រង់ទ្វារផ្ទះ ។

យ, មាននរណាដទៃមកខ្លះទៀត ។

ខ, មានភិក្ខុ ៥០០ រូប ។

យ, មកធ្វើអ្វី ។

គេក៏ប្រាប់ហេតុនោះ ។ នាងព្រាហ្មណី គិតថា កូនប្រុសយើងហេតុអ្វី ទើបឲ្យត្រៀមទីកន្លែងដល់ពួកភិក្ខុទាំងនេះ លោកបួសតាំងតែពីកម្លោះដល់វេលាចាស់ប្រាថ្នានឹងសឹកទេដឹង ទើបឲ្យចាត់ចែងបន្ទប់ប្រសូតិ ឲ្យរៀបចំទីស្នាក់របស់ភិក្ខុ ៥០០ រូប ឲ្យដុតទៀន និងចង្កៀងថ្វាយព្រះថេរៈ ព្រះថេរៈព្រមជាមួយពួកភិក្ខុឡើងប្រាសាទ ចូលទៅអង្គុយនៅក្នុងបន្ទប់ប្រសូតិ លុះនឹងអង្គុយចុះហើយ ក៏ប្រាប់ទៅពួកភិក្ខុថា ពួកលោកចូរទៅសម្រាកបន្ទរកម្លាំង

ចុះ ពេលពួកភិក្ខុទៅហើយប៉ុណ្ណោះ អាពាធដ៏ខ្លាំងក៏កើតឡើងដល់ព្រះថេរៈ វេទនាជិតនឹងស្លាប់ព្រោះធ្លាក់លោហិត ត្រូវយកភាជនៈមួយចូលទៅ (ត្រូវ) យកភាជនៈមួយចេញមក ។ នាងព្រាហ្មណីគិតថា យើងមិនពេញចិត្តការប្រព្រឹត្តទៅនៃបុត្តរបស់យើងឡើយ បានឈរផ្អែកទ្វារបន្ទប់ទីនៅរបស់ខ្លួន ។ ស្តេចមហារាជទាំង ៤ ពិចារណាមើលថា ព្រះធម្មសេនាបតីនៅទីណា ឃើញថា ដេកលើគ្រែជាទីបរិនិព្វាន ក្នុងបន្ទប់របស់លោកប្រសូតិក្នុងស្រុកនាឡកៈ ពួកយើងនឹងទៅសួរសុខទុក្ខជាលើកចុងក្រោយ ក៏បានមកហើយព្រមទាំងឈរសំពះ ។

សារីបុត្ត, ពួកលោកជានរណា ។

មហារាជ, ជាស្តេចមហារាជ លោកម្ចាស់ ។

សារីបុត្ត, មកព្រោះហេតុអ្វី ។

មហារាជ, មកបម្រើលោកម្ចាស់ ដែលមានជម្ងឺ ។

ស, ណ្ហើយចុះ អ្នកបម្រើយើងជាអ្នកឈឺមានហើយ ពួកលោកចូរទៅចុះ ហើយបានឲ្យត្រឡប់ទៅ ក្រោយស្តេចមហារាជទាំង ៤ ទៅហើយ ស្តេចសក្កទេវរាជ ក៏មកដោយន័យនោះៗ ឯង ក៏កាលស្តេចសក្កទេវរាជទៅហើយ ស្តេចមហាព្រហ្មណ៍ក៏មក ព្រះថេរៈក៏បានប្រាប់លោកទាំងនោះឲ្យទៅ

ដូចយ៉ាងនោះៗ ឯង ។ កាលនាងព្រាហ្មណីឃើញពួកទេវតានាំគ្នាមក ទើបគិតថា ទេវតាទាំងនេះសំពះបុត្ររបស់យើងហើយក៏ទៅ ព្រោះហេតុអ្វីហ្ន៎ ទើបដើរទៅកាន់ទ្វារបន្ទប់ព្រះថេរៈ ហើយសួរថា លោកកូនចុន្ទៈ មានការប្រព្រឹត្តទៅយ៉ាងណា ។ ចុន្ទភិក្ខុ ប្រាប់ការប្រព្រឹត្តទៅនោះហើយ ទើបហៅព្រះថេរៈថា លោកម្ចាស់ មហាឧបាសិកាមក ។ ព្រះថេរៈទើបសួរថា ហេតុអ្វី ទើបមកក្នុងកាលមិនគួរ ។ នាងទើបពោលថា លោកកូន ម៉ែមកដើម្បីមើលលោកកូន ហើយទើបសួរថា លោកកូន ពួកនរណាមកមុននោះ ។

សារីបុត្ត, ស្ដេចមហារាជទាំង ៤ មហាឧបាសិកា ។

មាតា, លោកកូនធំជាងស្ដេចមហារាជទាំង ៤ ឬ ។

ស, ឧបាសិកា ស្ដេចមហារាជទាំង ៤ ដូចក្មេងវត្ត តាំងតែពីព្រះសាស្ដារបស់ពួកយើងចាប់បដិសន្ធិ ក៏កាន់ព្រះខ័នរក្សាហើយ ។

ម, លោកកូន ក្រោយស្ដេចមហារាជទៅហើយ ជានរណា ។

ស, ស្ដេចសក្កទេវរាជ ។

ម, លោកកូន ធំជាងស្ដេចទេវរាជទៀតឬ ។

ស, ឧបាសិកា ស្ដេចសក្កៈក៏ដូចជាសាមណេរអ្នកកាន់របស់របរ កាលដែលព្រះសាស្ដារបស់ពួកយើង ស្ដេចចុះចាកតាវត្តិង្សព្រិភព ក៏បានកាន់បាត្រ

ចីវរតាមចុះមក ។

ម, លោកកូន ក្រោយពីស្តេចសក្កៈនោះទៅហើយ ឃើញមានពន្លឺស្វាងស្វែ នរណាមក ។

ស, ឧបាសិកា នោះក៏គឺមហាព្រហ្មណ៍ ដែលជាព្រះ និងជាសាស្តារបស់ញោម ។

ម, លោកកូនទៅធំជាងមហាព្រហ្មណ៍ ជាព្រះរបស់ញោមទៀតឬ ។

ស, មែន ឧបាសិកា បានឮមកថា ឈ្មោះថា មហាព្រហ្មណ៍ទាំង ៤ នោះ ថ្ងៃដែលព្រះសាស្តារបស់ពួកយើងប្រសូតិ យកអង្រឹងមាសទ្រទទួលព្រះមហាបុរស ។

ខណៈនោះ នាងព្រាហ្មណីគិតថា ត្រឹមតែលោកកូនរបស់យើងមានអានុភាពប៉ុណ្ណេះ ព្រះសាស្តា ដែលជាព្រះរបស់លោកកូនយើង នឹងមានអានុភាពប៉ុនណាហ្ន៎ ភ្លាមនោះបីតិ ៥ យ៉ាង កើតឡើងផ្សាយទូទាំងសរីរៈ ។ ព្រះថេរៈគិតថា បីតិសោមនស្សកើតឡើងហើយដល់មាតាហើយ ។ ឥឡូវនេះជាវេលាសមគួរសម្តែងធម៌ ទើបពោលថា មហាឧបាសិកា លោកកំពុងគិតអ្វី ។

ម, លោកកូន ម៉ែកំពុងគិតដល់ហេតុនេះថា ត្រឹមតែលោកកូនយើង

មានគុណដល់ត្រឹមនេះហើយ សាស្តារបស់លោកកូននោះនឹងប៉ុនណា ។

ស, មហាឧបាសិកា ក្នុងខណៈដែលព្រះសាស្តារបស់អាត្មាប្រសូតិ ក្នុងខណៈស្តេចចេញបួស ក្នុងខណៈត្រាស់ដឹង និងក្នុងខណៈប្រកាសធម្ម-ចក្ក មុឺនលោកធាតុញាប់ញ័រហើយ ដែលឈ្មោះថា បុគ្គលដែលស្មើដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈ មិនមាន ហើយក៏សម្តែងព្រះធម៌ទេសនាទាក់ទងព្រះគុណរបស់ព្រះពុទ្ធជាម្ចាស់ ដែលបរិយាយឲ្យពិស្តារថា សូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គនោះដូច្នេះ ជាដើម ។ វេលាចប់ធម្មទេសនារបស់លោកកូនជាទីស្រឡាញ់ នាងព្រាហ្មណីតាំងនៅក្នុងព្រះសោតាបត្តិផល ទើបពោលជាមួយលោកកូនថា ឧបតិស្សៈកូន ហេតុអ្វី លោកកូនទើបធ្វើយ៉ាងនេះ លោកកូនមិនបានឲ្យអមតធម៌បែបនេះដល់ម៉ែហូតកាលប៉ុណ្ណោះ ។ ព្រះថេរៈគិតថា ឥឡូវនេះ យើងឲ្យប៉ុណ្ណោះក៏គួរដល់មាតាហើយ តម្លៃចិញ្ចឹមសម្រាប់ម៉ែព្រាហ្មណីសារីនឹងគួរដោយហេតុប៉ុណ្ណោះ ទើបពោលថា មហាឧបាសិកា លោកចូរទៅចុះ ប្រាប់នាងព្រាហ្មណីទៅហើយ ទើបពោលថា ចុន្ទៈ វេលាណាហើយ ។

ចុន្ទៈ ជិតភ្លឺហើយ លោកម្ចាស់ ។

ស, អ្នកចូរប្រជុំភិក្ខុសង្ឃ ។

ច, ភិក្ខុសង្ឃប្រជុំគ្នាហើយ លោកម្ចាស់ ។

ស, អ្នកចូរគ្រាយើងឲ្យអន្ទយ ចុន្ទះ ។

ព្រះចុន្ទះ គ្រាឲ្យអន្ទយហើយ ។ ព្រះថេរៈទើបហៅភិក្ខុទាំងឡាយមកថា អាវុសោ កាលពួកលោកទាំងឡាយត្រាច់ទៅជាមួយខ្ញុំរហូត ៤៤ ឆ្នាំ កម្មណារបស់ខ្ញុំដែលប្រព្រឹត្តទៅផ្លូវកាយក្តី ផ្លូវវាចាក្តី ដែលពួកលោកមិនពេញចិត្ត សូមពួកលោកចូរអត់ទោសនោះដល់ខ្ញុំផង ។

ភិក្ខុ, លោកម្ចាស់ដ៏ចម្រើន ដែលឈ្មោះថា វត្ថុដែលមិនគួរគាប់ចិត្ត រមែងមិនមានដល់ពួកខ្ញុំ ជាអ្នកលះបង់លោកត្រាច់ទៅ ដូចស្រមោលរបស់លោកម្ចាស់ អស់កាលប៉ុណ្ណេះ ។ តែថា សូមលោកម្ចាស់ចូរអត់ទោសឲ្យដល់ពួកខ្ញុំផងចុះ ។

លំដាប់នោះ ព្រះថេរៈទាញមហាចីវរមកបិទមុខ ដេកផ្អៀងខាងស្តាំ ចូលសមាបត្តិ ៩ តាមលំដាប់សមាបត្តិទាំងដោយអនុលោម និងបដិលោម ដូចព្រះសាស្តា តែថា ចូលផ្តើមពីបឋមជ្ឈានរហូតដល់ចតុត្ថជ្ឈាន ចេញពីចតុត្ថជ្ឈាននោះហើយ មហាបឋវីក៏កក្រើកញាប់ញ័រ ក្នុងពេលនោះឯង លោកក៏បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ។

ឧបាសិកាគិតថា លោកកូនរបស់យើងមិនពោលអ្វីសោះហ្ន៎ ក្រោក

ឡើង ស្តាប់ខ្លួនដើងដឹងថា បរិនិព្វានហើយ បន្ទឺសំឡេងទ្រោបត្រង់ជើង ពោលថា លោកកូន ពួកយើងមិនដឹងគុណរបស់លោកកូនអំពីមុន ឥឡូវនេះ ម៉ែមិនបានសូម្បីនិមន្តភិក្ខុច្រើនរយ ច្រើនពាន់ ច្រើនសែន សូម្បីត្រឹមតែលោកកូន ឲ្យគង់ឆាន់ក្នុងនិវេសន៍នេះ មិនបានឲ្យស្លៀកដណ្តប់ដោយចីវរ មិនបានឲ្យសាងវិហារជារយ ជាពាន់ខ្នង ដូច្នេះ យំរៀបរាប់រហូតដល់អរុណរះឡើង ។ ពេលអរុណរះឡើងហើយ នាងក៏ឲ្យហៅជាងមាសមក ឲ្យបើកបន្ទប់រក្សាមាស ឲ្យថ្លឹងមាសដោយជញ្ជីងធំ បញ្ជូនទៅ ដោយពោលថា បា! ទាំងឡាយ ចូរធ្វើផ្ទះកំពូលប្រាំរយ ផ្ទះទទួលភ្ញៀវប្រាំរយ ។

ចំណែកស្តេចសក្កទេវរាជ ត្រាស់ហៅវិស្សកម្មទេវបុត្តមក ត្រាស់ថា បា! ព្រះធម្មសេនាបតីបរិនិព្វានហើយ បា! ចូរនិមិត្តផ្ទះកំពូលប្រាំរយ ផ្ទះទទួលភ្ញៀវប្រាំរយ ។ ផ្ទះដែលឧបាសិកាឲ្យសាងហើយ រួមជាមួយនឹងព្រះវិស្សកម្មនិមិត្តផង ត្រូវជាពីរពាន់ ដោយប្រការដូច្នេះ ។ លំដាប់នោះ មនុស្សទាំងឡាយ ទើបឲ្យសាងមហាមណ្ឌបសុទ្ធតែរបស់សារៈ ដាក់ផ្ទះកំពូលដែលធំត្រង់កណ្តាលមណ្ឌប ហើយដាក់របស់ដ៏សេស ដោយសង្ខេបជាបរិវារ ប្រារព្ធការលេងយ៉ាងល្អ ចន្លោះពួកទេវតាមានពួកមនុស្ស ចន្លោះពួកមនុស្សមានពួកទេវតា ។ ឧបដ្ឋាយិការបស់ព្រះថេរៈម្នាក់ឈ្មោះ រេវតី

គិតថា យើងនឹងបូជាព្រះថេរៈ ទើបឲ្យធ្វើសសរផ្កាឈើមាស ៣ ដើម (ដើមឈើមាស) ។ សក្កទេវរាជគិតថា យើងនឹងបូជាព្រះថេរៈ មានទេពអប្សរពីរកោដិកន្លះហែហម ស្តេចដាក់ចុះមកហើយ ។ មហាជនបែរមុខ ហើយដើរត្រឡប់ ដោយគិតថា ស្តេចសក្កៈ ស្តេចយាងចុះមក ។ សូម្បីឧបាសិកានោះ ក្នុងទីនោះថយក្រោយដែរ ព្រោះមានការៈធ្ងន់មិនអាចនឹងថយទៅក្នុងទីសមគួរបាន ក៏ដួលក្នុងចន្លោះពួកមនុស្ស ។ ពួកមនុស្សមិនឃើញ បានជាន់ឧបាសិកានោះឯង នាងស្លាប់ក្នុងទីនោះ កើតក្នុងវិមានមាសឯជាន់តាវត្តិង្ស ។ ខណៈដែលកើតនោះឯង នាងមានអត្តភាព ៣ គាវុត ដោយប្រមាណ ដូចដុំបងកែវ នាងប្រដាប់ដោយគ្រឿងប្រដាប់ប្រមាណពេញស្មើដោយហុកសិបរទេះ មានទេពអប្សរមួយពាន់ហែហមហើយ ។ នាងទេព-អប្សរទាំងឡាយ ដាក់កញ្ចក់សម្រាប់ស្អិតស្អាងកាយទាំងអស់ដែលជាទិព្វទុកខាងមុខនាង ។ នាងឃើញសិរីសម្បត្តិរបស់ខ្លួន គិតថា យើងធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិដ៏ច្រើន បានឃើញថា យើងបានធ្វើការបូជាព្រះថេរៈដោយសសរផ្កាឈើមាសបីដើម ក្នុងទីបរិនិព្វានរបស់ព្រះសារីបុត្ត មហា-ជនក៏ជាន់លើយើង បន្ទាប់ពីនោះ យើងបានស្លាប់ក្នុងទីនោះ កើតហើយក្នុងទីនេះ យើងនឹងពោលផលបុណ្យដែលយើងអាស្រ័យព្រះថេរៈ ក្នុងឥឡូវនេះ

ដល់ពួកមនុស្ស ទើបចុះមកព្រមទាំងវិមាននោះឯង ។ មហាជនឃើញអំពីចម្ងាយ សម្គាល់ថា ព្រះអាទិត្យរះឡើងពីរដងឬហ្ន៎ ពេលវិមានអណ្តែតមកជិត លក្ខណៈផ្ទះកំពូលក៏ប្រាកដ ។ បាននិយាយគ្នាថា នេះមិនមែនជាព្រះអាទិត្យទេ ជាវិមានមួយខ្នង ។ សូម្បីវិមាននោះ មកហើយក្នុងខណៈនោះអណ្តែតនៅលើជើងថ្ករឈើរបស់ព្រះថេរៈ ។ ទេពធីតា ទើបបញ្ឈប់វិមានទុកក្នុងអាកាសនោះឯង ហើយចុះមកកាន់ផែនដី ។ មហាជននាំគ្នាសួរថា នាងម្ចាស់ នាងជានរណា ។ យើងឈ្មោះ នាងរេវតី បូជាព្រះថេរៈដោយសសរប្រដាប់ដោយផ្កាឈើមាស ៣ ដើម ត្រូវពួកមនុស្សជាន់លើ ហើយស្លាប់ទៅកើតក្នុងតាវត្តិង្សពិភព សូមអ្នកទាំងឡាយមើលសិរីសម្បត្តិរបស់យើង ឥឡូវនេះ សូម្បីពួកអ្នកក៏ចូរឲ្យទានធ្វើបុណ្យចុះ ។

លុះនាងពោលសរសើរការធ្វើកុសលហើយ ក៏ប្រទក្សិណជើងថ្ករព្រះថេរៈសំពះហើយ បានទៅទេវស្ថានរបស់ខ្លួននោះទៅ ។ ចំណែកមហាជនលេងយ៉ាងរៀបរយអស់ ៧ ថ្ងៃហើយ បានធ្វើជើងថ្ករដោយគ្រឿងក្រអូបទាំងពួង ។ ជើងថ្ករប្រកបដោយកែវ ៩៩ ប្រភេទ ។ មនុស្សទាំងឡាយទើបលើកសរីរៈរបស់ព្រះថេរៈឡើងកាន់ជើងថ្ករ ហើយដុតដោយបាច់ស្បូវ ការស្តាប់ធម៌រមែងប្រព្រឹត្តទៅរាល់រាត្រីទាំងអស់ក្នុងទីបូជា ។ ព្រះអនុរុទ្ធត្ថេរ

យកទឹកក្រអូបគ្រប់ប្រភេទ រំលត់ជើងថ្ករព្រះថេរៈ ។

[៥៧] ព្រះចុន្ទត្ថេរៈ ដាក់ធាតុចុះក្នុងធម្មក្រកហើយ គិតថា ឥឡូវនេះ យើងមិនអាចនឹងរក្សាទុកទីនេះបាន នឹងក្រាបទូលដល់ព្រះសម្មាសម្ពុទ្ធថា ព្រះសារីបុត្តដែលជាធម្មសេនាបតី បងប្រុសរបស់យើង បរិនិព្វានហើយ ដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានកាន់យកសំពត់តម្រងទឹកដែលខ្ចប់ធាតុ និងបាត្រចីវរព្រះថេរៈ ទៅក្រុងសាវត្ថី ។ និងមិនសម្រាកលើសពី ២ យប់ ក្នុងទីមួយកន្លែងៗ ដល់ក្រុងសាវត្ថី ដោយការនៅក្នុងទីមួយកន្លែងតែមួយយប់នោះឯង ។ ដើម្បីសម្តែងសេចក្តីនេះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ពាក្យជាដើមថា ពេលនោះឯង សាមណេរចុន្ទៈ (អថខោ ចុន្ទោ សមណុទ្ទេសោ) ។

បណ្តាបទទាំងនោះ បទថា ចូលទៅរកព្រះអានន្ទដល់ទីនៅ (យេនាយស្មា អានន្ទោ) សេចក្តីថា លោកបានចូលទៅកាន់ទីនៅរបស់ព្រះអានន្ទ ជាឃ្មាំងនៃធម៌ដែលជាឧបជ្ឈាយ៍របស់ខ្លួន ។

សួរថា ព្រោះហេតុអ្វី ព្រះចុន្ទៈ លោកមិនទៅកាន់សម្នាក់ព្រះសាស្តា (តែ) ទៅសម្នាក់ព្រះថេរៈវិញ ។

ឆ្លើយថា ព្រោះសេចក្តីគោរពក្នុងព្រះសាស្តា និងព្រះថេរៈ ។

បានឮថា ព្រះចុន្ទៈត្ថេរនោះ បានងូតទឹកឯស្រះបោក្ខរណីក្នុងព្រះជេត-

ពនមហាវិហារស្រេចហើយ ស្លៀកដណ្តប់យ៉ាងល្អ មានការគិតថា ឈ្មោះថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ធ្ងន់ដូចឆត្រថ្មធំ និងដូចពស់វែកបើកពពារ រាជសីហ៍ ខ្លា និងដំរីចុះប្រេងជាដើម ចូលជិតបានដោយលំបាក យើងមិនអាចនឹងទៅកាន់សម្នាក់ព្រះសាស្តាភ្លាមៗ គួរទៅសម្នាក់របស់នរណាហ្ន៎ ។ លំដាប់នោះ ទើបគិតថា ឧបជ្ឈាយ៍របស់យើង លោកជាឃ្លាំងនៃព្រះធម៌ជាសម្លាញ់ដ៏ប្រសើររបស់ព្រះថេរៈជាបងប្រុសយើងៗ នឹងទៅកាន់សម្នាក់របស់លោក ឲ្យលោកនាំទៅក្រាបទូលព្រះសាស្តា ទើបបានចូលទៅរក ព្រោះសេចក្តីគោរពក្នុងព្រះសាស្តា និងព្រះថេរៈ ។

បទថា **នេះបាត្រចីវររបស់លោក (ឥទមស្រ បត្តចីវរំ)** សេចក្តីថា ព្រះថេរៈក្រាបទូលតែមួយយ៉ាងៗ ដូច្នេះថា នេះបាត្រសំរាប់ប្រើប្រាស់របស់លោក នេះសំពត់តម្រងទឹកខ្ចប់ធាតុរបស់លោក ។ តែក្នុងបាលី លោកពោលត្រឹមប៉ុណ្ណេះថា នេះបាត្រចីវររបស់លោក ។ ពាក្យថា **ពាក្យដែលចាប់ផ្តើម (កថាបាភតំ)** គឺ ពាក្យសំដីដែលជាដើមទុន ។ **មូល** លោកហៅថា ដើមទុន ដូចដែលលោកពោលទុកថា ៖

**អ្នកមានបញ្ញា ពិចារណាហើយ រមែងតាំងខ្លួន**

**បានដោយដើមទុនសូម្បីតិច ដូចអ្នកបង្កាត់ភ្លើង**

តិចតួច ដូច្នេះ ។

បទថា ដើម្បីគាល់ព្រះមានព្រះភាគ (ភគវន្តំ ទស្សនាយ) សេចក្តីថា ដើម្បីត្រូវការគាល់ព្រះមានព្រះភាគជាម្ចាស់ ។

សួរថា ក៏ព្រះចុន្ទៈនេះ មិនធ្លាប់ឃើញព្រះមានព្រះភាគជាម្ចាស់ឬ? ឆ្លើយថា មិនធ្លាប់ឃើញក៏ទេ ព្រោះថា ព្រះចុន្ទៈនេះ រមែងទៅទំនុកបម្រុង នោះមួយថ្ងៃ ១៨ ដង គឺ ពេលថ្ងៃ ៩ ដង ពេលយប់ ៩ ដង សូម្បីលោក បំណងនឹងទៅមួយថ្ងៃមួយរយដង មួយពាន់ដង តែក៏ទៅមិនបាន ព្រោះមិន មានហេតុ ដោយប្រការដូច្នេះ ទើបលើកបញ្ហាមួយជាហេតុទើបទៅ ។ ថ្ងៃ នោះ លោកបំណងនឹងទៅដោយពាក្យដែលជាមូលដើម ទើបក្រាបទូលយ៉ាង នេះថា នេះបាត្រចីវររបស់លោក ។ ចំណែកព្រះថេរៈ ក៏ក្រាបទូលបង្ហាញ ដោយចំពោះមួយយ៉ាងៗ ថា នេះបាត្រចីវររបស់លោក និងនេះសំពត់ត្រង ទឹកខ្ចប់ធាតុរបស់លោក ។

ព្រះសាស្តាទ្រង់លាព្រះហស្ត ទទួលយកសំពត់ត្រងទឹកខ្ចប់ធាតុ ដាក់ លើបាតព្រះហស្ត ត្រាស់ហៅភិក្ខុទាំងឡាយមកថា ភិក្ខុទាំងឡាយ ភិក្ខុណា ថ្ងៃមុនធ្វើបាដិហារិយ៍ច្រើនរយយ៉ាង សូមអនុញ្ញាតបរិនិព្វាន ឥឡូវនេះ ធាតុ ទាំងឡាយ ពណ៌ប្រៀបដោយស័ង្ខទាំងនេះរបស់លោកប្រាកដហើយ ភិក្ខុ

ទាំងឡាយ ភិក្ខុនេះបំពេញបារមីមកមួយអសង្ខេយ្យកម្រៃសែនកប្ប ឲ្យធម្មចក្ក ដែលតថាគតឲ្យប្រព្រឹត្តទៅ ទៅហើយ លោកជាអ្នកស្ថិតអង្គទីពីរ ដែលតថាគតបានចំពោះ ជាអ្នកញុំាងសាវកសន្និបាតឲ្យគ្រប់ ភិក្ខុនេះ វៀរតថាគតចេញ រកអ្នកស្មើដោយបញ្ញាក្នុងម៉ឺនចក្រវាឡមិនបាន ជាអ្នកមានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាពោលឲ្យញាប់ញ័របាន មានបញ្ញារហ័ស មានបញ្ញាចាស់ក្លា មានបញ្ញាក្នុងការចាក់ធ្លុះ គេមានសេចក្តីប្រាថ្នាតិច សន្តោស ស្ងប់ស្ងាត់ មិនស្និទ្ធស្នាល ប្រារព្ធសេចក្តីព្យាយាម ជាអ្នកដាស់តឿន តិះដៀលសេចក្តីអាក្រក់ លោកលះបង់មហាសម្បត្តិដែលបានហើយដោយចំពោះ បួសមកហើយប្រាំរយជាតិ មានសេចក្តីអត់ធន់ស្មើដោយផែនដីក្នុងសាសនារបស់តថាគត ដូចជាគោឧសភៈដែលបាក់ស្នែង មានចិត្តទន់ភ្លន់ ដូចកូនមនុស្សចណ្ឌាល ភិក្ខុទាំងឡាយ ពួកអ្នក ចូរមើលធាតុរបស់អ្នកមានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាធំទូលាយ មានបញ្ញារហ័ស មានបញ្ញាក្លៀវក្លា មានបញ្ញាក្នុងការចាក់ធ្លុះ អ្នកមានសេចក្តីប្រាថ្នាតិច សន្តោស ស្ងប់ស្ងាត់ មិនស្និទ្ធស្នាល ប្រារព្ធសេចក្តីព្យាយាម ជាអ្នកដាស់តឿន តិះដៀលសេចក្តីអាក្រក់ ។

សារីបុត្តណា លះកាមទាំងឡាយដែលជា

ទីសប្បាយនៃចិត្ត បួសហើយប្រាំរយជាតិ ពួកអ្នកចូរថ្វាយបង្គំព្រះសារីបុត្តនោះ អ្នកប្រាសចាករាគៈ មានឥន្ទ្រិយសង្រួមល្អហើយ បរិនិព្វានហើយចុះ ។

សារីបុត្តណា មានសេចក្តីអត់ធន់ជាកម្លាំង ស្មើដោយផែនដី រមែងមិនញាប់ញ័រ ទាំងមិនប្រព្រឹត្តទៅក្នុងអំណាចចិត្តផង មានការអនុគ្រោះ ជាអ្នកប្រកបដោយករុណា បរិ-និព្វានហើយ ពួកអ្នកចូរថ្វាយបង្គំសារីបុត្តនោះចុះ ។

កូនមនុស្សចណ្ឌាល ចូលទៅព្រះនគរហើយ មានចិត្តដាក់ខ្លួន កាន់ក្បៀងដើរទៅ យ៉ាងណា សារីបុត្តនេះ ក៏នៅដូច្នោះ ពួកអ្នកចូរថ្វាយបង្គំសារីបុត្តដែលបរិនិព្វានហើយចុះ ។

ក៏គោឧសភៈមានស្នែងបាក់ហើយ មិនបៀតបៀន ត្រាច់ទៅខាងក្នុងក្រុង យ៉ាងណា

សារីបុត្តនេះ ក៏ទៅដូច្នោះ ពួកអ្នកចូរ
ថ្វាយបង្គំសារីបុត្តដែលបរិនិព្វានហើយ
ចុះ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សរសើរព្រះថេរៈ ដោយព្រះគាថាប្រាំរយ ដោយប្រការដូច្នេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សរសើរគុណព្រះថេរៈ ដោយប្រការណាៗ ព្រះអានន្ទក៏មិនអាចនឹងតាំងនៅដោយប្រការនោះៗ លោកញាប់ញ័រ ដូចសត្វមាន់រត់ទៅខាងមុខឆ្មា ដូច្នោះ ។ ព្រោះហេតុនោះ ព្រះអានន្ទត្ថេរ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាយរបស់ខ្ញុំព្រះអង្គរមែងញាប់ញ័រហាក់ដូចជារឹងស្ពូកស្ពឹង ។ រឿងទាំងអស់គួរឲ្យពិស្តារ ។

[៥៨] អត្ថនៃបទជាដើមថា ហាក់ដូចជារឹងស្ពូកស្ពឹង (មធុរកជាតោ) ក្នុងបទនោះ លោកពោលទុកហើយ ។ ក៏ធម៌ គឺ ឧទ្ទេស និងការសាកសួរ លោកបំណងយកក្នុងបទថា ធម៌ នេះ ។ ព្រោះថា កាលមិនកាន់យកធម៌ គឺ ឧទ្ទេស និងការសាកសួរ ចិត្តក៏មិនប្រព្រឹត្តទៅដើម្បីនឹងកាន់យក ឬថា (លុះកាន់យកហើយ) ចិត្តរបស់ព្រះថេរៈនោះ ក៏មិនប្រព្រឹត្តទៅដើម្បីស្វាធ្យាយ ។

[៥៩] លំដាប់នោះ ព្រះសាស្តាទ្រង់បើកព្រះនេត្រដែលវិចិត្រដោយបសាទទាំង ៥ ឡើង ទ្រង់ក្រឡេកមើលព្រះថេរៈ ទ្រង់ទប់ព្រះទ័យដោយសន្សឹម

ថា តថាគតនឹងឲ្យគេជូរចិត្ត ទើបត្រាស់ពាក្យជាដើមថា **អានន្ទ សារីបុត្តរបស់អ្នកទៅណាហើយ (កឹ នុ តេ អានន្ទ សារីបុត្តោ)** ។

បណ្ដាបទទាំងនោះ បទថា **គំនរសីល (សីលក្ខន្ធំ)** បានដល់ សីលដែលជាលោកិយៈ និងលោកុត្តរៈ ។ សូម្បីក្នុងសមាធិ និងបញ្ញាក៏ន័យនេះឯង ។ ចំណែកវិមុត្តិ ជាលោកុត្តរៈ ។ វិមុត្តិញាណទស្សនៈ គឺ បច្ចវេក្ខ-ញាណនោះ ជាលោកិយៈប៉ុណ្ណោះ ។ បទថា **អ្នកបង្រៀន (ឱវាទកោ)** គឺអ្នកឲ្យឱវាទ ។ អ្នកមានប្រក្រតីពោលទូន្មានដោយប្រការផ្សេងៗ ក្នុងរឿងទាំងឡាយដែលមានជម្រៅ ។ បទថា **ឲ្យដឹងច្បាស់ (វិញ្ញាបកោ)** សេចក្ដីថា ឲ្យដឹងច្បាស់ហេតុ និងផល ក្នុងវេលាដែលពោលធម៌ ។

បទថា **អ្នកសម្ដែងឲ្យឃើញ (សន្ទស្សកោ)** សេចក្ដីថា ពន្យល់ធម៌នោះៗ ដោយអំណាចខន្ធ ធាតុ និងអាយតនៈ ។ បទថា **ឲ្យសមាទាន (សមាទបកោ)** សេចក្ដីថា ឲ្យកាន់យកយ៉ាងនេះថា ពួកលោកចូរកាន់យកវត្តនេះផង ។ បទថា **ឲ្យអាចហ៊ាន (សមុត្តេជកោ)** បានដល់ ឲ្យឧស្សាហៈឡើង ។ បទថា **ឲ្យរីករាយ (សម្បហំសកោ)** បានដល់ ឲ្យរីករាយ គឺ ឲ្យផុសឡើងដោយគុណដែលបានហើយ ។ បទថា **មិនខ្ជិលច្រអូសក្នុងការសម្ដែងធម៌ (អកិលាសុ ធម្មទេសនាយ)** សេចក្ដីថា កាលផ្ដើមសម្ដែងធម៌

ក៏ជាអ្នកវៀរចាកការធ្វើដោយសន្ទើប ស្រូត យ៉ាងនេះថា ខ្ញុំម្ចាស់ឈឺក្បាល ឈឺចិត្ត ឈឺពោះ ឬឈឺខ្នង ជាអ្នកមិនខ្ជិលច្រអូស គឺ ជាអ្នកអង់អាច ស្ទុះទៅយ៉ាងរហ័សដូចសីហៈ មួយក្បាល ឬពីរក្បាល ។ សេចក្តីនៃបទថា **អនុគ្រោះដើម្បីសព្រហ្មចារីទាំងឡាយ** (អនុគ្គាហកោ សព្រហ្មចារីនំ) លោកឲ្យពិស្តារហើយក្នុងខន្ធកវគ្គ ។ ភោគៈនោះឯង ព្រះថេរៈពោលហើយសូម្បីដោយបទទាំងពីរថា **ធម្មឱជះ ធម្មភោគះ** (ធម្មោជំ ធម្មភោគំ) ។ បទថា **ការអនុគ្រោះដោយធម៌** (ធម្មានុគ្គហំ) បានដល់ ការសង្គ្រោះដោយធម៌ ។ ព្រះសាស្តាទ្រង់ត្រិះរិះថា ភិក្ខុរមែងលំបាកយ៉ាងក្រៃលែង ពេលនឹងលួង-លោមចិត្តអ្នកទៀត ទើបត្រាស់ពាក្យជាដើមថា អានន្ទ សេចក្តីនោះ តថាគតបានប្រាប់អ្នកហើយ មិនមែនឬ ។

[៦០] បណ្តាបទទាំងនោះ បទថា **របស់ស្រឡាញ់ របស់ពេញចិត្ត** (បិយេហិ មនាបេហិ) សេចក្តីថា ភាពផ្សេងៗ គ្នា ដោយជាតិ ការលះបង់គ្នាដោយសេចក្តីស្លាប់ (និង) ដោយប្រការដទៃព្រោះភព ចាកមាតាបិតា បងប្អូនប្រុសនិងបងប្អូនស្រីជាដើម រមែងមាន ។ បទថា **អានន្ទ នឹងគប្បីបានក្នុងរបស់ស្រឡាញ់ របស់គាប់ចិត្តនេះអំពីទីណា** (តំ កុតេត្ថ អានន្ទ លព្ភា យន្តំ) សេចក្តីថា ព្រោះហេតុដែលមានសេចក្តីផ្សេងៗ គ្នា ចាកវត្ថុដែលជាទីស្រឡាញ់

ជាទីពេញចិត្តទាំងពួង ព្រោះដូច្នោះ ព្រះតថាគតបំពេញបារមី ១០ ក្តី សម្រេចសម្ពោធិញ្ញាណក្តី ឲ្យធម្មចក្កប្រព្រឹត្តទៅក្តី សម្តែងយមកបាដិហារិយ៍ក្តី ធ្វើការឈានចាកទេវលោកក្តី សរីរៈនោះណាដែលកើតហើយ មានហើយ ត្រូវបច្ច័យតាក់តែងហើយ មានការបែកធ្លាយទៅជាធម្មតា ប្រការដែលប្រាថ្នាថា សូមសរីរៈសូម្បីរបស់ព្រះតថាគតនោះ កុំបែកធ្លាយទៅឡើយ នោះមិនមែនជាឋានៈឡើយ ទាំងអ្នកយំអង្វរ ទាំងអ្នកពោលហើយ ក៏មិនអាចនឹងបានឋានៈនោះ ៗ

[៦១] បទថា *លំដាប់នោះ គប្បីទម្លាយ (សោ បលុជ្ជេយ្យ)* សេចក្តីថា ដើមឈើនោះគប្បីរលំ ។ ក្នុងពាក្យថា *ដូច្នោះដូចគ្នា (ឯវមេ ខោ)* មានអធិប្បាយថា ភិក្ខុសង្ឃដូចដើមព្រឹងធំខ្ពស់រយយោជន៍ ។ ព្រះធម្មសេនាបតីប្រៀបដូចមែកធំប្រមាណហាសិបយោជន៍ ដែលដុះកាន់ទិសខាងស្តាំនៃដើមឈើនោះ ៗ ព្រះថេរៈបរិនិព្វានហើយ ការមិនមានភិក្ខុដទៃដែលដល់ទីបំផុតនៃបញ្ហា[១] ១៦ ដូចជាព្រះសារីបុត្ត ដែលអាចនឹងអង្គុយលើអាសនៈខាងស្តាំអំពីភិក្ខុនោះ ដូចដើមឈើធំនោះ បាក់ហើយ ក៏មិនមានដើមឈើដទៃដែលអាចចម្រើនឡើងដោយលំដាប់ តអំពីដើមឈើដែលបាក់ហើយនោះ ដែល

---

១ ដីកា : សោឡសន្នំ បញ្ហានំ ប្រែថា បញ្ហា ១៦ យ៉ាង ។

*អាចឲ្យទីនោះពេញដោយផ្កា និងផ្លែជាដើម ។ ពួកភិក្ខុសង្ឃដូចជាដើមឈើក្នុងទិសនោះ ចំណែកតួដើម គប្បីជ្រាបថា កើតហើយ ។ បទថា* ***ព្រោះហេតុនោះ (តស្មា)*** *សេចក្តីថា ព្រោះវត្ថុដែលជាបច្ច័យទាំងអស់តាក់តែងហើយ មានសេចក្តីវិនាសជាធម្មតា បុគ្គលមិនអាចនឹងបានថា សូមវត្ថុនោះចូរកុំវិនាសទៅឡើយ ។*

ចប់អដ្ឋកថា ចុន្ទះសូត្រទី ៣

# អ ដ្ឋ ក ថា

## ឧក្កចេលសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧក្កចេលសូត្រទី ៤

[៦៤] បទថា ពេលព្រះសារីបុត្តនិងព្រះមោគ្គល្លាន បរិនិព្វានទៅហើយមិនយូរ (អចិរបរិនិព្វុតេសុ សារីបុត្តមោគ្គល្លានេសុ) សេចក្តីថា កាលព្រះអគ្គសាវកទាំងពីរបរិនិព្វានហើយមិនយូរ ក៏បណ្តាព្រះអគ្គសាវកទាំងពីរនោះ ព្រះធម្មសេនាបតី បរិនិព្វានក្នុងថ្ងៃពេញបូរមីខែ ១២ (កត្តិក) បន្ទាប់ពីនោះកន្លងទៅកន្លះខែ ក្នុងថ្ងៃឧបោសថនៃកាឡបក្ខ កន្លះខែនោះ ព្រះមហាមោគ្គល្លានទើបបរិនិព្វាន ។ កាលព្រះអគ្គសាវកទាំងពីរបរិនិព្វានហើយ ព្រះសាស្តា មានភិក្ខុពួកធំហែហមស្តេច ចារិកទៅក្នុងមហាមណ្ឌលជនបទ ស្តេចដល់ឧក្កចេលនគរដោយលំដាប់ ស្តេចទៅបិណ្ឌបាត្រក្នុងឧក្កចេលនគរនោះហើយប្រថាប់នៅលើឆ្នេរខ្សាច់ មានពណ៌ដូចផែនប្រាក់ ត្រង់ឆ្នេរទន្លេគង្គា ព្រោះហេតុនោះ លោកទើបពោលថា កាលព្រះសារីបុត្ត និងព្រះមោគ្គល្លានបរិនិព្វានហើយមិនយូរ ។

[៦៧] សូម្បីក្នុងបទថា ដើមឈើដែលធំជាងទាំងនោះណា គប្បីបាក់

*(យេ មហន្តតរា ខន្ធា តេ បលុជ្ជេយ្យុំ)* មានអធិប្បាយថា ពួកភិក្ខុប្រៀបដូចដើមព្រឹងធំខ្ពស់រយយោជន៍ ព្រះអគ្គសាវកទាំងពីរប្រៀប ដូចជាមែកដែលធំទាំង ២ ប្រមាណហាសិបយោជន៍ ដែលដុះចេញទៅទិសខាងត្បូង និងទិសខាងជើងនៃដើមឈើនោះ ។ ពាក្យដ៏សេស គួរប្រកបក្នុងន័យមុននោះឯង ។

ចប់អដ្ឋកថា ឧក្កាចេលសូត្រទី ៤

# អ ដ្ឋ ក ថា

## ពាហិយសុត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពាហិយសូត្រទី ៥*

[៧០] *បទថា ការឃើញ (ទិដ្ឋិ) បានដល់ ការឃើញថា សត្វមានកម្មជារបស់ខ្លួន ។*

ចប់អដ្ឋកថា ពាហិយសូត្រទី ៥

# អ ដ្ឋ ក ថា

## ឧត្តិយសូត្រទី ៦

[៧៣] *គប្បីជ្រាបវិនិច្ឆ័យក្នុង ឧត្តិយសូត្រទី ៦*

[៧៤] *បទថា ត្រើយ (និព្វាន) នៃវដ្តៈដែលជាទីតាំងនៃមច្ចុ (មច្ចុធេយ្យស្ស បារំ) សេចក្តីថា ព្រះនិព្វាន ចាត់ជាត្រើយនៃវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។*

ចប់អដ្ឋកថា ឧត្តិយសូត្រទី ៦

# អ ដ្ឋ ក ថា

## ព្រហ្មសូត្រទី ៨

[៧៨] គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រហ្មសូត្រទី ៨

[៧៩] បទថា **បពិត្រព្រះអង្គដ៏ចម្រើន ឬថាភិក្ខុទាំងឡាយ,,,, ក្នុងកាយ (កាយេ វា ភន្តេ ភិក្ខុ)** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងថា ភិក្ខុទាំងឡាយរមែងមិនមានក្នុងកាលនោះឯង សូម្បីដូច្នេះ បុគ្គលណាចម្រើន សតិប្បដ្ឋាន បុគ្គលនោះ ឈ្មោះថា ជាភិក្ខុ ព្រោះទម្លាយកិលេសបាន ទើបត្រាស់យ៉ាងនេះ ។

[៨០] បទថា **ផ្លូវឯក (ឯកាយនំ)** គឺ ផ្លូវតែមួយ ។ បទថា **ទ្រង់ឃើញការអស់ទៅនៃជាតិ និងទីបំផុតនៃជាតិ (ជាតិខយន្តទស្សី)** សេចក្តីថា ឈ្មោះថា និព្វាន ព្រោះអត្ថថា អស់ និងព្រោះអត្ថថា ទីបំផុតនៃជាតិ ។ អធិប្បាយ ថា ឃើញនិព្វាននោះ ។ បទថា **ទ្រង់ដឹងផ្លូវ (មគ្គំ បជានាតិ)** សេចក្តីថា ទ្រង់ដឹងផ្លូវដែលជាផ្លូវឯក ពោលគឺ ផ្លូវប្រព្រឹត្តទៅតែមួយ ។ ផ្លូវ គឺ សតិប្បដ្ឋាន ដែលជាចំណែកខាងដើម លោកហៅថា ផ្លូវតែមួយដែលប្រព្រឹត្តទៅខាងមុខ ។ អធិប្បាយថា ទ្រង់ដឹងផ្លូវនោះ ។

ចប់អដ្ឋកថា ព្រហ្មសូត្រទី៨

# អ ដ្ឋ ក ថា

## បឋមសេទកសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសេទកសូត្រទី ៩*

*[៨១] បទថា **ក្នុងនិគមឈ្មោះសុមកៈ (សុម្ភេសុ)** បានដល់ ក្នុងជនបទទីមានឈ្មោះយ៉ាងនេះ ។ ពាក្យថា **មេទកថាលិកៈ (មេទកថាលិកា)** គឺ បានឈ្មោះយ៉ាងនេះដោយអំណាចឥត្ថីលិង្គ ។ ក្នុងបទថា **លោកចូររក្សាយើង យើងនឹងរក្សាលោក** នេះ មានអធិប្បាយថា មនុស្សចណ្ឌាលនោះ មានលទ្ធិថា អាចារ្យពេលមិនចាប់យកឫស្សីដែលកូនសិស្សលើកឡើងហើយទុកឲ្យល្អ មិនទៅកាន់ទិសដែលលេងទៅហើយ និងមិនសម្លឹងមើលចុងឫស្សីគ្រប់វេលាទេ ឈ្មោះថា មិនរក្សាកូនសិស្ស ។ កូនសិស្ស ដែលអាចារ្យមិនរក្សាហើយយ៉ាងនេះ រមែងធ្លាក់ទៅបែកខ្ទេចខ្ទី ។ តែថា អាចារ្យចាប់ឫស្សីទុកដោយល្អ ទៅតាមទិសដែលកូនសិស្សលេងទៅនោះ និងសម្លឹងមើលចុងឫស្សីគ្រប់វេលា ឈ្មោះថា រមែងរក្សាសិស្សនោះ ។ សូម្បីកូនសិស្សដែលឡើងទៅខាងនោះខាងនេះ នឿយហត់ដូចម្រឹគរត់ទៅ ក៏ឈ្មោះថា មិនរក្សាអាចារ្យ ។ ព្រោះថា បើយ៉ាងនេះ ចុងឫស្សីដ៏មុត ដែលដាក់ទុក*

លើដី ឬលើថ្ងាសអាចារ្យ ក៏នឹងគប្បីទម្លាយក្ដៅនូវអាចារ្យនោះឈរ ឬស្សី ក៏នឹងទោរទៅតាមអាការ សិស្សកាលមិនបន្ទន់ទៅខាងនោះ ដូចទាញឫស្សីនោះមកបែងចេញជាចំណែកអំពីចំណែកមួយ ហើយឲ្យចាប់សសរទប់ខ្លួនតាំងសតិ អន្ទ្រយស្នៀម ឈ្មោះថា រមែងរក្សាចារ្យ ។

[៨២] អាចារ្យ សូមលោក ចូររក្សាខ្លួន ខ្ញុំក៏នឹងរក្សាខ្លួន (ត្វំ អាចរិយ អត្តានំ រក្ខ អហំ អត្តានំ) ក្នុង ពាក្យនេះ មានអធិប្បាយដូចតទៅនេះ ។ អាចារ្យ ពេលចាប់ឫស្សីឲ្យមាំល្អ ទៅតាមទិសដែលសិស្សឡើងទៅនិងសម្លឹងមើលចុងឫស្សីគ្រប់ពេល ឈ្មោះថា រក្សាខ្លួននោះឯង មិនឈ្មោះថា រក្សាសិស្ស ។ ចំណែកសិស្ស បែងកាយឲ្យជាចំណែកៗ ពីចំណែកមួយ ហើយចាប់សសរទប់ខ្លួន តាំងសតិទុកល្អ អន្ទ្រយស្នៀម ឈ្មោះថា រក្សាខ្លួនតែម្យ៉ាង មិនឈ្មោះថា រក្សាអាចារ្យ ។

បទថា ហេតុផលក្នុងសេចក្ដីនោះមាន (សោ តត្ថ ញាយោ) សេចក្ដីថា សិស្ស ឈ្មោះថា មេទកថាលិកៈ ពោលហេតុផលណាមួយជាមួយអាចារ្យ ហេតុផលនោះ គឺ ឧបាយនោះ ក៏ប្រើបានបានក្នុងសេចក្ដីនោះ អធិប្បាយថា ឈ្មោះហេតុនោះ ។ បទថា គប្បីសេពសតិប្បដ្ឋាន (សតិប្បដ្ឋានំ សេវិតព្វំ) សេចក្ដីថា ដើម្បីសេពសតិប្បដ្ឋាន ៤ ។

[៨៣] បទថា **ដោយការសេព (អាសេវនាយ)** សេចក្តីថា ដោយការសេពកម្មដ្ឋាន ។ សេចក្តីថា **ភិក្ខុទាំងឡាយ បុគ្គលកាលរក្សាខ្លួន ឈ្មោះថា រក្សាអ្នកដទៃយ៉ាងនេះ (ឯវំ ខោ ភិក្ខវេ អត្តានំ រក្ខន្តោ បរំ រក្ខតិ)** សេចក្តីថា ភិក្ខុណាលះកាមរាគៈជាដើម សេពមូលកម្មដ្ឋាន ទាំងក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃ រមែងសម្រេចព្រះអរហត្ត ។ ទីនោះ បុគ្គលដទៃឃើញគេចូលទៅ គិតថា ភិក្ខុនេះប្រសើរពិតហ្ន៎ ជាអ្នកបដិបត្តិប្រពៃ ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងភិក្ខុនោះ លុះស្លាប់ទៅក៏ទៅកាន់សួគ៌ បុគ្គលនេះកាលរក្សាខ្លួន ក៏ឈ្មោះថា រក្សាអ្នកដទៃផង ។

[៨៤] ពាក្យថា **ដោយសេចក្តីអត់ធន់ (ខន្តិយា)** បានដល់ ដោយការអត់ធន់ គឺ ការអត់ទ្រាំ ។ ពាក្យថា **ដោយការមិនបៀតបៀន (អវិហឹសាយ)** គឺ ដោយសេចក្តីអាណិត ដែលប្រព្រឹត្តទៅជាចំណែកខាងដើម ។ ពាក្យថា **ព្រោះជាអ្នកមានចិត្តដែលប្រកបដោយមេត្តា (មេត្តចិត្តតាយ)** គឺ ដោយការរក្សាដែលប្រព្រឹត្តទៅជាចំណែកខាងដើម ។ ពាក្យថា **ដោយសេចក្តីអាណិត (អនុទយតាយ)** សំដៅដល់ ដោយសេចក្តីចម្រើនតាមលំដាប់ អធិប្បាយថា ដោយសេចក្តីរីករាយ ដែលប្រព្រឹត្តទៅជាចំណែកខាងដើម ។ ក្នុងពាក្យថា **កាលរក្សាអ្នកដទៃ ក៏ឈ្មោះថារក្សាខ្លួន (បរំ រក្ខន្តោ អត្តានំ**

រក្ខតិ) នេះ មានអធិប្បាយថា ភិក្ខុទៅកាន់ទីសម្រាកពេលយប់ ឬទីសម្រាក ពេលថ្ងៃហើយ ធ្វើឈានពួកបី ឬពួកបួនក្នុងព្រហ្មវិហារបើឲ្យកើត ធ្វើឈានជាបាទ ពិចារណាសង្ខារ ចម្រើនវិបស្សនារហូតបានសម្រេចជាព្រះអរហត្ត នេះ ក៏គប្បីជ្រាបថា កាលរក្សាអ្នកដទៃ ក៏ឈ្មោះថារក្សាខ្លួនផង ។

ចប់អដ្ឋកថា បឋមសេទកសូត្រទី ៩

# អ ដ្ឋ ក ថា

## ទុតិយសេនកសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១០ ។

[៨៧] ពាក្យថា ស្រ្តីល្អក្នុងជនបទ សំដៅដល់ស្រ្តីដែលស្អាតបំផុតក្នុងជនបទ ដែលប្រាសចាកទោសប្រចាំខ្លួន ៦ យ៉ាង ហើយប្រកបដោយសេចក្តីស្អាត ៥ យ៉ាង ។ ក៏ព្រោះនាងនោះមិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនស.ពេក ពណ៌សម្បុរសូម្បីមិនដល់ទិព្វ តែពណ៌សម្បុរប្រសើរលើសមនុស្សផងគ្នា ដូច្នេះ ទើបចាត់ថាប្រាសចាកទោសប្រចាំខ្លួន ៦ យ៉ាង ។ និងព្រោះប្រកបដោយសេចក្តីស្អាតទាំងនេះ គឺ សម្បុរស្អាត សាច់ស្អាត ក្រចកស្អាត[១] (នហារុកល្យាណំ) ធ្មេញស្អាត វ័យស្អាត ទើបឈ្មោះថា ប្រកបដោយសេចក្តីស្អាត ៥ យ៉ាង ។ នាងមិនចាំបាច់ប្រើពន្លឺចូលមកឡើយ ដោយពន្លឺប្រចាំខ្លួននោះឯង ក៏ធ្វើឲ្យភ្លឺក្នុងទីប្រមាណ ១២ ហត្ថ មានសម្បុរដូចផ្កាប្រយុង ឬដូចជាមាស នេះជាសេចក្តីស្អាតនៃសម្បុរស្បែករបស់នាង ។ ចំណែកដៃជើងទាំង ៤ និង

---

១-ពាក្យថា នហារុកល្យាណំ នេះ អដ្ឋកថាអធិប្បាយរឿងក្រចក មិនអធិប្បាយរឿងសរសៃទេ ទើបប្រែថា ក្រចកស្អាត មិនប្រែថា សរសៃស្អាត តាមស័ព្ទ ។

បបូរមាត់របស់នាង ហាក់ដូចជាលាបដោយពណ៌ក្រហម ដូចកែវប្រពាឡ ក្រហម ឬសំពត់កម្ពលក្រហម នេះជាភាពស្អាតនៃសាច់របស់នាង ។ ចំណែក ក្រចកទាំង ២០ នោះឯង ក្នុងទីនេះមិនផុតអំពីសាច់ ស្រដៀងនឹងលាបដោយ ពណ៌ក្រហមទុក ដែលផុតពីសាច់ ក៏ដូចជាផ្ការទឹកដោះ នេះជាភាពស្អាត នៃក្រចករបស់នាង ។ គ្រង់ធ្មេញ ៣២ ដែលដុះឡើងមកនោះឯង ក៏ប្រាកដ ដូចជាយកពេជ្រដែលធ្វៃហើយមករៀបជាជួរ នេះគឺភាពស្អាតនៃធ្មេញរបស់ នាង ។ និងសូម្បីមានអាយុដល់ ១២០ ឆ្នាំ ក៏នៅក្រមុំស្រស់ដូចអាយុត្រឹម តែ ១៦ ឆ្នាំ សក់មិនមានស្កូវឡើយ នេះគឺភាពស្អាតនៃវ័យរបស់នាង ។

ចំណែកក្នុងពាក្យថា **សម្តែងបានល្អក្រៃលែង (បរមបាសាវិនី)** នេះ មានន័យថា ការស្តាប់ ការមើលរមែងប្រព្រឹត្តទៅ ការមើលនោះល្អ ក្រៃលែង ឈ្មោះថា បរមបាសាវ: ការមើលល្អយ៉ាងក្រៃលែងរបស់នាង នោះមានហើយ ។ មានពាក្យដែលលោកអធិប្បាយថា នាងមានការប្រព្រឹត្ត ដ៏ខ្ពង់ខ្ពស់ មានកិរិយាប្រសើរ ក្នុងការរាំ និងច្រៀង មានលំនាំកិរិយាឧត្តម ក្នុងការរាំ ឬប្រសិនបើច្រៀង ក៏មានលំនាំកិរិយាឧត្តមក្នុងការច្រៀងប៉ុណ្ណោះ ។ ពាក្យដ៏សេសក្នុងគ្រប់បទ មានសេចក្តីពក់ទាំងអស់ ។ ក៏វិបស្សនាដែល ផ្តើមដំបូង ទ្រង់ត្រាស់ទុកហើយក្នុងសូត្រទាំងពីរនេះ ដោយប្រការដូច្នេះ

ឯង ៗ

ចប់អដ្ឋកថា ទុតិយសេទកសូត្រទី ១០

## ចប់នាឡន្ទវគ្គទី ២

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា នាឡន្ទសូត្រ
២ អដ្ឋកថា ចុន្ទសូត្រ
៣ អដ្ឋកថា ឧក្កាចេលសូត្រ
៤ អដ្ឋកថា ពាហិយសូត្រ
៥ អដ្ឋកថា ឧត្តិយសូត្រ
៦ អដ្ឋកថា ព្រហ្មសូត្រ
៧ អដ្ឋកថា បឋមសេទកសូត្រ
៨ អដ្ឋកថា ទុតិយសេទកសូត្រ

# សីលដ្ឋិតិវគ្គទី ៣

## អ ដ្ឋ ក ថា

### សីលសូត្រទី ១

[៩០] *គប្បីជ្រាបវិនិច្ឆ័យក្នុង សីលសូត្រទី ៣ នៃវគ្គទី ៣ ។*

[៩១] *បទថា សីលទាំងឡាយ (សីលានិ) បានដល់ ចតុប្បារិសុទ្ធ-សីល ។*

ចប់អដ្ឋកថា សីលសូត្រទី ១

# អ ដ្ឋ ក ថា

## ឋិតិសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ២ ដូចតទៅ ៖*

*[៩១] បទថា ស្វែងរក (ឧម្មង្គោ) បានដល់ ការស្វែងរកប្រស្នា គឺរិះរកបញ្ហា ។*

ចប់អដ្ឋកថា ឋិតិសូត្រទី ២

# អ ដ្ឋ ក ថា

## បរិហានសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិហានសូត្រទី ៣ ដូចតទៅនេះ ៖*

[៩៧] *បទថា ជាហេតុធ្វើឲ្យព្រះសទ្ធម្មវិនាស (សទ្ធម្មបរិហានំ ហោតិ) បានដល់ រមែងមានសេចក្តីវិនាសដោយអំណាចបុគ្គល ។ ពិតហើយ ភិក្ខុណា កាលព្រះពុទ្ធជាម្ចាស់ទាំងឡាយទ្រង់គង់ព្រះជន្មនៅ មិនចម្រើនសតិប្បដ្ឋាន ៤ ព្រះសទ្ធម្មរបស់ភិក្ខុនោះក៏វិនាសទៅ ដូចព្រះសទ្ធម្មរបស់ព្រះទេវទត្តជាដើម ។ ក្នុងសូត្រនេះ ត្រាស់ដល់សេចក្តីវិនាសនៃធម៌របស់បុគ្គលនោះឯង ។*

ចប់អដ្ឋកថា បរិហានសូត្រទី ៣

# អ ដ្ឋ ក ថា

## បទេសសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង បទេសសូត្រទី ៦ ដូចតទៅនេះ ៖*

[១០៥] *បទថា ព្រោះអប់រំបានចំណែកខ្លះ (បទេសំ ភាវិតត្តា) គឺ ព្រោះចម្រើនសតិប្បដ្ឋាន ៤ បានជាចំណែកៗ ។ ពិតហើយ បុគ្គលដែលកំពុងធ្វើឲ្យមគ្គ ៤ និងផល ៣ កើតឡើង ឈ្មោះថា បានអប់រំសតិប្បដ្ឋានជាចំណែកៗ ។*

ចប់អដ្ឋកថា បទេសសូត្រទី ៦

# អ ដ្ឋ ក ថា

## សមត្តសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមត្តសូត្រទី ៧* ដូចតទៅនេះ ៖

[១០៧] *បទថា ព្រោះចម្រើនបរិបូរហើយ (សមត្តំ ភាវិតត្តា)* គឺ *ព្រោះភាពនៃខ្លួនបានអប់រំពេញលេញហើយ ។ ពិតណាស់ បុគ្គលដែលកំពុងធ្វើឲ្យកើតអរហត្តផល ឈ្មោះថា បានអប់រំសតិប្បដ្ឋានពេញលេញហើយ ។*

ចប់អដ្ឋកថា សមត្តសូត្រទី ៧

# អ ដ្ឋ ក ថា

# លោកសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុង លោកសូត្រទី ៨ ដូចតទៅនេះ ៖

[១០៩] បទថា ភាពជាអ្នកមានអភិញ្ញាច្រើន (មហាភិញ្ញតំ) សេចក្តីថា ព្រះថេរៈពោលដោយអំណាចអភិញ្ញា ៦ យ៉ាង ។ បទថា ខ្ញុំដឹងលោកបានទាំងពាន់ (សហស្សលោកំ អភិជានាមិ) លោកពោលដោយអំណាចការនៅជាប់តគ្នា ។ បានឮមកថា ព្រះថេរៈភ្ញាក់អំពីព្រឹក ខ្ពុលមាត់ហើយអង្គុយលើសេនាសនៈ តាមរលឹកដល់អតីត ១ ពាន់កប្ប អនាគត ១ ពាន់កប្ប ។ តាមដំណើរគតិនៃការរឭកនោះរបស់ពាន់ចក្រវាឡសូម្បីក្នុងបច្ចុប្បន្ន ។ ព្រះថេរៈនោះ ដឹងច្បាស់ពាន់លោកធាតុដោយភ្នែកទិព្វ ដូចពោលមកនេះ ។ នេះគឺធម៌ជាគ្រឿងនៅរបស់លោក ។

សូត្រដ៏សេសក្នុងគ្រប់កន្លែង មានសេចក្តីជាក់ច្បាស់ហើយទាំងនោះឯង ។

ចប់អដ្ឋកថា លោកសូត្រទី ៨

# អ ដ្ឋ ក ថា

## សិរិវឌ្ឍសូត្រទី ៩ និងមានទិន្នសូត្រទី ១០

*មានសេចក្តីងាយទាំងនោះឯង ។*

## ចប់សីលដ្ឋិតិវគ្គទី ៣

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា សីលសូត្រ ២ អដ្ឋកថា ឋិតិសូត្រ
៣ អដ្ឋកថា បរិហានសូត្រ ៤ អដ្ឋកថា បទេសសូត្រ
៥ អដ្ឋកថា សមត្តសូត្រ ៦ អដ្ឋកថា លោកសូត្រ

# អននុស្សុតវគ្គទី ៤

## អ ដ្ឋ ក ថា

### សតិសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុងវគ្គទី ៤ សូត្រទី ៥ ។*

[១២៧] *ពាក្យថា វេទនាដែលដឹងច្បាស់ហើយ (វិទិតា វេទនា) មានន័យថា ពិចារណាវេទនាណាហើយ ទើបបានសម្រេចជាព្រះអរហន្ត វេទនាដែលលោកដឹងច្បាស់ហើយនោះឯង រមែងកើតឡើង ។ វេទនាដែលដឹងច្បាស់ហើយ រមែងចូលទៅតាំងនៅ វេទនាដែលដឹងច្បាស់ហើយ ឈ្មោះថា រមែងដល់ការរលត់ទៅ អស់ទៅ ។ សូម្បីវេទនានោះឯង ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលកំណត់កាន់យកពួកណាដែលដឹងច្បាស់ហើយ រមែងកើតឡើង វេទនាដែលដឹងច្បាស់ហើយទាំងនោះ ក៏ឈ្មោះថា រមែងដល់ការរលត់ទៅ អស់ទៅ ។ សូម្បីក្នុងរឿងវិតក្កៈជាដើម ក៏ទំនងដូចគ្នានេះឯង ។ សូត្រដ៏សេសក្នុងគ្រប់កន្លែង មានសេចក្តីពាក់ហើយទាំងនោះឯង ។*

ចប់អដ្ឋកថា សតិសូត្រទី ៥

## ចប់អននុស្សុតវគ្គទី ៤

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា សតិសូត្រ

# អមតវគ្គទី ៥

## អ ដ្ឋ ក ថា

## សមុទយសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងវគ្គទី ៥ សមុទយសូត្រទី ២ ។

[១៤២] ពាក្យថា *ការកើតនៃកាយ រមែងមានព្រោះការកើតនៃអាហារ (អាហារសមុទយា កាយសមុទយោ)* មានន័យថា ការកើតឡើងព្រមនៃកាយ រមែងមាន ព្រោះការកើតឡើងព្រមនៃអាហារ ។ ក្នុងពាក្យដ៏សេស ក៏ទំនង ដូចគ្នានេះឯង ។ ចំណែកក្នុងពាក្យថា ព្រោះការកើតឡើងព្រមនៃមនសិការ *(មនសិការសមុទយា)* មានន័យថា ការកើតឡើងព្រមនៃធម៌ដែលជាចំណែក ប្រកបនៃការត្រាស់ដឹង រមែងមានបាន ព្រោះការកើតឡើងព្រមនៃការធ្វើ ទុកក្នុងចិត្តដែលមានហេតុផល និងធម៌ គឺ នីវរណៈ (គ្រឿងរាំង) នឹង កើតមានបាន ក៏ព្រោះការមិនធ្វើទុកក្នុងចិត្តដែលមានហេតុផលកើតឡើង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ បានត្រាស់ការតាំងសតិទុកដ៏ មុតមាំក្នុងអារម្មណ៍ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា សមុទយសូត្រទី ២

# អ ដ្ឋ ក ថា

## សតិសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង សតិសូត្រទី ៤ ។*

[១៤៣] *ព្រះដ៏មានព្រះភាគជាម្ចាស់ លុះទ្រង់សម្ដែងនូវហេតុកើតឡើង (សមុទ័យ) សុទ្ធៗ ស្រេចហើយ ព្រះអង្គក៏ត្រាស់ (ព្រះសូត្រនេះ) តាមអធ្យាស្រ័យរបស់បុគ្គលទឹងគប្បីត្រាស់ដឹងបាន ។*

ចប់អដ្ឋកថា សតិសូត្រទី ៤

# អ ដ្ឋ ក ថា

## បាតិមោក្ខសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បាតិមោក្ខសូត្រទី ៦** ។*

[១៥១] *បទថា **បុគ្គលសង្រួម ដោយការសង្រួមក្នុងព្រះបាតិមោក្ខ (បាតិមោក្ខសំវរសំវុតោ)** សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងសីលដែលប្រសើរទីបំផុតនៃសីលទាំង ៤ យ៉ាង ទើបបានត្រាស់យ៉ាងនោះ ។ ព្រះបិកដចុល្លនាគត្ថេរ ពោលថា សីល ក៏គឺ ការសង្រួមក្នុងព្រះបាតិមោក្ខនោះឯង ។ លោកជំទាស់ថា ដែលឈ្មោះថា ឋានៈ ៣ ប្រការទៀត ជាសីលមិនមាន កាលមិនទាន់ឃើញដោយយ៉ាងដាច់ខាតទើបពោល ។ ដែលឈ្មោះថា **ឥន្ទ្រិយសំវរៈ** ក៏ត្រឹមតែថា ប្រព្រឹត្តទៅក្នុងទ្វារ ៦ ប៉ុណ្ណោះ **អាជីវបារិសុទ្ធិ** ក៏ត្រឹមតែថា ដែលកើតបច្ច័យឡើង ដោយត្រឹមត្រូវតាមទំនងគន្លងធម៌ប៉ុណ្ណោះ ។ ឈ្មោះថា **បច្ច័យនិស្សិត** ក៏ត្រង់ដែលពិចារណាថាដើម្បីប្រយោជន៍នេះ ក្នុងបច្ច័យដែលបានមក ហើយបរិភោគ (ព្រោះដូច្នោះ) ពោលដោយត្រង់ សីល ក៏គឺ ការសង្រួមក្នុងព្រះបាតិមោក្ខប៉ុណ្ណោះ ។ បាតិមោក្ខសំវរៈនោះ របស់ភិក្ខុណាបែកធ្លាយហើយ ភិក្ខុនេះក៏មិនគប្បីពោល*

បានថា នឹងរក្សាសីលដ៏សេសទុកបាន ព្រោះដូចមនុស្សដាច់ក្បាល មិនអាចនឹងរក្សាដៃជើងទុកបាន ដូច្នោះ ។ ចំណែកបាតិមោក្ខសំវរៈនោះ របស់ភិក្ខុណាមិនវិនាស ភិក្ខុនេះ ក៏អាចធ្វើសីលដ៏សេសឲ្យត្រឡប់ជាប្រក្រតីបានហើយក៏រក្សាប្រការដទៃ ដូចមនុស្សមិនដាច់ក្បាល អាចរក្សាជីវិតទុកបានដូច្នេះ ។ ព្រោះដូច្នោះ សីល ក៏គឺ បាតិមោក្ខសំវរៈនោះឯង ។ ដោយការសង្រួមក្នុងព្រះបាតិមោក្ខនោះ ។ ពាក្យថា **អ្នកសង្រួមហើយ (សំវុតោ)** មានន័យថា អ្នកសង្រួម អធិប្បាយថា ចូលដល់ គឺ ប្រកបដោយសេចក្ដីសង្រួមក្នុងព្រះបាតិមោក្ខ ។ ពាក្យថា **ដល់ព្រមដោយមារយាទ និងគោចរៈ (អាចារគោចរសម្បន្នោ)** គឺ បរិបូរទាំងអាចារៈ ទាំងគោចរៈ ។ ពាក្យថា **មានប្រមាណតិច (អណុមត្តេសុ)** គឺ មានប្រមាណតិចតួច ។ ពាក្យថា **ទោស (វជ្ជេសុ)** គឺ ក្នុងធម៌ដែលជាអកុសល ។ ពាក្យថា **មានប្រក្រតីឃើញភ័យ (ភយទស្សាវី)** គឺ ឃើញជារបស់គួរខ្លាចដោយប្រក្រតី ។ បទថា **សមាទាន (សមាទាយ)** គឺ ប្រកាន់ទុកយ៉ាងត្រឹមត្រូវ ។ ពាក្យថា **ចូរសិក្សាក្នុងសិក្ខាបទទាំងឡាយ (សិក្ខស្សុ សិក្ខាបទេសុ)** បានដល់ កាន់យកការសិក្សាសិក្ខាបទនោះៗ ក្នុងសិក្ខាបទទាំងឡាយ គឺ ក៏សិក្ខាបទអ្វីៗ ដែលទាក់ទងជាមួយកាយ ឬដែលទាក់ទងជាមួយវាចា ដែលត្រូវសិក្សាក្នុងចំណែក

សិក្ខាក្នុងសិក្ខាបទទាំងឡាយនោះ ចូរសមាទានសិក្សាសិក្ខាបទទាំងអស់នោះ ដោយប្រការដូច្នេះ ។ នេះជាសេចក្តីសង្ខេបក្នុងព្រះសូត្រនេះ ចំណែកសេចក្តីពិស្តារ លោកពោលទុកហើយក្នុងវិសុទ្ធមគ្គ ។ ដោយប្រការនេះក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងតែបាតិមោក្ខសំវរសីលប៉ុណ្ណោះ ។

ចប់អដ្ឋកថា ចាតិមោក្ខសូត្រទី ៦

# អ ដ្ឋ ក ថា

## ទុច្ចរិតសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុច្ចរិតសូត្រទី ៧ ។

[១៥៥] កាយសុចរិត និងវចីសុចរិត ជាបាតិមោក្ខសំវរៈសីល មនោ-សុចរិត ជាសីល ៣ ប្រភេទ ព្រោះហេតុនោះ ទើបជាចតុប្បារិសុទ្ធិសីល ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បានសម្ដែងទុកហើយ ។ ដោយន័យនេះ សូម្បីកម្មបថ ៣ ខាងក្រោយ ក្នុងកុសលកម្មបថ ១០ ក្នុងបបញ្ចសូត្រ និងក្នុង ៩ សូត្រទៀត ក៏គប្បីជ្រាបថា ជាសីលផងដែរ ។ ពាក្យដ៏សេសងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ទុច្ចរិតសូត្រទី ៧

## ចប់អមតវគ្គទី ៥

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា សមុទយសូត្រ ២ អដ្ឋកថា សតិសូត្រ
៣ អដ្ឋកថា បាតិមោក្ខសូត្រ ៤ អដ្ឋកថា ទុច្ចរិតសូត្រ

# ឥន្ទ្រិយសំយុត្ត

## សុទ្ធិកវគ្គទី ១

## អ ដ្ឋ ក ថា

### សុទ្ធិកសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុទ្ធិកសូត្រទី ១ នៃឥន្ទ្រិយសំយុត្ត ។*

*[១៦៦] ឥន្ទ្រិយសំយុត្ត សុទ្ធិកសូត្រទី ១ ។ ឥន្ទ្រិយ ៣ យ៉ាងនេះ គឺ **សទ្ធិន្ទ្រិយ សតិន្ទ្រិយ បញ្ញិន្ទ្រិយ** រមែងបានទាំងក្នុងកុសល និងវិបាក ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងក្នុងកិរិយា ។ **វិរិយិន្ទ្រិយ សមាធិន្ទ្រិយ** រមែងបានក្នុងចិត្តគ្រប់ជួង គឺ ក្នុងកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ក្នុងអកុសលវិបាក ក្នុងកិរិយា ។ គប្បីជ្រាបថា ព្រះសូត្រនេះ ព្រះមានព្រះភាគបានត្រាស់ដោយអំណាចការកំណត់ធម៌ ដែលរួមចូលទុកទាំងបួនភូមិ ។*

ចប់អដ្ឋកថា សុទ្ធិកសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយសមណព្រាហ្មណសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៧ ។

[១៧៣] ពាក្យថា **មិនដឹងច្បាស់សទ្ធិន្ទ្រិយ (សទ្ធិន្ទ្រិយំ នប្បជានន្តិ)** គឺ មិនដឹងច្បាស់ដោយអំណាចនៃទុក្ខសច្ច ។ ពាក្យថា **មិនដឹងច្បាស់នូវការកើតឡើងនៃសទ្ធិន្ទ្រិយ (សទ្ធិន្ទ្រិយសមុទយំ នប្បជានន្តិ)** គឺ មិនដឹងច្បាស់ដោយអំណាចសមុទយសច្ច ។ មិនដឹងច្បាស់នូវនិរោធ ដោយអំណាចនៃនិរោធសច្ច មិនដឹងច្បាស់ផ្លូវបដិបត្តិ ដោយអំណាចមគ្គសច្ច យ៉ាងនេះឯង ។ សូម្បីក្នុងពាក្យដ៏សេស ក៏មានន័យនេះឯង ។

ក្នុងចំណែកស ការកើតឡើងព្រមនៃសទ្ធិន្ទ្រិយ រមែងមានបានព្រោះការកើតឡើងព្រមនៃការពិចារណាដោយអំណាចអធិមោក្ខ (ការបង្អោនចិត្តជឿ) ។ ការកើតឡើងព្រមនៃវីរិយិន្ទ្រិយ រមែងមាន ព្រោះការកើតឡើងព្រមនៃការពិចារណាដោយអំណាចការផ្គងចិត្តទុក ការកើតឡើងព្រមនៃសតិន្ទ្រិយ រមែងមាន ព្រោះការកើតឡើងព្រមនៃការពិចារណាដោយអំណាចការចូលទៅតាំងចិត្ត (ការប្រាកដ) ការកើតឡើងព្រមនៃសមាធិន្ទ្រិយ រមែងមានព្រោះ

ការកើតឡើងព្រមនៃការពិចារណាដោយអំណាចសេចក្តីមិនវើវវាយ (មិនរាយមាយ) ការកើតឡើងព្រមនៃបញ្ញិន្ទ្រិយ រមែងមាន ព្រោះការកើតឡើងព្រមនៃការពិចារណាដោយអំណាចទស្សនៈ (ការឃើញ) ។

ម្យ៉ាងទៀត ការកើតឡើងព្រមនៃសទ្ធិន្ទ្រិយ រមែងមានបានដោយការកើតឡើងព្រមនៃការពិចារណាដោយអំណាចឆន្ទៈ (សេចក្តីពេញចិត្ត) ។ ការកើតឡើងព្រមនៃវិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ រមែងមានបានព្រោះការកើតឡើងព្រមនៃការពិចារណាដោយអំណាចឆន្ទៈ ។ ការកើតឡើងព្រមនៃសទ្ធិន្ទ្រិយ រមែងមានបានព្រោះការកើតឡើងព្រមនៃការពិចារណាដោយអំណាចមនសិការ (ការធ្វើទុកក្នុងចិត្ត) ។ ការកើតឡើងព្រមនៃវិរិយន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ រមែងមានបានព្រោះការកើតឡើងព្រមនៃការពិចារណាដោយអំណាចមនសិការ ។ គប្បីជ្រាបន័យ សូម្បីដោយប្រការដូច្នេះ ។ ក្នុង ៦ សូត្រតាមលំដាប់នេះ ព្រះដ៏មានព្រះភាគទ្រង់បានសម្តែងទាក់ទងជាមួយនឹងសច្ចៈបួនប្រការទុំះឯង ។

ចប់អដ្ឋកថា ទុតិយសមណព្រាហ្មណសូត្រទី ៧

# អ ដ្ឋ ក ថា

## ទដ្ឋព្វសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨ ។

[១៧៦] ពាក្យថា ម្នាលភិក្ខុទាំងឡាយ ក៏គប្បីឃើញសទ្ធិន្ទ្រិយក្នុងធម៌ណាហ្ន៎ ។ ក្នុងសោតាបត្តិយង្គៈ ៤ ប្រការ ដូច្នេះជាដើម (កត្ថ ច ភិក្ខវេ សទ្ធិន្ទ្រិយំ ទដ្ឋព្វំ ។ ចតូសុ សោតាបត្តិយង្គេសុ) ព្រះមានព្រះភាគ បានត្រាស់ទុក ដើម្បីទ្រង់បង្ហាញដល់ឥន្ទ្រិយទាំងនេះដែលសំខាន់បំផុត ក្នុងវិស័យ (អារម្មណ៍) របស់ខ្លួន ។

ដូចឧបមាថា សេដ្ឋីបុត្ត ៤ នាក់ មានសម្លាញ់ដែលជាព្រះរាជាធិរាជ ជាទី ៥ ធ្វើដំណើរតាមថ្នល់ ដោយគិតថា ពួកយើងនឹងលេងនក្ខត្តឫក្ស ដូច្នេះ វេលាទៅដល់ផ្ទះសេដ្ឋីបុត្តម្នាក់ ៤ នាក់ក្រៅពីនេះ ក៏អង្គុយស្ងៀម ។ ម្ចាស់ផ្ទះប៉ុណ្ណោះ ដែលបានបង្គាប់ការងារក្នុងផ្ទះថា “ចូរឲ្យរបស់ទំពារ របស់ស៊ី ដល់លោកទាំងនេះ ចូរឲ្យគ្រឿងតុបតែងខ្លួន មានគ្រឿងក្រអូប និងកម្រងផ្កាជាដើមដល់លោកទាំងនេះ” ។ លុះវេលាទៅដល់ផ្ទះអ្នកទី ២ ទី ៣ និងទី ៤ , ៤ នាក់ក្រៅពីនេះ ក៏អង្គុយស្ងៀម ។ ម្ចាស់របស់ផ្ទះប៉ុណ្ណោះ

ដែលបានបង្គាប់ការងារក្នុងផ្ទះថា “ចូរឲ្យរបស់ទំពារ របស់ស៊ី ដល់លោកទាំងនេះ ចូរឲ្យរបស់តុបតែងខ្លួន មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ដល់លោកទាំងនេះ” យ៉ាងណា ៗ ក៏ដូច្នោះដូច្នោះដូចគ្នា សូម្បីកាលឥន្ទ្រិយដែលមានសទ្ធាជាទី ៥ ដែលកើតឡើងក្នុងអារម្មណ៍តែមួយ ដូចកាលពួកសម្លាញ់ទាំងនោះ ចុះកាន់ថ្នល់ដើរទៅជាមួយគ្នា កាលទៅដល់សោតាបត្តិ-យង្គៈ (ចំណែកប្រកបនៃការដល់ក្រសែ) សទ្ធិន្ទ្រិយដែលមានការបង្អោនចិត្តជឿជាលក្ខណៈប៉ុណ្ណោះ រមែងជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសក្រៅពីនេះ ក៏បណ្តោយទៅតាមសទ្ធិន្ទ្រិយនោះ ដូចក្នុងផ្ទះរបស់អ្នកដំបូង ៤ នាក់ទៀត អន្តុយស្ងៀម ម្ចាស់ផ្ទះប៉ុណ្ណោះ ជាអ្នកចាត់ចែងការងារ ដូច្នោះ ៗ កាលមកដល់ព្យាយាមត្រូវ វិរិយិន្ទ្រិយ ដែលមានការផ្គងចិត្តជាលក្ខណៈប៉ុណ្ណោះ ជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសផ្សេងពីនោះ ក៏បណ្តោយទៅតាមវិរិយិន្ទ្រិយនោះ ដូចក្នុងផ្ទះអ្នកទី ២ , ៤ នាក់ទៀតអង្គុយស្ងៀម បណ្តោយឲ្យម្ចាស់របស់ផ្ទះប៉ុណ្ណោះចាត់ចែងការងារ ដូច្នោះ ៗ លុះមកដល់សតិប្បដ្ឋានសតិន្ទ្រិយដែលមានការចូលទៅប្រាកដជាលក្ខណៈ ប៉ុណ្ណោះ ដែលជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសក៏បណ្តោយទៅតាមសតិន្ទ្រិយនោះ ដូចក្នុងផ្ទះអ្នកទី ៣ , ៤ អ្នកទៀតអង្គុយស្ងៀម បណ្តោយឲ្យម្ចាស់ផ្ទះប៉ុណ្ណោះ ចាត់ចែង

ការងារ ដូច្នោះ ។ កាលដល់រឿងឈាន និងវិមោក្ខ សមាធិន្ទ្រិយដែលមាន លក្ខណៈមិនរវើរវាយប៉ុណ្ណោះ ជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសផ្សេងពី នេះ ក៏បណ្ដោយទៅតាមសមាធិន្ទ្រិយនោះ ដូចក្នុងផ្ទះអ្នកទី ៤ , ៤ នាក់ អន្ដុយស្ងៀម បណ្ដោយឲ្យម្ចាស់ប៉ុណ្ណោះ ចាត់ចែងកិច្ចការងារ ដូច្នោះ ។ តែចុងក្រោយ កាលដល់អរិយសច្ច បញ្ញិន្ទ្រិយដែលមានលក្ខណៈដឹងច្បាស់ ប៉ុណ្ណោះ រមែងជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសក៏បណ្ដោយទៅតាមបញ្ញិ-ន្ទ្រិយនោះ ដូចវេលាទៅដល់ព្រះរាជវាំង ៤ នាក់ក្រៅពីនេះ អន្ដុយស្ងៀម ព្រះរាជាប៉ុណ្ណោះ រមែងទ្រង់ចាត់ចែងការងារក្នុងព្រះតំណាក់ ដូច្នោះ ដោយ ប្រការដូច្នេះ ។

ចប់អដ្ឋកថា ឧដ្ឋសូត្រទី ៨

# អ ដ្ឋ ក ថា

## បឋមវិភង្គសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៩ ។*

*[១៩០] ក្នុងបទថា* ***សតិជាគ្រឿងរក្សាខ្លួន (សតិនេបក្កេន)*** *នេះ សំដៅដល់ ការកើត គឺ បញ្ញាជាគ្រឿងរក្សាខ្លួន ។ ពាក្យថា* ***បញ្ញាជាគ្រឿងរក្សាខ្លួន (នេបក្កំ)*** *នេះ ជាឈ្មោះរបស់បញ្ញា ។*

*សួរថា ហេតុដូចម្តេចព្រះមានព្រះភាគ ទើបទ្រង់ហៅបញ្ញា ក្នុងភាជនៈ (ទីទទួល) នៃសតិហ្ន៎? ។*

*ឆ្លើយថា ដើម្បីទ្រង់សម្តែងដល់សតិដែលមានកម្លាំង ពិតយ៉ាងនោះ ក្នុងទីនេះ ព្រះអង្គទ្រង់សំដៅយកតែសតិដែលមានកម្លាំងប៉ុណ្ណោះ ។ កាលនឹងទ្រង់សម្តែងដល់សតិដែលប្រកបដោយបញ្ញាថា "សតិដែលប្រកបដោយបញ្ញានោះ ជាសតិដែលមានកម្លាំង , ដែលមិនប្រកបដោយបញ្ញា រមែងមិនមានកម្លាំង ទើបបានត្រាស់យ៉ាងនេះ ។ ពាក្យថា* ***កិច្ចដែលត្រូវធ្វើទុកយូរហើយ (ចិរកតំ)*** *គឺ ទាន សីល ឬឧបោសថកម្ម ដែលបានធ្វើមកអស់កាលយូរហើយ ។ ពាក្យថា* ***ពាក្យដែលពោលទុកយូរហើយ (ចិរភាសិតំ)*** *សេចក្តីថា*

ក្នុងទីឯណោះ បានពោលពាក្យឈ្មោះឯណោះ ប៉ុណ្ណោះ ។ ពាក្យពោលដែលបុគ្គលគប្បីពោលក្នុងវេលាដែលយូរយ៉ាងនេះ ។

[១៩១] ប្រការថា *ធ្វើការបណ្តោយតាមអារម្មណ៍ (វោស្សគ្គារម្មណំ ករិត្វា)* គឺ ធ្វើនិព្វានជាអារម្មណ៍ ។

[១៩២] ពាក្យថា *គ្រឿងកំណត់ការកើត និង ការរលត់ (ឧទយត្ថគាមិនិយា)* គឺ ដល់ការកើតឡើង និងសេចក្តីរលត់ទៅ មានន័យថា កំណត់កាន់យកទាំងការកើតឡើង និងសេចក្តីវិនាសទៅ ។ ក្នុងសូត្រនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តែលោកុត្តរៈ ដែលឲ្យកើតសទ្ធិន្ទ្រិយ សតិន្ទ្រិយ បញ្ញិន្ទ្រិយ ដែលជាចំណែកខាងដើម និងសមាធិន្ទ្រិយដែលលាយជាមួយវិរិយិន្ទ្រិយទុកប៉ុណ្ណោះ ។

ចប់បឋមវិភង្គ សូត្រទី៩

## ចប់សុទ្ធិកវគ្គទី ១

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា សុទ្ធិកសូត្រ ២ អដ្ឋកថា ទុតិយព្រាហ្មណសូត្រ
៣ អដ្ឋកថា បឋមវិភង្គសូត្រ

# មុទុតរវគ្គទី ២

## អ ដ្ឋ ក ថា

### បដិលាភសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង បដិលាភសូត្រទី ១ ។*

[១៩៥] *ពាក្យថា ប្រារព្ធសម្មប្បធាន (សម្មប្បធានេ អារព្ភ) គឺ អាស្រ័យសេចក្តីព្យាយាមត្រូវ មានន័យថា ចម្រើនសេចក្តីព្យាយាមត្រូវ ។ សូម្បីក្នុងសតិន្ទ្រិយ ក៏ទំនងដូចគ្នានោះឯង ។*

ចប់អដ្ឋកថា បដិលាភសូត្រទី ១

# អ ដ្ឋ ក ថា

## បឋមសន្ទិដ្ឋសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង *បឋមសន្ទិដ្ឋសូត្រទី ២* ។

[២០០] ពាក្យថា ជាង...នោះ (តតោ) គឺ គប្បីជ្រាបសេចក្ដីលាយគ្នាដោយអំណាចវិបស្សនា មគ្គ និងផល ។ ពិតហើយ បញ្ញិន្ទ្រិយ ដែលបរិបូរពេញលេញហើយ រមែងឈ្មោះថា ជាវិបស្សនិន្ទ្រិយរបស់អរហត្តមគ្គ ។ ពាក្យថា ដែលទន់ខ្សោយជាង...នោះ (តតោ មុទុតរេហិ) គឺ ដែលទន់ខ្សោយជាងវិបស្សនិន្ទ្រិយរបស់អរហត្តមគ្គទាំងនោះ ឈ្មោះថា ជាវិបស្សនិន្ទ្រិយរបស់អនាគាមិមគ្គ ។ ដែលទន់ជាងនោះ ក៏ជារបស់សកទាគាមិមគ្គ ។ ដែលទន់ជាងនោះ ឈ្មោះថា ជាវិបស្សនិន្ទ្រិយរបស់សោតាបត្តិមគ្គ ។ ដែលទន់ជាងនោះ ក៏ជារបស់ធម្មានុសារិមគ្គ ។ ដែលទន់ជាងនោះ ឈ្មោះថា ជាវិបស្សនិន្ទ្រិយរបស់សទ្ធានុសារិមគ្គ ។

បញ្ញិន្ទ្រិយដែលបរិបូរពេញលេញយ៉ាងនោះ ឈ្មោះថា ជាឥន្ទ្រិយរបស់អរហត្តមគ្គ និងអរហត្តផល ។ ដែលទន់ជាងនោះ ឈ្មោះថា ជាឥន្ទ្រិយរបស់អនាគាមិមគ្គ សកទាគាមិមគ្គ និងសោតាបត្តិមគ្គ ។ ដែលទន់

ជាងនោះ ក៏ជារបស់ធម្មានុសារិមគ្គ ។ ដែលទន់ជាងនោះ ឈ្មោះថា ជាឥន្ទ្រិយរបស់សទ្ធានុសារិមគ្គ ។ ឥន្ទ្រិយទាំងប្រាំ ដែលបរិបូរពេញលេញ ឈ្មោះថា ជាឥន្ទ្រិយរបស់អរហត្តផល ។ ដែលទន់ជាងនោះ ក៏ជារបស់អនាគាមិផល ។ ដែលទន់ជាងនោះ ក៏ជារបស់សកទាគាមិផល ។ ដែលទន់ជាងនោះ ឈ្មោះថា ជាឥន្ទ្រិយរបស់សោតាបត្តិផល ។ ចំណែកធម្មានុសារី និងសទ្ធានុសារី សូម្បីទាំងពីរ ក៏គឺ បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ ដោយអំណាចនៃបុគ្គលដែលតាំងនៅក្នុងមគ្គហើយ នឹងជ្រាបសេចក្តីផ្សេងគ្នារបស់បុគ្គលទាំង ២ នោះបាន ព្រោះដោយការសម្រេចខ្លះដោយមគ្គខ្លះ ។ សទ្ធានុសារីបុគ្គល ដែលកំពុងឲ្យរៀនឧទ្ទេស សាកសួរហើយ រមែងសម្រេចមគ្គដោយលំដាប់ ។ ធម្មានុសារីបុគ្គល រមែងសម្រេចមគ្គដោយការស្តាប់ត្រឹមតែមួយដង ឬពីរដង ប៉ុណ្ណោះ គប្បីជ្រាបសេចក្តីប្លែកគ្នាក្នុងការសម្រេចរបស់ធម្មានុសារីបុគ្គល និងសទ្ធានុសារីបុគ្គលទាំងនោះយ៉ាងនេះ ។

សម្រាប់របស់ធម្មានុសារីបុគ្គល មគ្គជារបស់ខ្លាំងក្លា រមែងនាំទៅកាន់ញាណដែលក្លៀវក្លា រមែងកាត់កិលេស ដោយមិនត្រូវមានអ្នកណាមកដាស់តឿន មិនត្រូវប្រើសេចក្តីព្យាយាម ដូចប្រើកាំបិតដ៏មុតកាត់ដើមចេក

ដូច្នោះ ។ ចំណែកមគ្គរបស់សទ្ធានុសារីបុគ្គល មិនខ្លាំងក្លាដូចធម្មានុសារី-បុគ្គល មិននាំទៅកាន់ញាណដែលក្លៀវក្លា រមែងកាត់កិលេសដោយមិនត្រូវឲ្យអ្នកណាមកជាស់តឿន មិនត្រូវប្រើសេចក្តីព្យាយាម ដូចប្រើកាំបិតដែលមានមុខរិលកាត់ដើមចេក ដូច្នោះ ។ តែក្នុងរឿងអស់កិលេសហើយ លោកទាំងនោះ មិនមានសេចក្តីផ្សេងគ្នាឡើយ ។ និងពួកកិលេសដ៏សេស ក៏រមែងអស់ទៅ (ដូចគ្នា) ។

ចប់អដ្ឋកថា បឋមសន្និត្តសូត្រទី ២

# អ ដ្ឋ ក ថា

## ទុតិយសង្ខិត្តសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសង្ខិត្តសូត្រទី ៣ ។*

[២០២] *បទថា ជាង...នោះ (តតោ) គឺ គប្បីជ្រាបសេចក្តីលាយគ្នាដោយអំណាចផល ។ ពិតហើយ ឥន្ទ្រិយទាំងប្រាំដែលបរិបូរពេញលេញហើយ ក៏រមែងឈ្មោះថា ជាឥន្ទ្រិយរបស់អរហត្តផល ។ បុគ្គលដែលប្រកបដោយអរហត្តផល ឈ្មោះថា ជាព្រះអរហន្ត , ដែលទន់ជាងនោះ ក៏រមែងឈ្មោះថា ជាឥន្ទ្រិយរបស់អនាគាមិផល ។ល។ ដែលទន់ជាងនោះ ក៏ជាឥន្ទ្រិយរបស់សោតាបត្តិផល ។ បុគ្គលដែលប្រកបដោយសោតាបត្តិផលឈ្មោះថា ជាព្រះសោតាបន្ន ។ បទថា* ***សេចក្តីផ្សេងគ្នានៃផល រមែងមានព្រោះសេចក្តីផ្សេងគ្នានៃឥន្ទ្រិយ*** *(ឥន្ទ្រិយវេមត្តតា ផលវេមត្តតា ហោតិ) សេចក្តីថា សេចក្តីផ្សេងគ្នារបស់បុគ្គល រមែងមាន ព្រោះសេចក្តីផ្សេងគ្នានៃឥន្ទ្រិយ ព្រោះសេចក្តីផ្សេងគ្នានៃផល ។*

ចប់អដ្ឋកថា ទុតិយសង្ខិត្តសូត្រទី ៣

# អ ដ្ឋ ក ថា

## តតិយសន្ទិដ្ឋសុត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយសន្ទិដ្ឋសុត្រទី ៤ ។

[២០៤] ពាក្យថា អ្នកបំពេញអរហត្តមគ្គឲ្យបរិបូណ៌ រមែងបានអរហត្តផលបរិបូណ៌ (បរិបូរំ បរិបូរការី អារាធេតិ) គឺ អ្នកធ្វើអរហត្តមគ្គឲ្យបរិបូណ៌ រមែងសម្រេចអរហត្តផល ។ ពាក្យថា អ្នកបំពេញមគ្គ ៣ ដ៏សេសឲ្យបរិបូណ៌ ផល ៣ រមែងបរិបូណ៌ (បទេសំ បទេសការី) គឺ អ្នកធ្វើមគ្គចំណែកខ្លះដ៏សេស ៣ ទៀត ក៏រមែងសម្រេចផល ៣ ជាចំណែកខ្លះ ។

ក្នុង ៤ សូត្រនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងឥន្ទ្រិយលាយគ្នាដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា តតិយសន្ទិដ្ឋសុត្រទី ៤

# អ ដ្ឋ ក ថា

## បឋមវិត្ថារសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមវិត្ថារសូត្រទី ៥ ។*

[២០៦] *ពាក្យថា ព្រោះឥន្ទ្រិយ ៥ នៅទន់ជាង...នោះ (តតោ មុទុតរេហិ) គឺ គប្បីជ្រាបសេចក្ដីលាយគ្នាដោយអំណាចវិបស្សនា ។ ពិតហើយ ឥន្ទ្រិយទាំងប្រាំដែលពេញលេញហើយ រមែងជាវិបស្សនិន្ទ្រិយរបស់អរហត្តមគ្គ ។ ដែលទន់ជាងនោះ ជាវិបស្សនិន្ទ្រិយរបស់អន្តរាបរិនិព្វាយី ដែលទន់ជាងនោះ ក៏ជារបស់ឧបហច្ចបរិនិព្វាយី ដែលទន់ជាងនោះ ក៏ជារបស់អសង្ខារបរិនិព្វាយី ដែលទន់ជាងនោះ ក៏ជារបស់សសង្ខារបរិនិព្វាយី ។ ដែលទន់ជាងនោះ ក៏រមែងឈ្មោះថា ជាវិបស្សនិន្ទ្រិយរបស់ឧទ្ធំសោតោអកនិដ្ឋគាមី ។*

*មួយ៉ាងទៀត ក្នុងឋាន:នេះ គប្បីនាំចេញមកពីការលាយគ្នាទាំង ៥ យ៉ាង ដែលតាំងនៅក្នុងអរហត្តមគ្គប៉ុណ្ណោះ ។ គឺថា វិបស្សនិន្ទ្រិយរបស់អន្តរាបរិនិព្វាយីជាដំបូង ទន់ជាងវិបស្សនិន្ទ្រិយរបស់អរហត្តមគ្គ ដែលទន់ជាងនោះ ក៏ជារបស់អន្តរាបរិនិព្វាយីទីពីរ , ដែលទន់ជាងនោះ ក៏ជារបស់*

អន្តរាបរិនិព្វាយីទីបី , ដែលទន់ជាងនោះ ក៏ជារបស់ឧបហច្ចបរិនិព្វាយី , ដែលទន់ជាងនោះ ក៏ជាវិបស្សនិន្ទ្រិយរបស់ឧទ្ធំសោតោអកនិដ្ឋគាមី របស់អសង្ខារបរិនិព្វាយី និងរបស់សសង្ខារបរិនិព្វាយី ជនទាំង ៥ ពួកនេះឯង ។ ចំណែកសេចក្តីលាយគ្នា ៣ យ៉ាងទៀត ជាឥន្ទ្រិយរបស់សកទាគាមិមគ្គ ។

ចប់អដ្ឋកថា បឋមវិត្ថារសូត្រទី ៥

សូត្រទី ៦ និងទី ៧ មានន័យដូចលោកពោលទុកហើយនោះឯង ។ តែក្នុង ៣ សូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់បានសម្តែងវិបស្សនិន្ទ្រិយ ដែលជាចំណែកខាងដើមទុកប៉ុណ្ណោះ ។

# អ ដ្ឋ ក ថា

## បដិបន្នសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង បដិបន្នសូត្រទី ៨ ។*

[២១២] *ពាក្យថា* ***ព្រោះឥន្ទ្រិយ ៥ នៅទន់ជាង...នោះ*** *(តតោ មុទុតរេហិ) គឺ គប្បីជ្រាបសេចក្តីលាយគ្នាដោយអំណាចមគ្គ និងផលទាំងឡាយ ។ សេចក្តីលាយគ្នានោះ ព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ទុកក្នុងបាលីស្រេចហើយ ។ ពាក្យថា* ***ជាបុគ្គលខាងក្រៅ*** *(ពាហិរោ) គឺ ជាបុគ្គលដែលក្រៅពីបុគ្គលទាំង ៨ ពួកនេះ ។ ពាក្យថា* ***តាំងនៅក្នុងចំណែកជាបុថុជ្ជន*** *(បុថុជ្ជនបក្ខេ ឋិតោ) គឺ តាំងនៅក្នុងចំណែកនៃបុគ្គលដែលមានកិលេសក្រាស់ ។ ក្នុងសូត្រនេះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងតែឥន្ទ្រិយដែលជាលោកុត្តរៈប៉ុណ្ណោះ ។*

ចប់អដ្ឋកថា បដិបន្នសូត្រទី ៨

# អ ដ្ឋ ក ថា

## ឧបសមសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបសមសូត្រទី ៩ ។*

[២១៣] *ពាក្យថា អ្នកដល់ព្រមដោយឥន្ទ្រិយ (ឥន្ទ្រិយសម្បន្នោ) គឺ បុគ្គលអ្នកបរិបូណ៌ដោយឥន្ទ្រិយ ។*

ចប់អដ្ឋកថា ឧបសមសូត្រទី៩

# អ ដ្ឋ ក ថា

## អាសវក្ខយសូត្រទី ១០

[២១៦] *គប្បីជ្រាបវិនិច្ឆ័យក្នុង អាសវក្ខយសូត្រទី ១០ ងាយទាំងនោះ ឯង ។ ក្នុង ២ សូត្រនេះ (សូត្រទី ៩-១០) ព្រះដ៏មានព្រះភាគទ្រង់សម្តែងឥន្ទ្រិយ លាយគ្នា ។*

ចប់អដ្ឋកថា អាសវក្ខយសូត្រទី ១០

## ចប់មុទុតរវគ្គទី ២

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា បដិលាភសូត្រ
២ អដ្ឋកថា បឋមសង្ខិត្តសូត្រ
៣ អដ្ឋកថា ទុតិយសង្ខិត្តសូត្រ
៤ អដ្ឋកថា តតិយសង្ខិត្តសូត្រ
៥ អដ្ឋកថា បឋមវិត្ថារសូត្រ
៦ អដ្ឋកថា បដិបន្នសូត្រ
៧ អដ្ឋកថា ឧបសមសូត្រ
៨ អដ្ឋកថា អាសវក្ខយសូត្រ

# ឥន្ទ្រិយវគ្គទី ៣

## អ ដ្ឋ ក ថា

## ជីវិតិន្ទ្រិយសុត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង សូត្រទី ២ នៃតតិយវគ្គក្នុងឥន្ទ្រិយវគ្គ ។*

[២២០] *ក្នុងពាក្យជាដើមថា* ***ឥត្ថិន្ទ្រិយ*** *គប្បីជ្រាបវិគ្រោះដូចតទៅនេះ ។ ដែលឈ្មោះថា* ***ឥត្ថិន្ទ្រិយ*** *ព្រោះរមែងធ្វើអត្ថថា ធំក្នុងភាពជាស្ត្រី ។ ដែលឈ្មោះថា* ***បុរិសិន្ទ្រិយ*** *ព្រោះរមែងធ្វើអត្ថថា ធំក្នុងភាពជាបុរស ។ ដែលឈ្មោះថា* ***ជីវិតិន្ទ្រិយ*** *ព្រោះរមែងធ្វើអត្ថថា ធំក្នុងភាពរស់នៅ ។ បានឮមកថា ព្រះសូត្រនេះ មានហេតុកើតនៃអត្ថថា ក៏ក្នុងកណ្ដាលសង្ឃ កើតពាក្យថា ឥន្ទ្រិយដែលជាវដ្ដៈមានប៉ុន្មានហ្ន៎ ។ លំដាប់នោះ កាលព្រះមាន-ព្រះភាគទ្រង់ជ្រាបឥន្ទ្រិយដែលជាវដ្ដៈហើយ ទើបត្រាស់ពាក្យជាដើមថា* ***ភិក្ខុទាំងឡាយ ឥន្ទ្រិយទាំង ៣ នេះ ។***

ចប់អដ្ឋកថា ជីវិតិន្ទ្រិយសូត្រទី ២

# អ ដ្ឋ ក ថា

## អញ្ញាតាវិន្ទ្រិយសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៣ ។

[២២១] ឥន្ទ្រិយដែលកើតឡើងក្នុងខណៈនៃសោតាបត្តិមគ្គរបស់អ្នកបដិបត្តិ ដែលគិតថា យើងនឹងដឹងធម៌ដែលមិនធ្លាប់បានដឹងក្នុងសង្សារ ដែលមានទីបំផុតខាងដើមមិនមាននរណាដឹងបាន ឈ្មោះថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ** ។ ឥន្ទ្រិយដែលកើតឡើងក្នុងឋានៈទាំង ៦ មានសោតាបត្តិផលជាដើម ដោយអាការត្រាស់ដឹងធម៌ដែលខ្លួនមិនទាន់បានដឹងនោះឯង ឈ្មោះថា **អញ្ញិន្ទ្រិយ** ។ ដែលឈ្មោះថា **អញ្ញាតាវិន្ទ្រិយ** បានដល់ ឥន្ទ្រិយដែលកើតឡើងក្នុងធម៌ទាំងឡាយក្នុងអរហត្តផល ដែលខ្លួនមិនទាន់ដឹងអំពីមុន ។ ពាក្យថា ឥន្ទ្រិយនេះ ជាឈ្មោះរបស់ញាណដែលកើតឡើង ដោយអាការនោះៗ ក្នុងមគ្គផលនោះៗ ។ សូម្បីសូត្រនេះ ក៏មានហេតុកើតឡើងនៃអត្ថដូចគ្នា គឺ ក្នុងកណ្តាលសង្ឃកើតពាក្យឡើងថា **ឥន្ទ្រិយ** ដែលជាលោកុត្តរៈ មានប៉ុន្មានហ្ន៎ ។ លំដាប់នោះ កាលព្រះដ៏មានព្រះភាគទ្រង់នឹងសម្តែងឥន្ទ្រិយទាំងនោះ ទើបត្រាស់ពាក្យជាដើមថា ភិក្ខុទាំងឡាយ ឥន្ទ្រិយទាំង ៣ យ៉ាង

*នេះ ដូច្នេះ ។*

ចប់អដ្ឋកថា អញ្ញាតាវិន្ទ្រិយសូត្រទី ៣

# អ ដ្ឋ ក ថា

## ឯកាភិញ្ញាសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៤ ដូចតទៅ ។

[២២៣] គប្បីជ្រាបសេចក្តីលាយគ្នាដោយវិបស្សនា ដោយពាក្យថា ព្រោះឥន្ទ្រិយ ៥ នៅទន់ជាង...នោះ (តតោ មុទុតរេហិ) គឺ ឥន្ទ្រិយទាំង ៥ ដែលបរិបូណ៌ហើយ ក៏រមែងឈ្មោះថា វិបស្សនិន្ទ្រិយរបស់អរហត្តមគ្គ ។ ដែលទន់ជាងនោះ ជាវិបស្សនិន្ទ្រិយរបស់អន្តរាបរិនិព្វាយី ។ល។ ឈ្មោះថា ជាវិបស្សនិន្ទ្រិយរបស់ឧទ្ធំសោតោអកនិដ្ឋគាមី ។ សូម្បីក្នុងឋានៈនេះ ក៏គប្បីនាំយកអំពីសេចក្តីលាយគ្នាទាំង ៥ យ៉ាង ដែលតាំងនៅក្នុងអរហត្តមគ្គចេញតាមន័យមុនដូចគ្នា ។ និងក្នុងទីនេះ ត្រូវនាំយកសេចក្តីលាយគ្នា ៥ យ៉ាងចេញមក ដូចដែលតាំងនៅក្នុងសកទាគាមិមគ្គ ត្រូវនាំយកសេចក្តីលាយគ្នា ៣ យ៉ាងចេញមក តាមន័យមុននុ៎ះឯង ។ ក៏វិបស្សនិន្ទ្រិយនៃសោតាបត្តិមគ្គ ទន់ជាងវិបស្សនិន្ទ្រិយរបស់សកទាគាមិមគ្គ និងវិបស្សនិន្ទ្រិយនៃមគ្គរបស់ឯកពីជីជាដើម ក៏ទន់ជាងវិបស្សនិន្ទ្រិយទាំងនោះ របស់សោតាបត្តិមគ្គ ។ គប្បីជ្រាបវិនិច្ឆ័យក្នុង ពាក្យថា ឯកពីជី (មានពូជមួយ)

តទៅ ។ បុគ្គលណាបានជាព្រះសោតាបន្នហើយ លះត្រឹមតែមួយអត្តភាព ប៉ុណ្ណោះ ហើយសម្រេចជាព្រះអរហន្ត បុគ្គលនេះឈ្មោះ **ឯកពីជី** ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ៖

ក៏ **ឯកពីជីបុគ្គល** ដូចម្តេច បុគ្គលខ្លះក្នុងលោកនេះ ព្រោះសញ្ញោជនៈ ៣ អស់ទៅ ទើបជាព្រះសោតាបន្ន ដែលមិនមានការធ្លាក់ចុះជាធម្មតា ទៀងតែនឹងត្រាស់ដឹង ត្រាច់ទៅកាន់ភពមនុស្សម្តងទៀតប៉ុណ្ណោះ ហើយក៏នឹងធ្វើទីបំផុតនៃទុក្ខបាន បុគ្គលនេះហៅថា **ឯកពីជី** ។

ចំណែកបុគ្គលណា ត្រាច់ទៅ ២-៣ ភព ទើបនឹងធ្វើទីបំផុតទុក្ខបាន បុគ្គលនេះឈ្មោះ **កោលង្កោលៈ** (អ្នកចេញចាកត្រកូលទៅកាន់ត្រកូល) ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ៖

ក៏ "**កោលង្កោលបុគ្គល** ដូចម្តេច" បុគ្គលខ្លះក្នុងលោកនេះ ព្រោះសញ្ញោជនៈ ៣ អស់ទៅ ទើបជាព្រះសោតាបន្ន ដែលមិនមានការធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង មានមុខឆ្ពោះទៅកាន់ការត្រាស់ដឹង គេត្រាច់ទៅកាន់ពីរ ឬបីត្រកូលទៀត ទើបនឹងធ្វើទីបំផុតនៃទុក្ខបាន បុគ្គលនេះហៅថា **កោលង្កោលៈ** ។

គប្បីជ្រាបថា **ត្រកូល** ក្នុងព្រះពុទ្ធតម្រាស់នោះ បានដល់ ភព ។

និងពាក្យថា ពីរ ឬបីនេះ ត្រឹមតែជាការសម្ដែងក្នុងទីនេះប៉ុណ្ណោះ ព្រោះបុគ្គលត្រាច់ទៅដរាបដល់ភពទី ៦ ក៏នៅតែជាកោលង្កោលៈនុ៎ះឯង ។

បុគ្គលដែលកើតឡើងយ៉ាងច្រើនត្រឹមតែ ៧ ដង មិនកាន់យកភពទី ៨ នេះឈ្មោះ **សត្តក្ខត្តុបរមៈ** (មាន ៧ ដងជាយ៉ាងក្រៃលែង) សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា

ក៏ **សត្តក្ខត្តុបរមបុគ្គល** ដូចម្ដេច? បុគ្គលខ្លះក្នុងលោកនេះ ព្រោះសញ្ញោជនៈ ៣ អស់ទៅ ទើបជាព្រះសោតាបន្ន ដែលមិនមានការធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងប្រាកដតែនឹងត្រាស់ដឹង លោកត្រាច់ទៅកាន់ទេវលោក និងមនុស្ស ៧ ដងទៀត ទើបនឹងធ្វើទីបំផុតនៃទុក្ខបាន បុគ្គលនេះហៅថា **សត្តក្ខត្តុបរមៈ** ។

ក៏ឋានៈរបស់លោកទាំងនោះ រមែងមានដោយអំណាចឈ្មោះ ដែលព្រះដ៏មានព្រះភាគទ្រង់កាន់យកហើយ គឺ ព្រះដ៏មានព្រះភាគទ្រង់កាន់យកឈ្មោះរបស់លោកទាំងនេះថា បុគ្គលចូលដល់ឋានៈប៉ុណ្ណេះ ជាឯកពីជីប៉ុណ្ណេះជាកោលង្កោលៈ ប៉ុណ្ណេះជាសត្តក្ខត្តុបរមៈ ។ ចំណែកទីកំណត់ស្ទាប់ថា នេះជាឯកពីជី នេះជាកោលង្កោលៈ នេះជាសត្តខត្តុបរមៈ មិនមាន ។

សួរថា ក៏នរណាកំណត់ប្រភេទប៉ុណ្ណេះប៉ុណ្ណោះរបស់លោកទាំងនោះ ។

ឆ្លើយថា ក៏ព្រះថេរៈខ្លះ លោកពោលថា **បុព្វហេតុ** ជាការកំណត់ ខ្លះក៏ថា បឋមមគ្គ ខ្លះក៏ថា មគ្គ ៣ ខាងលើ ខ្លះក៏ថា វិបស្សនានៃមគ្គទាំង ៣ ជាការកំណត់ ។ ក្នុងវាទៈដែលថា បុព្វហេតុ ជាការកំណត់នោះ ដូច្នេះ ឧបនិស្ស័យនៃបឋមមគ្គ រមែងឈ្មោះថា ជាការលោកបានធ្វើទុកហើយ ។ រមែងត្រូវគ្នានឹងពាក្យថា មគ្គ ៣ ខាងលើ ក៏ជាឧបនិស្ស័យដែលកើតហើយ ។ ក្នុងវាទៈដែលថា **បឋមមគ្គ** ជាការកំណត់ ដូច្នេះ ក៏ជាប់ទាក់ទងជាមួយប្រការដែលថា មគ្គ ៣ ខាងលើ រកប្រយោជន៍អ្វីមិនបាន ។ ក្នុងវាទៈដែលថា **មគ្គ ៣ ខាងលើ** ជាការកំណត់ ក៏នឹងទៅត្រូវគ្នាជាមួយប្រការថា កាលបឋមមគ្គមិនទាន់កើតឡើង មគ្គ ៣ ខាងលើ ក៏កើតឡើងហើយ ។ ចំណែកវាទៈដែលថា **វិបស្សនានៃមគ្គទាំងបី** រមែងជាការកំណត់ ក៏ត្រូវ ។ ព្រោះថា ប្រសិនបើវិបស្សនានៃបីមគ្គខាងលើមានកម្លាំង ក៏ឈ្មោះថា ជាឯកពីជី ។ ដែលទន់ខ្សោយជាងនោះ ក៏ជាកោលង្កោលៈ , ដែលទន់ខ្សោយជាងនោះទៀត ក៏ជាសត្តក្ខត្តុបរមៈ ដោយប្រការដូច្នេះ ។

ពិតណាស់ ព្រះសោតាបន្នខ្លះ លោកនៅមានអជ្ឈាស្រ័យក្នុងវដ្តៈ ពេញចិត្តវដ្តៈ ទើបត្រាច់ទៅក្នុងវដ្តៈនុ៎ះឯងរឿយៗ ។ អនាថបិណ្ឌិកសេដ្ឋី វិសាខាឧបាសិកា ចូឡរថទេវបុត្រ មហារថទេវបុត្រ អនេកវណ្ណទេវបុត្រ

ស្តេចសក្កទេវរាជ នាគទត្តទេវបុត្រ លោកទាំងនេះប៉ុណ្ណោះឯង នៅមានអជ្ឈាស្រ័យក្នុងវដ្ដៈ ចូលចិត្តវដ្ដៈ ត្រូវពិចារណាទេវលោក ៦ ជាន់តាំងពីដើម ហើយតាំងនៅក្នុងជាន់អកនិដ្ឋព្រហ្មលោក ទើបនឹងបរិនិព្វាន លោកទាំងនេះ មិនកាន់យកក្នុងករណីនេះ ។ មិនមែនតែលោកទាំងនេះប៉ុណ្ណោះ អ្នកដែលត្រាច់នៅក្នុងមនុស្សប៉ុណ្ណោះ គ្រប់ ៧ ដងហើយ ទើបសម្រេចជាព្រះអរហន្តក្តី ។ អ្នកដែលកើតក្នុងទេវលោកហើយ ត្រាច់ទៅត្រាច់មកអំពីទេវលោកប៉ុណ្ណោះ ដរាបដល់គ្រប់ ៧ ដងហើយ ទើបនឹងសម្រេចជាព្រះ-អរហន្តក្តី សូម្បីលោកទាំងនេះ ក៏មិនកាន់យកក្នុងទីនេះ ។ តែក្នុងទីនេះកាន់យកតែបុគ្គលពេលខ្លះក៏ត្រាច់ទៅក្នុងមនុស្ស ពេលខ្លះក៏ក្នុងទេវតា ហើយសម្រេចជាព្រះអរហន្តប៉ុណ្ណោះ ។ ព្រោះដូច្នោះ ពាក្យថា សត្តក្ខត្តុបរមៈ នេះ គប្បីជ្រាបថា ក្នុងទីនេះទ្រង់សម្តែងឈ្មោះរបស់ព្រះសោតាបន្នប្រភេទសុក្ខវិបស្សកៈ ដែលលាយគ្នានៅក្នុងព្រះអរិយបុគ្គលទាំង ៨ ពួក ។

ចំពោះក្នុងបទថា **ធម្មានុសារី** (អ្នកប្រព្រឹត្តទៅតាមធម៌) **សទ្ធានុសារី** (អ្នកប្រព្រឹត្តទៅតាមសេចក្តីជឿ) នេះ មានន័យថា ក្នុងសាសនានេះ មានធុរៈពីរយ៉ាង គឺ សទ្ធាធុរៈ បញ្ញាធុរៈ , មានសេចក្តីតាំងមាំពីរយ៉ាង គឺ តាំងមាំក្នុងសទ្ធា តាំងមាំក្នុងបញ្ញា ចំពោះបុគ្គលដែលនឹងឲ្យលោកុត្តរធម៌កើត

ឡើង ។ ក្នុងធុរៈ និងសេចក្ដីតាំងមាំនោះ ភិក្ខុណា បើអាចឲ្យកើតឡើងដោយសទ្ធាបាន ហើយធ្វើសទ្ធាធុរៈថា យើងនឹងឲ្យលោកុត្តរធម៌កើតឡើង ហើយញ៉ាំងសោតាបត្តិមគ្គឲ្យកើតឡើងមកបាន ភិក្ខុនោះ រមែងជាអ្នកឈ្មោះថា **សទ្ធានុសារី** (អ្នកប្រព្រឹត្តទៅតាមសេចក្ដីជឿ) ក្នុងខណៈនៃមគ្គ ។ ឯក្នុងខណៈនៃផល ក៏ឈ្មោះថា **សទ្ធាវិមុត្តិ** (ជាអ្នករួចផុតដោយសេចក្ដីជឿ) បែងចែកជាបីពួក គឺ ឯកពីជី (អ្នកកើតម្ដងទៀត) កោលង្កោលៈ អ្នកចាកពីត្រកូលកាន់ត្រកូល) សត្តក្ខត្តុបរមៈ (បុគ្គលដែលច្រើនក៏ត្រឹម ៧ ជាតិ) ។ ក្នុងបុគ្គលទាំងនេះ បុគ្គលតែមួយ រមែងបានបួនពួកដោយអំណាចនៃទុក្ខាបដិបទាជាដើម ដូច្នោះ ដោយសទ្ធាធុរៈ ទើបមាន ១២ ពួក ។ ចំណែកភិក្ខុណា បើអាចឲ្យកើតដោយបញ្ញាបាន ហើយធ្វើបញ្ញាធុរៈថា យើងនឹងឲ្យលោកុត្តរមគ្គកើតឡើង ហើយញ៉ាំងសោតាបត្តិមគ្គឲ្យកើតឡើងបាន ភិក្ខុនោះ ក្នុងខណៈនៃមគ្គ រមែងជាអ្នកឈ្មោះថា **ធម្មានុសារី** (អ្នកប្រព្រឹត្តទៅតាមធម៌) ។ ចំណែកក្នុងខណៈនៃផល ក៏ឈ្មោះថា **បញ្ញាវិមុត្ត** (ជាអ្នករួចផុតដោយការដឹងច្បាស់) ដែលចែកជា ១២ ពួក ផ្សេងដោយព្រះអរិយបុគ្គល មានឯកពីជីជាដើម ដោយប្រការដូច្នេះ ។ ព្រះសោតាបន្នដែលតាំងនៅក្នុងមគ្គ ២ ក៏រួមជា ២៤ ពួក ក្នុងខណៈនៃផល ។

បានឮមកថា ព្រះតិស្សត្ថេរ លោកជំនាញព្រះត្រៃបិដក គិតថា យើងនឹងជម្រះបិដកទាំងបី ទើបទៅកាន់ត្រើយដទៃ ។ មានកុដុម្ពីម្នាក់ ទំនុកបម្រុងលោកដោយបច្ច័យ ៤ ។ ព្រះថេរៈពោលថា "ឧបាសក យើងនឹងទៅក្នុងវេលាមកដល់" ។

កុដុម្ពី, ទីណា លោកម្ចាស់ ។

ថេរៈ, សម្នាក់អាចារ្យ និងឧបជ្ឈាយ៍របស់អាត្មា ។

កុដុម្ពី, ខ្ញុំទៅផងមិនបានទេឬ លោកម្ចាស់ ក៏ខ្ញុំដឹងគុណព្រះសាសនាបាន ក៏ព្រោះអាស្រ័យគុណលោកម្ចាស់ ក្រៅពីលោកម្ចាស់ហើយ ខ្ញុំនឹងទៅរកភិក្ខុបែបណាបាន ។

លំដាប់នោះ ព្រះថេរៈបានប្រាប់គេថា "ភិក្ខុណាដែលអាចដើម្បីនឹងបង្អុលព្រះសោតាបន្ន ២៤ ពួក ព្រះសកទាគាមី ១២ ពួក ព្រះអនាគាមី ៤៨ ពួក ព្រះអរហន្ត ១២ ពួក ហើយសម្តែងធម៌បាន ឧបាសកគួរទំនុកបម្រុងភិក្ខុបែបនោះចុះ" ។ ដូចដែលពោលមកនេះ ទើបក្នុងព្រះសូត្រនេះ ព្រះអង្គទ្រង់បានសម្តែងវិបស្សនាទុក ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ឯកាភិញ្ញាសូត្រទី ៤

# អ ដ្ឋ ក ថា

## សុទ្ធកសូត្រទី ៥ ជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុង សូត្រទី ៥ ។

[២២៥] ចក្ខុ និងធម៌ដែលឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ជំ គឺ ជាអធិបតីរបស់ធម៌ទាំងឡាយ ដែលកើតក្នុងចក្ខុទ្វារនោះ ឈ្មោះថា ចក្ខុន្ទ្រិយ ។ សូម្បីក្នុងសោតិន្ទ្រិយជាដើម ក៏មានន័យដូចគ្នានេះឯង ។ ពាក្យដ៏សេសគ្រប់កន្លែង ងាយទាំងអស់នោះឯង ។ សូត្រទាំង ៦ សូត្រ គឺ សូត្រទី ១ ក្នុងវគ្គនេះ និង ៥ សូត្រទៀត មានសូត្រទី ៦ ជាដើម ព្រះដ៏មានព្រះភាគទ្រង់បានសម្តែងដោយអំណាចសច្ចៈ ៤ នោះឯង ។

ចប់អដ្ឋកថា សុទ្ធកសូត្រទី ៥ ជាដើម

### ចប់ឆឡិន្ទ្រិយវគ្គទី ៣

### រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា ជីវិតិន្ទ្រិយសូត្រ
២ អដ្ឋកថា អញ្ញាតាវិន្ទ្រិយសូត្រ
៣ អដ្ឋកថា ឯកាភិញ្ញាសូត្រ
៤ អដ្ឋកថា សុទ្ធកសូត្រ

# សុខិន្ទ្រិយវគ្គទី ៤

## អ ដ្ឋ ក ថា

### សុទ្ធកសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុទ្ធកសូត្រទី ១ នៃសុខិន្ទ្រិយវគ្គទី ៤ ។*

[២៣៧] *សេចក្តីសុខ និងជាឥន្ទ្រិយ ព្រោះអត្ថថា ជំ ពោលគឺ ជាអធិបតីនៃធម៌ទាំងឡាយដែលកើតរួមគ្នានោះ ព្រោះហេតុនោះ ទើបឈ្មោះថា សុខិន្ទ្រិយ ។ សូម្បីក្នុងទុក្ខិន្ទ្រិយជាដើម ក៏ន័យនេះឯង និងក្នុងឥន្ទ្រិយទាំងនោះ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ និងទោមនស្សិន្ទ្រិយ ជាកាមាវចរៈតែម្យ៉ាង រូបាវចរៈ អរូបាវចរៈ វៀរសោមនស្សិន្ទ្រិយ ដ៏សេសប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ឧបេក្ខិន្ទ្រិយ ប្រព្រឹត្តទៅក្នុងភូមិ ៤ ។*

ចប់អដ្ឋកថា សុទ្ធកសូត្រទី ១

# អ ដ្ឋ ក ថា

## សោតាបន្នសូត្រទី ២ ជាដើម

[២៣៩] ៤ សូត្រ មានសូត្រទី ២ ជាដើម ព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយអំណាចសច្ចៈ ៤ តែម្យ៉ាង ៗ

ចប់អដ្ឋកថា សោតាបន្នសូត្រទី ២ ជាដើម

# អ ដ្ឋ ក ថា

## បឋមវិភង្គសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមវិភង្គសូត្រទី ៦** ។*

*[២៤៩] បទថា **ផ្លូវកាយ** (កាយិកំ) បានដល់ សុខដែលមានកាយ-បសាទជាទីតាំង ។ នេះជាពាក្យសម្តែងសរុបរបស់បទថា សុខ នោះឯង ។ បទថា **សេចក្តីត្រេកអរ** (សាតំ) ក៏ជាពាក្យប្រើជំនួសបទថា សុខ នោះឯង ។ មានអធិប្បាយថា ឆ្ងាញ់ពិសារ ។ បទថា **កើតពីកាយសម្ផ័ស្ស** (កាយ-សម្ផស្សជំ) សេចក្តីថា សេចក្តីសុខ សេចក្តីត្រេកអរ ដែលកើតពីកាយ-សម្ផ័ស្ស ។ បទថា **សេចក្តីសុខ សេចក្តីត្រេកអរ** (សុខំ សាតំ) មានន័យដូចបានពោលហើយនោះឯង ។ បទថា **វេទនា** (វេទយិតំ) នេះ ជាពាក្យសម្តែងសភាវៈដែលវិសេសរបស់ធម៌ប្រការដទៃពីវេទនា ដែលទូទៅទាំងអស់នៃសុខនោះ ។ សូម្បីក្នុងប្រការដ៏សេសទាំងឡាយ ក៏គប្បីជ្រាបន័យតាមនេះ ។*

*[២៥៣] ចំណែកក្នុងបទថា **ផ្លូវកាយ ឬផ្លូវចិត្ត** (កាយិកំ វា ចេតសិកំ វា) នេះ លោកពោលថា ផ្លូវកាយ ដោយអំណាចការកើតឡើង*

*ព្រោះធ្វើកាយបសាទទាំង ៤ មានភ្នែកជាដើម ឲ្យជាទីតាំង ។ ចំណែកដែលឈ្មោះថា អទុក្ខមសុខ ដែលមានកាយបសាទជាទីតាំង មិនមាន ។*

ចប់អដ្ឋកថា បឋមវិភង្គសូត្រទី ៦

# អដ្ឋកថា

## អរហន្តសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង **អរហន្តសូត្រទី ៩** ។*

*[២៧៨] ពាក្យថា **ឈើ ២ កំណាត់ (ទ្វិន្នំ កដ្ឋានំ)** បានដល់នៃឈើពួតភ្លើង ២ កំណាត់ ។ ពាក្យថា **ពួតគ្នា (សង្ឃដ្ដនសមោធានា)** បានដល់ ដោយការពួត និងដោយការប្រជុំចូលជាមួយគ្នា ។ ពាក្យថា **កំដៅ (ឧស្មា)** គឺ បង្កើតភាពក្តៅ ។ ពាក្យ **ភ្លើង (តេជោ)** គឺ ចំហាយភ្លើង ។ម្យ៉ាងទៀត ក្នុងពាក្យថា **តេជោ** នេះ គប្បីឃើញថា អារម្មណ៍ដែលប្រព្រឹត្តទៅ ដូចឈើពួតភ្លើងខាងក្រោម , ផស្សៈ ដូចឈើពួតភ្លើងខាងលើ , ការពួតរបស់ផស្សៈ ដូចការពួត (របស់ឈើពួត) , វេទនា ដូចភ្លើង ។ ឬគប្បីឃើញថា អារម្មណ៍ដែលប្រព្រឹត្តទៅ ដូចឈើពួតភ្លើងខាងលើ , ផស្សៈ ដូចឈើពួតភ្លើងខាងក្រោម ។*

ចប់អដ្ឋកថា អរហន្តសូត្រទី៩

# អ ដ្ឋ ក ថា

## ឧប្បដិកសុត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧប្បដិកសូត្រទី ១០ ។

[២៨០] យថាធម្មទេសនាដែលមិនចាំបាច់សម្តែង គប្បីជ្រាបថា ឈ្មោះថា ជាសូត្រដែលផុតចាកលំដាប់ (មិនចូលលំដាប់) ដូចយ៉ាងសូត្រដ៏សេសក្នុងឥន្ទ្រិយវិភង្គ សូម្បីដែលពោលហើយ តាមលំដាប់នេះ ។

ក្នុងសូត្រទី ១០ នោះ ពាក្យទាំងអស់ជាដើមថា **និមិត្ត (និមិត្តំ)** ជាពាក្យប្រើជំនួសបច្ច័យនុ៎ះឯង ។ ពាក្យថា **រមែងដឹងច្បាស់ទុក្ខិន្ទ្រិយ (ទុក្ខិន្ទ្រិយញ្ច បជានាតិ)** គឺ រមែងដឹងដោយអំណាចទុក្ខសច្ចៈនោះឯង ។ បទថា **ការកើតឡើងនៃទុក្ខន្ទ្រិយ (ទុក្ខិន្ទ្រិយសមុទយំ)** គឺ វិញ្ញាណដែលសហគតៈដោយទុក្ខ រមែងកើតឡើងដល់បុគ្គលដែលត្រូវបន្ទាមុតនោះឯង ត្រូវសង្កើចខាំ ឬត្រូវស្នាមជ្រួញនៃសំពត់ក្រាលដេកប៉ះខ្ទប់ រមែងដឹងច្បាស់វត្ថុនោះថា ជាហេតុឲ្យកើតឡើង (សមុទ័យ) របស់ទុក្ខិន្ទ្រិយនោះ ។

[២៨១] គប្បីជ្រាបសមុទ័យ ដោយអំណាចហេតុនៃឥន្ទ្រិយទាំងនោះ សូម្បីក្នុងបទជាដើមថា **ការកើតឡើងនៃទោមនស្សិន្ទ្រិយ (ទោមនស្សិន្ទ្រិយ-**

សមុទយំ) ខាងមុខ ។ ទោមនស្សិន្ទ្រិយ រមែងកើតឡើងដោយអំណាចសេចក្តីវិនាសនៃសង្ខារខាងក្រៅ មានបាត្រ និងចីវរជាដើម ឬនៃពួកសត្វមានសទ្ធិវិហារិកជាដើម ដោយប្រការដូច្នេះ ។ រមែងដឹងច្បាស់សេចក្តីវិនាសនៃសង្ខារ និងសត្វទាំងនោះថា ជាហេតុឲ្យកើតឡើងនៃទោមនស្សិន្ទ្រិយនោះ ។ បុគ្គលដែលបរិភោគអាហារយ៉ាងល្អហើយ ដេកលើទីដេកដ៏ប្រសើរ រមែងកើតសុខិន្ទ្រិយឡើងដោយការសម្ផស្ស មានការគក់ប្របាច់ដៃ និងជើង និងខ្យល់ដែលកើតអំពីផ្ចិតស្លឹកត្នោតជាដើម រមែងដឹងច្បាស់ផស្សៈនោះថា ជាហេតុរបស់សុខិន្ទ្រិយនោះ ។ ចំណែកសោមនស្សិន្ទ្រិយ ដែលកើតឡើងដោយអំណាចការបានចំពោះនូវសត្វ និងសង្ខារដែលគួរពេញចិត្ត មានប្រការដូចពោលមកហើយ ។ រមែងដឹងច្បាស់ការបានចំពោះនោះថា ជាហេតុនៃសោមនស្សិន្ទ្រិយនោះ ។ ចំណែកឧបេក្ខិន្ទ្រិយ រមែងកើតឡើងដោយអាការជាកណ្តាលៗ រមែងដឹងច្បាស់អាការដែលជាកណ្តាលៗ ក្នុងសត្វ និងសង្ខារនោះថា ជាហេតុឲ្យកើតឡើងនៃឧបេក្ខិន្ទ្រិយនោះ ។

ក៏ពាក្យចន្លុលបង្ហាញទៅព្រមៗ គ្នាក្នុងពាក្យថា ទុក្ខិន្ទ្រិយដែលកើតឡើងហើយ រមែងរលត់ទៅដោយមិនមានសេសសល់ក្នុងទីណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ស្ងាត់ចាកកាមទាំងឡាយជាដើម (កត្ត

ឧប្បន្នំ ទុក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ) ដូចតទៅនេះ ។ ពិតណាស់ ទុក្ខិន្ទ្រិយ រមែងរលត់ក្នុងខណៈឧបចារៈនៃបឋមជ្ឈានប៉ុណ្ណោះ ទុក្ខិន្ទ្រិយនោះ ឈ្មោះថា ជាការលះបង់បានហើយ ។ ទោមនស្សជាដើម រមែងរលត់អស់ក្នុងខណៈឧបចារៈនៃឈានទី ២ ជាដើម ទោមនស្សជាដើមនោះ ឈ្មោះថា ជាការលះបានហើយ ។ បើដូច្នេះ ការរលត់ (នៃឥន្ទ្រិយទាំងនោះ) ក្នុងឈានទាំងឡាយនុ៎ះឯង លោកពោលទុកហើយ ព្រោះទោមនស្សជាដើមទាំងនោះ រលត់អស់ទៅយ៉ាងស្និទ្ធ ពិតហើយ សេចក្តីរលត់អស់ទៅជាយ៉ាងក្រៃលែងនៃទោមនស្សជា ដើមទាំងនោះ ក៏គឺសេចក្តីរលត់យ៉ាងស្និទ្ធនៃទោមនស្សជាដើមនោះ រមែងមានក្នុងបឋមជ្ឈានជាដើមនោះ (និង) មិនមែនជាការរលត់យ៉ាងពិត ទាំងជាការរលត់ទៅក្នុងខណៈនៃឧបចារៈប៉ុណ្ណោះ មិនមែនជាការរលត់ដោយបរិបូរណ៍នោះទេ ។ ពិតដូច្នោះ ទុក្ខិន្ទ្រិយ សូម្បីរលត់ទៅហើយក្នុងឧបចារនៃបឋមជ្ឈាន ដែលមានអាវជ្ជនចិត្តផ្សេងៗ នឹងគប្បីកើតឡើងបាន ព្រោះសម្ផស្សនៃរបោម មូស និងខ្យល់ជាដើម ឬព្រោះការក្តៅស្អុះ និងចក្ខុន្ទ្រិយនោះ មិនកើតឡើងបានទៀតឡើយក្នុងខណៈអប្បនា ម្យ៉ាងទៀត ទុក្ខិន្ទ្រិយសូម្បីរលត់ទៅក្នុងឧបចារៈក៏មិនឈ្មោះថា រលត់ទៅដោយល្អ ព្រោះឥន្ទ្រិយទាំងនោះ មិនត្រូវវត្ថុដែល

ផ្សុយគ្នាកម្មាត់ ។ តែកាយគ្រប់ចំណែករមែងជាសុខ គួរប្រាថ្នាទូទៅសូម្បី ដោយការផ្សាយបីតិទៅខាងក្នុងអប្បនា ឈ្មោះថា ជាសុខ ព្រោះជាវត្ថុដែលគួរប្រាថ្នា និងទុក្ខិន្ទ្រិយ ទើបឈ្មោះថា រមែងរលត់ទៅដោយល្អ ព្រោះឥន្ទ្រិយទាំងនោះ ត្រូវវត្ថុជាចំណែកផ្សុយគ្នាកម្មាត់ ។ និងព្រោះកាលទោមនស្សិ-ន្ទ្រិយត្រូវលះក្នុងឧបចារៈនៃឈានទី ២ ដែលមានអាវជ្ជនចិត្តផ្សេងៗ គ្មានទុំះឯង ដូច្នោះ ទោមនស្សិន្ទ្រិយនោះ កាលមានសេចក្តីលំបាកកាយ និងចិត្តត្រូវបៀតបៀន ព្រោះសេចក្តីត្រិះរិះជាបច្ច័យ ក៏កើតឡើង ។ ព្រោះមិនមានសេចក្តីត្រិះរិះនុំះឯង សុខិន្ទ្រិយទើបកើតឡើងក៏និង ក៏កើតឡើងក្នុងទីណា ក្នុងទីនោះក៏ជាអប្បនា ព្រោះមិនមានសេចក្តីត្រិះរិះ ក៏សេចក្តីត្រិះរិះ រមែងកើតឡើងក្នុងឧបចារៈនៃឈានទី ២ យ៉ាងនេះ ។ ប្រសិនបើមានការកើតឡើងនៃសុខិន្ទ្រិយនោះ ក្នុងឧបចារៈឈានទី ២ ក៏មិនមែនកើតក្នុងឈានទីពីរឡើយ ព្រោះលះបច្ច័យបានហើយ សូម្បីកាលសុខិន្ទ្រិយត្រូវលះក្នុងឧបចារៈនៃឈានទី ៣ ក៏យ៉ាងនោះ គប្បីមានការកើតឡើងនៃកាយ ត្រង់រូបដែលប្រណីត ដែលមានបីតិជាសមុដ្ឋានពាល់ត្រូវហើយ តែមិនមែនកើតឡើងក្នុងឈានទី ៣ ទេ ។ ព្រោះថា បីតិដែលជាបច្ច័យនៃសុខ រលត់ទៅហើយដោយឈានទីបី ។ ក្នុងឧបចារៈនៃឈានទី ៤ ក៏ដូចគ្នា ព្រោះមិនទាន់

មានឧបេក្ខាដែលដល់អប្បនា ហេតុថា នៅជិតសោមនស្សិន្ទ្រិយ ដែលសូម្បីនឹងលះបានហើយ (សោមនស្សិន្ទ្រិយ) ក៏អាចនឹងមានការកើតឡើងបាន ព្រោះឈានកន្លងមិនបានដោយពិត តែក៏មិនមែនកើតឡើងក្នុងឈានទី ៤ ឡើយ ។ ព្រោះដូច្នោះ ក្នុងឈានទី ៤ នេះ ទុក្ខិន្ទ្រិយដែលកើតឡើងហើយ ទើបរលត់ទៅដោយមិនមានសល់ ការកាន់យកដោយមិនមានសល់ ក្នុងឈាននោះៗ លោកបានធ្វើហើយដូចដែលពោលមកនេះ ។ ក៏ពាក្យណាដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងទីនេះថា **រមែងបង្អោនចិត្តទៅដើម្បីភាពជាយ៉ាងនោះ** ។ ក្នុងពាក្យនោះ ក៏គប្បីជ្រាបសេចក្តីយ៉ាងនេះថា បុគ្គលជាអ្នកដែលនៅមិនទាន់បាន រមែងបង្អោនចិត្តទៅដើម្បីប្រយោជន៍នៃការកើតឡើង ដូច្នោះ បុគ្គលជាអ្នកបាន ក៏រមែងបង្អោនចិត្តទៅដើម្បីប្រយោជន៍ការចូលដល់ ។ ក៏ឯវារៈការពិចារណាក្នុងពីរសូត្រនេះ ព្រះអង្គបានត្រាស់ទុក ដូចដែលពោលមកនេះ ។

ចប់អដ្ឋកថា ឧប្បដិកសូត្រទី ១០

## ចប់សុខិន្ទ្រិយវគ្គទី ៤
## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១អដ្ឋកថា សុទ្ធកសូត្រ ២អដ្ឋកថា សោតាបន្នសូត្រ
៣អដ្ឋកថា បឋមវិភង្គសូត្រ ៤អដ្ឋកថា អរហន្តសូត្រ
៥អដ្ឋកថា ឧប្បដិកសូត្រ

# ជរាវគ្គទី ៥

## អ ដ្ឋ ក ថា

### ជរាសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង ជរាសូត្រទី ១ នៃជរាវគ្គទី ៥ ។

[២៨៥] ពាក្យថា ក្នុងទីមានពន្លឺថ្ងៃចាំងមកពីទិសបច្ចិម (បច្ឆាតបកេ) គឺ មានកំដៅថ្ងៃនៅទិសខាងលិចនៃប្រាសាទ ព្រោះស្រមោលប្រាសាទបាំងទៅទិសខាងកើត ។ អធិប្បាយថា ស្តេចប្រថាប់គង់លើព្រះបវរពុទ្ធាសនៈដែលក្រាលទុកក្នុងទីនោះ ។ ពាក្យថា ទ្រង់គង់ហាលព្រះបិដ្ឋិក្នុងទីកំដៅថ្ងៃ (ខ្នង) (បិដ្ឋឹ ឱតាបយមានោ) សេចក្តីថា ព្រោះក្នុង ព្រះសរីរៈដែលជាឧបាទិន្នកសង្ខារសូម្បីជារបស់ព្រះសម្មាសម្ពុទ្ធ ក្នុងវេលាក្តៅក៏ក្តៅ ក្នុងវេលាត្រជាក់ក៏ត្រជាក់ ក៏សម័យនេះជាសម័យត្រជាក់ មានទឹកសន្សើមធ្លាក់ ដូច្នោះ ក្នុងវេលានោះ ទើបទ្រង់យកមហាចីវរចេញហើយ ស្តេចប្រថាប់គង់ ទ្រង់ហាលព្រះបិដ្ឋិក្នុងទីកំដៅថ្ងៃ ។

សួរថា ពន្លឺកំដៅថ្ងៃអាច គ្របសង្កត់ព្រះរស្មីព្រះមានព្រះភាគចូលទៅខាងក្នុងបានឬ ។

ឆ្លើយថា មិនបាន ។ បើដូច្នេះ ពន្លឺអ្វីឲ្យក្តៅ ។ តេជៈនៃរស្មីឲ្យក្តៅ ។ ដូចយ៉ាងថា ពន្លឺកំដៅថ្ងៃពាល់ត្រូវខ្លួនបុគ្គលដែលអង្គុយក្រោមម្លប់ឈើដែលជាបរិមណ្ឌលក្នុងវេលាថ្ងៃត្រង់មិនបាន ក៏ពិតហើយ សូម្បីយ៉ាងនោះ កំដៅក៏នៅផ្សាយទៅពីគ្រប់ទិស ដូចយកភ្លើងមកដុតជុំវិញ យ៉ាងណា ដូច្នោះដូចគ្នា កំដៅថ្ងៃមិនអាចគ្របសង្កត់ព្រះរស្មីព្រះពុទ្ធ ហើយជ្រែកចូលទៅខាងក្នុងបាន ក៏គប្បីជ្រាបថា ព្រះសាស្តាប្រថាប់គង់ទទួលកំដៅហើយ ។

បទថា **ប្របាច់ (អនោមជ្ជន្តោ)** គឺ ប្របាច់ដោយអំណាចធ្វើបរិកម្មព្រះបិដ្ឋិ ។

[២៨៦] ពាក្យថា **បពិត្រព្រះអង្គដ៏ចម្រើន គួរអស្ចារ្យ (អច្ឆរិយំ ភន្តេ)** គឺ ព្រះថេរៈដោះមហាចីវរចេញចាកព្រះបិដ្ឋិរបស់ព្រះដ៏មានព្រះភាគបានឃើញស្នាមជ្រីវជ្រួញប៉ុនចុងសក់ ដូចស្នាមបិទមាស ក្នុងរវាងព្រះចម្ពះ (ស្មា) ទាំងពីរខាងរបស់ព្រះអង្គដែលប្រថាប់គង់ កើតសេចក្តីសង្វេគ កាលនឹងតិះដៀលដល់ភាពជរាថា សូម្បីតែក្នុងព្រះសរីរៈបែបនេះ ក៏នៅប្រាកដភាពជរាបាន ទើបពោលយ៉ាងនោះ ។ ន័យថា នេះឈ្មោះថា ជារបស់អស្ចារ្យសម្រាប់បុគ្គលអ្នកមានប្រក្រតីតិះដៀល ។ កាលសម្តែងថា ព្រះឆវីវណ្ណដែលបរិសុទ្ធដោយប្រក្រតី (ឥឡូវនេះ) មិនដូច្នោះ វិនាសហើយ ទើប

ក្រាបទូលយ៉ាងនេះថា ឥឡូវនេះ ព្រះដ៏មានព្រះភាគមិនបានបរិសុទ្ធដូចកាលមុនទេ (ន ចេវទានិ ភន្តេ ភគវតោ តាវ បរិសុទ្ធោ) ។ ពិតហើយ កាលវេលាដែលព្រះតថាគតទ្រង់នៅកម្លោះ ព្រះវរកាយមិនមានស្នាមជ្រួញជ្រីវ ដូចស្បែកគោដែលគេយកមកតាំង ១០០ ផ្ទាំង ហើយទាញសន្ធឹងឲ្យប៉ុនគ្នា ដោយប្រការដូច្នេះ ។ ល្អងធូលីដែលធ្លាក់មកត្រង់ព្រះហស្តនោះ ក៏ជ្រុះទៅ យាត់ទុកនៅមិនបានឡើយ ដូចដល់អាការដូតដោយប្រេង ។ តែក្នុងវ័យចាស់ជរា (សម្រាប់បុគ្គលទូទៅ) ចំណែកត្រង់សីសៈក៏ជ្រួញជ្រីវទៅ សូម្បីតែសន្ទាក់ក៏ធូររលុង ។ សាច់ក៏មិនឱបត្អឹងស្អិទ្ធ ដល់នូវការយុរយារធូរជ្រាយក្នុងទីនោះៗ ។ តែរបស់ព្រះពុទ្ធទាំងឡាយ មិនដូច្នោះទេ ។ អាការដូចដែលមកនេះ មិនបានប្រាកដដល់អ្នកពួកដទៃទេ ប្រាកដដល់តែព្រះអានន្ទប៉ុណ្ណោះ ព្រោះលោកនៅកៀកជិត ដូច្នោះ លោកទើបទូលយ៉ាងនោះ ។

ពាក្យថា ព្រះសរីរៈក៏ទន់ទោរ (សិថិលានិ ច គត្តានិ) គឺ ភាពជ្រួញជ្រីវប្រាកដក្នុងទីនោះៗ គឺ ត្រង់មុខ ត្រង់ចន្លោះចង្កេះស្មារបស់បុគ្គលដទៃ តែសភាពនោះ មិនមានដល់ព្រះសាស្តា តែព្រះថេរៈសម្លឹងឃើញស្នាមជ្រួញជ្រីវរវាងព្រះចង្កេះទាំងពីរខាង ទើបបានទូលយ៉ាងនោះ ។ សូម្បីពាក្យថា ធូរជ្រាយ (សព្វានិ វលិជាតានិ) នេះ លោកក៏ពោលដោយអំណាចដែល

ប្រាកដដល់ខ្លួនលោកប៉ុណ្ណោះ ។ តែធម្មតាស្នាមជ្រីវជ្រួញដូចរបស់បុគ្គលដទៃ មិនមានដល់ព្រះសាស្តា ។ ពាក្យថា *ព្រះវរកាយក៏ទន់ទោរទៅខាងមុខ (បុរតោ បព្ភារោ ច កាយោ)* គឺ ព្រះសាស្តាទ្រង់មានព្រះកាយត្រង់ដូចកាយព្រហ្ម គឺ ព្រះកាយរបស់ព្រះអង្គខ្ពស់ត្រង់ឡើងទៅ ដូចសសរគោលមាសដែលគេបញ្ឈរទុកក្នុងទេវនគរ ។ តែកាលទ្រង់ព្រះជរាហើយ ព្រះកាយក៏ឱនទៅខាងមុខ ។ ម្យ៉ាងទៀតលោកថា ព្រះកាយដែលឱនទៅខាងមុខនេះ មិនប្រាកដដល់បុគ្គលដទៃ ប្រាកដដល់ព្រះថេរៈប៉ុណ្ណោះ ព្រោះលោកនៅកៀកជិត ដូច្នោះលោកទើបពោលយ៉ាងនោះ ។

[២៨៧] បទថា *និងសេចក្តីប្រែប្រួលនៃឥន្ទ្រិយទាំងឡាយក៏ប្រាកដ (ទិស្សតិ ច ឥន្ទ្រិយានំ អញ្ញថត្តំ)* គឺ ដែលឈ្មោះថា ឥន្ទ្រិយទាំងឡាយ មិនមែនឥន្ទ្រិយដែលត្រូវដឹងច្បាស់ដោយភ្នែក ព្រោះដោយប្រក្រតី ព្រះឆវីវណ្ណក៏បរិសុទ្ធហើយ តែឥឡូវនេះ មិនបានបរិសុទ្ធ ស្នាមជ្រួញជ្រីវប្រាកដត្រង់រវាងព្រហ្មចម្ម: ព្រះកាយដែលត្រង់ដូចកាយព្រហ្ម ក៏កោងទៅខាងមុខ ដោយហេតុនេះឯង លោកទើបពោលយ៉ាងនេះ ដោយការកាន់យកន័យថា ក៏ឥន្ទ្រិយ មានភ្នែកជាដើមប្រែប្រួលទៅ ។

[២៨៨] បទថា *សូម្បីលោកនឹងតិះដៀលដល់ភាពជរាដ៏លាមក (ធិ*

*តំ ជម្មីជរេ អត្ថុ) សេចក្តីថា សូម្បីទឹងតិះដៀលភាពជរាដ៏លាមក ភាពជរាក៏នៅមានចំពោះលោក គឺ អ្នកធ្វើការតិះដៀល ក៏នៅតែប្រសព្វនឹងភាពជរាដ៏លាមកនោះ ។*

ចប់អដ្ឋកថា ជរាសូត្រទី ១

# អ ដ្ឋ ក ថា

## ឧណ្ណាភព្រាហ្មណសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧណ្ណាភព្រាហ្មណសូត្រទី ២ ។

[២៩០] បទថា *អារម្មណ៍ដែលជាគោចរ (គោចរវិសយំ)* បានដល់ អារម្មណ៍ដែលជាទីត្រាច់ទៅ (របស់ចិត្ត) ។ បទថា *នៃគ្នានឹងគ្នា (អញ្ញមញ្ញស្ស)* គឺ ឥន្ទ្រិយមួយ រមែងមិនសោយអារម្មណ៍មួយទៀត ដូចជាភ្នែកនឹងសោយអារម្មណ៍ជំនួសត្រចៀកមិនបាន ឬត្រចៀកនឹងសោយអារម្មណ៍ជំនួសភ្នែក (ក៏មិនបាន) ពិតណាស់ បើនឹងយកអារម្មណ៍ គឺ រូប ដែលផ្សេងគ្នាដោយពណ៌ខៀវជាដើម មករួមគ្នាហើយ ក៏បញ្ជូនទៅឲ្យសោតិន្ទ្រិយថា នែ៎! ចូរស្ដាប់ឲ្យច្បាស់ហើយបង្ហាញមកថា នេះឈ្មោះអារម្មណ៍អ្វីហ្នឹង? ចក្ខុវិញ្ញាណ សូម្បីនឹងយកមាត់ចេញមក ក៏នឹងត្រូវនិយាយដោយធម្មតារបស់ខ្លួនយ៉ាងនេះថា ណែ៎! អន្ធពាល សូម្បីឲ្យឯងស្វែងរកអស់ ១០០ ឆ្នាំ ១.០០០ ឆ្នាំក៏ដោយ ក្រៅពីខ្ញុំហើយ ឯងនឹងបានដឹងអារម្មណ៍នេះអំពីណា ឯងនាំយកវាបញ្ជូនមកឲ្យចក្ខុបសាទ ខ្ញុំនឹងស្គាល់អារម្មណ៍ មិនថា វាជាពណ៌ខៀវ ឬពណ៌លឿង ។ ព្រោះអារម្មណ៍នេះ មិនមែនជាវិស័យរបស់អ្នកដទៃ

តែវាជាវិស័យរបស់ខ្ញុំប៉ុណ្ណោះ ។ សូម្បីក្នុងទ្វារដ៏សេស ក៏ទំនងនេះឯង ។ ឥន្ទ្រិយទាំងនេះ ឈ្មោះថា មិនសោយអារម្មណ៍នៃគ្នានឹងគ្នា ដូចពោលមកនេះឯង ។

បទថា *អ្វី ជាទីពឹង (កឹ បដិសរណំ)* គឺ លោកសួរថា អ្វីជាទីពឹងរបស់ឥន្ទ្រិយទាំងនេះ គឺ ឥន្ទ្រិយទាំងនេះពឹងអ្វី ។

[២៩១] បទថា **ចិត្តជាទីពឹង (មនោ បដិសរណំ)** គឺ ចិត្តដែលជាជវនៈ (ស្ទុះទៅសេពអារម្មណ៍) ជាទីពឹង ។ បទថា **ចិត្តសោយអារម្មណ៍របស់ឥន្ទ្រិយទាំងនោះ (មនោ ច នេសំ)** សេចក្តីថា ចិត្តនុ៎ះឯង ដែលស្ទុះទៅតាមមនោទ្វារនុ៎ះឯង រមែងសោយអារម្មណ៍របស់ឥន្ទ្រិយទាំងនោះ ដោយអំណាចសេចក្តីស្រឡាញ់ជាដើម ។ ពិតហើយ ចក្ខុវិញ្ញាណ ឃើញតែរូបប៉ុណ្ណោះឯង សេចក្តីស្រឡាញ់ សេចក្តីក្រោធ ឬសេចក្តីវង្វេង ក្នុងការដឹងតាមផ្លូវភ្នែកនេះរមែងមិនមាន ។ តែជវនក្នុងទ្វារមួយ រមែងស្រឡាញ់ ក្រោធ ឬវង្វេង ។ សូម្បីក្នុងសោតវិញ្ញាណជាដើម ក៏ន័យនេះឯង ។ ក្នុងរឿងនោះមានការប្រៀបធៀបដូច្នេះ ។

បានឮមកថា មានសំឡាញ់ទុព្វល ៥ នាក់ សេពគប់ព្រះរាជ បានអំណោយបន្តិចបន្តួចពីផ្ទះ ៥ ត្រកូលក្នុងស្រុកមួយ ដោយសេចក្តីលំបាក ។

ក្នុងផ្ទះនោះ ពួកគេទទួលបានត្រឹមតែប៉ុណ្ណោះឯង គឺ ត្រី សាច់ កហាបណៈ លួមទិញខ្សែបាន កន្ទះកហាបណៈ មួយកហាបណៈមានតម្លៃ ១ មាសកៈ កហាបណៈ ៨ រៀល កហាបណៈ១៦ រៀល កហាបណៈ ៦៤ រៀល និង តម្លៃទ្រព្យណា ។ ព្រះរាជាប៉ុណ្ណោះ ទ្រង់ទទួលយកអំណោយដ៏ធំ មានវត្ថុ ១០០ យ៉ាង ៥០០ យ៉ាង ១.០០០ យ៉ាង ។ ក្នុងរឿងប្រៀបធៀបនោះ គប្បី ឃើញបសាទទាំង ៥ ដូចជាផ្ទះ ៥ ត្រកូល ។ វិញ្ញាណទាំង ៥ ដូចសំឡាញ់ ទុព្វល ៥ នាក់ ។ ជវនៈ ដូចព្រះរាជា ។ មុខនាទីត្រឹមតែឃើញរូបជាដើម របស់ចក្ខុវិញ្ញាណជាដើម ដូចការទទួលអំណោយបន្តិចបន្តួចរបស់ពួក សំឡាញ់ដែលទុព្វល ។ តែសេចក្តីប្រាថ្នាជាដើម មិនមានចក្ខុវិញ្ញាណជាដើម នេះ ។ គប្បីជ្រាបថា សេចក្តីប្រាថ្នាជាដើម ជារឿងរបស់ជវនក្នុងទ្វារទាំង នោះ ដូចជាការទទួលយកសួយដ៏ធំរបស់ព្រះរាជា ។ ជវនៈទាំងជាកុសល និងអកុសល លោកហៅថា "ចិត្ត" ក្នុងទីនេះ ដូចពោលមកនេះ ។

[២៩២] ពាក្យថា **សតិជាទីពឹង (សតិ បដិសរណំ)** បានដល់ សតិ ក្នុងមគ្គ ជាទីពឹង ។ ពិតណាស់ ចិត្តដែលជាជវន រមែងពឹងសតិក្នុងមគ្គ ។

[២៩៣] ពាក្យថា **វិមុត្តិ (វិមុត្តិ)** គឺ ការរួចផុតដោយអំណាចផល គឺ ជាទីពឹង ។

[២៩៤] បទថា **និព្វាន (និព្វានំ)** គឺ និព្វានជាទីពឹងនៃការរួចផុតដោយអំណាចផល ព្រោះការរួចផុតនោះ រមែងអាស្រ័យនិព្វាននោះ ។ បទថា **មិនអាចកាន់យកទីបំផុតនៃបញ្ហាបាន (នាសក្ខិ បញ្ហស្ស បរិយន្តំ គហេតុំ)** គឺ មិនអាចកាន់យកប្រមាណដែលជាប្រភេទនៃបញ្ហាបាន ។ លោកសួរដល់ធម៌ដែលមិនមានទីពឹងថា មានទីពឹង ។ ធម្មតាថា និព្វាននេះ មិនមានទីពឹង គឺ មិនអាស្រ័យអ្វីៗ ដោយប្រការដូច្នេះ ។ បទថា **មាននិព្វានជាទីឈានចុះ (និព្វានោគធំ)** គឺ ឈមទៅកាន់និព្វាន ចូលទៅកាន់និព្វាន ។ បទថា **ព្រហ្មចរិយៈ (ព្រហ្មចរិយំ)** បានដល់ មគ្គព្រហ្មចរិយៈ ។ បទថា **មាននិព្វានជាខាងមុខ (និព្វានបរាយនំ)** គឺ និព្វានជាទីទៅខាងមុខ គឺ ជាគតិខាងមុខនៃព្រហ្មចរិយៈនោះ មានន័យថា ក្រៅពីនិព្វាននោះ ព្រហ្មចរិយៈនោះមិនទៅទីដទៃ ។ ដែលឈ្មោះថា **មាននិព្វានជាទីបំផុត (និព្វានបរិយោសានំ)** ក៏ព្រោះនិព្វានជាទីបញ្ចប់ គឺ ជាទីបំផុតនៃព្រហ្មចរិយៈនោះ ។

លោកហៅសទ្ធាដែលមកជាមួយគ្នានឹងមគ្គថា **មានឫសកើតហើយតាំងមាំហើយ** ។ ព្រះដ៏មានព្រះភាគទ្រង់សំដៅយកអ្វី ទើបត្រាស់ថា **ភិក្ខុទាំងឡាយ បើ ...ក្នុងសម័យនេះ** ដូច្នេះជាដើម ទ្រង់សំដៅយកព្រះអនាគាមីដែលប្រកបដោយឈាន ។ ពិតយ៉ាងនោះ ក្នុងសម័យនោះ ចិត្តដែលជា

អកុសលទាំង ៥ ជួង ដែលព្រាហ្មណ៍លះបានហើយដោយមគ្គជំបូង និវរណៈទាំង ៥ ក៏លះបានហើយដោយឈានទី ១ ព្រោះហេតុនោះ ព្រាហ្មណ៍នោះតាំងនៅក្នុងតំណែងអនាគាមីដែលប្រកបដោយឈាន មិនវិនាសចាកឈានស្លាប់ទៅ ក៏ត្រូវបរិនិព្វានក្នុងទីនោះឯង ។ តែកាលបើព្រាហ្មណ៍គ្រប់គ្រងកូនប្រពន្ធ ចាត់ចែងការងារហើយ ឈានវិនាសទៅ កាលបើឈានវិនាសទៅហើយ គតិក៏មិនទំនាក់ទំនងគ្នា តែកាលឈានមិនវិនាស គតិទើបមានការទំនាក់ទំនងជាប់គ្នា ព្រោះដូច្នោះ ទើបត្រាស់សំដៅយកភាពជាអនាគាមីដែលប្រកបដោយឈាននេះ យ៉ាងនេះ ។

ចប់អដ្ឋកថា ឧណ្ណាភព្រាហ្មណសូត្រទី ២

# អ ដ្ឋ ក ថា

## សាកេតសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង សាកេតសូត្រទី ៣ ។

[២៩៨] បទថា ក្នុងព្រៃអញ្ជន (អញ្ជនវនេ) គឺ ក្នុងព្រៃដែលដាំដើមឈើមានផ្កាពណ៌ដូចផ្កាអញ្ជន ។

[៣០០] បទថា ភិក្ខុទាំងឡាយ វត្ថុណាជាសទ្ធិន្ទ្រិយ វត្ថុនោះជាសទ្ធាពលៈ (យំ ភិក្ខវេ សទ្ធិន្ទ្រិយំ តំ សទ្ធាពលំ) គឺ ដែលឈ្មោះថា សទ្ធិន្ទ្រិយ ព្រោះអត្ថថា ជំ ក្នុងវត្ថុទីមានការបង្អោនជឿ ជាលក្ខណៈ ឈ្មោះថា សទ្ធាពលៈ ព្រោះមិនញាប់ញ័រក្នុងឥន្ទ្រិយដែលមិនគប្បីជឿ ។ គុណធម៌ក្រៅពីនេះជាឥន្ទ្រិយ ក៏ព្រោះអត្ថថា ជំ ក្នុងលក្ខណៈ គឺ ការផ្គង ការប្រាកដ ការមិនរាយមាយ និងការដឹងច្បាស់ ។ គប្បីជ្រាបថា ជាពលៈ ព្រោះមិនញាប់ញ័រព្រោះសេចក្តីខ្ជិលប្រអូស ការមិនមានសតិ សេចក្តីរាយមាយ និងការមិនដឹង ។

[៣០៤] គប្បីជ្រាបហេតុដែលធ្វើឲ្យឥន្ទ្រិយ និងពលៈទាំងនោះ មិនផ្សេងគ្នា ដោយអំណាចសទ្ធា វីរិយៈ សតិ សមាធិ និងបញ្ញា ដូចខ្សែទឹក

មួយខ្សែនៃទន្លេនោះ ដោយពាក្យថា **យ៉ាងនោះដូចគ្នា** (ឯវមេវ ខោ) ។ គប្បីជ្រាបហេតុដែលធ្វើឲ្យផ្សេងគ្នា ដោយអំណាចឥន្ទ្រិយ និងពលៈ ដោយអត្ថថា ធំ និងមិនញាប់ញ័រ ដូចខ្សែទឹកពីរខ្សែ ដូច្នោះ ។

ចប់អដ្ឋកថា សាកេតសូត្រទី ៣

# អ ដ្ឋ ក ថា

## បុព្វកោដ្ឋកសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង បុព្វកោដ្ឋកសូត្រទី ៤ ។*

*[៣០៧] បទថា **ឈានចុះកាន់អមតៈ (អមតោគធំ)** គឺ កាន់ខាងក្នុងអមតៈ ។ បទថា **មានអមតៈជាខាងមុខ (អមតបរាយនំ)** គឺ ដែលកើតពីអមតៈ សម្រេចពីអមតៈ ។ បទថា **មានអមតៈជាទីបំផុត (អមតបរិយោសានំ)** គឺ ទីបំផុតអមតៈ ។*

*[៣០៨] បទថា ប្រពៃហើយៗ (សាធុ សាធុ) គឺ កាលទ្រង់សរសើរពាក្យព្យាករណ៍របស់ព្រះថេរៈ ទើបប្រទានសាធុការ ។*

ចប់អដ្ឋកថា បុព្វកោដ្ឋកសូត្រទី ៤

# អ ដ្ឋ ក ថា

## បឋមបុព្វារាមសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមបុព្វារាមសូត្រទី ៥ ។*

[៣១២] *បទថា ប្រព្រឹត្តទៅតាមបញ្ញា (តទន្វយា) គឺ ប្រព្រឹត្តទៅតាមបញ្ញានោះ មានន័យថា វិលទៅតាម (បញ្ញានោះ) ។ ព្រះមានព្រះភាគទ្រង់ធ្វើចំណែកខាងដើមឲ្យជាដើមហេតុ ហើយទ្រង់ត្រាស់តែឥន្ទ្រិយក្នុងផលប៉ុណ្ណោះ ក្នុង ៦ សូត្រតាមលំដាប់ ។*

ចប់អដ្ឋកថា បឋមបុព្វារាមសូត្រទី ៥

# អ ដ្ឋ ក ថា

## សទ្ធាសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង សទ្ធាសូត្រទី ១០ ។*

*[៣៣៨] បទថា **ធម៌ទាំងនេះ (ឥមេ ខោ តេ ធម្មា)** បានដល់ មគ្គ ៣ ខាងលើ ព្រមនឹងវិបស្សនា ។ បទថា **ក៏គឺ ធម៌ដែលយើងធ្លាប់ស្តាប់ហើយនោះឯង ( យេ មេ បុព្វេ សុតា វា អហេសុំ)** បានដល់ ធម៌ពួកណា របស់ពួកលោក (អរិយសាវក) ដែលកំពុងពោលហើយនោះឯងថា "ឥន្ទ្រិយនៃអរហត្តផល មានហើយ" ជាធម្មតាដែលយើង (អរិយសាវក) បានស្តាប់មកអំពីមុនហើយ ។ បទថា **ពាល់ត្រូវដោយនាមកាយ (កាយេន ច ផុសិត្វា)** សេចក្តីថា និងពាល់ត្រូវ គឺ បានចំពោះដោយនាមកាយ ។ បទថា **និងឃើញច្បាស់ចាក់ធ្លុះដោយបញ្ញា (បញ្ញាយ ច អតិវិជ្ឈ បស្សាមិ)** សេចក្តីថា និងឃើញច្បាស់ចាក់ធ្លុះយ៉ាងក្រៃលែងដោយបញ្ញាជាគ្រឿងពិចារណា ។*

*[៣៣៩] បទថា **បពិត្រព្រះអង្គដ៏ចម្រើន ក៏សទ្ធារបស់អរិយសាវកនោះ (យាហិស្ស ភន្តេ សទ្ធា)** សេចក្តីថា ក៏សទ្ធាណា គឺ សទ្ធាដែលប្រកបដោយឥន្ទ្រិយទាំង ៤ យ៉ាង ដែលត្រាស់ទុកក្នុងខាងក្រោយហើយ ។ ក៏*

ឯសទ្ធានេះ ជាសទ្ធាសម្រាប់ពិចារណា ។ ពិតហើយ សម្បយុត្តសទ្ធា ជាសទ្ធាដែលលាយគ្នា ។ បច្ចវេក្ខណសទ្ធា ជាលោកិយៈតែម្យ៉ាង ។ ពាក្យដ៏សេសគ្រប់បទ រាក់ទាំងនោះឯង ។

ចប់អដ្ឋកថា សទ្ធាសូត្រទី ១០

## ចប់ជរាវគ្គទី ៥

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា ជរាសូត្រ ២ អដ្ឋកថា ឧណ្ណាភព្រាហ្មណសូត្រ
៣ អដ្ឋកថា សាកេតសូត្រ ៤ អដ្ឋកថា បុព្វកោដ្ឋកសូត្រ
៥ អដ្ឋកថា បឋមបុព្វារាមសូត្រ ៦ អដ្ឋកថា សទ្ធាសូត្រ

# សូករខាតវគ្គទី ៦

## អ ដ្ឋ ក ថា

### កោសលសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង កោសលសូត្រទី ១ នៃសូករខាតវគ្គទី ៦ ។*

[៣៤៧] *បទថា ដោយសេចក្តីក្លៀវក្លា (សូរិយេន) គឺ ដោយភាពជាអ្នកក្លាហាន ។ បទថា ដើម្បីការត្រាស់ដឹង (ពោធាយ) គឺ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹង ។*

ចប់អដ្ឋកថា កោសលសូត្រទី ១

# អ ដ្ឋ ក ថា

## មល្លកសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង មល្លកសូត្រទី ២ ។

[៣៥០] បទថា ក្នុងដែនមល្លៈ (មល្លកេសុ) គឺ ក្នុងជនបទដែលមានឈ្មោះយ៉ាងនោះ ។ ក្នុងសូត្រនេះ ឥន្ទ្រិយទាំង ៤ លាយគ្នា អរិយញ្ញាណជាលោកុត្តរៈ ។ ក៏អរិយញ្ញាណសូម្បីនោះ ក៏គួរចែកថា ធ្វើឲ្យអាស្រ័យឥន្ទ្រិយទាំង ៤ ជារបស់លាយគ្នា ។

ចប់អដ្ឋកថា មល្លកសូត្រទី ២

# អ ដ្ឋ ក ថា

# សេក្ខសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង សេក្ខសូត្រទី ៣ ។

[៣៥៨] បទថា ពិតដូច្នោះ ភិក្ខុជាសេក្ខៈនៅមិនទាន់ពាល់ត្រូវវត្ថុនោះ ដោយនាមកាយ (ន ហេវ ខោ កាយេន ផុសិត្វា វិហរតិ) បានដល់ពិតហើយ ភិក្ខុជាសេក្ខៈ រមែងពាល់ត្រូវ គឺ បានចំពោះដោយនាមកាយហើយក៏មិនមែន គឺ រមែងមិនអាចពាល់ត្រូវ គឺ បានចំពោះ (នូវគតិដ៏ប្រសើរនិងផលដែលជាទីបំផុត) ។ បទថា តែបានឃើញច្បាស់ចាក់ធ្លុះដោយបញ្ញា (បញ្ញាយ ច អតិវិជ្ឈ បស្សតិ) គឺ រមែងដឹងច្បាស់ដោយបញ្ញាជាគ្រឿងពិចារណាថា ឈ្មោះថា ឥន្ទ្រិយ គឺ អរហត្តផល ខាងលើនៅមាន ។

[៣៥៩] ក្នុងភូមិរបស់អសេក្ខៈ បទថា ពាល់ត្រូវហើយ (ផុស្សិត្វា វិហរតិ) គឺ បានចំពោះហើយ ។ បទថា ដោយបញ្ញា (បញ្ញាយ) គឺ រមែងដឹងច្បាស់ដោយបញ្ញាជាគ្រឿងពិចារណាថា ឈ្មោះថា ឥន្ទ្រិយ គឺ អរហត្តផល នៅមាន ។

[៣៦០] សូម្បីបទទាំងពីរថា ន កុហិញ្ចិ កិស្មិញ្ចិ ក៏ជាបទដែលប្រើ

ជំនួសគ្នានឹងគ្នា ។ អធិប្បាយថា នឹងមិនកើតឡើងក្នុងភពណាៗ ។ ក្នុងសូត្រនេះ ឥន្ទ្រិយទាំង ៥ ជាលោកុត្តរៈ ព្រះដ៏មានព្រះភាគត្រាស់ឥន្ទ្រិយ ៦ ដែលជាលោកិយៈ អាស្រ័យវដ្តៈប៉ុណ្ណោះ ។

ចប់អដ្ឋកថា សេក្ខសូត្រទី ៣

# អ ដ្ឋ ក ថា

## បទសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង បទសូត្រទី ៤ ។*

*[៣៦១] បទថា បទនៃធម៌ពួកណាមួយ រមែងប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង (យានិ កានិចិ បទានិ ពោធាយ សំវត្តន្តិ) គឺ បទធម៌ណាមួយបានដល់ ចំណែកធម៌ណាមួយ រមែងប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង ។*

ចប់អដ្ឋកថា បទសូត្រទី ៤

# អ ដ្ឋ ក ថា

# បតិដ្ឋិតសុត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង បតិដ្ឋិតសូត្រទី ៦ ។*

*[៣៦៨] បទថា រមែងរក្សាចិត្តទុកក្នុងអាសវៈ និងធម៌ដែលមានអាសវៈ (ចិត្តំ រក្ខតិ អាសវេសុ ច សាវេសុ ច ធម្មេសុ) គឺ បុគ្គលប្រារព្ធធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ហើយហាមការកើតឡើងនៃអាសវៈ ឈ្មោះថា រមែងរក្សាចិត្តក្នុងវត្ថុដែលជាអាសវៈ និងដែលប្រកបដោយអាសវៈ ។*

ចប់អដ្ឋកថា បតិដ្ឋិតសូត្រទី ៦

# អ ដ្ឋ ក ថា

## សូករខាតសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង សូករខាតសូត្រទី ៨ ។*

[៣៧៥] *ពាក្យថា សូករខាតៈ (សូករខាតាយំ)* គឺ ក្នុងទីពួនសម្ងំដែលជ្រូកឈ្មុសទុក ។ បានឮមកថា ក្នុងសម័យព្រះកស្សបសម្ពុទ្ធ ល្អាងនោះកាលផែនដីដុះឡើងមកក្នុងមួយពុទ្ធន្តរ ក៏លិចចុះក្នុងផែនដី ។ ថ្ងៃមួយ ជ្រូកមួយក្បាល ឈ្មុសកកាយដីទីជិតៗ ជុំវិញលើខ្នងល្អាងនោះ ។ កាលភ្លៀងធ្លាក់មក ដីក៏ហូរចេញ ទើបប្រាកដ (ស្នាម) ជាជំបូលល្អាង ។ ព្រានព្រៃម្នាក់មកឃើញ ទើបគិតថា ពីមុនកន្លែងនេះជាទីដែលលោកអ្នកមានសីលទាំងឡាយធ្លាប់ប្រើប្រាស់ដោយពិត យើងនឹងសម្អាតកន្លែងនេះ ទើបជញ្ជូនយកដីជុំវិញចេញ ធ្វើល្អាងឲ្យស្អាត សាងកុដិព័ទ្ធជុំវិញ ជាប់នឹងមុខទ្វារបុកកំបោរស គូររូបភាពចិត្រកម្មជាពបសម្រេចយ៉ាងល្អ ហើយយកខ្សាច់ដែលដូចជាផែនប្រាក់មកចាក់រោយទូទាំងបរិវេណ តាំងគ្រែ និងតាំងទុកហើយបានថ្វាយដល់ព្រះដ៏មានព្រះភាគដើម្បីប្រយោជន៍ជាទីប្រថាប់ ។ ល្អាងនេះជ្រៅ ជាទីគប្បីឡើងចុះបាន ពាក្យនោះព្រះអានន្ទសំដៅយកល្អាងនោះ ទើប

*ពោលយ៉ាងនេះ ។ បទថា **បរមនិបច្ចការំ** (ការនមស្ការយ៉ាងក្រៃលែង) ជានបុំសកលិង្គសម្តែងដល់ការ: មានពាក្យដែលលោកអធិប្បាយទុកថា ជាអ្នកធ្វើសេចក្តីឱនលំទោនជាយ៉ាងក្រៃលែង កំពុងប្រព្រឹត្តទៅហើយ រមែងប្រព្រឹត្តទៅ ។*

*[៣៧៦] បទថា **ក្សេមចាកពីយោគៈដ៏កំពូល** (អនុត្តរំ យោគក្ខេមំ) បានដល់ ភាពជាព្រះអរហន្ត ។*

*[៣៨២] បទថា **អ្នកមានការគោរពកោតក្រែង** (សប្បជិស្សា) គឺអ្នកមានសេចក្តីចម្រើនបំផុត ។ ពាក្យដ៏សេសគ្រប់កន្លែង មានសេចក្តីងាយយល់ទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូករខាតាសូត្រទី ៨

## ចប់សូករខាតាវគ្គទី ៦

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា កោសលសូត្រ ២ អដ្ឋកថា មល្លកសូត្រ
៣ អដ្ឋកថា សេក្ខសូត្រ ៤ អដ្ឋកថា បទសូត្រ
៥ អដ្ឋកថា បតិដ្ឋិតសូត្រ ៦ អដ្ឋកថា សូករខាតាសូត្រ

# ពោធិបក្ខិយវគ្គទី ៧

## អ ដ្ឋ ក ថា

## ពោធិបក្ខិយវគ្គទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពោធិបក្ខិយវគ្គទី ៧ ។*

[៣៩២] *ផល ៧ យ៉ាង ជាចំណែកខាងដើម បណ្ដាផលទាំង ៧ យ៉ាងនោះ ផល ២ យ៉ាងក្នុងខាងក្រោយ ធ្វើឲ្យជាដើមហើយ ក៏ជារបស់លាយគ្នា ។ បទដ៏សេសក្នុងព្រះសូត្រនេះ និងបទទាំងអស់ក្រៅអំពីនេះ សុទ្ធតែងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ពោធិបក្ខិយវគ្គទី ៧ ចប់

**ចប់ពោធិបក្ខិយវគ្គទី ៧**

# ឥន្ទ្រិយសំយុត្ត គង្គាទិបេយ្យាល

[៤០៥] *ឥន្ទ្រិយសំយុត្តមានចំណែកដូចគ្នានឹងមគ្គសំយុត្ត*

*(មិនមានអដ្ឋកថាកែសេចក្ដីទេ)*

# សម្មប្បធានសំយុត្ត

[៤១៣] *គប្បីពង្រីកសេចក្តីគង្គាបេយ្យាលនៃសម្មប្បធានសំយុត្ត*

*ដោយអំណាចសម្មប្បធាន ។*

*(មិនមានអដ្ឋកថាកែសេចក្តីទេ)*

# ពលសំយុត្ត

## អ ដ្ឋ ក ថា

### ពលសំយុត្ត

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពលសំយុត្ត ។*

[៤២២] *ពលៈទាំងឡាយដែលត្រាស់ទុកក្នុងពលសំយុត្ត ក៏ជារបស់លាយគ្នាដូចគ្នា ។ ពាក្យដ៏សេសគ្រប់កន្លែងងាយទាំងនោះឯង ។*

ចប់អដ្ឋកថា ពលសំយុត្ត

# ឥទ្ធិបាទសំយុត្ត

## ចាបាលវគ្គទី ១

## អ ដ្ឋ ក ថា

### អបារសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង អបារសូត្រទី ១ នៃឥន្ទ្រិយសំយុត្ត ។*

[៤៣១] *សមាធិដែលអាស្រ័យឆន្ទៈប្រព្រឹត្តទៅ ឈ្មោះថា* **ឆន្ទសមាធិ** *។ ពួកសង្ខារដែលជាប្រធាន ឈ្មោះថា* **បធានសង្ខារ** *។ បទថា* **ប្រកប** *(សមន្នាគតំ) គឺ ចូលដល់ដោយធម៌ទាំងនោះ ។ ឈ្មោះថា* **ឥទ្ធិបាទ** *ព្រោះជាបាទនៃឫទ្ធិ ឬបាទដែលជាឫទ្ធិ ។ សូម្បីក្នុងពាក្យដ៏សេស ក៏ទំនងនេះឯង ។ នេះជាសេចក្ដីសង្ខេបក្នុងឥទ្ធិបាទសំយុត្តនេះ ។ ចំណែកសេចក្ដីពិស្ដារមកស្រេចហើយក្នុងឥទ្ធិបាទវិភង្គ ។ ចំណែកខ្លឹមសារនៃឥទ្ធិបាទសំយុត្តនោះ លោកក៏បានសម្ដែងទុកហើយក្នុងវិសុទ្ធិមគ្គ ។ ក្នុងមគ្គសំយុត្ត ពោជ្ឈង្គសំយុត្ត សតិប្បដ្ឋានសំយុត្ត និងឥទ្ធិបាទសំយុត្តនេះ ក៏យ៉ាងនោះ គឺ ជា*

បរិច្ឆេទតែម្យ៉ាងដូចគ្នាដោយពិត ។

ចប់អដ្ឋកថា អចារសូត្រទី ១

# អ ដ្ឋ ក ថា

## ឥទ្ធិបទេសសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥទ្ធិបទេសសូត្រទី ៥ ។*

[៤៣៥] *មគ្គ ៣ និងផល ៣ ឈ្មោះថា ឥទ្ធិបាទបទេស ។*

ចប់អដ្ឋកថា ឥទ្ធិបទេសសូត្រទី ៥

# អ ដ្ឋ ក ថា

## សម្មត្តសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង សម្មត្តសូត្រទី ៦ ។*

[៤៣៧] *បទថា ញ៉ាំងឫទ្ធិឲ្យសម្រេចបានបរិបូរណ៍ (សមត្តំ ឥទ្ធឹ) គឺ អរហត្តផលទុំះឯង ។ ក៏ក្នុង ៩ សូត្រតាំងពីដើមមក ព្រះអង្គបានត្រាស់តែឥទ្ធិបាទ ដែលមានវិវដ្ដៈជាបាទប៉ុណ្ណោះ ។*

ចប់អដ្ឋកថា សម្មត្តសូត្រទី ៦

# អ ដ្ឋ ក ថា

## ចេតិយសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចេតិយសូត្រទី ១០ ។*

[៤៤៦] *បទថា **សំពត់និសីទនៈ** (និសីទនំ) គឺ សំពត់ដែលយកកំណាត់ស្បែក ។*

[៤៤៧] *លោកហៅវត្តដែលសាងទុកត្រង់ចេតិយស្ថានរបស់ឧទេនយក្ខថា **ឧទេនចេតិយ** ។ សូម្បីក្នុង **គោតមកចេតិយ** ជាដើម ក៏ន័យដូចគ្នានេះឯង ។ បទថា **ដែល...ចម្រើនហើយ** (ភាវិតា) គឺ ដែល (តថាគត) ចម្រើនហើយ ។ បទថា **ធ្វើឲ្យច្រើន** (ពហុលីកតា) គឺ ដែលធ្វើរឿយៗ ។ បទថា **ធ្វើឲ្យដូចជាយាន** (យានីកតា) គឺ ធ្វើឲ្យដូចយានដែលទឹមហើយ ។ បទថា **ធ្វើឲ្យជាទីតាំង** (វត្ថុកតា) គឺ ធ្វើឲ្យដូចជាវត្ថុ ព្រោះអត្ថថា ជាទីតាំង ។ បទថា **ឲ្យរហ័សរហួនហើយ** (អនុដ្ឋិតា) គឺ ដ៏មុតមាំក្រៃលែង ។ បទថា **សន្សំហើយ** (បរិចិតា) បានដល់ សន្សំទុកដោយគ្រប់សព្វ គឺ ដែលចម្រើនល្អហើយ ។ បទថា **ដែលប្រារព្ធល្អហើយ** (សុសមារទ្ធា) គឺ ដែលផ្តើមទុកហើយយ៉ាងល្អ ។*

លុះត្រាស់ដោយមិនចង្អុលឲ្យច្បាស់យ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងបញ្ជាក់ឲ្យច្បាស់ម្តងទៀត ទើបត្រាស់ពាក្យថា **តថាគតស្ស ខោ** ដូច្នេះជាដើម ។ ម្យ៉ាងទៀត ក្នុងបទទាំងនេះ បទថា **កប្បំ (កប្បំ)** សំដៅយកអាយុកប្ប (កំណត់អាយុ) ។ ក្នុងកាលនោះ ជាប្រមាណអាយុរបស់ពួកមនុស្ស បុគ្គលគប្បីធ្វើប្រមាណអាយុនោះឲ្យបរិបូណ៌ចុះ ។ បទថា **ឬច្រើនជាងមួយកប្ប (កប្បាវសេសំ វា)** គឺ ឬលើសមួយរយឆ្នាំ ដែលត្រាស់ថា "មួយកប្ប ឬច្រើនជាង" ។ ចំណែកព្រះមហាសិវត្ថេរ ពោលថា "ចំពោះព្រះពុទ្ធទាំងឡាយ រមែងមិនមានការគំរាមក្នុងវត្ថុដែលប្រព្រឹត្តទេ ក៏ដូចកាលទ្រង់គ្របសង្កត់វេទនាទៀបនឹងអស់ព្រះជន្ម ដែលកើតឡើងក្នុងស្រុកវេឡុវៈ (វេឡុវគ្រាម) អស់ ១០ ខែទុំះឯង យ៉ាងណា ក៏ដូច្នោះ កាលទ្រង់ចូលសមាបត្តិនោះរឿយៗ គប្បីគ្របសង្កត់បានអស់ ១០ ខែ ក៏ទ្រង់គប្បីតាំងព្រះជន្មនៅបានរហូតកទ្រកប្បនេះឯង" ។

សួរថា ក៏ហេតុដូចម្តេច ទើបទ្រង់មិនតាំងនៅ ។ ឆ្លើយថា ដែលឈ្មោះថា ព្រះសរីរៈដែលជាផលរបស់កម្ម ដែលត្រូវកិលេសចូលទៅប្រកាន់ហើយ ត្រូវជរាទាំងឡាយ មានព្រះទន្តបាក់ជាដើមនឹងគ្របសង្កត់ ធម្មតាថាព្រះពុទ្ធទាំងឡាយ មិនដល់ភាពជាបុគ្គលមានព្រះទន្តបាក់ជាដើមឡើយ ក៏

រមែងបរិនិព្វានក្នុងចំណែកព្រះជន្មាយុទី ៥ ក្នុងវេលាដែលទ្រង់នៅជាទីស្រឡាញ់ ជាទីរីករាយរបស់ពពួកច្រើនទុំះឯង ។ តែកាលពួកព្រះសាវកដ៏ច្រើន ជាពុទ្ធានុពុទ្ធបរិនិព្វានហើយ ក៏រមែងជាសរីរៈដែលត្រូវតាំងនៅឯកោ ប្រៀបដូចដង្គត់ឈើ ។ ឬមានកិក្ខុកម្ទោះ និងសាមណេរហែហមខ្វះ តែក៏នឹងត្រូវដល់ភាពជាបុគ្គលដែលត្រូវចំអកឡកឡឺយ ប្រមាថមើលងាយថា ឱ! បរិស័ទរបស់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ ព្រះអង្គទើបមិនស្ថិតនៅ ។ តែកាលត្រាស់ពាក្យដូច្នេះហើយ មារនោះក៏ពេញចិត្ត ។ បទថា **អាយុកប្ប** នេះឯងលោកបានបញ្ជាក់ច្បាស់ហើយក្នុងអដ្ឋកថា ។

[៤៤៨] បទថា **តំ** នោះ ក្នុងបទថា **ព្រោះត្រូវមារចូលទៅជ្រែកចិត្ត (យថា តំ មារេន បរិយុដ្ឋិតចិត្តោ)** ត្រឹមតែជាពាក្យចុះមកជ្រៀតចូលទុក ។ អធិប្បាយថា បុថុជ្ជនសូម្បីដទៃណាៗ ដែលត្រូវមារជ្រែកចិត្ត គឺត្រូវមារប្រេបាច់បេះដូងហើយ មិនគប្បីអាចចាក់ធ្លុះបាន យ៉ាងណា ព្រះថេរៈក៏មិនអាចចាក់ធ្លុះដូច្នោះ ដូចគ្នា ។ ពិតហើយ មាររមែងជ្រែកចិត្តរបស់បុគ្គលដែលលះវិបល្លាស ១២ យ៉ាងមិនទាន់បានអស់ ។ ចំណែកព្រះថេរៈនៅលះវិបល្លាស ៤ យ៉ាងមិនបាន ព្រោះដូច្នោះ មារទើបជ្រែកចិត្តរបស់លោកបាន ។ សួរថា ក៏កាលមារនោះនឹងធ្វើការជ្រែកចិត្ត រមែងធ្វើអ្វី?

ធ្វើយថា រមែងសម្ដែងរូបារម្មណ៍ដែលគួរខ្លាចខ្លះ ឲ្យឮអារម្មណ៍ គឺ សំឡេងខ្លះ បន្ទាប់ពីនោះ សត្វទាំងឡាយបានឃើញរូបនោះ ឬបានឮសំឡេងនោះ ហើយក៏បាត់បង់សតិ កើតវិលមុខឡើង មារក៏ស៊កដៃចូលតាមមាត់ ហើយប្របាច់បេះដូងសត្វទាំងនោះ សត្វទាំងនោះក៏ឈរសន្ធប់ ។ ក៏មារនេះ អាចស៊កដៃចូលទៅក្នុងមាត់របស់ព្រះថេរៈឬ ក៏មារសម្ដែងអារម្មណ៍ដែលគួរខ្លាច ព្រះថេរៈបានឃើញអារម្មណ៍នោះ ក៏ចាក់ចុះពន្ធ័នៃនិមិត្តមិនបាន ។ ព្រះដ៏មានព្រះភាគត្រាស់ដល់ ៣ ដង ដើម្បីអ្វី ។ ដើម្បីទ្រង់ធ្វើឲ្យសង្វេគ ដោយការលើកកំហុសឡើងថា នេះជាការធ្វើមិនល្អរបស់អ្នក នេះជាកំហុសរបស់អ្នក កាលព្រះថេរៈទូលអង្វរជាខាងក្រោយថា សូមព្រះដ៏មានព្រះភាគទ្រង់ចូរស្ដិតនៅចុះ ព្រះអង្គ ។

[៤៥២] ក្នុងបទថា **មារមានបាប (មារោ បាបិមា)** នេះ មានអធិប្បាយដូច្នេះ ដែលឈ្មោះថា មារ ព្រោះប្រកបសត្វទុកក្នុងសេចក្ដីវិនាសឲ្យស្លាប់ ។ បទថា **អ្នកមានបាប (បាបិមា)** ជាពាក្យប្រើជំនួសមារនោះឯង ។ ក៏មារនោះ ព្រោះប្រកបដោយបាបធម៌ ទើបហៅថា "អ្នកមានបាប" ។ សូម្បីពាក្យថា **កណ្ហៈ** (ខ្មៅ) **អន្តកៈ** (អ្នកធ្វើទីបំផុត) **នមុចិ** ផៅពង្សអ្នកប្រមាទ ក៏សុទ្ធតែជាឈ្មោះរបស់មារនោះឯង ។

បទថា ព្រះដ៏មានព្រះភាគបានត្រាស់ព្រះតម្រាស់នេះ (ភាសិតា ខោ បនេសា) គឺ ក្នុងសប្តាហ៍ទី ៨ នៃការសម្រេចសេចក្តីត្រាស់ដឹងព្រមរបស់ព្រះដ៏មានព្រះភាគ មារនេះឯង បានមកត្រង់គល់ពោធិតែម្តង ទូលថា "បពិត្រព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បានបំពេញព្រះបារមីមក ដើម្បីប្រយោជន៍ណា ព្រះអង្គក៏ទ្រង់បានសម្រេចប្រយោជន៍នោះហើយ ទ្រង់ចាក់ធ្លុះសព្វញ្ញុតញ្ញាណហើយ ព្រះអង្គត្រាច់ទៅក្នុងលោកដើម្បីប្រយោជន៍អ្វីទៀត" ហើយបានអង្វរដូចក្នុងថ្ងៃនេះឯងថា "បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានចុះ សូមព្រះសុគតទ្រង់បរិនិព្វានចុះ" ។ ព្រះមានព្រះភាគបានត្រាស់បដិសេធចំពោះមារនោះ ជាដើមថា **តថាគតនៅមិនទាន់បរិនិព្វានត្រឹមនោះ (ន តាវាហំ)** ។ មារ សំដៅយកព្រះតម្រាស់នោះ ទើបពោលពាក្យថា **បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគបានត្រាស់ព្រះតម្រាស់នេះទុកហើយ** ដូច្នេះ ជាដើម ។

ក្នុងបទទាំងនោះ បទថា **អ្នកវាងវៃ (វិយត្តា)** សំដៅដល់ អ្នកឆ្លាតដោយអំណាចមគ្គ ។ អ្នកបានទទួលការណែនាំ និងអ្នកក្លៀវក្លា ក៏យ៉ាងនោះ ។ បទថា **ជាពហុស្សូត (ពហុស្សុតា)** គឺ ឈ្មោះថា **ជាពហូសូត** ព្រោះគេបានស្តាប់ព្រះត្រៃបិដកមកច្រើន ។ ឈ្មោះថា **អ្នកទ្រទ្រង់ធម៌** ក៏ព្រោះ

នឹងចាំធម៌នោះឯង ។ម្យ៉ាងទៀត គប្បីឃើញខ្លឹមសារក្នុងពាក្យថា **អ្នកទ្រទ្រង់ធម៌** នេះ យ៉ាងនេះថា ជាពហុស្សូតផ្លូវបរិយត្តិ និងជាពហុស្សូតផ្លូវបដិវេធ ទើបឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ព្រោះចាំធម៌ គឺ បរិយត្តិ និងបដិវេធទាំងឯង ។ បទថា **បដិបត្តិធម៌សមគួរដល់ធម៌** (ធម្មានុធម្មប្បដិបន្នា) គឺ ជាអ្នកបដិបត្តិធម៌ គឺ វិបស្សនា ដែលជាធម៌ប្រព្រឹត្តទៅតាមធម៌របស់ព្រះអរិយៈ ។ បទថា **បដិបត្តិត្រូវ** (សាមីចិបដិបន្នា) គឺ ជាអ្នកបដិបត្តិដល់ការបដិបត្តិដែលសមគួរ ។ បទថា **ប្រព្រឹត្តិតាមធម៌** (អនុធម្មចារិនោ) គឺ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី ។ បទថា **ជាមួយអាចារ្យរបស់ខ្លួន** (សកំ អាចរិយកំ) គឺ វាទៈរបស់អាចារ្យខ្លួន ។ ពាក្យទាំងអស់ជាដើមថា **នឹងប្រាប់** ជាពាក្យសម្រាប់ប្រើជំនួសគ្នានឹងគ្នាទាំងឯង ។ បទថា **ដោយសហធម៌** (សហធម្មេន) គឺ ដោយពាក្យដែលមានហេតុ មានការណ៍ ។ បទថា **មានបាដិហារ្យ** (សប្បាដិហារិយំ) គឺ នឹងសម្តែងធម៌ធ្វើឲ្យចេញចាកទុក្ខបាន ។

[៤៥៥] បទថា **ព្រហ្មចរិយៈ** (ព្រហ្មចរិយំ) បានដល់ សាសនព្រហ្មចរិយៈទាំងអស់ ដែលសង្គ្រោះដោយត្រៃសិក្ខា ។ បទថា **សម្បូរហើយ** (ឥទ្ធំ) បានដល់ សម្រេចព្រមហើយដោយអំណាចសេចក្តីត្រេកអរក្នុងឈានជាដើម ។

បទថា **មានឈ្មោះល្បី (ផីតំ)** បានដល់ ដល់សេចក្ដីចម្រើន ដោយអំណាចការដល់ព្រមនៃអភិញ្ញា ដូចផ្កាឈើរីកស្គុះស្គាយ ។ បទថា **ធំទូលាយ (វិត្ថារិតំ)** បានដល់ ផ្សាយទៅដោយអំណាចតាំងមាំ ក្នុងចំណែកនៃទិសនោះៗ ។ បទថា **មានអ្នកដឹងដោយច្រើន (ពាហុជញ្ញំ)** បានដល់ ដែលពួកមនុស្សជាច្រើនបានដឹង គឺ ចាក់ធ្លុះដោយអំណាចការត្រាស់ដឹងរបស់មហាជន ។ បទថា **ក្រាស់ (បុថុភូតំ)** បានដល់ ដល់សភាពជារបស់ក្រាស់ ដោយអាការគ្រប់យ៉ាង ។ សួរថា យ៉ាងណា? ឆ្លើយថា ទូទាំងពួកទេវតា និងមនុស្សបានប្រកាសល្អហើយ មានន័យថា ដែលពួកទេវតា និងមនុស្ស ដែលប្រកបដោយជាតិជាបណ្ឌិតទាំងអស់ ប្រកាសល្អហើយ ។

[៤៥៦] បទថា **មានសេចក្ដីខ្វល់ខ្វាយតិច (អប្បោស្សុក្កោ)** គឺ អស់អល័យ ។ ព្រះដ៏មានព្រះភាគត្រាស់ថា “ម្នាលមារមានបាប តាំងពីសប្ដាហ៍ទី ៨ មក អ្នកបានត្រាច់ឡូឡាថា “បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគចូរបរិនិព្វានចុះ សូមព្រះសុគតចូរបរិនិព្វានចុះ ដូច្នេះ តាំងអំពីថ្ងៃនេះ អ្នកចូរលះសេចក្ដីឧស្សាហ៍បានហើយ ចូរកុំធ្វើនូវសេចក្ដីព្យាយាមដើម្បីការបរិនិព្វានរបស់តថាគតឡើយ” ។

[៤៥៧] បទថា **ទ្រង់មានព្រះសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារ**

**(សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ)** គឺ ទ្រង់តាំងព្រះសតិទុកយ៉ាងល្អ ទ្រង់ប្រើព្រះញាណកំណត់ហើយទើបទ្រង់ដាក់ គឺ ទ្រង់លះបង់អាយុសង្ខារ ។ ក្នុងករណីនោះ ព្រះដ៏មានព្រះភាគទ្រង់មិនបានដាក់អាយុសង្ខារទ្រង់ប្រើព្រះហស្តចាប់ដុំដីបោះចោល តែទ្រង់កើតព្រះតម្រិះថា តថាគតនឹងចូលផលសមាបត្តិរហូតអស់វេលាប្រមាណ ៣ ខែ តអំពីនោះនឹងមិនចូលសមាបត្តិដទៃ ។ ព្រះអានន្ទសំដៅយកអាការយ៉ាងនោះ ទើបបានពោលថា "ទ្រង់ដាក់ព្រះជន្មហើយ" ។ បាឋៈថា **ឧស្សជ្ជិ** ដូច្នេះក៏មាន ។

ពាក្យថា **ផែនដីធំកើតក៏ករ្រើក (មហាភូមិចាលោ)** គឺ ការញ័ររបស់ផែនដីដ៏ធំ ។ បានឮថា គ្រានោះ ម៉ឺនលោកធាតុបានញាប់ញ័រហើយ ។ បទថា **គួរតក់ស្លុត (ភឹសនកោ)** គឺ ធ្វើឲ្យកើតសេចក្តីភ័យខ្លាច ។ បទថា **ស្គរទិព្វ ក៏បន្លឺលាន់ឡើង (ទេវទុន្ទុភិយោ ច ផលឹសុ)** គឺ ស្គររបស់ទេវតាក៏លាន់ឡើង ។ មហាមេឃក៏គម្រាមគឹកកង ។ ផ្លេកបន្ទោរដែលមិនមែនវេលាក៏កើតឆ្វេលឆ្វាត់ ។ មានពាក្យដែលលោកអធិប្បាយថា ភ្លៀងក៏ធ្លាក់មួយរំពេច ។

[៤៥៨] សួរថា បទថា **ទ្រង់ថ្លែងឧទាន (ឧទានំ ឧទានេសិ)** នេះ ទ្រង់ថ្លែងដូចម្តេច? អាចមានបុគ្គលខ្លះនិយាយថា "ព្រះដ៏មានព្រះភាគ ត្រូវ

មារដែលជាប់តាមក្រោយ (ខ្ញុំ) បៀតបៀនថា បរិនិព្វានចុះ សូមព្រះអង្គបរិនិព្វានចុះ ព្រះអង្គ ទើបទ្រង់ដាក់អាយុសង្ខារព្រោះសេចក្តីភ័យខ្លាច" ។ ឆ្លើយថា ឱកាសរបស់មារនោះចូរកុំមាន ។ សម្រាប់បុគ្គលដែលខ្លាចមិនមានឧទានទេ ព្រោះដូច្នោះ ទើបទ្រង់ថ្លែងឧទានប្រភេទដែលសម្តែងចេញមក ព្រោះកម្លាំងបីតិ ។

ក្នុងព្រះឧទាននោះ ឈ្មោះថា **វត្ថុទីប្រៀបធៀប** ព្រោះត្រូវប្រៀបត្រូវកំណត់ហើយ ដោយវត្ថុប្រចក្ស សូម្បីដល់ក្អែស្រុក និងក្អែព្រៃជាដើមទាំងអស់ ។ វត្ថុប្រៀបនោះ គឺអ្វី ។ គឺ កាមាវចរកម្ម ។ ដែលឈ្មោះថា **មិនមានវត្ថុប្រៀប** ព្រោះមិនមែនវត្ថុដែលប្រៀបបាន ឬវត្ថុដែលប្រៀបបាន គឺ វត្ថុដែលដូចគ្នា វត្ថុនោះ បានដល់ លោកិយកម្មយ៉ាងដទៃ មិនមាន ។ វត្ថុដែលមិនមានអ្វីប្រៀបបាននោះ គឺអ្វី គឺ មហគ្គតកម្ម ។ ម្យ៉ាងទៀត វត្ថុដែលជាកាមាវចរៈ និងរូបាវចរៈ ជាវត្ថុដែលប្រៀបបាន វត្ថុដែលជាអរូបាវចរៈ ជាវត្ថុដែលប្រៀបមិនបាន ។ វត្ថុទីមានវិបាកតិច ជាវត្ថុដែលប្រៀបបាន វត្ថុដែលមានវិបាកច្រើន ជាវត្ថុដែលប្រៀបមិនបាន ។ បទថា **ភព** **(សម្ភវំ)** គឺ ជាហេតុនៃការកើតរបស់សត្វទាំងនោះ អធិប្បាយថា ធ្វើឲ្យជាដុំ ធ្វើឲ្យជាគំនរ ។ បទថា **ធម៌ដែលប្រជុំតាក់តែងភព (ភវសង្ខារំ)** គឺ គ្រឿង

តាក់តែងនៃការកើតឡើងទៀត ។ បទថា **បានដាក់ចុះហើយ (អវស្សជិ)** គឺ ព្រលែងហើយ ។ បទថា **មុនី (មុនិ)** គឺ មុនីដែលជាពុទ្ធ: ។ បទថា **ត្រេកអរហើយក្នុងខាងក្នុង (អជ្ឈត្តរតោ)** គឺ អ្នកត្រេកអរខាងក្នុងយ៉ាងស៊ប់សួន ។ បទថា **មានចិត្តតម្កល់មាំហើយ (សមាហិតោ)** គឺ អ្នកតាំងមាំដោយអំណាចឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា **បានទម្លាយហើយ ប្រៀបដូចទម្លាយនូវក្រោះ (អភិន្ទិ កវចមិវ)** គឺ បានទម្លាយ ដូចជាអ្នកទម្លាយក្រោះ ។ បទថា **ដែលកើតក្នុងខ្លួន (អត្តសម្ភវំ)** បានដល់ កិលេសដែលកើតក្នុងខ្លួន ។ ប្រការនេះ មានពាក្យអធិប្បាយថា ទ្រង់ដាក់វត្ថុដែលបានឈ្មោះថា **សមភព** ព្រោះអត្ថថា មានវិបាក ។ ឈ្មោះថា **ភវសង្ខារ** ព្រោះអត្ថថា ជាគ្រឿងតាក់តែងភព និងឈ្មោះថា ទ្រង់ដាក់នូវលោកិយកម្មពោលគឺ វត្ថុដែលប្រៀបធៀបបាន និងប្រៀបធៀបមិនបាន ទ្រង់បានទម្លាយកិលេសដែលកើតក្នុងខ្លួន ដូចអ្នកច្បាំងដ៏ធំក្នុងសង្គ្រាមទម្លាយក្រោះ និងទ្រង់ជាអ្នកត្រេកអរក្នុងខាងក្នុង ទ្រង់ជាអ្នក (មានព្រះហឫទ័យ) តម្កល់មាំហើយ ។

ម្យ៉ាងទៀត បទថា **កាលបើប្រៀបធៀប (តុលំ)** បានដល់ ទ្រង់ថ្លឹងហើយ គឺ ទ្រង់ពិចារណាហើយ ។ បទថា **អតុលញ្ច សម្ភវំ** ប្រែថា និព្វាន

និងភព ។ បទថា ធម៌ដែលតាក់តែងភព (ភវសង្ខារំ) បានដល់ កម្មដែលឲ្យដល់ភព ។ បទថា មុនី...បានដាក់ចុះហើយ (អវស្សជិ មុនិ) គឺ ព្រះពុទ្ធ-មុនី ទ្រង់បានថ្លឹងដោយន័យជាដើមថា ខន្ធ ៥ មិនទៀង ការរលត់ខន្ធ ៥ យ៉ាងស្និទ្ធ ជានិព្វាន ជារបស់ទៀង ទ្រង់ឃើញទោសក្នុងភព និងឃើញអានិសង្សក្នុងព្រះនិព្វានហើយ បានទ្រង់ដាក់តួដែលតាក់តែងភព ដែលជាឫសគល់នៃខន្ធ ៥ ចេញ ដោយអរិយមគ្គ ដែលធ្វើការអស់ទៅនៃកម្ម ដែលត្រាស់ទុកយ៉ាងនេះថា "ប្រព្រឹត្តទៅដើម្បីអស់កម្ម" គឺ ទ្រង់បានដាក់ចុះនូវតួតាក់តែងភព យ៉ាងណា? ទ្រង់ត្រេកអរខាងក្នុង មានព្រះហឫទ័យតម្កល់មាំ ទ្រង់បានទម្លាយហើយនូវសំណាញ់ គឺ កិលេស ដែលកើតក្នុងខ្លួន ដូចអ្នកចម្បាំងដ៏ធំទម្លាយនូវក្រោះ ដូច្នោះ ។ ពិតហើយ ព្រះដ៏មានព្រះភាគព្រះអង្គនោះ ទ្រង់បានទម្លាយកិលេសទាំងអស់ ដែលរួបរឹតអត្តភាពដោយកម្លាំងសមថៈ និងវិបស្សនា ដូចនាយទាហានធំទម្លាយនូវក្រោះ ដូច្នោះ ផ្តើមតាំងពីចំណែកខាងដើមយ៉ាងនេះ គឺ ទ្រង់ត្រេកអរក្នុងខាងក្នុង ដោយអំណាចវិបស្សនា ទ្រង់ជាបុគ្គលរឹងមាំដោយអំណាចសមថៈ (និងទ្រង់បានទម្លាយកិលេស) ដែលបានឈ្មោះថា កសាងខ្លួន ព្រោះសាងឲ្យកើតខាងក្នុងខ្លួន ។ មយ៉ាងទៀត ព្រោះមិនមានកិលេស ទើបឈ្មោះថា ទ្រង់លះកម្ម

ដោយការលះកិលេសយ៉ាងនេះ គឺ កម្ម ឈ្មោះថា ត្រូវបានដាក់ចុះហើយ ព្រោះទ្រង់មិនធ្វើឲ្យតជាប់ ។ ចំពោះបុគ្គលលះកិលេសបានហើយ ដែលឈ្មោះថា សេចក្តីខ្លាចមិនមាន ។ ព្រោះដូច្នោះ ទើបទ្រង់ជាអ្នកមិនខ្លាចឡើយ ទ្រង់ដាក់អាយុសង្ខារហើយ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ទ្រង់ថ្លែងព្រះឧទាន ដើម្បីទ្រង់ឲ្យដឹងភាពជាបុគ្គលមិនខ្លាច ដូច្នេះ ។

ចប់អដ្ឋកថា ចេតិយសូត្រទី ១០

## ចប់បាវាលវគ្គទី ១

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា អចារសូត្រ ២ អដ្ឋកថា ឥទ្ធិបទេសសូត្រ
៣ អដ្ឋកថា សម្មត្តសូត្រ ៤ អដ្ឋកថា ចេតិយសូត្រ

# បាសាទកម្បនវគ្គទី ២

## អ ដ្ឋ ក ថា

### បុព្វសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង បុព្វសូត្រទី ១ ក្នុងបាសាទកម្បនវគ្គ ។*

[៤៦០] *ពាក្យជាដើមថា មិនធូរថយពេក (ន ច អតិលីនោ) នឹងជាក់ច្បាស់ខាងមុខ ។ ក្នុងសូត្រនេះ ទ្រង់សម្តែងឥទ្ធិបាទដែលមានអភិញ្ញា ៦ ជាបាទ ។*

ចប់អដ្ឋកថា បុព្វសូត្រទី ១

# អ ដ្ឋ ក ថា

## ឆន្ទសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង ឆន្ទសូត្រទី ៣ ។

[៤៧៣] សេចក្តីពេញចិត្ត គឺ ភាពជាអ្នកប្រាថ្នានឹងធ្វើ ឈ្មោះថា ឆន្ទៈ ។ បទថា **អាស្រ័យហើយ** ((និស្សាយ) បានដល់ ធ្វើឲ្យជាទីអាស្រ័យ មានន័យថា ធ្វើឲ្យធំក្រៃលែង ។ គ្រឿងតាក់តែងដែលជាសេចក្តីព្យាយាម ឈ្មោះថា **បធានសង្ខារ** ពាក្យនេះជាឈ្មោះរបស់សេចក្តីព្យាយាម ដែលហៅឈ្មោះថា សេចក្តីព្យាយាមត្រូវ ដែលធ្វើនាទីបួនយ៉ាងឲ្យសម្រេច ។ សេចក្តីពេញចិត្ត ក្នុងពាក្យជាដើមថា **ឥតិ អយំ ច ឆន្ទោ** ជាឆន្ទសមាធិ ប្រកបដោយឆន្ទៈ និងបធានសង្ខារ សូម្បីបធានសង្ខារ ក៏ប្រកបដោយឆន្ទៈ និងសមាធិ ។ ព្រោះដូច្នោះ ទើបព្រះអង្គទ្រង់រួមធម៌ទាំងអស់នោះ ចូលជាមួយគ្នា ហើយត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ** ។

ចំណែកក្នុងឥទ្ធិបាទវិភង្គ ត្រាស់ដល់ធម៌ដែលរកឬប (សភាវៈ) មិនបាន ដ៏សេសដែលប្រកបដោយធម៌ទាំងនេះ ដោយន័យជាដើមថា វេទនាខន្ធ

របស់បុគ្គលដូច្នោះណា ដូច្នេះ ថាជាឥទ្ធិបាទ ។ ម្យ៉ាងទៀត ធម៌ទាំងបីយ៉ាង ទាំងជាឫទ្ធិ (សេចក្តីសម្រេច) ទាំងជាផ្លូវឲ្យដល់ឫទ្ធិ ។ ទាំងជាឫទ្ធិ ជាផ្លូវឲ្យដល់ឫទ្ធិ ដូចម្តេច? ពិតណាស់ កាលចម្រើនឆន្ទៈ ឆន្ទៈក៏រមែងឈ្មោះជាជាឫទ្ធិ សមាធិ និងបធានសង្ខារ ក៏រមែងឈ្មោះថា ជាផ្លូវឲ្យដល់ឫទ្ធិនៃឆន្ទៈ ។ កាលចម្រើនសមាធិ សមាធិក៏រមែងឈ្មោះថា ជាឫទ្ធិ ឆន្ទៈ និងបធានសង្ខារ ក៏រមែងក្លាយជាផ្លូវឲ្យដល់ឫទ្ធិនៃសមាធិ ។ កាលចម្រើនបធាន-សង្ខារ បធានសង្ខារក៏ក្លាយជាឫទ្ធិ ឆន្ទៈ និងសមាធិ ក៏នឹងក្លាយជាផ្លូវឲ្យដល់ឫទ្ធិនៃបធានសង្ខារ ។ ព្រោះកាលធម៌ដែលប្រកបព្រមគ្នាសម្រេចក្នុងធម៌មួយ សូម្បីធម៌ដ៏សេសក៏រមែងសម្រេចដូចគ្នា ។

ម្យ៉ាងទៀត គប្បីជ្រាបនូវធម៌ទាំងនេះជាឥទ្ធិបាទ សូម្បីដោយអំណាចជាចំណែកខាងដើមនៃធម៌នោះៗ ។ ពិតហើយ ឈានទី ១ ឈ្មោះថា ជាឫទ្ធិ ឆន្ទៈជាដើម ដែលប្រកបព្រមជាមួយការរៀបចំ ដែលជាចំណែកខាងដើមរបស់ឈានទី ១ ក៏ឈ្មោះថា ជាផ្លូវឲ្យដល់ឫទ្ធិ ។ តាមន័យនេះទៅដរាបដល់នេវសញ្ញានាសញ្ញាយតនៈ ផ្តើមពីការសម្តែងឫទ្ធិទៅដរាបដល់អភិញ្ញា គឺ ភ្នែកទិព្វ ហើយនាំយកន័យនេះទៅប្រើបាន តាំងពីសោតាបត្តិមគ្គ ទាំងដល់អរហត្តមគ្គ ។ សូម្បីក្នុងឥទ្ធិបាទដ៏សេសក៏ទំនងនេះ ។

តែអាចារ្យពួកខ្លះពោលថា "ឆន្ទៈដែលនៅមិនទាន់សម្រេច ជាឥទ្ធិបាទ" ក្នុងករណីនេះ ដើម្បីញាំញីវាទៈរបស់អាចារ្យទាំងនោះ យើងមានពាក្យឈ្មោះថា ឧត្តរចូឡវារៈ ដែលមកក្នុងអភិធម្មថា ឥទ្ធិបាទ មាន ៤ យ៉ាង គឺ ឆន្ទិទ្ធិបាទ វីរិយិទ្ធិបាទ ចិត្តិទ្ធិបាទ វិមំសិទ្ធិបាទ ។ ក្នុងឥទ្ធិបាទ ៤ នោះ ឆន្ទិទ្ធិបាទ ដូចជាម្ដេច? ភិក្ខុក្នុងធម៌វិន័យនេះ សម័យណា ចម្រើនលោកុត្តរឈាន ដែលនាំចេញចាកទុក្ខ ដែលឲ្យដល់ការអស់ទៅនៃទុក្ខ ស្ងាត់ចាកកាមទាំងឡាយបានហើយ ដើម្បីសម្រេចជាន់ទី ១ សម្រាប់លះសេចក្ដីយើញខុស ។ល។ ហើយចូលដល់ឈានទី ១ ដែលបដិបត្តិលំបាក ត្រាស់ដឹងយូរហើយនៅ ក្នុងសម័យនោះ សេចក្ដីពេញចិត្ត ភាពនៃបុគ្គលពេញចិត្ត ការប្រាថ្នាធ្វើ សេចក្ដីឆ្លាតវាងវៃ សេចក្ដីប្រាថ្នាធម៌ នេះ តថាគតហៅថា ឥទ្ធិបាទ គឺ សេចក្ដីពេញចិត្ត ។ ធម៌ដ៏សេសប្រកបចូលជាមួយឥទ្ធិបាទ គឺ សេចក្ដីពេញចិត្ត តែឥទ្ធិបាទទាំងនេះ មកហើយដោយអំណាចលោកុត្តរៈប៉ុណ្ណោះ ។

ក្នុងឥទ្ធិបាទ ៤ នោះ ព្រះរដ្ឋបាលត្ថេរ ធ្វើសេចក្ដីពេញចិត្តឲ្យជាធុរៈ ហើយទើបញុំាងលោកុត្តរធម៌ឲ្យកើតបាន ។ ព្រះសោណត្ថេរ ធ្វើសេចក្ដីព្យាយាមឲ្យជាធុរៈ ។ ព្រះសម្ភូតត្ថេរ យកចិត្តទុកដាក់ឲ្យជាធុរៈ ។ ព្រះមោឃរាជ

ដ៏មានអាយុ ធ្វើការពិចារណាពិចារណារកហេតុផលឲ្យជាធុរៈ ដោយប្រការដូច្នេះ ៗ ក្នុងឥទ្ធិបាទ ៤ នោះ ដូចជាកូនអាមាត្រ ៤ នាក់ ប្រាថ្នាតំណែងចូលទៅអាស្រ័យព្រះរាជា ម្នាក់កើតសេចក្តីពេញចិត្តក្នុងការបម្រើ ដឹងព្រះរាជអធ្យាស្រ័យ និងសេចក្តីពេញព្រះរាជហឫទ័យរបស់ព្រះរាជា ទើបបម្រើទាំងពេលថ្ងៃ និងពេលយប់ ធ្វើឲ្យព្រះរាជាប្រោសប្រាណ ហើយក៏បានទទួលតំណែង យ៉ាងណា គប្បីជ្រាបបុគ្គលដែលឲ្យលោកុត្តរធម៌កើតបានដោយឆន្ទធុរៈ ដូច្នោះ ៗ

បុគ្គលម្នាក់ទៀត មិនអាចបម្រើរាល់ៗ ថ្ងៃបាន ទើបគិតថា បើមានការចាំបាច់ឡើង យើងនឹងបម្រើដរាបដល់ទីបំផុតតាមដែលធ្វើបាន ដូច្នេះ កាលជាយដែនកម្រើក ត្រូវព្រះរាជាបញ្ជូនទៅហើយ ក៏បង្ក្រាបសត្រូវដរាបដល់ទីបំផុត ហើយបានទទួលតំណែង ៗ បុគ្គលនោះ យ៉ាងណា គប្បីជ្រាបបុគ្គលដែលឲ្យលោកុត្តរធម៌កើតបានដោយ វិរិយធុរៈ ដូច្នោះ ៗ

ម្នាក់ទៀតគិតថា ការបម្រើរាល់ៗ ថ្ងៃក្តី ការយកដើមទ្រូងទទួលលំពែង និងកូនសរក្តី ជាការៈដោយពិត យើងនឹងឲ្យពេញព្រះទ័យដោយកម្លាំងមន្ត ដូច្នេះ ហើយក៏តាំងខ្លួនហ្វឹកហាត់វិជ្ជាដែលទាក់ទងជាមួយការប្រែងអាវុធ ធ្វើឲ្យព្រះរាជាប្រោសប្រាណដោយការចាត់ចែងមន្ត ដរាបទទួល

បានតំណែង ។ បុគ្គលនោះ យ៉ាងណា គប្បីជ្រាបបុគ្គលដែលឲ្យលោកុត្តរ-ធម៌កើតបានដោយ ចិត្តធុរៈ (ការយកចិត្តទុកដាក់) ដូច្នោះ ។

ម្នាក់ទៀតគិតថា ការបម្រើជាដើម នឹងមានប្រយោជន៍អ្វី ធម្មតាពួកព្រះរាជា រមែងប្រទានតំណែងដល់អ្នកសម្បូរណ៍ដោយជាតិ (កូនល្អ) កាលប្រទានដល់បុគ្គលនោះ ក៏នឹងប្រទានដល់យើង អាស្រ័យសេចក្ដីដល់ព្រមដោយជាតិប៉ុណ្ណោះ ក៏បានទទួលឋានន្តរៈ ។ បុគ្គលនោះ យ៉ាងណា គប្បីជ្រាប បុគ្គលដែលអាស្រ័យសេចក្ដីពិនិត្យពិចារណារកហេតុផលសុទ្ធៗ ហើយធ្វើឲ្យកើតលោកុត្តរធម៌ដោយ វីមំសាធុរៈ ដូច្នោះ ។

ក្នុងសូត្រនេះ ទ្រង់សម្ដែងឥទ្ធិដែលមានវិវដ្ដៈជាបាទ ដូចពោលមកនេះ ។

ចប់អដ្ឋកថា ឆន្ទសូត្រទី ៣

# អ ដ្ឋ ក ថា

## មោគ្គល្លានសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង មោគ្គល្លានសូត្រទី ៤ ។*

[៤៧៧] *ជាអ្នករវើរវាយ (ឧទ្ធតា) គឺ អ្នកមានចិត្តញាប់ញ័រ ។ ពិតហើយ ចិត្តរមែងញាប់ញ័រក្នុងអារម្មណ៍មួយដោយឧទ្ធច្ចៈ ដូចទង់ត្រូវខ្យល់បក់ ដូច្នោះ ។ បទថា* **អួតអាង** *(ឧន្នឡា) គឺ បំប៉ោងខ្លួន ។ មានពាក្យអធិប្បាយថា ប្រកាន់ខ្លួនទីរកសារៈមិនបាន ។ បទថា* **មានចិត្តរំជើបរំជួល** *( ចបលា) គឺ ប្រកបដោយសេចក្តីរំជើបរំជួលក្នុងបាត្រ ចីវរ និងគ្រឿងប្រដាប់ជាដើម ។ បទថា* **មាត់រឹង** *(មុខរា) គឺ ធ្នាស់ មានពាក្យអធិប្បាយថា មានពាក្យនិយាយរឹងរូស ។ បទថា* **មានវាចាពេយពាយ** *(វិកិណ្ណវាចា) គឺ មាត់មិនស្ងៀម បានដល់ និយាយរហូតអស់មួយថ្ងៃខ្លះ និយាយពាក្យគ្មានប្រយោជន៍ខ្លះ ។ បទថា* **គ្មានសតិ** *(មុដ្ឋស្សតិនោ) គឺ គ្មានការរឭកបាន ។ បទថា* **មិនមានសម្បជញ្ញៈ** *(អសម្បជានា) គឺ ប្រាសចាកបញ្ញា ។ បទថា* **មានចិត្តមិនតាំងមាំ** *(អសមាហិតា) គឺ វៀរចាកឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា* **មានចិត្តអណ្តែតអណ្តូង** *(វិព្ភន្តចិត្តា) គឺ មានចិត្តអណ្តែត*

អណ្តូងដោយសេចក្តីរវើរវាយ ដែលបានឱកាស ព្រោះប្រាសចាកសមាធិ ។ បទថា **មិនសង្រួមឥន្ទ្រិយ** *(បាកតិន្ទ្រិយា)* គឺ មានឥន្ទ្រិយមិនសង្រួម ។

[៤៧៨] បទថា **សម្តែងឫទ្ធិ** *(ឥទ្ធាភិសង្ខារំ)* គឺ ចូលអាបោកសិណចេញហើយ អធិដ្ឋានចំណែកផែនដីជាទីតាំងនៃប្រាសាទថា ចូរជាទឹក ហោះឡើងកាន់អាកាស ដែលមានប្រាសាទតាំងនៅលើផ្ទៃទឹក ហើយយកម្រាមសង្កត់ចុះទៅ ។

[៤៧៩] បទថា **កប់ជ្រៅ** *(គម្ភីរនេមោ)* គឺ រណ្តៅជ្រៅ ។ មានន័យថា កប់ចូលទៅក្នុងផែនដីដ៏ជ្រៅ ។ បទថា **កប់ទុកល្អហើយ** *(សុនិខាតោ)* គឺ ទីកប់ចុះទៅយ៉ាងល្អ គឺ បោះគ្រឹះតាំងទុកយ៉ាងល្អ ។ ក្នុងសូត្រនេះ ទ្រង់សម្តែងឫទ្ធិ ដែលមានអភិញ្ញាជាបាទ ។

ចប់អដ្ឋកថា មោគ្គល្លានសូត្រទី ៤

# អដ្ឋកថា

## ព្រាហ្មណសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រាហ្មណសូត្រទី ៥ ។*

[៤៨៦] *បទថា ដើម្បីលះឆន្ទៈ (ឆន្ទប្បហានត្ថំ) គឺ ដើម្បីលះសេចក្តីពេញចិត្ត បានដល់ តណ្ហា ។ សូម្បីក្នុងសូត្រនេះ ក៏សម្តែងឥទ្ធិ ដែលមានវិវដ្តៈជាបាទ ។*

ចប់អដ្ឋកថា ព្រាហ្មណសូត្រទី ៥

# អ ដ្ឋ ក ថា

## ទេសនាសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទេសនាសូត្រទី ៩ ។*

*[៤៩៩] បទថា ម្នាលភិក្ខុទាំងឡាយ មគ្គាណា (យោ ភិក្ខវេ មគ្គោ) សំដៅយកឈានទី ៤ ដែលមានអភិញ្ញាជាបាទ ។*

ចប់អដ្ឋកថា ទេសនាសូត្រទី៩

# អ ដ្ឋ ក ថា

## វិភង្គសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិភង្គសូត្រទី ១០ ។*

[៤៨៦] ក្នុងបទថា *ប្រកបដោយសេចក្តីខ្ជិលច្រអូស (កោសជ្ជសហគតោ)* នេះ ភិក្ខុកាលញ៉ាំងសេចក្តីពេញចិត្តឲ្យកើតឡើងហើយ អង្គុយយកចិត្តដាក់ក្នុងកម្មដ្ឋាន ។ ទីនោះ លោកមានអាការរួញរាធ្លាក់ចុះក្នុងចិត្ត លោកដឹងថា អាការរួញរាធ្លាក់ចុះក្នុងចិត្តយើង ក៏យកភ័យក្នុងអបាយមកគ្របសង្កត់ចិត្ត ធ្វើឲ្យកើតសេចក្តីពេញចិត្តឡើងទៀត ហើយតាំងចិត្ត តម្កល់ចិត្តក្នុងកម្មដ្ឋាន ។ ទីនោះ លោកកើតមានអាការរួញរាធ្លាក់ចុះក្នុងចិត្តទៀត លោកក៏លើកយកភ័យក្នុងអបាយមកគ្របសង្កត់ចិត្តទៀត ញ៉ាំងសេចក្តីពេញចិត្តឲ្យកើតឡើងហើយ ក៏តាំងមុខធ្លោះកម្មដ្ឋាន ដូចពោលមកនេះ សេចក្តីពេញចិត្តរបស់លោក ឈ្មោះថា រមែងប្រព្រឹត្តជាមួយសេចក្តីខ្ជិលច្រអូស ព្រោះលោកត្រូវសេចក្តីខ្ជិលច្រអូសគ្របសង្កត់ ដោយប្រការដូច្នេះ ។ បទថា *សម្បយុត្តដោយសេចក្តីខ្ជិលច្រអូស (កោសជ្ជសម្បយុត្តោ)* ជាពាក្យដែលប្រើជំនួសពាក្យថា សហគតដោយសេចក្តីខ្ជិលច្រអូសនោះឯង ។

[៤៨៦] ក្នុងបទថា *សហគតដោយឧទ្ធច្ចៈ (ឧទ្ធច្ចសហគតោ)* នេះ ភិក្ខុកាលធ្វើសេចក្តីពេញចិត្តឲ្យកើតឡើងហើយ ក៏អង្គុយតាំងចិត្តក្នុងកម្ម-ដ្ឋាន ។ ពេលនោះ ចិត្តលោកធ្លាក់ទៅក្នុងសេចក្តីរាយមាយ លោកក៏មករំពឹងដល់គុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ធ្វើចិត្តឲ្យរីករាយ ឲ្យត្រេកអរ ធ្វើឲ្យគួរដល់ការងារ ហើយក៏ញុំាងសេចក្តីពេញចិត្តឲ្យកើតឡើងជាថ្មីទៀត តាំងចិត្តធ្វើកម្មដ្ឋានតទៅ ។ គ្រានោះ ចិត្តរបស់លោកក៏ធ្លាក់ទៅក្នុងសេចក្តីរាយមាយទៀត លោកក៏មករំពឹងដល់គុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃទៀត ធ្វើចិត្តឲ្យរីករាយ ឲ្យត្រេកអរ ធ្វើសេចក្តីពេញចិត្តឲ្យកើតឡើងជាថ្មី ហើយក៏តាំងចិត្តក្នុងកម្មដ្ឋានតទៅ ព្រោះហេតុនេះ សេចក្តីពេញចិត្តរបស់លោក ក៏រមែងឈ្មោះថា ប្រកបដោយសេចក្តីរាយមាយ ព្រោះត្រូវសេចក្តីរាយមាយគ្របសង្កត់ ដោយប្រការដូច្នេះ ។

[៤៨៦] ក្នុងបទថា *ប្រកបដោយថីនមិទ្ធៈ (ថីនមិទ្ធសហគតោ)* នេះ ភិក្ខុធ្វើសេចក្តីពេញចិត្តឲ្យកើតឡើងហើយ ក៏អង្គុយតាំងចិត្តក្នុងកម្មដ្ឋាន ។ ពេលនោះ សេចក្តីងងុយងោកងក់ ក៏កើតឡើងដល់លោក លោកជ្រាបថា ថីនមិទ្ធៈកើតឡើងដល់យើងហើយ ក៏យកទឹកមកលាងមុខ ទាញស្លឹកត្រចៀក ទន្ទេញធម៌ដែលបានចាំមក (ដោយសំឡេងខ្លាំង) ឬដាក់ចិត្តក្នុងអារម្មណ៍ថា

ក្ដី ដែលកាន់យកក្នុងពេលថ្ងៃ បន្ទោបង់ថីនមិទ្ធៈចេញទៅ ញុំាងសេចក្ដីពេញចិត្តឲ្យកើតឡើងទៀត ហើយតាំងចិត្តក្នុងកម្មដ្ឋានតទៅ ។ ពេលនោះ ថីនមិទ្ធៈកើតឡើងដល់លោកទៀត ។ លោកក៏បន្ទោបង់ថីនមិទ្ធៈចេញទៅទៀត តាមន័យដែលពោលហើយនុ៎ះឯង ធ្វើសេចក្ដីពេញចិត្តឲ្យកើតឡើងជាថ្មី តាំងចិត្តធ្វើកម្មដ្ឋានតទៅ ព្រោះហេតុនេះ សេចក្ដីពេញចិត្តរបស់លោក ទើបឈ្មោះថា ប្រកបដោយថីនមិទ្ធៈ ព្រោះថីនមិទ្ធៈគ្របសង្កត់ ដោយប្រការដូច្នេះ ។

[៤៨៦] ក្នុងបទថា *រវើរវាយ (អនុវិក្ខិត្តោ)* នេះ ភិក្ខុកាលធ្វើសេចក្ដីពេញចិត្តឲ្យកើតឡើង ហើយក៏អង្គុយតាំងចិត្តធ្វើកម្មដ្ឋាន ។ ពេលនោះ ចិត្តរបស់លោកក៏រសាត់ទៅក្នុងអារម្មណ៍ គឺ កាមគុណ លោកដឹងបានថា ចិត្តយើងរសាត់ទៅខាងក្រៅហើយ ក៏មករឭកដល់អនមតគ្គសូត្រ ទេវទូតសូត្រ វេលាមសូត្រ និងអនាគតភយសូត្រជាដើម យកអាជ្ញា គឺ ព្រះសូត្រមកជាគ្រឿងគ្របសង្កត់ចិត្ត ធ្វើឲ្យគួរដល់ការងារ ញុំាងសេចក្ដីពេញចិត្តឲ្យកើតឡើងទៀត ក៏តាំងចិត្តធ្វើកម្មដ្ឋានតទៅ ។ ពេលនោះ ចិត្តរបស់លោកក៏រសាត់ទៅទៀត ។ លោកគ្របសង្កត់ចិត្តដោយអជ្ញា គឺ ព្រះសូត្រ ធ្វើឲ្យគួរដល់ការងារ ញុំាងសេចក្ដីពេញចិត្តឲ្យកើតឡើងជាថ្មីទៀត ហើយតាំងចិត្តធ្វើកម្មដ្ឋានតទៅ ព្រោះហេតុនេះ សេចក្ដីពេញចិត្តរបស់លោក ទើបឈ្មោះ

ថា ប្រារព្ធកាមគុណ ៥ យ៉ាងខាងក្រៅ ហើយជារបស់រសាត់ទៅតាម ផ្សាយទៅតាម ព្រោះលាយឡំទៅដោយការត្រិះរិះក្នុងកាម ដោយប្រការដូច្នេះ ។

[៥០៧] ក្នុងបទថា *ខាងមុខយ៉ាងណា ខាងក្រោយក៏យ៉ាងនោះ (យថា បុរេ យថា បច្ឆា)* គប្បីជ្រាបខាងមុខ និងខាងក្រោយ ដោយអំណាចកម្មដ្ឋានខ្លះ ដោយអំណាចទេសនាខ្លះ ។ គប្បីជ្រាប ខាងមុខ និងខាងក្រោយ ដូចម្តេច ។ ក្នុងរឿងកម្មដ្ឋានមុន ការតាំងមាំនៃកម្មដ្ឋាន ឈ្មោះថា ខាងមុខ អរហត្ត ឈ្មោះថា ខាងក្រោយ ។ ក្នុងរឿងនោះ ភិក្ខុណាកាន់យកមូលកម្មដ្ឋានទុកមាំហើយ រាំងសេចក្តីចូរថយរបស់ចិត្តក្នុងឋានៈទាំង ៤ យ៉ាង មានសេចក្តីចូរថយពេកជាដើម មិនជំទាស់ក្នុងឋានៈទាំង ៤ សូម្បីតែកន្លែងមួយ ដូចទឹមគោកោង ប្រើប្រាសក្នុងការងារជកបបានសម្រេច ឬដូចដំណើ ៤ ជ្រុងជ្រៀតចូលទៅ ពិចារណាសង្ខារទាំងឡាយ រមែងសម្រេចព្រះអរហត្ត ។ ភិក្ខុសូម្បីនេះ ក៏រមែងឈ្មោះថា ខាងមុខ យ៉ាងណា ខាងក្រោយ ក៏ដូច្នោះ ។ នេះជាខាងមុខ និងខាងក្រោយ ដោយអំណាចកម្មដ្ឋាន ។ ចំណែកទីពោលដោយអំណាចទេសនា សក់ ឈ្មោះថា ខាងមុខ ខួរក្នុងឆ្អឹង ឈ្មោះថា ខាងក្រោយ ។

ក្នុងរឿងជាប់ទាក់ទងជាមួយទេសនា (ការសម្តែង) នោះ ភិក្ខុណាប្រកាន់

ក្នុងសក់ទាំងឡាយ ហើយកំណត់ក្នុងសក់ជាដើម ដោយអំណាចពណ៌ និងសណ្ឋានជាដើម មិនជំទាស់ក្នុងឋានៈទាំង ៤ យ៉ាង ញុំាងភាវនាឲ្យដល់រហូតដល់ខួរក្នុងឆ្អឹង ។ សូម្បីភិក្ខុនេះ ក៏រមែងឈ្មោះថា ខាងមុខ យ៉ាងណា ខាងក្រោយ ក៏យ៉ាងនោះឯង ។ គប្បីជ្រាបសេចក្តីខាងមុខ និងខាងក្រោយ ដោយអំណាចទេសនាដូចពោលមកនេះ ។ ពាក្យថា ខាងក្រោយយ៉ាងណា ខាងមុខក៏យ៉ាងនោះ នេះ ជាពាក្យដែលប្រើជំនួសគ្នារបស់ន័យមុននុ៎ះឯង ។

[៥០៨] ពាក្យថា **ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ានោះ (យថា អធោ តថា ឧទ្ធំ)** នេះ គប្បីជ្រាបដោយអំណាចសរីរៈ ។ ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគទើបត្រាស់ថា “ខាងលើអំពីបាតជើងឡើងមក ខាងក្រោមអំពីចុងសក់ចុះទៅ” ដូច្នេះ ។ ក្នុងករណីនោះ ភិក្ខុណាញុំាងភាវនាឲ្យដល់ដោយអំណាចអាការ ៣២ ប្រការ តាំងពីបាតជើងឡើងទៅរហូតដល់ចុងសក់ ឬដោយអំណាចឆ្អឹង អំពីចុងឆ្អឹងម្រាមជើងឡើងទៅ រហូតដល់ឆ្អឹងលលាដ៍ក្បាល អំពីឆ្អឹងលលាដ៍ចុះទៅរហូតដល់ឆ្អឹងចុងម្រាមជើង មិនភាំងក្នុងឋានៈទាំង ៤ សូម្បីតែកន្លែងមួយ ភិក្ខុនេះ រមែងឈ្មោះថា ខាងលើយ៉ាងណា ខាងក្រោមក៏ដូច្នោះ ខាងក្រោមក៏យ៉ាងណា ខាងលើក៏ដូច្នោះឯង ។

[៥០៩] បទថា **ដោយអាការណា (យេហិ អាការេហិ)** គឺ ដោយ

ចំណែកណា ៗ បទថា *ដោយភេទណា (យេហិ លិង្គេហិ)* គឺ ដោយសណ្ឋានណា ៗ បទថា *ដោយនិមិត្តណា (យេហិ និមិត្តេហិ)* គឺ ដោយលក្ខណៈដែលប្រាកដណា ៗ

[៥១០] បទថា *អាលោកសញ្ញាដែលភិក្ខុតម្កល់ទុកល្អហើយ (អាលោកសញ្ញា សុគ្គហិតា ហោតិ)* សេចក្តីថា ភិក្ខុណាអង្គុយត្រង់លាន ហើយធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញា បិទភ្នែកគ្រាខ្លះ បើកភ្នែកឡើងគ្រាខ្លះ ខណៈដែលលោកបិទភ្នែកហើយ រូបក៏រមែងប្រាកដតែម្យ៉ាងដូចគ្នានោះឯង ដូចកាលលោកកំពុងបើកភ្នែកមើល នោះឈ្មោះថា ការសម្គាល់ក្នុងពន្លឺ រមែងជាការបានកើតហើយ ៗ សូម្បីបទថា *ទិវាសញ្ញា* ក៏ជាឈ្មោះនៃការសម្គាល់ដល់ពន្លឺនោះឯង ៗ ក៏ប៉ុន្តែថា សេចក្តីសម្គាល់ដល់ពន្លឺ ដែលកើតឡើងនៅក្នុងពេលយប់ រមែងឈ្មោះថា ការកាន់យកល្អហើយ ៗ សូម្បីបទថា *តាំងមាំល្អហើយ (ស្វាធិដ្ឋិតា)* ក៏ជាឈ្មោះសម្រាប់ប្រើជំនួសបទនោះដូចគ្នា ៗ បទថា *ដែលតាំងមាំល្អហើយ* បានដល់ តាំងមាំបានយ៉ាងល្អ គឺហៅថា ឈ្មោះថា តាំងទុកដោយល្អ ៗ សេចក្តីសម្គាល់ដល់ពន្លឺនោះ ដោយអត្ថ ក៏គឺការសម្គាល់ប្រភេទដែលកាន់យកយ៉ាងល្អហើយនុ៎ះឯង ៗ ម្យ៉ាងទៀត ភិក្ខុណាបន្ទោបង់ថីនមិទ្ធៈបានដោយពន្លឺ ញុំាងសេចក្តីពេញចិត្តឲ្យកើត

ឡើង ធ្វើទុកក្នុងចិត្តដល់កម្មដ្ឋាន សេចក្តីសម្គាល់ក្នុងពន្លឺសូម្បីក្នុងពេលថ្ងៃ របស់ភិក្ខុនោះ ក៏ឈ្មោះថា ជាការកាន់យកល្អហើយ ជាការតម្កល់ទុកល្អហើយ មិនថាពេលយប់ ឬពេលថ្ងៃក៏ដោយ ។ ភិក្ខុញ៉ាំងពន្លឺណា បន្ទោបង់ថីនមិទ្ធៈបាន ហើយមកតម្កល់ចិត្តក្នុងកម្មដ្ឋាន សេចក្តីសម្គាល់ដែលកើតឡើងក្នុងពន្លឺ ដែលជាគ្រឿងបន្ទោបង់ថីនមិទ្ធៈនោះ ក៏ឈ្មោះថា ជាការកាន់យកល្អហើយដោយពិត ។ សូម្បីក្នុងឥទ្ធិបាទ មានវីរិយៈជាដើម ក៏ទំនងនេះឯង ។ ក្នុងសូត្រនេះ ទ្រង់សម្តែងចំពោះឫទ្ធិសម្រាប់ជាបាទនៃអភិញ្ញាទាំង ៦ ប្រការ ។

ចប់អដ្ឋកថា វិភង្គសូត្រទី ១០

## ចប់បាសាទកម្បនវគ្គទី ២

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា បុព្វសូត្រ
២ អដ្ឋកថា ផលសូត្រ
៣ អដ្ឋកថា មោគ្គល្លានសូត្រ
៤ អដ្ឋកថា សមណព្រាហ្មណសូត្រ
៥ អដ្ឋកថា ទេសនាសូត្រ
៦ អដ្ឋកថា វិភង្គសូត្រ

# អយោគុឡវគ្គទី ៣

## អ ដ្ឋ ក ថា

### អយោគុឡសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង អយោគុឡសូត្រទី ២ ។

[៥៣១] បទថា ដែលប្រកបដោយមហាភូតរូប ៤ (ឥមិនា ចាតុម្មហាភូតិកេន) គឺ សម្រេចមកពីមហាភូតទាំង ៤ នេះ សូម្បីជាការៈ ជារបស់ធូន់យ៉ាងនេះ ។

[៥៣២] បទថា អាច (ឱមាតិ) បានដល់ រមែងសមគួរ គឺ រមែងអាច ។ បទនេះ ជាបទដែលមិនផ្សេងក្នុងព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ។

[៥៣៣] បទថា រមែងតាំងសូម្បីកាយទុកក្នុងចិត្ត (កាយម្បិ ចិត្តេ សមាទហតិ) បានដល់ កាន់យកកាយមកទុកក្នុងចិត្ត គឺ ធ្វើឲ្យអាស្រ័យចិត្ត បញ្ជូនទៅក្នុងគតិរបស់ចិត្ត ។ ដែលឈ្មោះថា ចិត្ត សំដៅយកមហគ្គតចិត្ត ។ ការទៅរបស់គតិនៃចិត្ត រមែងជារបស់ស្រាលរហ័ស ។ បទថា រមែងតាំងសូម្បីចិត្តទុកក្នុងកាយ (ចិត្តម្បិ កាយេ សមាទហតិ) បានដល់ លើកយកចិត្ត

មកទុកក្នុងកាយ គឺ ធ្វើឲ្យអាស្រ័យកាយ បញ្ជូនទៅក្នុងគតិរបស់កាយ ។ ករជកាយ ឈ្មោះថា កាយ ។ ការទៅរបស់គតិនៃកាយ ជារបស់យឺតយូរ ។

បទថា *សុខសញ្ញា និងលហុសញ្ញា (សុខសញ្ញញ្ច លហុសញ្ញញ្ច)* សំដៅដល់ សញ្ញាដែលកើតព្រមនឹងអភិញ្ញាចិត្ត ។ ពិតហើយ សញ្ញានោះ ទើបឈ្មោះថា សុខសញ្ញា ព្រោះប្រកបដោយសុខស្ងប់ ។ និងទើបឈ្មោះថា លហុសញ្ញា ព្រោះមិនមានការប្រព្រឹត្តយឺតយូរព្រោះកិលេស ។

[៥៣៤] បទថា *ដុំដែកដែលដុតភ្លើងអស់មួយថ្ងៃ រមែងស្រាលជាងប្រក្រតី (អយោគុឡោ ទិវសំ សន្តត្តោ លហុតរោ ចេវ ហោតិ)* សេចក្តីថា ក៏ដុំដែកនោះ សូម្បីត្រូវមនុស្ស ២-៣ នាក់ នាំគ្នាលើកដាក់ក្នុងចង្ក្រានជាងដែក ត្រូវដុតរហូតអស់មួយថ្ងៃ ជាវត្ថុដែលប្រព្រឹត្តទៅជាមួយខ្យល់ ព្រោះភ្លើង និងខ្យល់ ដែលឆេះចូលទៅតាមប្រហោងចង្ក្រាន ជារបស់ដែលទៅជាមួយគ្នានឹងចំហាយក្តៅ និងជារបស់ដែលទៅជាមួយគ្នានឹងភ្លើងយ៉ាងនេះ ទើបក្លាយជារបស់ស្រាល ។ ជាងដែក យកដង្កៀបធំមកចៀបចាប់ផ្នែកម្ខាងត្រឡប់ទៅមក ហើយលើកយកចេញមកខាងក្រៅ យ៉ាងណា ។ កាយរបស់ព្រះតថាគត ក៏ដូច្នោះ រមែងទន់ និងគួរដល់ការងារ ។ ជាងដែកនឹងកាត់ជាកំណាត់តូច-ធំ នឹងយកញញួរមកដំធ្វើជាវត្ថុផ្សេងៗ មានវត្ថុប្អូនជ្រុងវែង

ជាដើមបាន យ៉ាងណា ក្នុងព្រះសូត្រនេះទ្រង់សម្តែងការប្រែងប្ញទ្ធិ ដូច្នោះ ។

ចប់អដ្ឋកថា អយោគុឡសូត្រទី ២

# អ ដ្ឋ ក ថា

## ភិក្ខុសុទ្ធកសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភិក្ខុសុទ្ធកសូត្រទី ៣ ។*

[៥៣៥] *ទ្រង់ត្រាស់ឫទ្ធិ ដែលមានវិវដ្ដៈជាបាទ ។*

ចប់អដ្ឋកថា ភិក្ខុសុទ្ធកសូត្រទី ៣

# អ ដ្ឋ ក ថា

## បឋមផលសុត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមផលសូត្រទី ៤ ។*

*[៥៤១] ក្នុងបឋមផលសូត្រទី ៤ ក៏យ៉ាងនោះ ។ មួយ៉ាងទៀត តាំងពីផល ២ ជាដើមទៅ ទ្រង់សម្តែងគ្រឿងទទួលឫទ្ធិ ដែលលាយគ្នាទុកក្នុងខាងក្រោយ ។ ទ្រង់សម្តែងបុព្វភាគក្នុងផលទាំងប្រាំពីរទៀត ៤ សូត្រ មានសូត្រទី ៧ ជាដើម ក៏មានទំនងដូចដែលពោលទុកក្នុងខាងក្រោយហើយនោះឯង ។*

ចប់អដ្ឋកថា បឋមផលសូត្រទី ៤ ជាដើម

# អ ដ្ឋ ក ថា

## មោគ្គល្លានសូត្រជាដើម

*គប្បីជ្រាបវិនិច្ឆ័យក្នុង មោគ្គល្លានសូត្រជាដើម ។*

*[៥៦៤] ក្នុងសូត្រទី ១១ និងទី ១២ ទ្រង់សម្តែងអភិញ្ញា ៦ ។ ពាក្យ ដ៏សេសក្នុងទីគ្រប់កន្លែង មានខ្លឹមសារងាយទាំងអស់ ។*

ចប់អដ្ឋកថា មោគ្គល្លានសូត្រជាដើម

## ចប់ឥទ្ធិបាទសំយុត្ត

### ចប់អយោគុឡវគ្គទី ៣

### រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា អយោគុឡសូត្រ ២ អដ្ឋកថា ភិក្ខុសុទ្ធកសូត្រ
៣ អដ្ឋកថា បឋមផលសូត្រជាដើម ៤ អដ្ឋកថា មោគ្គល្លានសូត្រជាដើម

# អនុរុទ្ធសំយុត្ត

## រហោគតវគ្គទី ១

## អ ដ្ឋ ក ថា

### បឋមរហោគតសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមរហោគតសូត្រទី ១ ។*

*[៩៧៦] បទថា ដែល...ប្រារព្ធហើយ (អារទ្ធា) គឺ ពេញលេញហើយ ។ ក្នុងសូត្រនេះ ពោលដោយសង្ខេប ក៏គឺ ទ្រង់បានសម្តែងវិបស្សនា ដែលឲ្យដល់ភាពជាព្រះអរហន្តក្នុង ៣៦ ឋានៈ ។*

ចប់អដ្ឋកថា បឋមរហោគតសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយវេហោគតសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយវេហោគតសូត្រទី ២ ។*

*[៥៨៦] ក្នុងវេហោគតសូត្រទី ២ ទ្រង់សម្ដែងវិបស្សនាដែលឲ្យដល់ព្រះអរហត្តក្នុង ១២ ឋានៈ ។*

ចប់អដ្ឋកថា ទុតិយវេហោគតសូត្រទី ២

# អ ដ្ឋ ក ថា

## សុតនុសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុតនុសូត្រទី ៣ ។*

*[៥៩៣] បទថា **ភាវៈនៃមហាអភិញ្ញា (មហាភិញ្ញតំ)** គឺ ភាវៈជាអភិញ្ញា ។*

*[៥៩៤] ក្នុងពាក្យថា **ធម៌ថោកទាប (ហីនំ ធម្មំ)** ជាដើម គប្បីជ្រាបសេចក្តីតាមបាលីនេះថា ៖*

*ឈ្មោះថា **ធម៌ថោកទាប** ដូចម្តេច? ការកើតឡើងនៃចិត្តដែលជាអកុសល ១២ ដួង ទាំងនេះជាធម៌ថោកទាប ។ **ធម៌ជាកណ្តាល** ដូចម្តេច? កុសលក្នុងភូមិទាំង ៣ វិបាកក្នុងភូមិទាំង ៣ និងរូបទាំងអស់ ទាំងជាកិរិយាអព្យាក្រិតក្នុងភូមិទាំង ៣ ទាំងនេះ ជាធម៌កណ្តាល ។ **ធម៌ដែលប្រណីត** ដូចម្តេច? មគ្គទាំង ៤ ដែលជាវត្ថុមិនជាប់ជំពាក់ សាមញ្ញផល ៤ និងនិព្វាន ១ ទាំងនេះ ជាធម៌ដ៏ប្រណីត ។*

ចប់អដ្ឋកថា សុតនុសូត្រទី ៣

# អ ដ្ឋ ក ថា

## បឋមកណ្ដកីសូត្រទី ៤ ជាដើម

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមកណ្ដកីសូត្រទី ៤ ជាដើម ។*

[៥៩៥] *បទថា នៅនាកណ្ដកីវ័ន (កណ្ដកីវនេ) គឺ ក្នុងព្រៃញាតស្បាតដោយបន្លា ។*

[៦០០] *តតិយកណ្ដកីសូត្រទី ៦ ។ លោកសម្ដែងធម៌ជាគ្រឿងនៅជានិច្ចរបស់ព្រះថេរៈ ដោយបទថា លោកមួយពាន់ (សហស្សលោកំ) នេះ ។ ពិតណាស់ ព្រះថេរៈលុបលាងមុខអំពីព្រឹកព្រលឹមហើយ ក៏មករឭកដល់ ១.០០០ កប្ប ក្នុងអតីត និងអនាគត ។ តែក្នុងបច្ចុប្បន្ន មកកាន់គន្លងនៃការរឭកម្ដង មានចំនួនមួយម៉ឺនចក្រវាឡ ។ តណ្ហក្ខយសូត្រទី ៧ សេចក្ដីងាយយល់ទាំងនោះឯង ។*

ចប់អដ្ឋកថា បឋមកណ្ដកីសូត្រទី ៤ ជាដើម

# អ ដ្ឋ ក ថា

## សលឡាគារសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង សលឡាគារសូត្រទី ៨ ។*

[៦០២] *បទថា* នាសលឡាគារ *(សលឡាគារេ)* គឺ ក្នុងសាលាប្រក់ដោយស្លឹកឈើ យកដើមស្រល់ធ្វើ ។ ឬក្នុងអាគារទីមានឈ្មោះដូច្នោះ ព្រោះនៅជិតទ្វារដើមស្រល់ ។ ក្នុងសូត្រនេះ ទ្រង់សម្តែងវិបស្សកបុគ្គល ព្រមទាំងវិបស្សនា ។

ចប់អដ្ឋកថា សលឡាគារសូត្រទី ៨

# អ ដ្ឋ ក ថា

## អម្ពបាលិសូត្រទី ៩

[៦០៤] គប្បីជ្រាបវិនិច្ឆ័យក្នុង *អម្ពបាលិសូត្រទី ៩* ។

[៦០៥] បទថា *អាសភិវាចា (អាភិសវាចំ)* សំដៅដល់ វាចាខ្ពស់បំផុត ដែលញុំាងឲ្យដល់ភាពជាព្រះអរហន្តនៃខ្លួន ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្តីងាយយល់ទាំងអស់នោះឯង ។

ចប់អដ្ឋកថា អម្ពបាលិសូត្រទី៩

## ចប់រោគតវគ្គទី ១

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

| | |
|---|---|
| ១អដ្ឋកថា បឋមរោគតសូត្រ | ២អដ្ឋកថា ទុតិយរោគតសូត្រ |
| ៣អដ្ឋកថា សុតនុសូត្រ | ៤អដ្ឋកថា បឋមកណ្ឌកីសូត្រជាដើម |
| ៥ អដ្ឋកថា សលឡាគារសូត្រ | ៦អដ្ឋកថា អម្ពបាលិសូត្រ |

# ទុតិយវគ្គទី ២

## អ ដ្ឋ ក ថា

### ទុតិយវគ្គទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយវគ្គទី ២ ។*

[៦១៣] *ព្រះថេរៈបង្ហាញទសពលញាណដោយពាក្យជាដើមថា ឋានៈ ដោយភាពជាឋានៈ (ឋានញ្ច ឋានតោ) ។ ក៏ទសពលញាណនេះ ពួកសាវក មានឬទេ? មានដោយចំណែកខ្លះ ។ តែចំពោះព្រះសព្វញ្ញុពុទ្ធទាំងឡាយ ទសពលញាណនេះ មានគ្រប់បរិបូណ៌ដោយអាការគ្រប់យ៉ាង ។*

ចប់អដ្ឋកថា អនុរុទ្ធសំយុត្តឯកធម្មវគ្គទី ១

## សំយុត្តនិកាយ មហាវារវគ្គ
## ទសមភាគ ចប់
## ភាគ៣៨

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 1.000 US |
| ភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក | $ 300 US |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | $ 70 US |
| -ឧបាសក វ៉ាន់ ស៊ីមវ៉ា ឧបាសិកា តាំង សានីតា ព្រមទាំងបុត្ត | $ 30 US |
| -កុមារី តាំង សុមាវតី | $ 10 US |

